# ពាក្យប្រារព្ធ

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់មាននូវព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ និងព្រះមហា-ករុណាគុណ ដែលប្រមាណមិនបាន ។

ព្រះធម៌ទាំងពួងដែលព្រះអង្គទ្រង់បានត្រាស់ដឹង ហើយទ្រង់បានត្រាស់សម្ដែង គឺជាព្រះធម៌ដ៏ប្រសើរ និងជាព្រះធម៌ដ៏មានតម្លៃថ្លៃថ្លា ប្រៀបប្រដូចនឹងការប្រោះព្រំដោយទឹកអម្រឹត ធ្វើឱ្យសន្ដានចិត្តរបស់សត្វលោក ដែលកំពុងតែទុរន់ទុរាដោយកិលេសរបស់ខ្លួន បានមាំមួនឡើង ។ ព្រះធម៌ជាព្រះធម្មរតនៈដែលព្រះអង្គទ្រង់ព្រះប្រទានឱ្យដល់សត្វលោក ជាសម្បត្តិដែលប្រាសចាកទោស ប្រាសចាកមន្ទិល និងប្រាសចាកសត្រូវព្រមទាំងអន្តរាយទាំងពួង។ ព្រះធម៌ជាប្រទីបបំភ្លឺផ្លូវសត្វលោក និងដើម្បីនាំសត្វលោកឆ្លងអំពីផ្លូវ កន្ទារ គឺផ្លូវឆ្ងាយដាច់ស្រយាល និងជាផ្លូវងងឹតដ៏ក្រៃលែង ។

បុគ្គលណាបានសិក្សាព្រះធម៌ដ៏ល្អិតសុខុម សែនជ្រៅ ដែល





លំបាកនឹងឃើញបាន រហូតដល់មានការយល់ដឹងច្រើនឡើងៗតាមលំដាប់ហើយ បុគ្គលនោះនឹងដឹងខ្លួនឯងថា អាត្មាអញបានជួបនូវផ្លូវដ៏ប្រសើរ គឺអរិយមគ្គហើយ ។

សិក្សាព្រះធម៌ដើម្បីដុសខាត់ និង ដើម្បីរំលត់នូវកិលេស បុគ្គលដែលបានស្គាល់ខ្លួនឯងតាមសេចក្ដីពិតថា ខ្លួនឯងនៅមានកិលេស រមែងបានទទួលនូវប្រយោជន៍អំពីការសិក្សាព្រះធម៌ តាមសមគួរដល់ការយល់ដឹង និងការខំប្រឹងប្រែងរបស់ខ្លួន ។

សិក្សាព្រះធម៌ដើម្បីយល់ ដើម្បីលះការមិនដឹងគឺអវិជ្ជា និងដើម្បីទំនុកបម្រុងបញ្ញា ឱ្យមានការយល់ដឹងក្នុងព្រះធម៌ដែលមិនធ្លាប់បានដឹងពីមុនមក គឺជាការអប់រំចម្រើនបញ្ញា ដឹងក្នុងសភាវធម៌តាមសេចក្ដីពិត បន្តិចម្ដងៗ ។ កាលបើមានបញ្ញាបានដឹងបានយល់ក្នុងព្រះធម៌ច្រើនឡើងៗហើយ បញ្ញាយល់ដឹងនេះរមែងធ្វើកិច្ច របស់បញ្ញា គឺលះកិលេសហ្នឹងឯង ។

យើងមិនមានផ្លូវនឹងលះកិលេសបាន ដោយភាពជាអត្តាតួខ្លួនឡើយ ព្រោះភាពជាយើងក្ដី ភាពជាអត្តាតួខ្លួនក្ដី គឺត្រឹមតែជាកិលេសដ៏ធំធេងប៉ុណ្ណោះ ។ កិលេសដែលប្រកាន់ថាជាខ្លួនយើងនេះ មានការលំបាកបំផុតក្នុងការលះបង់ ព្រោះយើងមានសេចក្ដីប្រកាន់ក្នុងតួខ្លួនរបស់យើងមករហូត អស់រយៈវេលាដ៏វែង

ឆ្ងាយណាស់ហើយ និង ព្រោះមកអំពីយើងមិនធ្លាប់បានស្តាប់ ព្រមទាំងមិនធ្លាប់បានជ្រាបមកពីមុនសោះថា «គ្រប់យ៉ាងជាធម្មៈ ដែលមានការប្រព្រឹត្តទៅតាមហេតុ-បច្ច័យ» ។

បុគ្គលអ្នកដឹងដោយប្រចក្សច្បាស់ នូវសភាវធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅតាមហេតុ-បច្ច័យ មុនបុគ្គលណាទាំងអស់នោះ គឺ ព្រះអរហន្តសម្មាសម្ពុទ្ធ ប៉ុន្តែការប្រចក្សក្នុងសភាវធម៌ទាំងឡាយ ប្រព្រឹត្តទៅដើម្បីលះបង់នូវការយល់ខុសថាជាតួខ្លួន ជាសត្វបុគ្គល នោះ មិនមែនជាការងាយឡើយ សម្រាប់បុគ្គលដែលក្រាស់ដោយ កិលេស ដូចជាមនុស្សយើងសព្វថ្ងៃនេះ ។

យើងមិនអាចប្រចក្សចំពោះការកើតរលត់ នៃសភាវធម៌ ផ្សេងៗ ដោយត្រឹមតែសេចក្តីប្រាថ្នា ឬដោយការប្រកាន់តួខ្លួន ឬ ដោយផ្លូវបដិបត្តិដទៃ ក្រៅអំពីផ្លូវមូលតែមួយគឺសតិប្បដ្ឋានប្បដិបត្តិ បានឡើយ ដូច្នេះពុទ្ធបរិស័ទគ្រប់គ្នាដែលបានស្គាល់នូវព្រះធម៌ថា «ព្រះធម៌គឺជាសេចក្តីពិតទាំងពួង» គួរតែផ្ទន់ក្នុងចិត្តថាអាត្មាអញ កំពុងសិក្សានូវព្រះបញ្ញាគុណ ដ៏អស្ចារ្យក្រៃលែងរបស់ព្រះបរម-សាស្តាដែលទ្រង់បានបំពេញនូវបារមីអស់កាលដ៏យូរអង្វែង ។

តើពុទ្ធបរិស័ទគួរយល់ថា ការកសាងបារមី ៤អសង្ខេយ្យ កម្រៃ១សែនកប្ប ដើម្បីត្រាស់ដឹងនូវរបស់ដែលគេដឹងបានដោយ





ងាយ យល់បានដោយងាយ ដែលអ្នកណាៗក៏អាចនឹងយល់បាន ដោយមិនចាំបាច់មានការព្យាយាមអប់រំចម្រើនបញ្ញា ដូច្នេះឬ ?

ការសិក្សារៀនសូត្រនូវព្រះធម៌ដ៏សែនល្អិតល្អន់នេះ ធ្វើឱ្យ ពុទ្ធបរិស័ទយើងបានស្គាល់ខ្លួនឯងទៅតាមសេចក្តីពិតថា ខ្លួននៅ មានកិលេសក្រាស់ដ៏ក្រៃលែង ហើយធ្វើឱ្យយើងដឹងខ្លួនឯងទៀត ថា យើងនៅមានការអប់រំបញ្ញាយូរអង្វែងតទៅទៀត រហូតដល់ បានលះនូវកិលេសដែលសន្សំអស់កាលដ៏យូរមកហើយ ។ យើង គ្រប់គ្នា សន្សំកិលេសជាប្រចាំ ទាំងដែលបានដឹងខ្លួន ទាំងដែល មិនបានដឹងខ្លួន ឯចំណែកឱកាសចម្រើននូវកុសលវិញ មានតែ បន្តិចបន្តួចប៉ុណ្ណោះ និងកុសលដែលបន្តិចបន្តួចនោះ ច្រើនតែជា កុសលដែលមិនប្រកបដោយបញ្ញាទៀតផង ដូច្នេះធ្វើឱ្យយើងបាន ដឹងទៀតថា ប្រសិនបើយើងមិនបានសិក្សានូវព្រះធម៌ដ៏ល្អល្អិតល្អន់ និងដ៏មានជម្រៅ ដើម្បីរំលត់ការប្រកាន់នៅក្នុងបញ្ចក្ខន្ធនេះទេ គឺ យើងមិនមានផ្លូវណាដែលនឹងអាចចេញរួចអំពីវដ្តៈបានឡើយ។

សៀវភៅ **ជំនួយសតិភាគទី៧** ដែលជា **កម្មកថា** នេះ ជាការប្រមូលចងក្រងនូវព្រះធម៌អំពីច្បាប់ផ្សេងៗ ដូចជាគម្ពីរ បរមត្ថជោតិកដីកា (ដីកាអភិធម្មត្ថសង្គហៈ) គម្ពីរសារត្ថសង្គហៈ និងព្រះត្រៃបិដក ព្រមទាំងអដ្ឋកថាជាដើម ។ មានពាក្យខ្លះនៅ

ក្នុងវង់ក្រចក គឺខ្ញុំព្រះករុណាខ្ញុំបាទសរសេរពន្យល់បន្ថែម មួយអន្លើដោយពាក្យជាសុភាសិតរំលឹកដាស់តឿន ដែលបានមកពីកន្លែងផ្សេងៗ ។

ទិសដៅនៃការសរសេរសៀវភៅនេះ គឺដើម្បីអ្នកអាន និងអ្នកស្តាប់ បានសិក្សានូវព្រះធម៌ដ៏ល្អិតល្អន់ ដែលព្រះអង្គទ្រង់បានត្រាស់ដឹង ដូចជាកុសលកម្ម អកុសលកម្ម ឬបុណ្យបាបគុណទោសតាមសេចក្តីពិត និងផលវិបាករបស់កម្មជាដើម គឺដើម្បីបានដឹងនូវហេតុដែលពិតរបស់សុខទុក្ខក្នុងជីវិតនៃសត្វលោក និងដើម្បីបានឃើញទោសនៃកិលេសរបស់ខ្លួនឯងផង។

ខ្ញុំព្រះករុណាខ្ញុំបាទសង្ឃឹមថា អ្នកសិក្សានឹងបានយល់នូវព្រះធម៌ ដែលពោលអំពីកម្មនេះបានច្រើនឡើងថែមទៀត ដោយអំណាចនៃសៀវភៅមួយច្បាប់នេះ សូមឧទ្ទិសនូវសៀវភៅនេះជាសក្ការបូជាថ្វាយចំពោះព្រះរតនត្រ័យ សូមបុណ្យកុសលនេះបានសម្រេចដល់មាតាបិតារបស់ខ្ញុំទាំងអស់ក្នុង សង្សារវដ្ត មួយអន្លើនិងពពួកញាតិព្រមទាំងអ្នកដែលកំពុងអាននូវសៀវភៅនេះ។

**ភ្នំពេញថ្ងៃ១៥កើត ខែបឋមាសាឍ ព.ស ២៥៤៦**

**ខ្ញុំព្រះករុណា**

**ខ្ញុំបាទ ប៊ុត_សាវង្ស**

# មាតិកា


ព្រះពុទ្ធសាសនា ..................១

កម្មចតុក្កៈ ...........................៩

I-កិច្ចចតុក្កៈ ........................... ១១

-ជនកកម្ម .............................១១

-ឧបត្ថម្ភកកម្ម ........................១២

-ឧបបីឡកកម្ម ....................... ៤២

-ឧបឃាតកកម្ម .......................៥០

II-បាកទានបរិយាយចតុក្កៈ .......... ៦៤

-គរុកកម្ម ..............................៦៤

-អាសន្នកម្ម ...........................៦៩

-អាចិណ្ណកម្ម ..........................៧៧

-កដត្តាកម្ម ............................៨២

III-បាកកាលចតុក្កៈ ..................... ៨៨

-ទិដ្ឋធម្មវេទនីយកម្ម ................៨៨

-ឧបបជ្ជវេទនីយកម្ម ..............១០១

-អបរាបរិយវេទនីយកម្ម ......... ១០២

-អហោសិកម្ម ........................១១២

IV-បាកដ្ឋានចតុក្កៈ .....................១១៦

-អកុសលកម្ម ........................១១៦

-កាមាវចរកុសលកម្ម .............១៣៨

-រូបាវចរកុសលកម្ម .................១៤៩

-អរូបាវចរកុសលកម្ម .............១៥២

មហាបដ្ឋាន-កម្មប្បច្ចយោ...១៥៤

ទីបំផុតនៃកុសលធម៌.........១៩១

កម្មវដ្ដៈ...........................១៩៧

ចុតិ-បដិសន្ធិ....................២០០

ប្រយោជន៍គួរយល់ដឹង......២០៨

# ព្រះពុទ្ធសាសនា

## ១_ព្រះពុទ្ធសាសនាថ្លៃថ្លាជានិច្ច

ព្រះពុទ្ធសាសនាមានលំអបទដើម ដោយការមិនធ្វើនូវបាបទាំងពួង មានលំអបទកណ្តាលដោយការចម្រើនកុសលឱ្យដល់ព្រម មានលំអបទចុងដោយការជុសខាត់សម្អាតចិត្តរបស់ខ្លួន ឱ្យបានជ្រះស្រឡះនូវការលោភលន់ ការខឹងក្រោធនិងការវង្វេងភាន់ច្រឡំ ។

តាំងពីដើមរហូតមកដល់ឥឡូវ ព្រះពុទ្ធសាសនាគឺយ៉ាងនេះឯង ដូច្នេះ សូមកុំមើលឃើញការឆ្គាំឆ្គងរបស់បព្វជិតខ្លះ ឧបាសកឧបាសិកាខ្លះ ថាជាការឆ្គាំឆ្គងរបស់ព្រះពុទ្ធសាសនាឱ្យសោះ ត្រូវចែកគ្នាឱ្យដាច់ នូវព្រះពុទ្ធសាសនា និងអ្នកកាន់ព្រះពុទ្ធសាសនា យ៉ាងនេះទើបបានជ្រាបច្បាស់ថា«ព្រះពុទ្ធសាសនាថ្លៃថ្លាជានិច្ច»។

## ២_សត្រូវនឹងព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាអប់រំពុទ្ធបរិស័ទឱ្យកម្ចាត់នូវកិលេសគ្រឿងសៅហ្មងក្នុងសន្តានរបស់ខ្លួនឯង កាលបើបុគ្គលណាកម្ចាត់នូវកិលេសក្នុងសន្តានរបស់ខ្លួនឱ្យអស់រលីងហើយ បុគ្គលនោះឈ្មោះ





ថា ចប់កិច្ចក្នុងបដិបត្តិសាសនា និងឈ្មោះថាបានបម្រើព្រះសម្មា-សម្ពុទ្ធហើយ បានតបស្នងសងព្រះគុណរបស់ព្រះអង្គហើយ ដូច្នេះកិលេសមានលោភៈ ទោសៈ មោហៈ ជាដើម គឺជាសត្រូវនឹងព្រះពុទ្ធសាសនា ។

អ្នកដែលប្រព្រឹត្តតាមអំណាចរបស់កិលេស មិនឈ្មោះថាប្រព្រឹត្តតាមព្រះពុទ្ធសាសនាឡើយ ព្រោះកិលេសជាសត្រូវនឹងព្រះពុទ្ធសាសនា ហើយជាសត្រូវជាមួយនឹងសត្វលោកផងដែរ ។ សត្វលោករមែងមានទុក្ខ មិនរួចចាកទុក្ខព្រោះតែកិលេសក្នុងសន្តាន ទើបគួរឃើញថា ព្រះពុទ្ធសាសនានៅខាងសត្វលោកជា-និច្ច ជួយសត្វលោកជានិច្ច គឺជួយកម្ចាត់កិលេសជាសត្រូវឱ្យសត្វ-លោក ឱ្យតែសត្វលោកព្រមឱ្យព្រះពុទ្ធសាសនាជួយ ។

## ៣_ទីតាំងនៃព្រះពុទ្ធសាសនា

សេចក្តីចម្រើននៃព្រះពុទ្ធសាសនាដែលពិតប្រាកដ ក៏គឺសេចក្តីចម្រើនផ្លូវចិត្តនៃពុទ្ធបរិស័ទហ្នឹងឯង ហើយចិត្តរបស់ពុទ្ធ-បរិស័ទដែលនឹងចម្រើនរុងរឿងទៅបាននោះ ក៏ត្រូវអាស្រ័យព្រះ-ធម៌ក្នុងព្រះពុទ្ធសាសនាជាគ្រឿងចិញ្ចឹមបីបាច់រក្សាជានិច្ចកាលដែរ ដូចទារកតូចអាស្រ័យទឹកដោះម្តាយអ៊ីចឹងឯង គឺថាបើយើងយកព្រះធម៌ក្នុងព្រះពុទ្ធសាសនាមកជាអាហារ មកជាគ្រឿងបីបាច់

ថែរក្សាទំនុកបម្រុងចិត្តសន្តាន ចិត្តរមែងបានដល់នូវសេចក្តីក្សេម-ក្សាន្ត ចម្រើនទៅដោយសេចក្តីស្អាត ចម្រើនទៅដោយពន្លឺភ្លឺស្វាង និងចម្រើនទៅដោយសេចក្តីស្ងប់ ។

បើយើងមិនយកព្រះធម៌ក្នុងព្រះពុទ្ធសាសនា មកជាគ្រឿងជួយទំនុកបម្រុងដល់ចិត្តទេ ចិត្តរបស់យើងរមែងមិនចម្រើនទៅដោយសេចក្តីស្អាត និងមិនបានដល់នូវសេចក្តីក្សេមក្សាន្តឡើយ វារមែងធ្លាក់ចុះទៅតាមអំណាចនៃសេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេង ការច្រណែនឈ្នានីស និងគំនុំគុំគួនព្យាបាទបៀត-បៀនមិនចេះចប់ ជាការសាងនូវបញ្ហាឱ្យដល់ជីវិតពិតប្រាកដ គឺជាចិត្តដែលមិនមានព្រះពុទ្ធសាសនានៅជាមួយ ព្រះពុទ្ធសាសនាមិនបានចម្រើននៅក្នុងចិត្តរបស់យើងឡើយ នេះជារឿងដែលគួរគិត ។

## ៤.ឈ្មោះថាភិក្ខុព្រោះបានទម្លាយកិលេស

(ភិក្ខកសូត្រ សំយុត្តនិកាយ សគាថវគ្គ)

សាវត្ថីនិទាន ។ គ្រានោះឯង ភិក្ខកព្រាហ្មណ៍ (ព្រាហ្មណ៍អ្នកសូម ) បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏





អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខកព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកសូមគេ ឯព្រះអង្គក៏ជាអ្នកសូមគេដែរ តើយើងទាំងពីរនាក់ផ្សេងគ្នាដូចម្តេច ក្នុងពាក្យថា "អ្នកសូម"នេះ ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា :

**ន តេន ភិក្ខកោ ហោតិ យាវតា ភិក្ខតេ បរេ**
**វិសំ ធម្មំ សមាទាយ ភិក្ខុ ហោតិ ន តាវតា ។**

បុគ្គលណា សូមពួកជនដទៃ ដោយហេតុណា បុគ្គលនោះមិនឈ្មោះថាភិក្ខុដោយហេតុនោះឡើយ បុគ្គលណា កាន់ធម៌មានពិសគឺអកុសលធម៌ បុគ្គលនោះ ក៏មិនឈ្មោះថាភិក្ខុដែរ ។

**យោធ បុញ្ញញ្ច បាបញ្ច បវាហេត្វា ព្រហ្មចរិយំ**
**សង្ខាយ លោកេ ចរតិ ស វេ ភិក្ខូតិ វុច្ចតីតិ។**

ក្នុងលោកនេះ លុះតែបុគ្គលណាបានបណ្តេតបង់នូវបុណ្យនិងបាបចេញហើយ (ព្រោះបាន)ប្រព្រឹត្តនូវព្រហ្មចរិយៈ ពិចារណាដោយបញ្ញានូវខន្ធលោក អាយតនលោក ធាតុលោក បុគ្គលនោះទើបតថាគតហៅថា ភិក្ខុពិត ។

កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខក-

ព្រាហ្មណ៍ បានក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹង ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

## អដ្ឋកថា ភិក្ខុកសូត្រ

បទថា **ឥធ** ក្នុងសេចក្ដីដែលថា ជាភិក្ខុនេះ នោះឯង ។ បទថា **វិសំ ធម្មំ** បានដល់ អកុសលធម៌ដែលមានក្លិនស្អុយ ។ បទថា **វាហេត្វា** បានដល់ លះបានដោយអរហត្តមគ្គ ។ បទថា **សង្ខាយ** បានដល់ ញាណ ។ បទថា **ស វេ ភិក្ខូតិ វុច្ចតិ** ដោយសេចក្ដីថា បុគ្គលនោះឯង លោកហៅឈ្មោះថា ភិក្ខុ ព្រោះបានទម្លាយនូវកិលេស ។

## ៥-ឈ្មោះថាព្រាហ្មណ៍ សមណៈ ភិក្ខុ

(ខុទ្ទកនិកាយ ឧទាន ពិលិន្ទវច្ឆសូត្រ)

**យម្ហិ ន មាយា វសតិ ន មានោ យោ វីតលោភោ អមមោ និរាសោ បនុណ្ណកោធោ អភិនិព្វុតត្តោ សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខូតិ** ។

មាយា គឺការបិទបាំងទោសមានពុតត្បុត មានះ គឺសេចក្ដីប្រកាន់អញ មិនប្រព្រឹត្តទៅក្នុងបុគ្គលណា ឬក៏បុគ្គលណា អស់សេចក្ដីលោភ មិនប្រកាន់ថារបស់អញ មិនមានសេចក្ដីប្រាថ្នា បន្ទោបង់សេចក្ដីក្រោធ មានចិត្តត្រជាក់ បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ បុគ្គលនោះឈ្មោះថាសមណៈ បុគ្គលនោះឈ្មោះថា ភិក្ខុ ។

## អដ្ឋកថា

**យម្ហិ ន មាយា វសតិ ន មានោ** ដោយសេចក្ដីថា មាយាមានលក្ខណៈបិទបាំងនូវទោសដែលមានក្នុងខ្លួន និងមានះមានលក្ខណៈប៉ោងឡើង ប្រព្រឹត្តទៅដោយការលើកតម្កើង មានជាអាទិ៍ថា យើងជាអ្នកប្រសើរ ដូច្នេះឯង អកុសលធម៌ទាំងនេះ រមែងមិនមាននៅក្នុងព្រះអរិយបុគ្គលណា គឺមិនប្រព្រឹត្តទៅ មិនកើតឡើង ព្រោះលោកដកបានហើយដោយមគ្គចិត្ត ។ បទថា **យោ វីតលោភោ អមមោ និរាសោ** ដោយសេចក្ដីថា បុគ្គលណា ឈ្មោះថា អស់នូវសេចក្ដីលោភ ព្រោះប្រាសចាក

លោភៈ ដែលមានលក្ខណៈចាប់យកនូវអារម្មណ៍ដោយប្រការទាំងពួង ប្រព្រឹត្តទៅដោយបរិយាយនៃកិលេសមានរាគៈជាដើម **អមមោ** មិនប្រកាន់ថាជារបស់យើង គឺមិនហួងហែង ព្រោះមិនមានការប្រកាន់ក្នុងអារម្មណ៍ មានរូបារម្មណ៍ជាដើម ថាជារបស់យើងនោះឯង **និរាសោ** មិនមានសេចក្តីប្រាថ្នា អស់សេចក្តីសង្ឃឹម ព្រោះមិនសង្ឃឹមភពជាដើម ក្នុងអនាគត ។ បទថា **បនុណ្ណកោធោ** ដោយសេចក្តីថា កម្ចាត់នូវសេចក្តីក្រោធបានហើយ គឺដកនូវអាឃាតព្យាបាទ ព្រោះលះបង់សេចក្តីក្រោធដែលមានលក្ខណៈជាការពុះក្តៅក្នុងចិត្ត ដោយអនាគាមិមគ្គ ។ បទថា **អភិនិព្វុតត្តោ** ដោយសេចក្តីថា បុគ្គលណាមានចិត្តត្រជាក់ត្រជុំ ដោយការរលត់នូវកិលេសទាំងពួង ព្រោះបានដកនូវមាយា មានះ លោភៈ និងសេចក្តីក្រោធអំពីចិត្តបាន និងព្រោះលះបង់នូវធម៌ ដែលជាចំណែកសង្កិលេសទាំងពួងបានដាច់ខាត ដោយសង្កិលេសទាំងនោះ តាំងនៅក្នុងឋានៈជាមួយគ្នានឹងមាយាជាដើមហ្នឹងឯង ។ បទថា **សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ** ដោយសេចក្តីថា បុគ្គលនោះជាព្រះខីណាស្រព ឈ្មោះថា ព្រាហ្មណ៍ព្រោះជាអ្នកបណ្តេតបាបដោយប្រការទាំងពួង បុគ្គលនោះឯងឈ្មោះថា សមណៈ ព្រោះជាអ្នកស្ងប់បាប និងជាអ្នក





ប្រព្រឹត្តស្មោះស្មើ ម្យ៉ាងទៀតបុគ្គលនោះឈ្មោះថាភិក្ខុ ព្រោះជាអ្នកទម្លាយកិលេសដោយប្រការទាំងពួង ។

## ស្រណោះស្រុកព្រះ

កាលពីស្រុកយើងឡើងសម្បុរខ្មៅ ប្រាជ្ញក្លាយជាខ្លៅដំបៅសង្គម
សាសនារលត់ជាតិត្រូវរលំ រាស្ត្ររងទុក្ខធំស្លាប់អស់រាប់លាន។
ឥឡូវស្រុកព្រះវិនាសធម៌អាថ៌ ព្រះពុទ្ធសាសនាស្ទើរតែរកគ្មាន
កិលេសរុំព័ទ្ធកម្សត់ស្រេកឃ្លាន ប្រជារាយលានគ្មានព្រះវិន័យ ។
សាសនាផ្សេងៗមានច្រើនអនេក គោរពពស់វែកគោរពសត្វព្រៃ
ងូតទឹកលាងបាបឱ្យជ្រះចង្រៃ អាំងភ្លើងហាលថ្ងៃឱ្យស្ងួតកិលេស។
ព្រះម៉ែទេវីរៀបគ្រប់កន្លែង គោរពកោតក្រែងជាព្រះពិសេស
រៀបចំពិធីឥតហ៊ានប្រហែស កូនចៅចាំចេះតពីម៉ែឪ ។
អចេលក៍បួសស្រាតអាក្រាតឥតខ្មាស គេគោរពណាស់រហូតឥឡូវ
តើធម៌វិន័យលៃដូចម្តេចទៅ រឿងរ៉ាវអាស្រូវកើតជាបន្ត ។
រឿងនេះគួរឱ្យសង្វេគក្រៃលែង ទាំងចាស់ទាំងក្មេងសទ្ធាទ័លក្រ
រៀនសូត្រពូកែតែខ្វះព្រះធម៌ ជ្រុលហួសផ្លូវល្អធ្លាក់ចូលអបាយ។

ដោយឧបាសក **គុយ-សុធន**

# កម្មចតុក្កៈ

សម្តែងកម្ម ១៦ ដោយបែងជា ៤ពួក :

I ‐ **ជនកំ ឧបត្ថម្ភកំ ឧបបីឡកំ ឧបឃាតកញ្ចេតិ កិច្ចវសេន** ។ ឈ្មោះថាកម្ម បើពោលដោយកិច្ចមាន៤យ៉ាងគឺ÷

១‐ **ជនកកម្ម** កម្មដែលរមែងតែងតែធ្វើឱ្យវិបាកកើតឡើង។

២‐ **ឧបត្ថម្ភកកម្ម** កម្មដែលរមែងតែងតែជួយទំនុកបម្រុង ។

៣‐ **ឧបបីឡកកម្ម** កម្មដែលចូលទៅបៀតបៀន ។

៤‐ **ឧបឃាតកកម្ម** កម្មដែលចូលទៅកាត់ ផ្តាច់ ។

II - **គរុកំ អាសន្នំ អាចិណ្ណំ កដត្តាកម្មញ្ចេតិ បាកទានបរិយាយេន** ។ បើពោលដោយលំដាប់នៃការឱ្យផល មាន ៤យ៉ាងគឺ ÷

១‐**គរុកកម្ម** កម្មយ៉ាងធ្ងន់ដែលកម្មដទៃៗមិនអាចនឹងហាមបាន។

២‐**អាសន្នកម្ម** កម្មដែលបានធ្វើនៅពេលជិតស្លាប់ ។

៣‐**អាចិណ្ណកម្ម** កម្មដែលបានសន្សំរឿយៗជានិច្ច ។





៤‐**កដត្តាកម្ម** កម្មដែលបានធ្វើល្មមប្រមាណក្រៅអំពីកម្ម៣ខាងដើម ឬកម្មដែលធ្លាប់ធ្វើហើយក្នុងអតីតភព ។

III - **ទិដ្ឋធម្មវេទនីយំ ឧបបជ្ជវេទនីយំ អបរាបរិយវេទនីយំ អហោសិកម្មញ្ចេតិ បាកកាលវសេន ចត្តារិ កម្មានិ នាម** ។ បើពោលដោយកាលក្នុងការឱ្យផល មាន ៤ យ៉ាងគឺ ÷

១‐**ទិដ្ឋធម្មវេទនីយកម្ម** កម្មដែលឱ្យផលក្នុងបច្ចុប្បន្នជាតិ ។

២‐**ឧបបជ្ជវេទនីយកម្ម** កម្មដែលឱ្យផលក្នុងជាតិទី ២ ។

៣‐**អបរាបរិយវេទនីយកម្ម** កម្មដែលឱ្យផលក្នុងជាតិទី ៣ ជាដើមទៅ រហូតដល់ព្រះនិព្វាន ។

៤‐**អហោសិកម្ម** កម្មដែលមិនឱ្យផល ។

IV – **តថា អកុសលំ កាមាវចរកុសលំ រូបាវចរកុសលំ អរូបាវចរកុសលញ្ចេតិ បាកដ្ឋានវសេន** ។ បើពោលដោយអំណាចនៃឋានក្នុងការឱ្យផល មាន៤យ៉ាង គឺ ÷

១‐**អកុសលកម្ម** បានដល់អកុសលចេតនា ១២

២‐**កាមាវចរកុសលកម្ម** បានដល់មហាកុសលចេតនា ៨

៣‐**រូបាវចរកុសលកម្ម** បានដល់រូបាវចរកុសលចេតនា ៥

៤‐**អរូបាវចរកុសលកម្ម** បានដល់អរូបាវចរកុសលចេតនា ៤។

# I - កិច្ចចតុក្កៈ

<u>កម្មឱ្យផលតាមកិច្ច</u>

**កិច្ចទី១-ជនកកម្ម** ជនកកម្មនេះ ជាកម្មដែលធ្វើឱ្យវិបាក និងកម្មជរូប ព្រមទាំងកម្មប្បច្ចយឧតុជរូបកើតឡើង ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល បានដល់អកុសលកម្ម ១២ និងលោកិយកុសលកម្ម ១៧ ។

ដោយសេចក្តីថា កាលសត្វទាំងឡាយស្លាប់ហើយ បានទៅកើតជាសត្វតិរច្ឆានក្តី ជាមនុស្សក្តី ជាទេវតាក្តី ជាព្រហ្មក្តី ទាំងអស់នេះ រមែងប្រព្រឹត្តទៅដោយអំណាចរបស់ជនកកម្ម ដែលធ្វើឱ្យវិបាកនិងកម្មជរូបកើតឡើងក្នុងបដិសន្ធិកាល ។ កាលសត្វទាំងឡាយកើតមកហើយ ក៏ត្រូវមានន្ធូវអវយវៈតូចធំកើតឡើងតាមសមគួរដល់សត្វនោះៗ ព្រមទាំងមានការឃើញ ការឮ ការធុំក្លិន ការដឹងរស ដឹងផោដ្ឋព្វៈ ការរក្សាភព (ភវង្គ ) កើតឡើងទាំងអស់នេះ រមែងប្រព្រឹត្តទៅដោយអំណាចនៃជនកកម្មដែលធ្វើឱ្យវិបាក កម្មជរូបនិងកម្មប្បច្ចយឧតុជរូបកើតឡើងក្នុងបវត្តិកាល ។

ជនកកម្មដែលអាចធ្វើឱ្យវិបាក និងកម្មជរូបកើតឡើងក្នុងបដិសន្ធិកាល ពោលគឺ ឱ្យកើតជាសត្វតិរច្ឆានឬមនុស្សជាដើមបាន





នោះ ត្រូវជាកម្មដែលគ្រប់អង្គក្នុងកម្មបថ ។ សម្រាប់ជនកកម្មដែលធ្វើឱ្យវិបាក កម្មជរូប និងកម្មប្បច្ចយឧតុជរូបកើតឡើងក្នុងបវត្តិកាល ពោលគឺឱ្យមានអវយវៈតូចធំ ព្រមទាំងការឃើញ ការឮជាដើម (វៀរភវង្គចិត្ត )នោះ ទោះជាកម្មប្រភេទដែលគ្រប់អង្គក្នុងកម្មបថក៏ដោយ ទោះជាកុសលកម្ម អកុសលកម្មដែលកើតឡើងក្នុងបញ្ចទ្វារវិថី ឬដែលកើតឡើងក្នុងពេលយល់សប្តិក្តី រមែងមានអំណាចអាចឱ្យវិបាក កម្មជរូប និងកម្មប្បច្ចយឧតុជរូបកើតបានទាំងអស់ ។

វិមានដែលជាទីនៅរបស់ពួកទេវតា ព្រហ្ម ឬ ភ្លើងនិងគ្រឿងធ្វើទារុណកម្មផ្សេងៗរបស់ពួកសត្វនរកជាដើម ទាំងអស់នេះ ក៏ចាត់ជាកម្មប្បច្ចយឧតុជរូបដែលកើតអំពីជនកកម្មផងដែរ ។

**កិច្ចទី២-ឧបត្ថម្ភកកម្ម** កម្មណារមែងឧបត្ថម្ភ ដល់កម្មដទៃៗ និង ឧបត្ថម្ភដល់ខន្ធដែលកើតឡើងអំពីកម្មដទៃៗ ដូច្នោះកម្មនោះ ឈ្មោះថាឧបត្ថម្ភកកម្ម បានដល់ អកុសលកម្ម ១២ និងមហាកុសលកម្ម ៨ ។

ឧបត្ថម្ភកកម្មនេះ ជាកម្មដែលជួយទំនុកបម្រុងជនកកម្មដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាននេះប្រការទីមួយ ម្យ៉ាងទៀត ជួយទំនុកបម្រុងជនកកម្មដែលកំពុង

តែមានឱកាសឱ្យផល ធ្វើឱ្យមានកម្លាំងក្នុងការឱ្យផលនោះខ្លាំងក្លាក្រៃលែង នេះប្រការទីពីរ និងម្យ៉ាងទៀត ជួយទំនុកបម្រុងនូវនាមរូប ដែលជាផលរបស់ជនកកម្មឱ្យចម្រើន និងឱ្យតាំងនៅបានយូរ នេះប្រការទីបី ។

**ឧបត្ថម្ភកកម្មប្រការទីមួយ** ជួយទំនុកបម្រុងជនកកម្មដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបានបានដល់ កុសលកម្ម និងអកុសលកម្ម ដែលឧបត្ថម្ភដល់ជនកកម្មនៅមិនទាន់មានឱកាសឱ្យផលនោះ មាន៨យ៉ាងគឺ ÷

១.កុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ។

២.កុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ។

៣.អកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ។

៤.អកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ។

៥.កុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ។





៦.កុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ។

៧.អកុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ។

៨.អកុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ។

## សេចក្តីអធិប្បាយ

១.កុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា :

មនុស្សឈ្មោះ **ក** ជាពុទ្ធសាសនិកជន តែក្នុងបច្ចុប្បន្នភពមនុស្សឈ្មោះ **ក** នេះ បានធ្វើនូវបាបអកុសលជាច្រើន ដោយហេតុនេះ ពេលមនុស្សឈ្មោះ **ក** មានជំងឺនៅពេលជិតស្លាប់ក៏មាននិមិត្តដែលមិនល្អប្រាកដកើតឡើងដល់គេ ធ្វើឱ្យគេមានសភាពខុសប្រក្រតី ។ កាលអ្នកជិតខាងឃើញដូច្នេះ ក៏ដឹងបានថាមនុស្សឈ្មោះ **ក** មាននិមិត្តមិនល្អកើតឡើងហើយ ធ្វើឱ្យចិត្តសៅ-

ហ្មង បើធ្វើកាលកិរិយានៅពេលនេះ នឹងទៅកាន់ទុគ្គតិភពយ៉ាងពិតប្រាកដ ដោយកុសលដែលជាអបរាបរិយវេទនីយកម្មក្នុងជាតិមុនរបស់មនុស្សឈ្មោះ **ក** នេះ មិនអាចនឹងជួយឱ្យគេរួចផុតអំពីទុគ្គតិទៅបាន ព្រោះសភាពនៃចិត្តមានការសៅហ្មងហ្នឹងឯង ។

អាស្រ័យហេតុនេះ អ្នកនៅជិតមានញាតិមិត្តជាដើមនោះទើបរកឧបាយដើម្បីជួយកែខៃអារម្មណ៍នៃមនុស្សឈ្មោះ **ក** ដែលមិនល្អនោះ ឱ្យផ្លាស់ប្តូរទៅជាល្អវិញ ដោយនិមន្តព្រះសង្ឃមកសូត្រមន្ត និងសម្តែងធម៌ទេសនាឱ្យស្តាប់ នាំយកព្រះពុទ្ធរូបមកតាំងបូជាទុកជិតៗ ដើម្បីឱ្យគេបាននឹកនមស្ការចំពោះព្រះរតនត្រ័យ ប៉ុណ្ណេះជាដើម ។ កាលញាតិមិត្តអ្នកនៅជិត បានចាត់ចែងកែខៃអារម្មណ៍ឱ្យមនុស្សឈ្មោះ **ក** ដូចពោលមកនេះ ទាំងដែលមនុស្សឈ្មោះ **ក** នោះនៅមានសេចក្តីដឹងខ្លួនល្អ សភាពនៃចិត្តរបស់គេក៏បានដូរផ្លាស់មកជាថ្លាស្អាតឡើងវិញ ហើយនិមិត្តដែលប្រាកដមិនល្អនោះក៏បាត់អស់ទៅ និមិត្តដែលល្អក៏មកប្រាកដជំនួសវិញ ដូច្នេះ កាលមនុស្សឈ្មោះ **ក** អស់ជីវិតទៅ គេក៏មានឱកាសទៅកើតក្នុងសុគតិភព ជាមនុស្ស ឬទេវតា នេះព្រោះកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុង អតីតភព ។



២-កុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា :

មនុស្សឈ្មោះ **ខ** ជាពុទ្ធសាសនិកជន មានចិត្តល្អប្រកបដោយសទ្ធាជ្រះថ្លា ធ្វើបុណ្យធ្វើទានរក្សាសីលជាប្រចាំ ប៉ុន្តែមិនធ្លាប់អប់រំចិត្តដោយសមថៈ ឬវិបស្សនាឡើយ ដោយហេតុនេះនៅពេលមនុស្សឈ្មោះ **ខ** នេះ មានជំងឺនៅពេលជិតស្លាប់ ក៏មានសេចក្តីភ័យខ្លាច តក់ស្លុត និងមានកង្វល់ក្នុងការហួងហែងទ្រព្យសម្បត្តិ កូនចៅ ក្នុងសភាពបែបនេះចិត្តរបស់គេក៏សៅហ្មង ។

ជាធម្មតានៃការដែលមានចិត្តសៅហ្មង បើធ្វើកាលកិរិយាក្នុងពេលហ្នឹង រមែងបដិសន្ធិក្នុងអបាយភូមិជាប្រាកដ ដូច្នេះ ញាតិមិត្តត្រូវជួយមនុស្សឈ្មោះ **ខ** មានទំនងដូចជួយមនុស្សឈ្មោះ **ក** ដែរ កាលបើបានជួយឱ្យគេមានចិត្តស្ងប់រម្ងាប់នូវការភ័យខ្លាចតក់ស្លុត លះបង់នូវការកង្វល់ហួងហែង តាមរយៈនៃធម៌ទេសនាជាដើម គេក៏បានទៅកាន់សុគតិភព ក្រោយអំពីអស់ជីវិតទៅនេះព្រោះកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ។

៣-អកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយ

ឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា :

មនុស្សឈ្មោះ **គ** ជាអ្នកមានចិត្តបុណ្យ បានធ្វើទានរក្សាសីលក្នុងបច្ចុប្បន្នភពនេះ ប៉ុន្តែ មិនបានអប់រំចិត្ត មិនបានសិក្សាឱ្យយល់នូវបរមត្ថធម៌ មិនបានបដិបត្តិសមថៈ ឬ វិបស្សនាឡើយ ដល់ពេលគេឈឺជិតស្លាប់ ក៏មានចិត្តសៅហ្មង ទំនងដូចមនុស្សឈ្មោះ**ខ**ដែរ គ្រាន់តែមនុស្សឈ្មោះ **ខ** មានញាតិមិត្តចេះដឹងធម៌អាថ៌ជួយរម្ងាប់ចិត្ត ឯចំណែកមនុស្សឈ្មោះ **គ** នេះ អ្នកនៅជិតសុទ្ធតែមិនបានដឹងអំពីធម៌អាថ៌អ្វីទាំងអស់ ដូច្នោះទើបមិនមានការជួយកែខៃឱ្យមនុស្សឈ្មោះ **គ** មានស្មារតីមកវិញឡើយ ។

កាលមនុស្សឈ្មោះ **គ** អស់ជីវិតទៅទាំងពេលដែលចិត្តកំពុងសៅហ្មងដូច្នេះ គេត្រូវទៅកើតក្នុងទុគ្គតិភព កុសលកម្មដែលគេបានធ្វើក្នុងជាតិនេះយ៉ាងច្រើនមកនោះ មិនអាចជួយឱ្យគេបានទៅកាន់សុគតិភពឡើយ នេះព្រោះអកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលកម្មដែលមនុស្សឈ្មោះ **គ** នេះ ធ្លាប់បានធ្វើទុកក្នុងជាតិមុនៗ ឱ្យអកុសលកម្មនោះមានឱកាស ជាជនកកម្មទៅបាន ។

៤.អកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយ





ឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា :

មនុស្សឈ្មោះ **ឃ** កាលនៅវ័យក្មេង ធ្វើបាបអកុសលកម្មច្រើនៗ មានការសម្លាប់សត្វជាដើម គ្រាកាលដែលវ័យក្មេងកន្លងទៅ ចូលមកដល់វ័យចាស់ ក៏បានឃើញទោសក្នុងការធ្វើនូវបាបកម្មទាំងអស់នោះ ហើយក៏មានសេចក្តីសង្វេគស្លុតចិត្តកើតឡើង បានលះបង់ភេទឃរាវាស ចូលបួសក្នុងព្រះពុទ្ធសាសនា ។ តមកព្រះភិក្ខុនាម **ឃ** នេះក៏មាននូវអាពាធជាទម្ងន់ ហើយបាននឹករលឹកឃើញទៅដល់គ្រាកាលដែលខ្លួននៅពីក្មេង នឹករលឹកឃើញបាបកម្មផ្សេងៗយ៉ាងច្រើនដែលខ្លួនបានធ្វើទុកហើយក្នុងកាលនោះ រួចហើយក៏មានចិត្តមិនសប្បាយ ស្តាយក្រោយ និងនឹកភ័យខ្លាចខ្លួនធ្លាក់ទៅអបាយភូមិ កាលបើដូច្នេះ សភាពចិត្តរបស់ព្រះភិក្ខុ **ឃ** ក៏សៅហ្មងកករល្អក់ប្រកបដោយសេចក្តីក្តៅក្រហាយ រហូតដល់មរណភាពទៅ ។

ព្រះភិក្ខុ **ឃ** ក្រោយអំពីចុតិ បានបដិសន្ធិក្នុងអបាយភូមិភ្លាមមួយរំពេច នេះព្រោះអកុសលដែលបានកើតឡើងក្នុងពេលជិតស្លាប់ ជួយឧបត្ថម្ភដល់អកុសលកម្មដែលខ្លួនធ្លាប់បានធ្វើទុកហើយក្នុងបច្ចុប្បន្នជាតិ ធ្វើឱ្យមានឱកាសជាជនកកម្មទៅបាន ។

៥-កុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា :

មនុស្សឈ្មោះ ង ជាមនុស្សមានមិច្ឆាទិដ្ឋិ មិនជឿបាបមិនជឿបុណ្យ មិនជឿគុណមាតាបិតាជាដើម ។ ក្រោយមកមនុស្សឈ្មោះ ង បានចូលខ្លួនបម្រើលោកសេដ្ឋីដែលមានចិត្តបុណ្យម្នាក់ លោកសេដ្ឋីតែងតែធ្វើបុណ្យឱ្យទានជាប្រចាំ ដូចជាដាក់បាត្រមុខផ្ទះរាល់ថ្ងៃ ទៅវត្តស្តាប់ធម៌ រក្សាឧបោសថសីលជាដើម ។ មនុស្សឈ្មោះ ង មានតួនាទីដាំបាយ ចាត់ចែងចង្ហាន់ ឬភេសជ្ជៈនាំយកទៅវត្តតាមលោកសេដ្ឋីរៀងរាល់ថ្ងៃឧបោសថ ។

មនុស្សឈ្មោះ ង បានបម្រើលោកសេដ្ឋីយ៉ាងនេះ ធ្វើឱ្យចិត្តរបស់គេភ្លឺស្វាងបន្តិចម្តងៗ ការយល់ឃើញខុសទាំងប៉ុន្មានក៏បាត់អស់ទៅ ចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនាក៏កើតឡើង ។ គ្រាកាលគេមានជំងឺឈឺជិតស្លាប់ ចិត្តរបស់គេមិនមានសេចក្តីសៅហ្មងឡើយ ព្រោះមនុស្សឈ្មោះ ង នេះ មានតែខ្លួនមួយផង ទ្រព្យសម្បត្តិក៏មិនមានផង រួមផ្សំនឹងឧបនិស្ស័យល្អរបស់គេ ដែលគេមានលោកសេដ្ឋីសម្មាទិដ្ឋិចិត្តបុណ្យជាចៅហ្វាយនាយផង ដូច្នេះចិត្តរបស់គេមិនមានកង្វល់ហួងហែងទៅលើអ្វីៗឡើយ ។



មនុស្សឈ្មោះ ង ស្លាប់ទៅ បានកើតក្នុងសុគតិភព សូម្បីកុសលមានការដាំបាយដាក់បាត្រ ស្តាប់ធម៌ទេសនាជាដើមដែលមនុស្សឈ្មោះ ង នេះ បានធ្វើជាប្រក្រតីក្នុងតួនាទីបម្រើលោកសេដ្ឋី មិនមានកម្លាំងខ្លាំងយ៉ាងណាក៏ដោយ ប៉ុន្តែ ក៏ជាកម្លាំងជួយឧបត្ថម្ភដល់កុសលកម្មដែលគេបានធ្វើទុកហើយក្នុងអតីតភពដែរ ។ កុសលកម្មក្នុងអតីតភពនោះជាអបរាបរិយវេទនីយកម្ម បាននូវឱកាសឱ្យផល នេះព្រោះកុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ។

៦-កុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា :

មនុស្សឈ្មោះ ច ធ្លាប់ឧបសម្បទាជាភិក្ខុ ធ្លាប់សិក្សានូវព្រះធម៌ និងធ្លាប់បដិបត្តិសមថៈ វិបស្សនា ។ ក្រោយមកមនុស្សឈ្មោះ ច នេះ បានលាចាកសិក្ខាបទមកជាអ្នកគ្រប់គ្រងផ្ទះ និងត្រូវប្រកបការងារចិញ្ចឹមជីវិត ។ ការងារអាជីពរបស់មនុស្សឈ្មោះ ច នេះ ទាក់ទងក្នុងការនេសាទ ប្រព្រឹត្តទៅជាបាណាតិបាត ប៉ុន្តែគេក៏នៅមានការធ្វើបុណ្យដាក់បាត្ររាល់ថ្ងៃសីលដែរ ហើយតាំងចិត្តធ្វើឱ្យជាប្រចាំទៀតផង ។

មនុស្សឈ្មោះ **ច** កាលពិចារណាដល់ការប្រព្រឹត្តរបស់ខ្លួនហើយ ក៏ដឹងថា ការចិញ្ចឹមជីវិតរបស់ខ្លួននេះមិនបានបរិសុទ្ធឡើយ ជាការងារទុច្ចរិតប្រព្រឹត្តក្នុងអកុសលកម្ម នឹងដូរផ្លាស់រកមុខរបរថ្មីក៏មិនបាន ព្រោះខ្លួនមិនមានចំណេះដទៃអ្វីសោះ ដូច្នេះហើយទើបមនុស្សឈ្មោះ **ច** ចាំបាច់ត្រូវរកកុសលឱ្យបានមកជាទីពឹងខ្លះៗ ប៉ុន្តែគេក៏មិនមានបុណ្យកុសលអ្វីជាធំដុំឡើយ គ្រាន់តែបានដាក់បាត្រព្រះសង្ឃជាប្រចាំ ជារៀងរាល់ថ្ងៃឧបោសថសីលប៉ុណ្ណោះ ព្រមដោយសេចក្តីជ្រះថ្លាត្រេកអរចំពោះអំពើល្អរបស់ខ្លួនផង ។

កាលដល់ពេលជិតស្លាប់ មនុស្សឈ្មោះ **ច** មានចិត្តឥតសៅហ្មងអ្វីឡើយ ដូច្នេះគេបានស្លាប់ទៅកាន់សុគតិភព ជាមនុស្សឬជាទេវតា ដោយអំណាចនៃសីលកុសល ឬភាវនាកុសលដែលគេធ្លាប់បានបំពេញក្នុងបច្ចុប្បន្ន គ្រាកាលដែលគេនៅក្នុងផ្នូស ។

បើតាមតែអាជីពរបស់មនុស្សឈ្មោះ **ច** ជាមិច្ឆាជីវៈ សីល-កុសល ឬភាវនាកុសលដែលគេបានធ្វើកាលអំពីនៅបួសនោះ មិនអាចមានឱកាសជាជនកកម្មឡើយ ប៉ុន្តែត្រឡប់ជាមានឱកាសទៅវិញ ព្រោះអាស្រ័យទានកុសលដែលគេបានធ្វើគឺដាក់បាត្រព្រះ-សង្ឃរាល់ៗថ្ងៃឧបោសថសីលហ្នឹងឯង ដែលជាកុសលជួយឧបត្ថម្ភដល់សីលកុសល ឬភាវនាកុសលក្នុងបច្ចុប្បន្នភពឱ្យមានឱកាសជា





ជនកកម្ម ញ៉ាំងមនុស្សឈ្មោះ **ច** នេះឱ្យទៅកាន់សុគតិភពបាន ។

៧-អកុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា :

មនុស្សឈ្មោះ **ឆ** តាំងពីតូចរហូតពេញវ័យ ជាអ្នកដែលមានចិត្តជាកុសល ជួយមាតាបិតាដាក់បាត្ររាល់ថ្ងៃ ចូលចិត្តស្តាប់ធម៌ជាមួយមាតាបិតា និងមានការធ្វើទានដោយចិត្តជ្រះថ្លា ទោះបីទេយ្យធម៌តិចច្រើនយ៉ាងណាក៏រីករាយជ្រះថ្លាធ្វើជាប្រចាំ ដែលគួរឱ្យសង្ឃឹមថា មនុស្សនេះស្លាប់ទៅមិនធ្លាក់ទៅអបាយភូមិឡើយ។

ក្រោយមកមនុស្សឈ្មោះ **ឆ** ក៏បានរៀបការមានក្រុមគ្រួ-សារ ឯការបំពេញកុសលរបស់គេ មានការថយចុះជាលំដាប់ ព្រោះគេមិនមានឱកាសដូចនៅពីក្មេងឡើយ គេត្រូវប្រកបការងារចិញ្ចឹមជីវិត ចិញ្ចឹមក្រុមគ្រួសារ គេមានកង្វល់ដោយការជាប់ជំពាក់នឹងមាសប្រាក់ ព្រមទាំងគិតតែពីការចង់បានប៉ុណ្ណោះ ។

ជាប្រក្រតី មនុស្សឈ្មោះ **ឆ** មានការវង្វេងភ្លើតភ្លើនក្នុងសេចក្តីសប្បាយរីករាយ ពេញចិត្តណាស់ក្នុងកាមគុណ ប៉ុន្តែគេមិនបានប្រព្រឹត្តធ្វើនូវបាបកម្មក្នុងការងារចិញ្ចឹមជីវិតជាដើមឡើយ ។ ជារឿយៗមកយ៉ាងនេះ រហូតដល់មនុស្សឈ្មោះ **ឆ** នេះឯងបាន

ទទួលមរណភាព ។ ក្រោយអំពីអស់ជីវិតទៅ គេបានធ្លាក់ទៅកាន់អបាយភូមិ ព្រោះអាស្រ័យអកុសលចិត្តដែលបានកើតឡើងចម្រើនឡើងជាខាងក្រោយក្នុងជីវិតរបស់គេ ជួយឧបត្ថម្ភដល់អកុសលកម្ម ដែលគេធ្លាប់បានធ្វើអំពីជាតិមុន ឱ្យអកុសលកម្មនោះមានឱកាសជាជនកកម្មទៅបាន ។

៨_អកុសលដែលកើតឡើងជាប្រក្រតីក្នុងបច្ចុប្បន្នភព ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា :

មនុស្សឈ្មោះ ជ តាំងតែពីតូចដល់ធំ គេមិនធ្លាប់បានធ្វើកុសលអ្វីឡើយ មានតែការដើរសេពគប់ជាមួយនឹងបាបមិត្ត គេដើរលួចដើរឆក់ទ្រព្យសម្បត្តិរបស់អ្នកដទៃ មិនត្រឹមតែប៉ុណ្ណោះ មនុស្សឈ្មោះ ជ បានប្រព្រឹត្តនូវអំពើឆ្គាំឆ្គងជាច្រើនទៀតក្នុងបឋមវ័យរបស់គេ ។

ក្រោយមក មាតាបិតារបស់មនុស្សឈ្មោះ ជ នេះ មានការរៀបចំចាត់ចែងដើម្បីឱ្យគេចូលកាន់ផ្នួសបួសជាបព្វជិត នឹងបានលះបង់នូវឧបនិស្ស័យមិនល្អរបស់គេចោលចេញ ។ មនុស្សឈ្មោះ ជ ក្រោយអំពីបួសហើយ គេក៏បានទៅជាបព្វជិតល្អមួយអង្គក្នុងព្រះពុទ្ធសាសនា ។ ព្រះភិក្ខុនាម ជ បដិបត្តិកិច្ចរបស់





សមណៈបានយ៉ាងល្អប្រសើរ និងតាំងចិត្តតាំងថ្លើមសិក្សារៀនសូត្របរិយត្តិធម៌ មិនឱ្យមានដាច់ ដោយសេចក្តីមិនប្រមាទ។ កាលបួសបានប្រមាណ ៣វស្សា ឃើញថាព្រះភិក្ខុនាម ជ ល្អពិត។ ប៉ុន្តែក្រោយមកសទ្ធាក៏ថយចុះ ការបដិបត្តិកិច្ចរបស់សមណៈក៏ខ្វះខាត ហើយការតាំងចិត្តសិក្សារៀនសូត្រក៏បាត់បង់អស់ទៅ ។

ព្រះភិក្ខុនាម ជ ចាប់តាំងពីចូលវស្សាទី៤មក លោកចូលចិត្តចេញក្រៅវត្តទៅរកជជែកគ្នា ជាមួយបុគ្គលនេះ ជាមួយបុគ្គលនោះ ក្នុងរឿងឥតប្រយោជន៍ផ្សេង។ លោកចូលចិត្តស្តាប់វិទ្យុ ចូលចិត្តអានទស្សនាវដ្តី កាសែត និងសៀវភៅផ្លូវលោកផ្សេង។ ។ លោករកឱកាសទៅរៀនវិជ្ជាផ្លូវលោក ត្រៀមខ្លួនដើម្បីនឹងសឹក មានចិត្តរវើរវាយ មិនបានស្ងប់ស្ងៀមដូចពេលដែលលោកទើបតែបួសឡើយ ។ ព្រះភិក្ខុនាម ជ មានចិត្តជ្រប់ទៅក្នុងផ្លូវលោកដូចនេះរឿយ។ បានប្រមាណតែ២ទៅ៣ឆ្នាំប៉ុណ្ណោះ លោកក៏បានប្រទះនូវគ្រោះថ្នាក់រហូតដល់បាត់បង់ជីវិត ទាំងដែលមិនទាន់បានសឹកផង ។

កាលព្រះភិក្ខុនាម ជ ទទួលមរណភាពហើយ ក៏បានទៅបដិសន្ធិនៅក្នុងអបាយភូមិ ដោយអំណាចនៃអកុសលដែលកើតឡើងពេលក្រោយ។ ជួយឧបត្ថម្ភដល់អកុសលជនកកម្ម គឺ អំពើ

បាបដែលបានធ្វើមុនពេលបួស មានឱកាសឱ្យផល ។

**ឧបត្ថម្ភកកម្មប្រការទីពីរ** រមែងជួយឧបត្ថម្ភដល់ជនកកម្ម ដែលកំពុងមានឱកាសឱ្យផល ឱ្យមានកម្លាំងក្នុងការឱ្យផលបរិបូណ៌ក្រៃលែងឡើងនោះ មាន១០ប្រការគឺ ÷

១.កុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ដែលកំពុងមានឱកាសឱ្យផល។

២.កុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល។

៣.អកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ដែលកំពុងមានឱកាសឱ្យផល។

៤.អកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល។

៥.កុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ដែលកំពុងមានឱកាសឱ្យផល។

៦.កុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភ ដល់





កុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល ។

៧.អកុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ដែលកំពុងមានឱកាសឱ្យផល។

៨.អកុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល។

៩.កុសលដែលកើតឡើងក្នុងអតីតភព ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល។

១០.អកុសលដែលកើតឡើងក្នុងអតីតភព ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល។

## សេចក្តីអធិប្បាយ

១.កុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ដែលកំពុងមានឱកាសឱ្យផល ឱ្យមានកម្លាំងក្នុងការឱ្យផលបរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ឈ** ជាមនុស្សមានឧបនិស្ស័យព្រងើយៗ មានចិត្តត្រជាក់ ខ្លាចបាប មិនធ្វើទុច្ចរិត តែការធ្វើបុណ្យរបស់គេ បន្តិចបន្តួច បន្ទាប់បន្សំ មិនបានមាំទាំអ្វីឡើយ ឯការអប់រំចិត្តតាម

ផ្លូវធម៌វិញ ក៏មិនបានល្អដែរ ព្រោះគេមិនមានឱកាស ដោយគេចេះតែរវល់ក្នុងការងារចិញ្ចឹមជីវិតគ្មានឈប់ឈរសោះឡើយ ។

នៅពេលដែលមនុស្សឈ្មោះ **ឈ** នេះជិតស្លាប់ ចិត្តសៅហ្មងពុំបានកើតមានដល់គេទេ គឺគេមានចិត្តស្អាតជាកុសលកើតឡើង ដូច្នេះ កាលដែលគេស្លាប់ទៅហើយ គេក៏បានកើតក្នុងសុគតិភព នេះព្រោះកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ទាំងដែលកុសលក្នុងអតីតភពនោះ មានឱកាសឱ្យផលស្រាប់ផង ម្ល៉ោះហើយកុសល-ជនកកម្មក៏រមែងមានកម្លាំងបរិបូណ៌ក្នុងការឱ្យផល ។

២-កុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យ ផល ឱ្យមានកម្លាំងក្នុងការឱ្យផល បរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ញ** ជាអ្នកមានចិត្តបុណ្យ បំពេញកុសលជានិច្ចកាល មិនបានធ្វើទុច្ចរិតឯណានីមួយឡើយ ព្រោះជាអ្នកខ្លាចបាប ។

ដល់ពេលដែលមនុស្សឈ្មោះ **ញ** នេះជិតនឹងស្លាប់នោះ ក៏មានចិត្តថ្លាស្អាតជាកុសលកើតឡើង ដូច្នេះ កាលមនុស្ស ឈ្មោះ





**ញ** ស្លាប់ទៅ គេក៏បានកើតជាមនុស្ស ឬទេវតាដែលមានឋានៈខ្ពស់ នេះព្រោះកុសលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់កុសលជនកកម្ម ដែលគេបានធ្វើទុកក្នុងជាតិបច្ចុប្បន្ន ទាំងដែលកុសលក្នុងបច្ចុប្បន្នជាតិហ្នឹងឯង មានឱកាសឱ្យផលស្រាប់ផង ម្ល៉ោះហើយកុសលជនកកម្មរមែងមានកម្លាំងបរិបូណ៌ក្នុងការឱ្យផល ។

៣-អកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ដែលកំពុងមានឱកាសឱ្យផល ឱ្យមានកម្លាំងក្នុងការឱ្យផល បរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ដ** មានអធ្យាស្រ័យកំណាញ់ស្វិត មិនចូលចិត្តក្នុងកិច្ចការជាកុសលឡើយ ខ្វាយខ្វល់រវល់ស្វែងរកតែទ្រព្យ-សម្បត្តិប៉ុណ្ណោះ ប៉ុន្តែ ក៏មិនបានធ្វើទុច្ចរិតអ្វីឱ្យធំដុំដែរ ។

ដល់ពេលជិតនឹងស្លាប់ ចិត្តរបស់មនុស្សឈ្មោះ **ដ** មានការសៅហ្មងជាអកុសលកើតឡើង ដោយប្រការណាមួយនោះ ធ្វើឱ្យគេស្លាប់ហើយទៅកាន់អបាយភូមិ នេះព្រោះអកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភពដែលមានឱកាសឱ្យផលស្រាប់ផង ម្ល៉ោះហើយ

អកុសល ជនកកម្មរមែងមានកម្លាំងបរិបូណ៌ក្នុងការឱ្យផល ។

៤.អកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល ឱ្យមានកម្លាំងក្នុងការឱ្យផល បរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ឋ** មានចិត្តជាអកុសលច្រើន មិនជឿក្នុងបាបបុណ្យគុណទោស មានមិច្ឆាទិដ្ឋិ មិនជឿថាមាននរកសួគ៌អ្វីឡើយ ព្រោះហេតុនេះ គេធ្វើអ្វីៗទៅតាមការពេញចិត្តរបស់ខ្លួនគេ ទោះបីជាបាបកម្មនោះខ្លាំងក្លាយ៉ាងណាក៏គេហ៊ានធ្វើដែរ ។

ដល់ពេលមនុស្សឈ្មោះ **ឋ** នេះជិតនឹងស្លាប់ ក៏មានចិត្តសៅហ្មងកើតឡើង លុះស្លាប់ហើយក៏បានបដិសន្ធិក្នុងអបាយភូមិសោយទុក្ខក្នុងទីនោះអស់កាលជាអង្វែង នេះព្រោះអកុសលដែលកើតឡើងក្នុងមរណាសន្នកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ទាំងដែលអកុសលក្នុងបច្ចុប្បន្នភពហ្នឹងឯង មានឱកាសឱ្យផលស្រាប់ផង ម្ល៉ោះហើយអកុសលជនកកម្មរមែងមានកម្លាំងបរិបូណ៌ក្នុងការឱ្យផល ។

៥.កុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ដែលកំពុងមានឱកាសឱ្យផល ឱ្យមាន





កម្លាំងក្នុងការឱ្យផល បរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ឌ** ជាកូនរបស់អ្នកមានចិត្តបុណ្យ មាតាបិតាអប់រំឱ្យចេះដាក់បាត្រលោក សូត្រធម៌ថ្វាយបង្គំព្រះជាប្រក្រតី ប៉ុន្តែកូនឈ្មោះ **ឌ** មានអាយុបានប្រមាណ៧ឆ្នាំប៉ុណ្ណោះ ក៏ស្លាប់ទៅហើយក៏បដិសន្ធិក្នុងស្ថានសួគ៌ ។

នេះព្រោះកុសលដែលកូនឈ្មោះ **ឌ** ធ្វើក្នុងបវត្តិកាលនោះ ជួយឧបត្ថម្ភដល់កុសលជនកកម្មដែលគេធ្លាប់ធ្វើក្នុងអតីតភព ទាំងដែលកុសលកម្មក្នុងអតីតភពហ្នឹងឯង មានឱកាសឱ្យផលស្រាប់ផង ម្ល៉ោះហើយ កុសលជនកកម្មរមែងមានកម្លាំងបរិបូណ៌ក្នុងការឱ្យផល ។

៦.កុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល ឱ្យមានកម្លាំងក្នុងការឱ្យផល បរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ឍ** ជាកូនរបស់អ្នកដែលមានចិត្តបុណ្យ មាតាបិតាមានការចេះដឹងនៅក្នុងព្រះធម៌ ដូច្នេះទើបបានអប់រំកូនឈ្មោះ **ឍ** ឱ្យបានយល់ដឹងក្នុងព្រះពុទ្ធសាសនា ឱ្យចេះដឹងបុណ្យបាបគុណទោស ឱ្យមានសទ្ធាជឿកម្មផល ម្ល៉ោះហើយ កូនឈ្មោះ **ឍ** ក៏ជឿ ហើយបដិបត្តិតាមពាក្យទូន្មានរបស់មាតាបិតាបានយ៉ាង

ល្អប្រសើរ បានខិតខំព្យាយាមធ្វើទាន រក្សាសីល ចម្រើនភាវនា ជានិច្ចកាល ។

ដោយបាននៅក្នុងឱវាទរបស់មាតាបិតា ដែលជាសប្បុរស មនុស្សឈ្មោះ **ឍ** ស្លាប់ទៅបានបដិសន្ធិក្នុងស្ថានសួគ៌ជាន់ខ្ពស់ នេះព្រោះកុសលដែលគេបានបំពេញជានិច្ចកាលហ្នឹងឯង ជួយឧបត្ថម្ភដល់កុសលជនកកម្មដែលបានកើតឡើងក្នុងបច្ចុប្បន្នភព ឱ្យមានកម្លាំងញ៉ាំងវិបាកបដិសន្ធិ ទាំងដែលជនកកម្មមានឱកាសស្រាប់ផង ។

សម្រាប់ជនកកម្មដែលមានឱកាសឱ្យផលនោះ ជាកុសលដែលកើតមុនក៏បាន ជាកុសលដែលកើតក្រោយក៏បាន។ បើកុសលដែលកើតមុនជាជនកកម្ម កុសលដែលកើតក្រោយរមែងជួយឧបត្ថម្ភឱ្យជនកកម្មមានកម្លាំង បើកុសលដែលកើតក្រោយជាជនកកម្ម កុសលដែលកើតមុនរមែងជួយឧបត្ថម្ភឱ្យជនកកម្មមានកម្លាំង ដោយប្រការដូច្នេះឯង ។

៧-អកុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ដែលកំពុងមានឱកាសឱ្យផល ឱ្យមានកម្លាំងក្នុងការឱ្យផល បរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ណ** ជាកូនរបស់មនុស្សដែលមិនបានរាប់-



អានព្រះពុទ្ធសាសនា តាំងតែពីតូចរហូតដល់ធំពេញវ័យ គេមិនដែលបានទទួលនូវការអប់រំក្នុងរឿងបុណ្យបាបអ្វីឡើយ គេមិនចេះគោរពកោតក្រែងដល់មនុស្សចាស់ទុំ ហើយគេចូលចិត្តណាស់ក្នុងរឿងសប្បាយរីករាយដោយប្រការផ្សេងៗ ប៉ុន្តែ មនុស្សឈ្មោះ **ណ** នេះ គេក៏មិនបានប្រព្រឹត្តនូវអកុសលកម្មអ្វីឱ្យធំដុំដែរ ។

លុះដល់មនុស្សឈ្មោះ **ណ** នេះឯងធ្វើកាលកិរិយាស្លាប់ទៅ ក៏បានបដិសន្ធិក្នុងនរក នេះព្រោះអកុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងអតីតភព ទាំងដែលអកុសលកម្មក្នុងអតីតភពហ្នឹងឯង មានឱកាសឱ្យផលស្រាប់ផង ម៉្លោះហើយ អកុសលជនកកម្មរមែងមានកម្លាំងបរិបូណ៌ក្នុងការឱ្យផល ។

៨-អកុសលដែលកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល ឱ្យមានកម្លាំងក្នុងការឱ្យផល បរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ត** ជាមនុស្សមានមិច្ឆាទិដ្ឋិ មិនជឿបាប មិនជឿបុណ្យ យល់ថាការធ្វើបុណ្យ មិនមានប្រយោជន៍អ្វីឡើយ ធ្វើហើយអស់តែទ្រព្យ ខាតតែកម្លាំង កាន់សីល៨ក៏មិនមានប្រយោជន៍ អត់បាយឃ្លានទទេៗ ការបដិបត្តិអប់រំចិត្តក៏មិនមាន

ប្រយោជន៍ដែរ ខាតពេលផង លំបាកផង គឺមិនចាំបាច់ធ្វើអ្វីទាំងអស់ ព្រោះមនុស្សស្លាប់ទៅ ត្រូវកើតជាមនុស្សទៀត ឆ្កែស្លាប់ទៅកើតឆ្កែទៀត ជ្រូកស្លាប់ទៅកើតជ្រូកទៀត ដូចនេះជាដើម ។

ព្រោះមិច្ឆាទិដ្ឋិយ៉ាងនេះ ទើបមនុស្សឈ្មោះ ត ធ្វើតែបាបកម្មយ៉ាងច្រើន ដល់ពេលស្លាប់ទៅ គេបានបដិសន្ធិក្នុងនរកសោយទុក្ខវេទនាដ៏យ៉ាងខ្លាំងក្លា នេះព្រោះអកុសលដែលបានកើតឡើងក្នុងបវត្តិកាល ជួយឧបត្ថម្ភដល់អកុសលជនកកម្ម ដែលមនុស្សឈ្មោះ ត នេះ បានធ្វើក្នុងបច្ចុប្បន្នភពទាំងដែលកំពុងមានឱកាសឱ្យផលស្រាប់ផង ម៉្លោះហើយ អកុសលជនកកម្មរមែងមានកម្លាំងបរិបូណ៌ក្នុងការឱ្យផល ។

៩-កុសលដែលកើតឡើងក្នុងអតីតភព ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល ឱ្យមានកម្លាំងក្នុងការឱ្យផល បរិបូណ៌ក្រៃលែងឡើងនោះ ដូចជា :

មនុស្សឈ្មោះ ថ មានសទ្ធាចាស់ក្លា ធុញទ្រាន់ក្នុងឃរាវាស ព្រោះមានឱកាសសាងកុសលបានតិច ហើយមានភាពចង្អៀតណែន ដោយសារបញ្ហាផ្សេងៗសន្ធឹកសន្ធាប់រួបរឹតជុំជិតខ្លួន ។ បើមិនមានប្រាក់ក៏លំបាក ព្រោះមិនមានអ្វីបរិភោគ តែបើមានវិញក៏លំបាកដែរ ព្រោះត្រូវហួងហែង ។ល។ និង។ល។





មនុស្សឈ្មោះ ថ ពិចារណាឃើញ ទោសក្នុងការគ្រប់គ្រងផ្ទះ ដោយប្រការផ្សេងៗ ហើយក៏ចេញចាកផ្ទះចូលមកបួសក្នុងព្រះពុទ្ធសាសនា កាលបួសហើយក៏តាំងចិត្តបដិបត្តិក្នុងគន្ថធុរៈ និងរក្សាវិន័យបានយ៉ាងហ្មត់ចត់ ជាភិក្ខុស្អាតល្អបរិសុទ្ធក្នុងសីលសិក្ខា លុះដល់ចប់ការសិក្សាហើយ ក៏តាំងចិត្តបង្រៀនដល់ព្រះភិក្ខុ សាមណេរ ឧបាសក ឧបាសិកាតទៅ ព្រមទាំងបដិបត្តិក្នុងវិបស្សនាធុរៈបានយ៉ាងប្រសើរទៀតផង ។

ភិក្ខុព្រះនាម ថ បានបដិបត្តិល្អរហូតដល់អស់ព្រះជន្ម កាលទទួលមរណភាពហើយ ក៏បានបដិសន្ធិក្នុងទេវលោកជាទេវតាជាន់ខ្ពស់ ។ កុសលចាស់ៗពីជាតិមុនដែលភិក្ខុព្រះនាម ថ ធ្លាប់សាងទុកមក ដែលជាអបរាបរិយវេទនីយកម្ម ក៏មានដែរ តែកុសលដែលព្រះភិក្ខុ ថ បានបំពេញក្នុងបច្ចុប្បន្នជាតិនេះមានកម្លាំងខ្លាំងជាង ដូច្នេះ ទើបកុសលក្នុងអតីតជាតិមិនមានកម្លាំងល្មមដែលនឹងឱ្យបដិសន្ធិបាន គឺបានត្រឹមតែជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងបច្ចុប្បន្នជាតិ ដែលមានឱកាសឱ្យផលស្រាប់ហើយនោះ ធ្វើឱ្យមានកម្លាំងក្នុងការឱ្យផលបានយ៉ាងបរិបូណ៌ ។

១០-អកុសលដែលកើតឡើងក្នុងអតីតភព ជួយឧបត្ថម្ភដល់អកុសលជនកកម្មក្នុងបច្ចុប្បន្នភព ដែលកំពុងមានឱកាសឱ្យផល

ធ្វើឱ្យមានកម្លាំងក្នុងការឱ្យផលបរិបូណ៌ឡើងនោះ ដូចជា :

មនុស្សឈ្មោះ **ទ** ជាអ្នកមានចិត្តបាបសាហាវយង់ឃ្នង មិនធ្លាប់បានធ្វើនូវកុសលណាមួយឡើយ មានតែការបំពេញនូវអកុសលរហូតតមក គឺសម្លាប់សត្វផង លួចប្លន់ទ្រព្យសម្បត្តិអ្នកស្រុកផង ប្រព្រឹត្តខុសលើបុត្រភរិយាអ្នកដទៃផង ជាដើម ។

កាលមនុស្សឈ្មោះ **ទ** នេះស្លាប់ទៅ អកុសលកម្មដែលគេបានធ្វើនៅក្នុងបច្ចុប្បន្នជាតិ មានឱកាសឱ្យផលបដិសន្ធិក្នុងអបាយភូមិ ។ បាបកម្មចាស់ៗដែលគេធ្លាប់បានធ្វើទុកពីអតីតជាតិដែរនោះ ជួយឧបត្ថម្ភដល់អកុសលដែលជាជនកកម្ម ធ្វើឱ្យមានកម្លាំងបរិបូណ៌ឡើង ។

ប្រៀបដូចមនុស្សដែលធ្វើខុសច្បាប់ច្រើនលើកមកហើយ លុះដល់ក្រោយមកបានធ្វើខុសទៀត ហើយត្រូវគេចាប់បាន កាលដែលចៅក្រមពិចារណាទោសរបស់គេនោះឯង ក៏យកសំណុំរឿងចាស់ៗ មករួមពិចារណាផង ហើយបានដាក់ទោសឱ្យគេយ៉ាងធ្ងន់ ។ នេះសម្តែងឱ្យឃើញថា ការធ្វើខុសលើកមុនៗ សូម្បីបានរួចខ្លួនពីការចាប់ក៏ដោយ ប៉ុន្តែពេលដែលបុគ្គលនោះត្រូវចាប់ខ្លួនបាន កំហុសមុនៗត្រូវគេបានដឹងទាំងប៉ុន្មាននោះឯង រមែងជួយធ្វើឱ្យកំហុសក្រោយនៅពេលដែលគេចាប់បាននោះ មានទោសធ្ងន់ក្រៃលែងឡើង ។

**ឧបត្ថម្ភកកម្មប្រការទីបី** រមែងជួយឧបត្ថម្ភដល់នាមរូបដែលជាផលរបស់ជនកកម្ម ឱ្យចម្រើនឡើង និងតាំងនៅបាននោះ មាន៧ប្រការគឺ ÷

១_កុសលដែលធ្លាប់ធ្វើមកក្នុងភពមុនៗ ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីកុសលជនកកម្ម ។

២_កុសលដែលធ្លាប់ធ្វើមកក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីកុសលជនកកម្ម ។

៣_អកុសលដែលធ្លាប់ធ្វើមកក្នុងភពមុនៗ ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ។

៤_អកុសលដែលធ្លាប់ធ្វើមកក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ។

៥_កុសលដែលធ្លាប់ធ្វើមកក្នុងភពមុនៗ ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ។

៦_កុសលដែលធ្លាប់ធ្វើមកក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ។

៧_អកុសលដែលធ្លាប់ធ្វើមកក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីកុសលជនកកម្ម ។

✍-តាំងពីចំណុចទី១ មកដល់ចំណុចទី៤ សម្តែងតាមន័យអដ្ឋកថា និងមូលដីកា ឯចំណុចទី៥ដល់ទី៧ សម្តែងតាមន័យបរមត្ថទីបនីដីកា និងភាសាដីកា ។

## សេចក្តីអធិប្បាយ

១-កុសលដែលធ្លាប់ធ្វើមកក្នុងភពមុនៗ ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីកុសលជនកកម្ម ឱ្យចម្រើនឡើងនិងតាំងនៅបាននោះ ដូចជា ព្រះសរីរៈរាងកាយ ពណ៌សម្បុរ ជាដើមរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ រមែងស្អាតប្រណីតល្អល្អះ វិសេសលើសអស់មនុស្សទាំងពួង ទាំងការឃើញ ការឮ ជាដើម ដោយចំណែកច្រើនគឺជាកុសលវិបាក ទទួលអារម្មណ៍ល្អៗ ប្រណីតៗ នេះព្រោះបារមីផ្សេងៗ ដែលព្រះអង្គទ្រង់ធ្លាប់សាងមកក្នុងភពមុននោះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីកុសលជនកកម្ម ឱ្យចម្រើននិងតាំងនៅបាន ។

២-កុសលដែលធ្លាប់ធ្វើមកក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីកុសលជនកកម្ម ឱ្យចម្រើនឡើងនិងតាំងនៅបាននោះ ដូចជា បុគ្គលមានចិត្តជាកុសល ពោលគឺជួយសង្គ្រោះ



ដល់អ្នកមានទុក្ខលំបាក ឬក៏ជួយទំនុកបម្រុងកិច្ចការងារក្នុងព្រះពុទ្ធសាសនា ឱ្យចម្រើនរុងរឿង ជាអ្នករក្សាខ្លួនឱ្យស្ថិតនៅក្នុងសីលធម៌ជានិច្ច ដោយអំណាចនៃកុសលដែលបានធ្វើទាំងអស់នេះ រមែងធ្វើឱ្យគេបានសុខកាយសប្បាយចិត្ត ពណ៌សម្បុរស្រស់ថ្លា មានកិត្តិយស បានទទួលអារម្មណ៍ល្អៗ ទាំងប្រាសចាករោគភ័យ មានកម្លាំងមាំមួន អាយុយឺនយូរ បើមានជំងឺអ្វីកើតឡើង ក៏បានជួបនឹងពេទ្យល្អ មានថ្នាំល្អឆាប់ជា និងមានមនុស្សល្អៗជួយទំនុកបម្រុងឱ្យបានទទួលនូវសេចក្តីសុខសប្បាយគ្រប់យ៉ាង ទាំងអស់នេះ ព្រោះកុសលដែលគេបានធ្វើក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតអំពីកុសលជនកកម្ម ឱ្យចម្រើននិងតាំងនៅបាន។

៣-អកុសលដែលធ្លាប់ធ្វើមកក្នុងភពមុនៗ ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ឱ្យចម្រើននិងឱ្យតាំងនៅបាននោះ ដូចជា ការរស់នៅរបស់សត្វនរកប្រេតទាំងឡាយ ជាការរស់នៅពេញទៅដោយទុក្ខដ៏សែនខ្លាំងក្លា ឬដូចជាសត្វសុនខដែលមានរូបអាក្រក់មិនមានអ្នកណាចូលចិត្ត កើតអង្គែ កើតរមាស់ពេញទាំងខ្លួន ចូលទៅជិតអ្នកណាៗ គេក៏គប់គ្រវែងដោយការខ្ពើមឆ្អើម ម្ល៉ោះហើយសត្វសុនខនោះក៏បានដល់នូវទុក្ខវេទនាកាន់តែខ្លាំងឡើង តែសូម្បីយ៉ាងនេះ សត្វនរកក្តី ប្រេតក្តី សុនខក្តី

ដែលមាននូវទុក្ខវេទនាខ្លាំងក្លាដូចពោលហើយនេះ ក៏អាចមានជីវិតរស់នៅបានយូរៗក្នុងភពនោះៗ ។

ទាំងអស់នេះ គឺដោយអំណាចនៃអកុសលកម្មដែលមានក្នុងភពមុនៗ ឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ឱ្យចម្រើននិងតាំងនៅបាន ។

៤.អកុសលដែលធ្លាប់ធ្វើមកក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ឱ្យចម្រើននិងតាំងនៅបាននោះ បានដល់ សត្វតិរច្ឆាន ដូចជា សត្វខ្លា គោ ចចក ជាដើម ជាសត្វកើតមកពីអកុសលជនកកម្ម ហើយដែលសត្វទាំង-អស់នេះ មានការបៀតបៀនសម្លាប់សត្វដទៃ បរិភោគជាអាហារ ធ្វើឱ្យរាងកាយរបស់សត្វនេះចម្រើនធំឡើង តាំងនៅបានរហូតដល់អស់ជីវិត នេះព្រោះអកុសលកម្មដែលកើតឡើងក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ឱ្យចម្រើន និងតាំងនៅបាន ។

៥.កុសលដែលធ្លាប់ធ្វើមកក្នុងភពមុនៗ ជួយឧបត្ថម្ភដល់នាមរូបដែលកើតអំពីអកុសលជនកកម្ម ឱ្យចម្រើន និងតាំងនៅបាននោះ ដូចជា សត្វឆ្កែខ្លះ សត្វឆ្មាខ្លះ ដែលមានម្ចាស់ចិញ្ចឹមបីបាច់ថែរក្សា បានទទួលសេចក្ដីសុខសប្បាយ រស់ស្រួលស៊ីឆ្ងាញ់





( មានសត្វនាគពពួកខ្លះរស់នៅក្នុងវិមានទិព្វ សម្បូណ៌ទៅដោយកាមគុណ៥ប្រការ ) នេះព្រោះអំណាចនៃកុសលកម្មដែលសត្វទាំងនោះបានធ្វើទុកមកក្នុងភពមុនៗនោះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតអំពីអកុសលជនកកម្ម ។

៦.កុសលដែលធ្លាប់ធ្វើមកក្នុងភពនេះឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតអំពីអកុសលជនកកម្ម ឱ្យចម្រើននិងតាំងនៅបាននោះ ដូចជា សត្វតិរច្ឆានខ្លះមានការឆ្លាត បង្ហាត់បានងាយសម្ដែងការគោរពដល់ម្ចាស់និងអ្នកដទៃតាមសមគួរ ធ្វើឱ្យម្ចាស់និងអ្នកដទៃបានឃើញហើយក៏ចូលចិត្ត ព្រោះចូលចិត្តស្រឡាញ់ផង អាណិតផង ក៏ចិញ្ចឹមឱ្យបានសេចក្ដីសុខសប្បាយ ឱ្យបរិភោគអាហារល្អៗ និងមានការថ្នាក់ថ្នមយ៉ាងពិសេស ។

មានសត្វសេកខ្លះ ម្ចាស់បង្ហាប់ឱ្យនិយាយបាន សូត្រធម៌បាន ពោលពាក្យធ្វើបដិសណ្ឋារៈបាន ធ្វើឱ្យអ្នកដែលបានឮកើតចិត្តអាណិតស្រឡាញ់ ហើយនាំយកអាហារល្អៗមកឱ្យ ក៏បានសេចក្ដីសុខសប្បាយ នេះព្រោះអំណាចនៃសេចក្ដីឆ្លាត និងកុសលកម្មខ្លះៗដែលសត្វទាំងនោះបានធ្វើក្នុងបច្ចុប្បន្នភពនេះ មានការសម្ដែងសេចក្ដីគោរពជាដើមហ្នឹងឯង ជួយឧបត្ថម្ភដល់នាមរូបដែលកើតពីអកុសលជនកកម្ម ឱ្យចម្រើននិងតាំងនៅបាន ។

ម្យ៉ាងទៀត ដូចជា ពពួកប្រេតទាំងឡាយ ដែលបានទទួលចំណែកបុណ្យរបស់ពួកញាតិដែលគេបានឧទ្ទិសទៅឱ្យ ដោយការអនុមោទនា កុសលដែលពួកប្រេតទាំងនោះបានបំពេញ ពោលគឺមានចិត្តត្រេកអរចំពោះកុសលនោះៗ រមែងធ្វើឱ្យពួកគេដែលមានចិត្តត្រេកអរនឹងបុណ្យ បាននូវសេចក្តីសុខ ផុតពីការស្រេកឃ្លានក្នុងកំណើតប្រេតនោះឯង នេះព្រោះអំណាចនៃកុសលកម្មដែលពួកប្រេតនោះបានធ្វើ ជួយឧបត្ថម្ភដល់នាមរូបដែលកើតអំពីអកុសលជនកកម្ម ឱ្យចម្រើននិងបានធូរស្បើយនូវទុក្ខវេទនា ។

៧.អកុសលដែលធ្លាប់ធ្វើមកក្នុងភពនេះ ជួយឧបត្ថម្ភដល់នាមរូបដែលកើតអំពីកុសលជនកកម្ម ឱ្យចម្រើននិងឱ្យតាំងនៅនោះ ដូចជា មនុស្សដែលមានការចិញ្ចឹមជីវិតដោយអំពើបាណាតិបាត ជាព្រានទេសាទត្រី ឬបាញ់សត្វ ឬក៏ជាអ្នកសម្លាប់ជ្រូកមាន់ទាជាប្រចាំរាល់ថ្ងៃជាដើម ពុំនោះសោត ជាអ្នកចិញ្ចឹមជីវិតដោយជំនួញ៥ប្រការ ជំនួញណាមួយ មានការជួញដូរមនុស្ស គ្រឿងសស្ត្រាវុធ និងគ្រឿងញៀនជាដើម ហើយក៏បាននូវសម្បត្តិ ធ្វើជាអ្នកមានស្តុកស្តម្ភ មានសេចក្តីសុខសប្បាយក្នុងការស៊ីក្នុងការចាយដោយអាស្រ័យអាជីពទាំងអស់នេះឯង ។

(អកុសលកម្ម ជាបច្ច័យនៃកុសលវិបាកដោយឧបនិស្សយ-





បច្ច័យ ក្នុងបច្ចុប្បន្នជាតិ ប៉ុន្តែ អកុសលកម្ម ជាបច្ច័យនៃអកុសលវិបាកដោយកម្មប្បច្ច័យ ដូច្នេះ អ្នកដែលធ្វើអំពើអាក្រក់ហើយជាអ្នកមានបាន ស៊ីចាយសប្បាយហ៊ឺហា មិនមែនព្រោះអំពើអាក្រក់នោះជាកម្មប្បច្ច័យទេ អំពើអាក្រក់គ្រាន់តែជាឧបនិស្សយ-បច្ច័យប៉ុណ្ណោះ ក៏ដោយអាស្រ័យមានបុណ្យគឺអំពើល្អដែលគេបានធ្វើហើយ ក្នុងកាលមុន ឬជាតិមុននោះឯង ជាកម្មប្បច្ច័យផងដោយពិត ឯចំណែកអំពើអាក្រក់កាលណាបើជាកម្មប្បច្ច័យហើយរមែងឱ្យផលវិបាកជាទុក្ខតែម្យ៉ាងប៉ុណ្ណោះ ) ក្នុងចំណុចទី៧នេះពោលអំពីអកុសលកម្មដែលបានធ្វើក្នុងភពនេះ ឧបត្ថម្ភដល់នាមរូបដែលកើតអំពីកុសលជនកកម្ម ឱ្យចម្រើននិងឱ្យតាំងនៅ (តាមរយៈនៃឧបនិស្សយបច្ច័យ) ដូច្នេះឯង ។

**កិច្ចទី៣-ឧបបីឡកកម្ម** កម្មណាដែលចូលទៅបៀតបៀនដល់កម្មដទៃៗ និងការបន្តនៃខន្ធ៥ដែលកើតអំពីកម្មដទៃៗនោះ កម្មនោះឯងឈ្មោះថា ឧបបីឡកកម្ម បានដល់អកុសលកម្មក្នុងចិត្ត១២ដួង និងកុសលកម្មក្នុងមហាកុសលចិត្ត៨ដួង ។

ឧបបីឡកកម្មនេះជាកម្មដែលបៀតបៀននូវជនកកម្មដទៃៗដែលមានសភាព ផ្ទុយពីខ្លួនឯង នេះម្យ៉ាង និងម្យ៉ាងទៀតមានការបៀតបៀន នាមរូបដែលកើតអំពីជនកកម្មនោះៗ ។

ឧបបីឡកកម្មដែលបៀតបៀនដល់ជនកកម្មដទៃៗ ដែលមានសភាពផ្ទុយពីខ្លួនឯងនោះ អាចបៀតបៀនបានពីរយ៉ាង គឺ យ៉ាងទីមួយ បៀតបៀនដើម្បីមិនឱ្យមានឱកាសបង្កើតផល និង យ៉ាងទីពីរ បៀតបៀនជនកកម្មដែលមានឱកាសឱ្យផលហើយនោះ ធ្វើឱ្យកម្លាំងថយចុះ បង្កើតផលមិនបានពេញលេញ ។

ដូច្នេះ ការបៀតបៀនរបស់ឧបបីឡកកម្មនេះ សរុបមក មាន បីប្រការ គឺ ÷

-ប្រការទីមួយ បៀតបៀនដោយការធ្វើឱ្យជនកកម្មដទៃៗ មិនអាចឱ្យផលបាន ។

-ប្រការទីពីរ បៀតបៀនដោយការធ្វើឱ្យជនកកម្មដទៃៗ ដែលមានឱកាសឱ្យផលហើយនោះ ថយចុះនូវកម្លាំង ឱ្យផលមិនបានពេញលេញ ។

-ប្រការទីបី គឺបៀតបៀននូវនាមរូបដែលកើតពីជនកកម្មហ្នឹងឯង ។

**ឧបបីឡកកម្មប្រការទីមួយ** រមែងបៀតបៀនដល់ជនកកម្មដទៃៗ ដើម្បីមិនឱ្យមានឱកាសបង្កើតផលនោះ មាន២ ប្រភេទគឺ ÷

១-កុសលដែលធ្វើក្នុងភពនេះ បៀតបៀនដល់អកុសល





ជនកកម្ម ដើម្បីមិនឱ្យមានឱកាសបង្កើតផល ។

២-អកុសលដែលធ្វើក្នុងភពនេះ បៀតបៀនដល់កុសលជនកកម្ម ដើម្បីមិនឱ្យមានឱកាសបង្កើតផល ។

## សេចក្តីអធិប្បាយ

១-ឧបបីឡកកម្មនេះ បានដល់ ឧបត្ថម្ភកកម្មនោះឯង គឺក្នុងខណៈដែលធ្វើកិច្ចជួយឧបត្ថម្ភដល់កម្មដទៃនោះ ក្នុងពេលជាមួយគ្នាហ្នឹងឯង ក៏ធ្វើកិច្ចបៀតបៀនផងដែរ ។ លើកតួយ៉ាងនៃកុសល-ឧបបីឡកកម្មក្នុងចំណុចទី១ ដែលថា « កុសលដែលធ្វើក្នុងភពនេះ បៀតបៀនអកុសលជនកកម្ម ដើម្បីមិនឱ្យមានឱកាសបង្កើតផល » នេះគឺប្រព្រឹត្តទៅក្នុងទំនងដូចគ្នានឹងកុសលឧបត្ថម្ភកកម្មក្នុងចំណុចទី១ ដែលថា «កុសលដែលកើតឡើងក្នុងមរណាសន្ន-កាល ជួយឧបត្ថម្ភដល់កុសលជនកកម្មក្នុងអតីតភព ដែលនៅមិនទាន់មានឱកាសឱ្យផល ធ្វើឱ្យមានឱកាសទៅបាន ដូចជា មនុស្សឈ្មោះ **ក** ... » (នៅក្នុងសេចក្តីនេះគប្បីជ្រាបថា ក្នុងកិច្ចឧបត្ថម្ភដល់កុសលជនកកម្មក៏ត្រូវបៀតបៀនដល់អកុសលជនកកម្មផងដែរ ) ។

២-អកុសលដែលធ្វើក្នុងភពនេះ បៀតបៀនដល់កុសលជនកកម្ម ដើម្បីមិនឱ្យមានឱកាសបង្កើតផល បានដល់ អកុសលកម្មដែលជួយឧបត្ថម្ភដល់អកុសលជនកកម្ម ដើម្បីឱ្យអកុសលជនកកម្មហ្នឹងឯងមានឱកាសបង្កើតផល ដូច្នេះ ទើបត្រូវបៀតបៀនដល់កុសលជនកកម្មមិនឱ្យមានឱកាសជាជនកប្បច្ច័យទៅបាន (អ្នកសិក្សាគប្បីបានជ្រាបតាមទំនងនៃឧបត្ថម្ភកកម្មដែលមានកិច្ចបៀតបៀនដល់កម្មដទៃផង ដោយប្រការដូច្នេះឯង)។

**ឧបបីឡកកម្មប្រការទីពីរ** រមែងបៀតបៀនដល់ជនកកម្មដទៃៗដែលមានឱកាសឱ្យផលហើយនោះ ធ្វើឱ្យមានកម្លាំងថយចុះ ឱ្យផលមិនបានពេញលេញ មាន២ប្រភេទ គឺ ÷

១-កុសលដែលធ្វើក្នុងភពនេះ បៀតបៀនដល់អកុសលជនកកម្មដែលមានឱកាសឱ្យផលហើយនោះ ធ្វើឱ្យមានកម្លាំងថយចុះ ឱ្យផលមិនបានពេញលេញ ។

២-អកុសលដែលធ្វើក្នុងភពនេះ បៀតបៀនដល់កុសលជនកកម្មដែលមានឱកាសឱ្យផលហើយនោះ ធ្វើឱ្យមានកម្លាំងថយចុះ ឱ្យផលមិនបានពេញលេញ ។





## សេចក្តីអធិប្បាយ

១-លើកតួយ៉ាងដូចជា ព្រះបាទអជាតសត្តុដែលបានធ្វើនូវអនន្តរិយកម្ម គឺ បិតុឃាត កម្មដ៏ធ្ងន់នេះត្រូវឱ្យផលធ្លាក់ក្នុងអវីចីមហានរក តែដោយព្រះបាទអជាតសត្តុ បានបំពេញនូវកុសលយ៉ាងច្រើនសន្ធឹកសន្ធាប់ គឺជាអ្នកឧបត្ថម្ភទំនុកបម្រុងនូវព្រះពុទ្ធសាសនា ដូចជាក្នុងបឋមសង្គាយនា ព្រះបាទអជាតសត្តុ គឺជាអ្នកឧបត្ថម្ភ ហើយក្នុងបណ្តាបុថុជ្ជនទាំងឡាយ ព្រះបាទអជាតសត្តុ ជាអ្នកជ្រះថ្លារាប់អានព្រះសម្មាសម្ពុទ្ធជាម្ចាស់ខ្លាំងក្លាជាទីបំផុត (បើមិនបានធ្វើបិតុឃាតទេនោះ ព្រះបាទអជាតសត្តុនៅពេលស្តាប់សាមញ្ញផលសូត្ររួចហើយ ត្រូវបានសម្រេចសោតាបត្តិផល ) ព្រោះហេតុដូច្នោះ ដោយអំណាចនៃកុសលហ្នឹងឯង ទើបជួយឱ្យព្រះបាទអជាតសត្តុ មិនបានធ្លាក់ទៅអវីចិមហានរក ដែលជានរករណ្តៅធំឡើយ ធ្លាក់ទៅត្រឹមតែលោហកុម្ភីនរក គឺ ជានរករណ្តៅតូចដែលជាបរិវាររបស់អវីចីមហានរកប៉ុណ្ណោះ ។ នេះគឺកុសលដែលធ្វើក្នុងភពនេះ បៀតបៀនដល់អកុសលជនកកម្មដែលមានឱកាសឱ្យផលហើយនោះ ធ្វើឱ្យមានកម្លាំងថយចុះ ឱ្យផលមិនបានពេញលេញ (បាបកម្មដែលព្រះបាទ

អជាតសត្តុបានធ្វើ ច្រើនតែមកអំពីភិក្ខុទេវទត្តផ្តល់នូវគំនិតឱ្យ )។

២.ចំពោះអកុសលបៀតបៀនកុសលជនកកម្មនោះ បាន ដល់ការធ្វើនូវកុសលកម្មឯណានីមួយហើយ មានអកុសលច្របូក ច្របល់ដូវផ្លាស់សៅហ្មងតាមក្រោយ ឬនៅពេលជ្រះថ្លាក្នុងការ ធ្វើនូវកុសលកម្មអ្វីមួយ គឺជាអ្នកឃើញប្រយោជន៍ក្នុងការធ្វើល្អ នោះ ដល់ធ្វើស្រេចហើយ ក៏ស្រាប់តែមានអកុសលកើតឡើង មានការមិនពេញចិត្តខ្លះ ស្តាយទ្រព្យសម្បត្តិខ្លះ ជាដើម ដូច្នេះ រមែងធ្វើឱ្យកុសលមានកម្លាំងថយចុះ លុះដល់ពេលស្លាប់ទៅ ជំនួសដែលនឹងត្រូវបដិសន្ធិដោយតិហេតុកៈ គឺ មានអលោភៈ អទោសៈ និងអមោហៈក្នុងខណៈបដិសន្ធិនោះ បែរទៅជា ទុហេតុកបដិសន្ធិវិញ គឺមានត្រឹមតែអលោភៈ និងអទោសៈក្នុង ខណៈបដិសន្ធិតែប៉ុណ្ណោះ មិនមាននូវអមោហៈផងឡើយ (ឬក៏ត្រូវ បដិសន្ធិជាទេវតាថ្នាក់ទាប ដូចជាចោរម្នាក់នៅក្រុងរាជគ្រឹះ មុន នឹងគេប្រហារជីវិត បានធ្វើទានដល់ព្រះមហាមោគ្គល្លានរួចហើយ ក៏មានចិត្តប្រតិព័ទ្ធស្រឡាញ់នាងសុលសា ដែលបាននាំអាហារមក ឱ្យខ្លួន បើតាមតែកម្លាំងបុណ្យខ្លាំង ព្រោះមានព្រះមហា-មោគ្គល្លានជាស្រែបុណ្យដ៏ប្រសើរ ត្រូវទៅបដិសន្ធិក្នុងទេវលោក ជាន់ខ្ពស់ តែនេះព្រោះមានចិត្តសៅហ្មងច្របូកច្របល់នៅពេល



ធ្វើកុសលនោះ ទើបកើតជាទេវតាថ្នាក់ទាប )នេះព្រោះអំណាច នៃអកុសលដែលកើតឡើងនោះឯង ចូលបៀតបៀននូវកុសល-ជនកកម្មឱ្យមានកម្លាំងថយចុះ ទើបមានផលទន់ខ្សោយដោយ ប្រការដូច្នេះ ។

ម្យ៉ាងទៀត បុគ្គលខ្លះបានបដិសន្ធិជាមនុស្ស តែដល់ពេល ប្រសូតចាកគភ៌មាតាមក ក៏ជាមនុស្សខ្វាក់ភ្នែក ថ្លង់គ ជាដើម ភាពពិការតាំងពីកំណើតមកយ៉ាងនេះ ព្រោះកុសលជនកកម្មដែល ជាបច្ច័យឱ្យបដិសន្ធិជាមនុស្សនោះ ត្រូវអកុសលឧបបីឡកកម្ម បៀតបៀនឱ្យមានកម្លាំងថយចុះ ព្រោះហេតុដូច្នេះ ទើបដល់ពេល ដែលត្រូវមានភ្នែក ឬត្រចៀកជាដើមនោះ ភ្នែកឬត្រចៀកវាមិន អាចកើតឡើងបាន ក៏ក្លាយជាមនុស្សពិការតាំងតែពីកំណើតមក ហ្នឹងឯង ។

**ឧបបីឡកកម្មប្រការទីពីរ** រមែងបៀតបៀនដល់នាមរូប ដែលកើតអំពីជនកកម្មនោះ មានពីរប្រភេទគឺ ÷

១.អកុសលឧបបីឡកកម្ម បៀតបៀននាមរូបដែលកើតពី កុសលជនកកម្ម ។

២.កុសលឧបបីឡកកម្ម បៀតបៀននាមរូបដែលកើតពី អកុសលជនកកម្ម ។

## សេចក្តីអធិប្បាយ

១.បុគ្គលដែលកើតមកមានរូបរាងអវយវៈគ្រប់គ្រាន់ ជាមនុស្សរឹងប៉ឹង សុខភាពល្អ មិនមានរោគភ័យអ្វីឡើយ តែលុះដល់ក្រោយមក ក៏កើតមានរោគផ្សេងៗ ដូចជា រោគសើស្បែក រោគស្លឹកមួយចំហៀងខ្លួន រោគឈឺក្បាលផ្តាសាយជាប្រចាំ ជាដើម ឬបើមិនមានរោគអ្វីមកបៀតបៀនទេ ក៏វាត្រូវឱ្យកើតសេចក្តីវិនាសទ្រព្យសម្បត្តិ យស បរិវារ ឬក៏ការងារចិញ្ចឹមជីវិតមិនបានចម្រើនមានតែខាតដើម ទាំងអស់នេះ ព្រោះអំណាចអកុសលឧបបីឡកកម្ម ដែលខ្លួនធ្លាប់ធ្វើមកក្នុងភពមុនៗ ឬភពនេះឯង ចូលបៀតបៀននាមរូបដែលកើតអំពីកុសលជនកកម្ម ។

២.កុសលឧបបីឡកកម្ម បៀតបៀននាមរូបដែលកើតពីអកុសលជនកកម្ម ( សត្វដែលកើតក្នុងអបាយភូមិ មានសត្វតិរច្ឆានជាដើម ដែលតែងលំបាកដោយអត់អាហារ មានរោគជាប្រចាំតែងតែមានសេចក្តីលំបាកដោយប្រការផ្សេងៗ នេះគឺជាផលដែលកើតពីអកុសលជនកកម្ម ប៉ុន្តែ ក្រោយមកសេចក្តីលំបាកផ្សេងៗក៏ធូរស្រាលទៅ ជំងឺផ្សេងៗដែលធ្លាប់មានមកក៏បានជាសះស្បើយរាងកាយក៏បានមាំមួន ទាំងអស់នេះ ព្រោះអំណាចនៃកុសលឧបបីឡកកម្មដែលបានសាងឡើងក្នុងភពមុននោះ ចូលបៀតបៀននាមរូបដែលកើតអំពីអកុសលជនកកម្ម )។



**កិច្ចទី៤.ឧបឃាតកកម្ម** កម្មណាដែលចូលទៅកាត់ផ្តាច់នូវកម្មដទៃៗ និង ការបន្តនៃខន្ធ៥ដែលកើតអំពីកម្មដទៃៗនោះ កម្មនោះឯងឈ្មោះថា ឧបឃាតកកម្ម បានដល់ អកុសលកម្ម១២ និងកុសលកម្ម២១ ។ ឧបឃាតកកម្មនេះជាកម្មដែលកាត់ផ្តាច់នូវកម្មដទៃ និងកាត់ផ្តាច់នូវផលរបស់កម្មដទៃនោះៗឱ្យដាច់បាត់អស់ទៅ ដែលមានសភាពខុសគ្នាអំពីឧបបីឡកកម្ម ។

ឧបបីឡកកម្ម គឺជាកម្មគ្រាន់តែបៀតបៀននូវកម្មដទៃៗ និងផលនៃកម្មដទៃនោះតែប៉ុណ្ណោះ ចំណែកឧបឃាតកកម្មនេះជាកម្មសម្លាប់ផ្តាច់បង់តែម្តង គឺថា បើកាត់នូវកម្មណាហើយ កម្មនោះមិនអាចឱ្យផលជារៀងរហូត ហើយបើកាត់នូវផលរបស់កម្មវិញ ពោលគឺរាងកាយ ឬ អវយវៈឯណានីមួយនោះ រមែងធ្វើឱ្យវិនាសខូចខាតទៅរហូតអស់ជីវិត ពុំនោះសោតទេ ឧបឃាតកកម្មហ្នឹងឯង រមែងកាត់ផ្តាច់នូវអាយុជីវិតតែម្តង ។

ការកាត់ផ្តាច់របស់ឧបឃាតកកម្មនេះ មានពីរប្រការ គឺប្រការទីមួយកាត់នូវជនកកម្មដទៃៗ ដើម្បីមិនឱ្យមានឱកាសបង្កើតផលរហូតតទៅ និងប្រការទីពីររមែងកាត់ផ្តាច់នូវនាមរូបដែល

កើតអំពីជនកកម្មនោះៗ ឱ្យវិនាសទៅ ដោយប្រការដូច្នេះឯង ។

**ឧបឃាតកកម្មប្រការទីមួយ** រមែងកាត់នូវជនកកម្មដទៃៗ ដើម្បីមិនឱ្យមានឱកាសបង្កើតផល រហូតតទៅនោះ មាន៣ប្រភេទគឺ ÷

១-កុសលឧបឃាតកកម្ម កាត់នូវអកុសលជនកកម្ម

២-កុសលឧបឃាតកកម្ម កាត់នូវកុសលជនកកម្ម

៣-អកុសលឧបឃាតកកម្ម កាត់នូវកុសលជនកកម្ម ។

## សេចក្តីអធិប្បាយ

១-កុសលឧបឃាតកកម្ម កាត់នូវអកុសលជនកកម្មមិនឱ្យមានឱកាសបង្កើតផល រហូតតទៅនោះ ដូចជា :

ព្រះអង្គុលិមាលត្ថេរ មុនពេលដែលបានសម្រេចជាព្រះ-អរហន្ត គឺជាឃាតករដ៏សាហាវ សម្លាប់មនុស្សអស់ជាច្រើននាក់ ដែលការប្រព្រឹត្តនោះឯង ត្រូវមានផលទៅកើតក្នុងនរក ប៉ុន្តែ (ព្រោះមិនចូលក្នុងកម្មដែលហាមឃាត់មគ្គផលផង បានជួបនឹងព្រះសម្មាសម្ពុទ្ធផង មានឧបនិស្ស័យគួរដល់ការត្រាស់ដឹងផង ) ព្រះអង្គុលិមាលត្ថេរត្រូវបានព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទូន្មានឱ្យភ្ញាក់





ខ្លួន មានស្មារតីឡើងវិញ ហើយបានឧបសម្បទាជាឯហិភិក្ខុក្នុងព្រះពុទ្ធសាសនា បានចម្រើននូវវិបស្សនាកម្មដ្ឋាន រហូតដល់បានសម្រេចជាព្រះអរហន្ត ។

ដោយអំណាចនៃលោកុត្តរកុសល គឺសោតាបត្តិមគ្គរបស់ព្រះអង្គុលិមាលត្ថេរ ដែលកើតឡើងជាដំបូងមុនមគ្គ៣ទៀតនោះឯង គឺជាកុសលឧបឃាតកកម្ម បានកាត់ផ្តាច់នូវអកុសលជនកកម្មដែលមានទាំងប៉ុន្មាន មិនឱ្យមានឱកាសបង្កើតផលរហូតទៅ ។

២-កុសលឧបឃាតកកម្ម កាត់នូវកុសលជនកកម្មមិនឱ្យមានឱកាសបង្កើតផល រហូតតទៅនោះ បានដល់ :

អរហត្តមគ្គ ជាកុសលឧបឃាតកកម្ម កាត់នូវកាមាវចរ-កុសលទាំងឡាយ សូម្បីរូបាវចរកុសលកម្មក្តី ឬ អរូបាវចរកុសល-កម្មក្តី ដែលបានសម្រេចហើយនោះ មិនឱ្យកុសលជនកកម្មទាំង-នោះឯង ជាបច្ច័យនៃបដិសន្ធិក្នុងសុគតិភពឯណានីមួយឡើយទាំងនេះព្រោះអំណាចនៃអរហត្តមគ្គ ជាកុសលឧបឃាតកកម្មកាត់នូវកុសលជនកកម្មដទៃៗ មិនឱ្យមានឱកាសបង្កើតផល រហូតតទៅ ។

បុគ្គលដែលធ្វើឈានបានដល់រូបបញ្ចមជ្ឈាន កាលបុគ្គលនោះស្លាប់ទៅ ក៏បានបដិសន្ធិក្នុងចតុត្ថជ្ឈានភូមិដែលជារូបព្រហ្ម

ជាន់ខ្ពស់ ឯចំណែកបឋមជ្ឈានកុសលមិនអាចបង្កើតផលឱ្យបដិសន្ធិបានឡើយ ទោះជាទុតិយជ្ឈានកុសលក្តី តតិយជ្ឈាន-កុសលក្តី ចតុត្ថជ្ឈានកុសលក្តី ក៏សុទ្ធតែមិនអាចបង្កើតផលឱ្យបដិសន្ធិបានទាំងអស់ នេះព្រោះអំណាចនៃរូបបញ្ចមជ្ឈានកុសលនោះឯង ជាកុសលឧបឃាតកកម្ម កាត់នូវមហគ្គតកុសលកម្មដែលទាបជាង មិនឱ្យមានឱកាសបង្កើតផល រហូតតទៅ ។

បុគ្គលណាចម្រើនសមថភាវនា រហូតដល់សម្រេចបាននូវអរូបជ្ឈាន កាលបុគ្គលនោះស្លាប់ទៅ ក៏ត្រូវបានបដិសន្ធិក្នុងអរូប-ព្រហ្ម កាលបើដូច្នេះ រូបាវចរកុសលទាំងអស់ មិនអាចបង្កើតផលបានឡើយ នេះព្រោះអំណាចនៃអរូបាវចរកុសល ជាកុសលឧប-ឃាតកកម្ម កាត់នូវរូបាវចរកុសលកម្មមិនឱ្យមានឱកាសបង្កើតផលរបស់ខ្លួនហ្នឹងឯង ។ ដូចគ្នានេះដែរ អរូបាវចរកុសលដែលខ្ពស់ជាង រមែងកាត់នូវអរូបាវចរកុសលថ្នាក់ទាបតាមលំដាប់ ដូចជាវិញ្ញាណញ្ចាយតនជ្ឈានកុសល បានកាត់នូវអាកាសានញ្ចាយត-នជ្ឈានកុសល មិនឱ្យមានឱកាសបង្កើតផលរបស់ខ្លួន ជាដើម ក្នុងសេចក្តីនេះសំដៅយកតែបុគ្គលដែលបានឈានជាន់ខ្ពស់នោះ មិនមាននូវនិកន្តិតណ្ហាចំពោះឈានថ្នាក់ក្រោម ឬ ភូមិថ្នាក់ទាបនៅពេលជិតនឹងស្លាប់ប៉ុណ្ណោះ ព្រោះជាធម្មតាបុគ្គលជិតនឹងស្លាប់





នោះឯង ទោះបីជាអ្នកធ្លាប់បាននូវឈានថ្នាក់ខ្ពស់ក៏ដោយ បើមាននូវនិកន្តិតណ្ហា គឺសេចក្តីពេញចិត្តក្នុងភូមិ ឬឈានថ្នាក់ទាបជាងដូចនេះ ឈានថ្នាក់ខ្ពស់ដែលខ្លួនបានសម្រេចនោះរមែងសាបសូន្យអស់ទៅ ។

៣-អកុសលឧបឃាតកកម្ម កាត់នូវកុសលជនកកម្ម មិនឱ្យមានឱកាសបង្កើតផលរហូតតទៅនោះ គឺសំដៅដល់បុគ្គលណាម្នាក់ដែលបានសម្រេចនូវមហគ្គតកុសល លុះដល់ក្រោយមកបុគ្គលនោះបានធ្វើនូវអនន្តរិយកម្មឱ្យសម្រេច មានមាតុឃាតជាដើម ម្ល៉ោះហើយ អកុសលឧបឃាតកកម្មនេះ បានកាត់នូវមហគ្គតកុសលជនកកម្មមិនឱ្យមានឱកាសបង្កើតផល (មហគ្គត-កុសលដែលធ្លាប់បានសម្រេចហើយនោះ ត្រូវសាបសូន្យជារៀងរហូតដល់ផុតជីវិត ក្រោយអំពីស្លាប់ទៀងតែទៅកើតក្នុងនរក ) ដូចជា ព្រះទេវទត្តដែលបានសម្រេចនូវឈានអភិញ្ញាហើយ ក្រោយមកទេវទត្តត្រូវលាភយសគ្របសង្កត់ចិត្តបាន នាំឱ្យទេវទត្តប្រព្រឹត្តធ្វើនូវអនន្តរិយកម្ម២យ៉ាង គឺម្យ៉ាងទេវទត្តបានញុំាងលោហិតព្រះសម្មាសម្ពុទ្ធឱ្យពុរពង ដោយចិត្តប្រទូសរ៉ាយ និងម្យ៉ាងទៀតគឺសង្ឃភេទកម្ម បានដល់ការបំបែកសង្ឃ ដូច្នេះ អនន្តរិយកម្មនេះគឺជាអកុសលឧបឃាតកកម្ម កាត់នូវមហគ្គតកុសលកម្មរបស់ព្រះ-

ទេវទត្តមិនឱ្យមានឱកាសបង្កើតផលបានឡើយ ។

**ឧបឃាតកកម្មប្រការទីពីរ** រមែងកាត់នូវនាមរូប ដែលកើតពីជនកកម្មនោះៗ ឱ្យដល់នូវសេចក្ដីវិនាស ចែកទៅជា ៤ប្រភេទ គឺ ÷

១.កុសលឧបឃាតកកម្ម កាត់នូវនាមរូបដែលជាផលវិបាករបស់អកុសលកម្ម ។

២.កុសលឧបឃាតកកម្ម កាត់នូវនាមរូបដែលជាផលវិបាករបស់កុសលកម្ម ។

៣.អកុសលឧបឃាតកកម្ម កាត់នូវនាមរូបដែលជាផលវិបាករបស់កុសលកម្ម ។

៤.អកុសលឧបឃាតកកម្ម កាត់នូវនាមរូបដែលជាផលវិបាករបស់អកុសលកម្ម ។

## សេចក្ដីអធិប្បាយ

១.កុសលឧបឃាតកកម្ម កាត់នូវនាមរូបដែលជាផលវិបាករបស់អកុសលកម្មនោះ គឺដូចជា បុគ្គលដែលស្លាប់ទៅបដិសន្ធិក្នុងស្ថាននរក រូបកាយនិងការឃើញ ការឮជាដើមរបស់សត្វនរកនោះឯង គឺជាផលរបស់អកុសលកម្ម (មនុស្សយើងគួរយល់ចូលចិត្តថា





អកុសលវិបាកបដិសន្ធិក្នុងនរក ឬប្រេតរមែងមានជាប្រាកដ ព្រោះជាធម៌ដែលត្រូវកើតអំពីអកុសលកម្ម មិនមានអ្វីដែលហាមឃាត់បានឡើយ សឹងដូចអកុសលវិបាក ដែលមានក្នុងជីវិតរបស់មនុស្សយើងរាល់ថ្ងៃនេះដែរ ដែលមិនមានអ្នកណាៗអាចហាមឃាត់បានឡើយ ) ។

មានសត្វនរកខ្លះ អាចនឹករលឹកដល់កុសលដែលខ្លួនធ្លាប់ធ្វើក្នុងកំណើតជាមនុស្ស ដូចជានៅពេលឃើញភ្លើងនរក ក៏នឹករលឹកឃើញដល់កុសលដែលខ្លួនធ្លាប់បំបួសកូន ឬបំបួសអ្នកដទៃ ពុំនោះសោត ក៏នឹករលឹកឃើញដល់កុសលដែលខ្លួនធ្លាប់បានថ្វាយចីវរដល់ព្រះសង្ឃ ព្រោះហេតុតែភ្លើងនរកមានពណ៌ស្រដៀងនឹងពណ៌ចីវរនោះឯង ឬបាននឹករលឹកឃើញដល់កុសលដែលខ្លួនបានយកមាសបិទព្រះពុទ្ធបដិមាជាដើម ។ សត្វនរកខ្លះ ត្រូវស្ដេចយមរាជដាស់តឿនសតិ ហើយក៏បាននឹករលឹកឃើញដល់កុសលផ្សេងៗដែលខ្លួនធ្លាប់បានធ្វើ សត្វនរកខ្លះទៀត ត្រូវបានស្ដេចយមរាជជួយនឹករលឹករកនូវអំពើបុណ្យកុសលឱ្យ ដូចដែលសត្វនរកខ្លះនោះកាលដែលនៅជាមនុស្សធ្លាប់បានបំពេញបុណ្យ ហើយឧទ្ទិសបុណ្យនោះឱ្យដល់ស្ដេចយមរាជទៀតផង កាលដែលស្ដេចយមរាជនឹករកឃើញហើយ បានប្រាប់ដល់សត្វនរកនោះឱ្យនឹករលឹកឃើញដែរ។

ក្នុងខណៈដែលសត្វនរក នឹករលឹកឃើញនូវបុណ្យកុសល ដែលខ្លួនធ្លាប់បានធ្វើ មហាកុសលចិត្តក៏បានកើតឡើងក្នុងពេលនោះ សត្វនរកក៏ចុតិ ហើយក៏បដិសន្ធិជាមនុស្សភ្លាម ឬជាទេវតាភ្លាម តាមកម្លាំងនៃកុសលនោះៗ (រឿងរ៉ាវសត្វនរកនេះមានក្នុងព្រះអដ្ឋកថា ទេវទូតសូត្រ មជ្ឈិមនិកាយ ឧបរិបណ្ណាសក) នេះគឺព្រោះកុសលចិត្តដែលកើតឡើង ក្នុងខណៈដែលនឹករលឹកដល់កុសលកម្មដែលខ្លួនធ្លាប់បានធ្វើនោះឯង ជាកុសលឧបឃាតកកម្ម កាត់ផ្តាច់នូវនាមរូបក្នុងស្ថាននរកនោះ ដែលមាននាមរូបនោះជាផលវិបាកកើតអំពីអកុសលកម្មឯណានីមួយ ។

បុគ្គលដែលបានកើតមកជាមនុស្ស តែជាអ្នកក្រលំបាក មានរោគភ័យបៀតបៀនជានិច្ចកាល ព្យាបាលពុំបានស្បើយឡើយ បានទទួលសេចក្តីលំបាកដោយប្រការទាំងពួង និងមានការជួបប្រទះនូវអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីប្រាថ្នារឿយៗ ពុំស្រាក-ស្រាន្ត ទាំងអស់នេះ គឺជាផលវិបាកនៃអកុសលកម្ម ដែលខ្លួនបានធ្វើទុកមក ហើយមាននូវឱកាសចូលបៀតបៀននាមរូប ឱ្យផលជាទុក្ខលំបាកក្នុងកំណើតមនុស្សនេះឯង ។ ក្រោយមក មានមនុស្សសប្បុរសចិត្តបុណ្យ ហើយជាអ្នកយល់ចូលចិត្តក្នុងព្រះពុទ្ធសាសនាទៀតផង បានជួយដាស់តឿនពន្យល់ណែនាំថា ការដែលអ្នកកើត



មកជាមនុស្សក្រលំបាក មានផ្ទះសម្បែងរខេករខាក ជួបប្រទះតែរបស់មិនស្អាត និងរឿងមិនល្អយ៉ាងនេះ ព្រោះអ្នកឯងខ្វះបុណ្យ គឺមិនបានធ្វើទានឱ្យបានជិតដល់ពីជាតិមុនមក ហើយដែលអ្នកឯងមានរោគ ឈឺជាអចិន្ត្រៃយ៍ពុំមានស្រាកស្រាន្តនោះក៏ព្រោះអ្នកមិនបានរក្សាសីលឱ្យល្អកាលពីជាតិមុនហ្នឹងឯង ព្រោះហេតុដូច្នេះ អ្នកឯងត្រូវព្យាយាមសាងកុសល ធ្វើទានរក្សាសីល បណ្តុះនូវគុណធម៌ក្នុងសន្តានឡើង ត្រូវប្រឹងប្រែងដោយសេចក្តីមិនប្រមាទ ។ កាលបុគ្គលនោះឮពាក្យណែនាំយ៉ាងនេះហើយ ក៏បានព្យាយាមខ្វល់ខ្វាយសាងនូវកុសលឱ្យកើតឡើង បានចូលទៅក្នុងវត្តអារាម ជួយធ្វើការងារជាវេយ្យាវច្ចកុសលដល់ព្រះភិក្ខុសាមណេរ ជួយសម្អាតវត្ត ជួយថែទាំរបស់របរប្រើប្រាស់ក្នុងវត្ត និងអធិដ្ឋាន ចិត្តរក្សាសីល៨ រហូតដល់អស់ជីវិត ព្រមទាំងសាងទានកុសលឱ្យកើតឡើងដោយការតម្កល់ទឹកប្រើប្រាស់ ដាំទឹកឱ្យឆ្អិនសម្រាប់ បរិភោគ ដល់អ្នកដែលទៅមក ឬចេញចូលក្នុងទីវត្តនោះ ជាដើម ។ កាលបើបានសាងនូវកុសលផ្សេងៗដូចបានពោលមកនេះ ជានិច្ចរាល់ថ្ងៃដូច្នេះហើយ ក៏បានជាទីស្រឡាញ់និងអាណិតរបស់មនុស្សទាំងឡាយ ដែលចេញចូលទៅមកក្នុងទីវត្តនោះ បានទទួលនូវការអើពើយកចិត្តទុកដាក់អំពីសំណាក់បព្វជិត និងគ្រហស្ថទាំងឡាយដោយ

ប្រការផ្សេងៗ មានអាហារបរិភោគ សំពត់ខោអាវ ប្រាក់ចាយ និងថ្នាំកែរោគល្អៗ ធ្វើឱ្យបុគ្គលនោះឯងបានទទួលនូវសេចក្តីសុខ-កាយសប្បាយចិត្ត ហើយជំងឺរោគាព្យាធិដែលមានពីមុនមកនោះក៏បានជាសះស្បើយដាច់ស្រឡះ នេះព្រោះទានកុសលនិងសីល-កុសលជាដើម ដែលបុគ្គលនោះបានធ្វើឡើងក្នុងភពនេះឯង ជាកុសលឧបឃាតកកម្ម កាត់ផ្តាច់នូវនាមរូបដែលជាផលវិបាកនៃអកុសល ក្នុងសុគតិភូមិឱ្យវិនាសសាបសូន្យទៅ ។

២-កុសលឧបឃាតកកម្ម កាត់ផ្តាច់នូវនាមរូបដែលជាផល-វិបាករបស់កុសលកម្ម បានដល់ យរាវាសណាសម្រេចជាព្រះ-អរហន្តហើយ ប៉ុន្តែមិនបានបួសជាបព្វជិត ម៉្លោះហើយអំណាចនៃអរហត្តមគ្គរបស់យរាវាសនោះជាកុសលឧបឃាតកកម្ម កាត់ផ្តាច់នូវនាមរូប គឺធ្វើឱ្យអស់ជីវិតបរិនិព្វានទៅ ដោយនៅរស់ពុំបានយូរឡើយ មិនមែនដូចជាការចូលកាន់ផ្នួសបួសជាបព្វជិតនោះទេ នេះមកអំពីគុណរបស់អរហត្តមគ្គ និងអរហត្តផល ជាសភាវៈដ៏យ៉ាងខ្ពង់ខ្ពស់និងធ្ងន់ក្រៃលែង ដែលភេទជាគ្រហស្ថគឺជាភេទតាំងនៅក្នុងសីលថ្នាក់ក្រោមនោះ មិនអាចទ្រាំទ្រទទួលបានឡើយ (ប្រៀបដូចជា ជង្រុកស្រូវដែលមានគ្រឹះនិងសសរមិនបានមាំមួន អាចទទួលបានត្រឹមតែទម្ងន់ស្រូវល្មមប៉ុណ្ណោះ ថាបើដាក់ស្រូវច្រើន





ហួស រហូតពេញដល់ដំបូលនោះ ជង្រុករមែងស្រុត ឬបាក់រលំជាប្រាកដ ព្រោះទ្រាំទ្រនឹងទម្ងន់ពុំបាន)។

៣-អកុសលឧបឃាតកកម្ម កាត់ផ្តាច់នូវនាមរូបដែលជាផលវិបាករបស់កុសលកម្ម គឺដូចជាអវយវៈផ្សេងៗរបស់មនុស្សមានដៃជើងជាដើម ដែលជាផលរបស់កុសលកម្ម និងការឃើញ ការឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ជាការបានដឹងនូវអារម្មណ៍ល្អៗនោះ វាជាវិបាករបស់កុសលកម្ម ផលវិបាករបស់កុសលកម្មនេះគឺជានាមរូប ។ មានឧបទ្ទវហេតុអ្វីមួយកើតឡើង ដូចជា ត្រូវគ្រោះ-ថ្នាក់ដោយរថយន្ត ឬត្រូវគេលបប្រហារ ឬត្រូវធ្លាក់ពីលើទីខ្ពស់ជាដើម វាធ្វើឱ្យគ្រាំគ្រា ពិការអវយវៈដាច់ដៃ ដាច់ជើង ខ្វាក់ភ្នែក ឬ រហូតដល់បាត់បង់ជីវិត នេះគឺជាអកុសលឧបឃាតកកម្ម កាត់ផ្តាច់នូវនាមរូបដែលជាផលវិបាករបស់កុសលកម្ម ។

៤-អកុសលឧបឃាតកកម្ម កាត់ផ្តាច់នូវនាមរូបដែលជាផលវិបាករបស់អកុសលកម្ម គឺដូចជា សត្វតិរច្ឆាន មានសុនខជាដើម សត្វសុនខមានរូបកាយនិងជីវិតអង្គភពកើតអំពីអកុសល-កម្ម ក្រោយមកមានឧបទ្ទវហេតុអ្វីមួយ គឺសត្វសុនខនោះត្រូវរថយន្តកិនស្លាប់ ឬត្រូវគេសម្លាប់ជាដើម ការស្លាប់របស់សុនខដូចនេះ ព្រោះអំណាចនៃអកុសលឧបឃាតកកម្មចូលមកកាត់ផ្តាច់

ហ្នឹងឯង ។

**ឧបឃាតកកម្ម** កាត់ផ្តាច់នូវនាមរូបដែលជាផលវិបាករបស់កម្មដទៃៗនោះ មានរបៀបបីយ៉ាងគឺ ÷

១.កាត់ផ្តាច់នូវផលវិបាករបស់កម្មដទៃៗ ប៉ុន្តែខ្លួនឯងមិនបានញុាំងផលឱ្យកើតឡើងឡើយ ហើយក៏មិនបានឱ្យឱកាសដល់ជនកកម្មដទៃៗបង្កើតផលដែរ ។

២.កាត់ផ្តាច់នូវផលវិបាករបស់កម្មដទៃៗ ហើយខ្លួនឯងក៏ជាជនកកម្មញុាំងបដិសន្ធិឱ្យកើតឡើង ។

៣.កាត់ផ្តាច់នូវផលវិបាករបស់កម្មដទៃៗ ហើយឱ្យឱកាសដល់ជនកកម្មដទៃផ្សេងទៀត ដោយខ្លួនឯងមិនធ្វើជាជនកកម្មឡើយ ។

## សេចក្តីអធិប្បាយ

១.ដូចជា ព្រះចក្ខុបាលត្ថេរ កាលពីអតីតជាតិរបស់លោកគឺលោកធ្លាប់ធ្វើជាពេទ្យរក្សាភ្នែក ហើយបានដាក់ថ្នាំឱ្យគេខ្វាក់ភ្នែក ព្រោះមានសេចក្តីក្រោធនឹងគេរមិលគុណខ្លួន និងព្រោះគេមិនបានឱ្យថ្លៃព្យាបាល ដោយភ្លែងថា គ្រូពេទ្យមើលភ្នែកមិនជា ។ អកុសលកម្មដែលព្រះចក្ខុបាលត្ថេរធ្វើក្នុងជាតិមុនហ្នឹងឯង បាន





តាមមកជាឧបឃាតកកម្ម ទម្លាយភ្នែកទាំងពីររបស់លោកនៅពេលដែលបានសម្រេចអរហត្តផល ប៉ុន្តែអកុសលឧបឃាតកកម្មនេះ ពុំបានញុាំងផលឱ្យកើតជាបន្តទៅទៀតឡើយ ពោលគឺមិនបានជាជនកកម្មដោយខ្លួនឯងផង និងមិនបានបើកឱកាសឱ្យដល់ជនកកម្មដទៃទៀតផង ព្រោះលោកជាព្រះអរហន្ត ។

(ឧបឃាតកកម្មនេះខ្លាំងក្លាក្រៃលែង អម្បាលព្រះមហា-មោគ្គល្លានមានឫទ្ធិអស្ចារ្យ ក៏នៅតែគេចពុំរួច ព្រោះថា កម្លាំងអ្វីស្មើដោយកម្លាំងកម្មមិនមានឡើយ ហើយសត្វលោករមែងប្រព្រឹត្តទៅតាមកម្មដូច្នោះឯង នេះជាការសម្តែងឱ្យឃើញថា ខន្ធ៥មិនប្រព្រឹត្តទៅតាមអ្វីដទៃក្រៅអំពីបច្ច័យទេ ដែលបច្ច័យទាំងអស់នោះមិនមានបច្ច័យណាមួយជាអត្តាតួខ្លួនឡើយ) ។

២.ដូចជា ទូសីមារ ដែលបានយកដុំថ្មគប់ព្រះសីសៈនៃព្រះអគ្គសាវ័កស្តាំរបស់ព្រះសម្មាសម្ពុទ្ធកកុសន្ធោ ស្តេចកលាបុ ដែលបានបៀតបៀនដល់ព្រះតាបសបរមពោធិសត្វនាមខន្តិវាទី រហូតដល់ព្រះតាបសអស់ជីវិត នន្ទយក្សដែលបានវាយសំពងព្រះសីសៈនៃព្រះសារីបុត្រ ក្នុងពេលដែលព្រះសារីបុត្រកំពុងតែគង់នៅក្នុងនិរោធសមាបត្តិ ទេវទត្តដែលបានប្រទូសរ៉ាយដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បុគ្គលទាំងអស់នេះ ត្រូវបានកម្មដែលខ្លួនបានធ្វើឱ្យផល

ទាន់ហន់ ហើយស្លាប់ទៅបដិសន្ធិក្នុងនរកសោយទុក្ខខ្លាំងក្លា នេះព្រោះអំណាចនៃអកុសលឧបឃាតកកម្ម កាត់ផ្តាច់នូវនាមរូបធ្វើឱ្យព្រះធរណីស្រូបទាំងរស់ រួចហើយស្លាប់ទៅត្រូវឧបឃាតកកម្មហ្នឹងឯងដើរតួជាជនកកម្មឱ្យផលបដិសន្ធិក្នុងអវិចីមហានរកដោយប្រការដូច្នេះឯង ។

៣_ដូចជា ព្រះបាទពិម្ពិសារ ក្នុងអតីតជាតិធ្លាប់បានពាក់ទ្រនាប់ជើងចូលទៅក្នុងបរិវេណនៃពុទ្ធចេតិយ ដោយអំណាចនៃអកុសលកម្មនេះ កាលបានមកកើតក្នុងជាតិជាព្រះបាទពិម្ពិសារទើបបានទទួលផល គឺត្រូវគេអារនូវបាទជើងរហូតដល់អស់ព្រះជន្មទៅ ប៉ុន្តែ កាលអស់ព្រះជន្មទៅនោះ កុសលជនកកម្មដទៃបានឱកាសបង្កើតផល ធ្វើឱ្យព្រះបាទពិម្ពិសារទៅកើតជាទេវតាក្នុងឋានចាតុម្មហារាជិកា នេះគឺអកុសលឧបឃាតកកម្ម ចូលមកកាត់ផ្តាច់នូវនាមរូប ហើយឱ្យឱកាសដល់ជនកកម្មដទៃទៀត ដោយខ្លួនឯងជាឧបឃាតកកម្មនោះមិនបានធ្វើជាជនកកម្មឡើយ ។

**ចប់កិច្ចចតុក្កៈ**





# II ~ បាកទានបរិយាយចតុក្កៈ

## កម្មឱ្យផលតាមលំដាប់

**លំដាប់ទី១_គរុកកម្ម** បានដល់កម្មណាដែលឱ្យផលដ៏ធ្ងន់កើតឡើង កម្មនោះឯងឈ្មោះថាគរុកកម្ម ឬដោយន័យម្យ៉ាងទៀតបានដល់ កម្មណាដែលធ្ងន់ ព្រោះកម្មដទៃៗទៀតមិនអាចហាមការឱ្យផលបាន ដូច្នោះ កម្មនោះទើបឈ្មោះថា គរុកកម្ម អង្គធម៌គឺនិយតមិច្ឆាទិដ្ឋិកម្មក្នុងលោភទិដ្ឋិគតសម្បយុត្តចិត្ត៤ដួង អនន្តរិយ_កម្ម៥យ៉ាងក្នុងទោសមូលចិត្ត២ដួង និងមហគ្គតកុសលកម្មក្នុងមហគ្គតកុសលចិត្ត៩ដួង រួមបានជាកម្មនៅក្នុងចិត្ត១៥ដួង ។

~ ចំពោះលោកុត្តរកុសលកម្ម ជាគរុកកម្មដោយពិត ប៉ុន្តែ ក្នុងកម្មចតុក្កៈនេះ ពោលអំពីគរុកកម្មណាដែលជាជនកកម្មអាចបង្កើតផលបានក្នុងជាតិបន្ទាប់ស្លាប់ គឺជាតិទី២ (ជាតិដែលបានធ្វើកម្ម ជាជាតិទី១ )ចំណែកលោកុត្តរកុសលនោះ មិនមែនជាជនកកម្មឱ្យបដិសន្ធិឡើយ ឱ្យចំពោះតែលោកុត្តរវិបាកប៉ុណ្ណោះ និងមានអំណាចកាត់ផ្តាច់នូវអកុសលជនកកម្មជាដើម ទម្លាយនូវការកើតក្នុងភពតាមសមគួរដល់កម្លាំងរបស់ខ្លួន ។

កម្មដែលឈ្មោះថាគរុកកម្មនេះ គឺជាកម្មដែលធ្ងន់ អាច

ញ៉ាំងផលឱ្យកើតក្នុងជាតិទី២ជាពិតប្រាកដ ដោយកម្មដទៃៗមិនអាចរារាំងបានឡើយ ប៉ុន្តែ មិនបានសំដៅថា ក្នុងបណ្ដាគរុកកម្មជាមួយគ្នានោះ មិនរារាំងគ្នានោះទេ ដោយសេចក្ដីថា គរុកកម្មណា ដែលមានកម្លាំងខ្លាំងជាងគរុកកម្មដទៃៗ គរុកកម្មនោះ ជាតួញ៉ាំងផលឱ្យបដិសន្ធិ ចំណែកគរុកកម្មដែលមានកម្លាំងខ្សោយជាងមិនជាជនកកម្មឡើយ គ្រាន់តែជួយឧបត្ថម្ភប៉ុណ្ណោះ ។

គរុកកម្មដែលមានកម្លាំងខ្សោយជាងគរុកកម្មដទៃទៀតនោះ ពិតមែនតែមិនមានឱកាសបង្កើតផលឱ្យបដិសន្ធិ ប៉ុន្តែកម្មនោះក៏នៅតែឈ្មោះថា គរុកកម្មដដែល ព្រោះបើគរុកកម្មដែលធ្ងន់ជាងខ្លួនមិនមានហើយ ខ្លួនឯងក៏ជាតួជនកកម្មឱ្យផលបដិសន្ធិក្នុងជាតិទី២ជាពិតប្រាកដ ។

បុគ្គលមាននូវនិយតមិច្ឆាទិដ្ឋិយ៉ាងណាមួយ ក្រោយមកគេបានធ្វើនូវបញ្ចានន្តរិយកម្មថែមទៀត កាលណាបុគ្គលនោះស្លាប់ទៅ និយតមិច្ឆាទិដ្ឋិកម្មនោះឯង ជាតួជនកកម្ម ព្រោះនិយតមិច្ឆា-ទិដ្ឋិធ្ងន់ជាងបញ្ចានន្តរិយកម្ម សម្រាប់បញ្ចានន្តរិយកម្មនោះ គ្រាន់តែជួយឧបត្ថម្ភក្នុងការឱ្យផលរបស់និយតមិច្ឆាទិដ្ឋិកម្មប៉ុណ្ណោះឯង។

បញ្ចានន្តរិយកម្ម គឺអនន្តរិយកម្ម៥យ៉ាង ក្នុងអនន្តរិយកម្ម៥យ៉ាងនេះ គឺសង្ឃភេទកកម្មធ្ងន់ជាទីបំផុត ប្រសិនបើបុគ្គលណា



ធ្វើអនន្តរិយកម្មគ្រប់ទាំង៥ ដល់ស្លាប់ទៅ ត្រូវសង្ឃភេទកកម្មជាជនកកម្មប្បច្ច័យឱ្យផលបដិសន្ធិ ចំណែកគរុកកម្ម៤យ៉ាងទៀតជាតួជួយឧបត្ថម្ភក្នុងការឱ្យផលរបស់សង្ឃភេទកកម្មនោះ ។

កម្មដែលធ្ងន់បន្ទាប់ពីសង្ឃភេទកកម្ម គឺពុទ្ធលោហិតុប្បាទ (ញ៉ាំងលោហិតព្រះសម្មាសម្ពុទ្ធឱ្យពុរពង ) បន្ទាប់មកទៀតគឺអរហន្តឃាតកកម្ម ចំណែកមាតុឃាតកកម្ម និងបិតុឃាតកកម្មទាំងពីរនេះ គឺស្រេចនៅលើគុណធម៌ បើបិតាជាអ្នកមានសីល រីឯមាតាមិនមានសីល បិតុឃាតកកម្មរមែងធ្ងន់ជាង តែបើមាតាជាអ្នកមានសីលវិញ ហើយបិតាអត់សីលទេនោះ មាតុឃាតកកម្មរមែងធ្ងន់ជាង ម្យ៉ាងទៀត បើមាតាបិតាទាំងពីរនាក់មានសីលដូចគ្នា ឬអត់សីលដូចគ្នា មាតុឃាតកកម្មរមែងធ្ងន់ជាង ។ នៅក្នុងអដ្ឋកថា ពហុធាតុកសូត្រ មជ្ឈិមនិកាយ ឧបរិបណ្ណាសក និងក្នុងអដ្ឋកថាគម្ពីរអង្គុត្តរនិកាយ បានសម្ដែងថា « **ទ្វីសុបិ សីលេន វា ទុស្សីលេន វា សមានេសុ មាតុឃាតកោវ បដិសន្ធិ-វសេន វិបច្ចតិ មាតា ហិ ទុក្ករការិនី ពហុបការា ច បុត្តានន្តិ** » ។

ប្រែថា «បើមាតាបិតាទាំងពីរ មានសភាពស្មើគ្នាដោយការមានសីល ឬដោយការអត់សីល មាតុឃាតកកម្មនោះឯងរមែងឱ្យផលបដិសន្ធិ ព្រោះថា មាតាជាអ្នកទទួលនូវភារៈធ្ងន់ ដែលធ្វើបានដោយលំបាក និងជាអ្នកមាននូវឧបការគុណច្រើន ដល់បុត្រទាំងឡាយ » ។

មហគ្គតកុសលកម្ម៩ ក៏ដូចគ្នាដែរ គឺបុគ្គលដែលបាននូវរូបាវចរកុសល៥និងអរូបាវចរកុសល៤ នៅពេលអស់ជីវិតទៅអរូបជ្ឈានទី៤រមែងជាជនកកម្ម ចំណែកឈានដទៃទៀតក៏ទៅជាអហោសិកម្ម មិនអាចសូម្បីតែ ឧបត្ថម្ភដល់អរូបជ្ឈានទី៤នោះ ។

អកុសលគរុកកម្ម ទោះបីជាខ្លួនមិនមានឱកាសបង្កើតផលឱ្យបដិសន្ធិក៏ដោយ តែក៏មានឋានៈជាឧបត្ថម្ភកកម្មបាន ចំណែកកុសលគរុកកម្មនោះ កាលបើខ្លួនឯងមិនមាននូវឱកាសឱ្យបដិសន្ធិហើយ ក៏ជាអហោសិកម្ម មិនមានឋានៈជាឧបត្ថម្ភកកម្មបានឡើយ។ ដោយហេតុផលដូចពោលមកនេះឯង អកុសលគរុកកម្មទើបមានឈ្មោះហៅជាពិសេសថា បញ្ចានន្តរិយកម្ម និងនិយត-មិច្ឆាទិដ្ឋិ ចំណែកឯកុសលគរុកកម្មវិញ មិនមានឈ្មោះហៅជាពិសេសឡើយ។ អកុសលគរុកកម្មតែកាលណាកើតឡើងក្នុងបុគ្គលណាហើយ បុគ្គលនោះទៀងតែធ្លាក់នរកជាពិតប្រាកដ ព្រោះកម្មនេះមិនសាបសូន្យរបៀបដូចកុសលគរុកកម្មឡើយ ព្រោះហេតុដូច្នេះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា **«មិច្ឆត្តនិយតា ធម្មា»** ប្រែថា «ពួកធម៌មានសភាពដ៏ខុសនិងទៀង» ចំណែកមហគ្គត-កុសលកម្មដែលជាកុសលគរុកកម្ម អាចមាន





ការសាបសូន្យទៅវិញ បុគ្គលដែលបានសម្រេចនូវឈានសមាបត្តិហើយ មិនប្រាកដថា ទៀងតែទៅកើតក្នុងព្រហ្មលោកឡើយ ដូចភិក្ខុទេវទត្តជាដើម ព្រោះហេតុនេះ ទើបមហគ្គតកុសលកម្មនៅក្នុងពួក **អនិយតា ធម្មា** គឺបានសេចក្ដីថា ពួកធម៌ក្រៅអំពី **មិច្ឆត្តនិយតា ធម្មា** និងក្រៅអំពី **សម្មត្តនិយតា ធម្មា** ។ មានតែលោកុត្តរកុសល ប៉ុណ្ណោះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា **«សម្មត្តនិយតា ធម្មា»** ប្រែថា «ពួកធម៌មានសភាពដ៏ត្រូវនិងទៀង» គឺទៀងតែ ញុំាងលោកុត្តរវិបាកឱ្យកើតជាពិតប្រាកដ បុគ្គលដែលបានសម្រេច សោតាបត្តិមគ្គ ទៀងតែមិនទៅកើតក្នុងអបាយភូមិ៤ និងទៀងតែ បានសម្រេចជាព្រះអរហន្តមិនលើសពី៧ជាតិទៀតឡើយ ។

**បញ្ចានន្តរិយកម្ម** បើកាត់បទ បានដល់ «**បញ្ច+អនន្តរ+ឥយ+កម្ម** » **បញ្ច**=៥ **អនន្តរ**=ភពដែលមិនមានរវាងចន្លោះ **ឥយ**=ឱ្យផល **កម្ម**=ការធ្វើ ; រួមទៅគឺ ការធ្វើ៥យ៉ាងដែលឱ្យផលមិនមានរវាងចន្លោះក្នុងលំដាប់នៃចុតិ ។

**និយតមិច្ឆាទិដ្ឋិកម្ម** បើកាត់បទ បានដល់ «**និយត+មិច្ឆា+ទិដ្ឋិ+កម្ម** » **និយត**=ទៀងទាត់ **មិច្ឆា**=ខុសអំពីការពិត

**ទិដ្ឋិ**=ការឃើញ **កម្ម**=ការធ្វើ ; រួមទៅគឺ កម្មក្នុងការឃើញខុសចាកការពិត ដែលឱ្យផលទៀងទាត់ក្នុងលំដាប់នៃចុតិ ។

**លំដាប់ទី២_អាសន្នកម្ម** បានដល់កម្មដែលកើតមាននៅពេលជិតស្លាប់ នៅក្នុងគម្ពីរសារត្ថសង្គហៈបានសម្តែងថា **យំ បន កុសលាកុសលេសុ អាសន្នមរណេ អនុស្សរិតុំ សក្កោតិ តំ យទាសន្នំ នាម** អធិប្បាយថា កុសល និងអកុសលដែលបុគ្គលធ្វើទុកនោះ បុគ្គលណារលឹកបាននៅពេលជិតស្លាប់ កម្មនោះបានឈ្មោះថា **យទាសន្នកម្ម** (បានដល់កម្មក្នុងខណៈនៃចិត្តនឹករលឹកឃើញអំពើល្អ ឬអាក្រក់ដែលខ្លួនបានធ្វើហើយ ដែលចិត្តនឹករលឹកឃើញនោះ នៅពេលជិតស្លាប់ ទាំងដែលចិត្តនឹករលឹកឃើញនោះឯង ជាកុសលជវនៈ ឬ ជាអកុសលជវនៈទៀតផង) ។

នៅក្នុងបរមត្ថសម្តែងថា **កម្មដែលបុគ្គលធ្វើក្នុងពេលជិតស្លាប់នោះ ក៏បានឈ្មោះថា យទាសន្នកម្ម** ដូចគ្នា យទាសន្នកម្មនេះ រៀរតែគរុកកម្មចេញ កម្មដទៃៗមិនអាចកាត់បានឡើយ ។

យទាសន្នកម្មនេះឯង សូម្បីតិចតួច តូចតាចក៏ដោយ ក៏អាចឱ្យផលមុនកម្មទាំងឡាយបានដែរ ប្រៀបដូចគោចាស់ដែលនៅក្នុងក្រោលក្បែរមាត់ទ្វារចេញ ជាធម្មតានៃគោដែលនៅក្បែរមាត់ទ្វារចេញនោះ សូម្បីជាគោចាស់ជរាមានកម្លាំងទន់ខ្សោយជាងគោ





ទាំងពួងទៀតក៏ដោយ កាលនាយគោបាលបើកទ្វារក្រោលហើយ ក៏រមែងចេញអំពីក្រោលមុនគោទាំងពួង ព្រោះអាស្រ័យខ្លួនឯងនៅជិតមាត់ទ្វារជាងគេ យ៉ាងណាមិញ យទាសន្នកម្មក៏មានរបៀបដូចគ្នាយ៉ាងនោះដែរ គឺរមែងឱ្យផលមុនកម្មទាំងពួង ដូចជាគោនៅក្បែរមាត់ទ្វារក្រោលអ៊ីចឹងឯង ។

**យទាសន្នកម្ម**រមែងឱ្យផលមុនកម្មទាំងពួងនោះ មានរឿងដូច **ទមិឡទោវារិកបុរស** មានប្រក្រតីនៅស្រុកមធុអង្គលគ្រាម បុរសនេះឯងគឺជាព្រានសន្ទូច ។ ទមិឡទោវារិកបុរស នេសាទត្រីបានហើយ គាត់ក៏ចាត់ចែងដូរយកស្រូវអង្ករ ទឹកដោះគោជាដើមជារៀងរាល់ថ្ងៃ ។ ការចិញ្ចឹមជីវិតដោយបាណាតិបាតរបស់ទមិឡ-ទោវារិកបុរសនេះ ជាប់តគ្នារាល់ថ្ងៃជារៀងរហូតមានប្រមាណ ៥០ឆ្នាំ លុះដល់ពេលគាត់ជរា មានជំងឺរោគាដេកនៅលើគ្រែសម្រាប់ស្លាប់ហើយនោះ **ព្រះចូឡបិណ្ឌបាតិយតិស្សត្ថេរ**ដែលគង់នៅឯ គីរីវិហារ បានត្រិះរិះថា អាត្មាអញនៅមិនឆ្ងាយអំពីបុរសនេះឡើយ បើដូច្នេះអាត្មាអញគួរនឹងអនុគ្រោះដល់គាត់ ហើយក៏បាននិមន្តចេញចាកអំពីគីរីវិហារ មកឈរនៅនឹងទ្វារផ្ទះរបស់ទមិឡ-ទោវារិកនោះឯង ។ កាលនោះភរិយារបស់ទមិឡទោវារិក ក៏បានជម្រាបដល់ស្វាមីថា **សាមិ** អ្នកជាម្ចាស់ ព្រះចូឡបិណ្ឌបាតិយ-

តិស្សត្ថេរ លោកបាននិមន្តមក ហើយឈរនៅមុខផ្ទះរបស់យើង។ ទមិឡទោវារិកបានពោលថា យើងនៅក្នុងទីនេះប្រមាណ៥០ឆ្នាំហើយ យើងមិនដែលបានទៅរកលោកឡើយ លោកម្ចាស់អង្គនេះ តើមានធុរៈអ្វីទើបបាននិមន្តមកហ្ន៎ បើថានិមន្តមកសួរយើងឈឺ ដូចជាពុំសមសោះ តែបើលោកនិមន្តមកដើម្បីបិណ្ឌបាត នាងចូរនិមន្តឱ្យលោកទៅប្រោសសត្វខាងមុខចុះ ។ ភរិយានោះក៏ចេញទៅនិមន្តព្រះមហាថេរៈថា សូមនិមន្តលោកម្ចាស់ទៅប្រោសសត្វខាងមុខចុះ ។ ព្រះមហាថេរៈទើបសួរថា ម្នាលឧបាសិកា ឥឡូវនេះឧបាសកមានសភាពយ៉ាងណាដែរ ? ភរិយារបស់ទមិឡទោវារិកក៏បានឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះស្វាមីរបស់ខ្ញុំម្ចាស់ទុព្វលភាពណាស់ ។

ព្រះមហាថេរៈ បាននិមន្តចូលទៅក្នុងផ្ទះដើម្បីដាស់តឿនសតិដល់អ្នកឈឺ បានញ៉ាំងទមិឡទោវារិកឱ្យមានសតិហើយ ទើបមានព្រះថេរដីកាថា ម្នាលឧបាសក អ្នកចូររក្សាសីល ។ ទមិឡទោវារិកបានទទួលពាក្យរបស់ព្រះថេរៈថា ខ្ញុំព្រះករុណានឹងទទួលសីល សូមនិមន្តលោកម្ចាស់ឱ្យសីលមកចុះ ។ ព្រះមហាថេរៈក៏បានឱ្យព្រះត្រៃសរណគមន៍ជាមុន រួចទៅប្រារព្ធនឹងឱ្យសីល៥ទៀត ស្រាប់តែទមិឡទោវារិកបានរឹងអណ្តាត មិនអាចទទួលសីល





តទៅទៀតបាន ។ ព្រះមហាថេរៈបានត្រិះរិះថា ត្រឹមតែទទួលព្រះ-ត្រៃសរណគមន៍ប៉ុណ្ណឹង ក៏ល្មមសមគួរនឹងរួចខ្លួនពីអបាយភូមិបាន លុះព្រះមហាថេរៈត្រិះរិះយ៉ាងនេះរួចហើយ ក៏បាននិមន្តចាកចេញពីទីនោះ ទៅកាន់គីរីវិហារវិញ ។

កាលព្រះមហាថេរៈត្រឡប់ទៅវិញហើយនោះ ទមិឡទោ-វារិកក៏បានធ្វើកាលកិរិយាស្លាប់ទៅ ហើយបានកើតជាទេវបុត្រក្នុងឋានទេវតាចាតុម្មហារាជិកា ។ ក្នុងខណៈដែលបានកើតឡើងជាទេវតាភ្លាមនោះ ក៏ពិចារណាថា អាត្មាអញបានធ្វើនូវកុសលអ្វីហ្ន៎ ទើបបានសម្បត្តិក្នុងទេវលោកយ៉ាងនេះ កាលពិចារណាទៅក៏ដឹងថា អាត្មាអញដែលបានសម្បត្តិនេះ អាស្រ័យព្រះចូឡបិណ្ឌបាតិយតិស្សត្ថេរ លោកបានឱ្យព្រះត្រៃសរណគមន៍ដល់អាត្មាអញ និងព្រោះ អាត្មាអញបានទទួលរក្សានូវព្រះត្រៃសរណគមន៍ហ្នឹងឯង ដូច្នេះ លោកម្ចាស់អង្គនេះមានគុណលើអាត្មាអញក្រៃលែងណាស់ គួរតែអាត្មាអញទៅថ្វាយបង្គំនមស្ការ និងសម្តែងនូវគុណរបស់លោកម្ចាស់ក្នុងពេលឥឡូវនេះ ។

ទេវបុត្រអង្គនោះឯង បានចុះចាកទេវលោក មកថ្វាយបង្គំនមស្ការចំពោះព្រះមហាថេរៈ ហើយក៏បានឈរនៅក្នុងទីបំផុតនៃផ្លូវចង្ក្រម ។ ព្រះមហាថេរៈបានសួរថា អ្នកឈ្មោះអ្វី ? អ្នកនៅទី

ណា ? ទេវបុត្របានឆ្លើយថា ខ្ញុំព្រះករុណានេះមិនមែនជាអ្នកដទៃណាឡើយ គឺទមិឡទោវារិកនោះឯង ។ ព្រះមហាថេរៈសួរបន្តទៀតថា ម្នាលអ្នកដ៏ចម្រើន តើអ្នកកើតទីណា ? ទេវបុត្រតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាកើតក្នុងស្ថានទេវតាជាន់ចាតុម្មហារាជិកា ប្រសិនបើលោកម្ចាស់ដ៏ចម្រើនឱ្យនូវសីល៥ដល់ខ្ញុំព្រះករុណាទៀតនោះ ខ្ញុំព្រះករុណាប្រាកដជាបានទៅកើតក្នុងទេវលោកជាន់លើ ដែលជាស្ថានខ្ពង់ខ្ពស់ជាងនេះជាពុំខានឡើយ ។ ព្រះមហាថេរៈបានមានព្រះថេរដីកាថា ម្នាលទេវបុត្រ តើឱ្យអាត្មាធ្វើអ្វីដល់អ្នកក្នុងកាលនោះបានទៅ បើអណ្តាតរបស់អ្នករឹងរូញទៅហើយនោះ គឺអ្នកមិនអាចទទួលសីលបានដោយខ្លួនឯងទេតើ ។ កាលដែលទេវបុត្រអង្គនោះ បានពោលឆ្លើយឆ្លងទៅវិញទៅមក ជាមួយព្រះមហាថេរៈហើយ ក៏បានថ្វាយបង្គំលាព្រះ-មហាថេរៈ ទៅកាន់ទេវលោក ដែលជាភពភូមិឋានរបស់ខ្លួនវិញទៅ ។

និទាននេះ ជាការសម្តែងឱ្យឃើញដល់កុសលក្នុងមរណា-សន្នកាល មានអំណាចអាចជួយឱ្យទមិឡទោវារិក ជាអ្នកធ្វើនូវបាណាតិបាត៥០ឆ្នាំហើយនោះ បានទៅកើតក្នុងទេវលោកសោយសម្បត្តិទិព្វ រួចផុតពីអបាយទុក្ខទាំងពួង ដោយប្រការដូច្នេះឯង ។





ជាបន្តទៅនេះគម្ពីរសារត្ថសង្គហៈ បានសម្តែងនូវនិទានបញ្ជាក់អំពីយទាសន្នកម្មផ្នែកខាងអកុសល **អន្តរគង្គាយំ បន មហាវាចកាលឧបាសកោ នាម អហោសិ** មានឧបាសកម្នាក់ឈ្មោះ មហាវាចកាលឧបាសក នៅក្នុងភូមិមួយដែលតាំងនៅក្នុងរវាងព្រៃនិងទន្លេគង្គា ។ មហាវាចកាលឧបាសកនោះ ត្រូវការនូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺសោតាបត្តិផល ហើយបានខំប្រឹងព្យាយាមចម្រើននូវកម្មដ្ឋាន យកនូវអាការ ៣២ មានកេសាជាដើម ជាអារម្មណ៍ ។ មហាវាចកាលឧបាសក បានចម្រើននូវកាយគតាសតិអស់៣០ឆ្នាំ សូម្បីតែពន្លឺអ្វីបន្តិចបន្តួចក៏មិនបានជួបប្រទះឡើយ ព្រោះថា ជាមនុស្សមានបុណ្យតិច បារមីនៅមិនទាន់ចាស់ក្លា ទាំងមិនធ្លាប់បានចម្រើននូវព្រះកម្មដ្ឋានពីមុនមកផង ជាអាទិកម្មិក-បុគ្គល ទើបមគ្គនិងផលមិនបានកើតឡើង ។

កាលដែលមហាវាចកាលឧបាសក ជិតនឹងអស់ជីវិតដល់នូវមរណភាពនោះ ក៏មានទិដ្ឋិយល់ខុសកើតឡើងក្នុងសន្តានដូច្នេះថា ព្រះពុទ្ធសាសនាមិនមែនជានិយ្យានិកធម៌ គឺមិនមែនជាធម៌ដឹកនាំសត្វឱ្យរួចផុតចាកទុក្ខបានឡើយ យើងបានចម្រើនកម្មដ្ឋានអស់៣០ឆ្នាំហើយ សូម្បីតែពន្លឺអ្វីក៏មិនដែលកើតមានម្តងសោះ រួចហើយក៏បានធ្វើកាលកិរិយាស្លាប់ទៅ ។ ការយល់ខុសក្នុងព្រះពុទ្ធ-

សាសនានោះ បានជាបច្ច័យនាំឱ្យមានវិបាកបដិសន្ធិក្នុងកំណើតសត្វតិរច្ឆាន គឺមហាវ៉ាចកាលឧបាសកស្លាប់ទៅ បានកើតជាសត្វក្រពើដ៏ធំមួយនៅនឹងទន្លេគង្គា ។

និទាននេះសម្តែងយទាសន្នកម្មផ្នែកខាងអកុសល បញ្ជាក់ឱ្យឃើញថា ការយល់ខុសដែលកើតឡើងក្នុងសន្តាននៃមហាវ៉ាច-កាលឧបាសកនៅពេលជិតស្លាប់នោះ មានអំណាចអាចឱ្យបដិសន្ធិក្នុងអបាយភូមិបាន (គឺជាមរណាសន្នកម្មដ៏អាក្រក់ក្រៃលែង ចូលបៀតបៀនដល់កុសលកម្មដទៃមិនឱ្យជាជនកកម្មបាន ដូច្នេះ សូមពុទ្ធបរិស័ទទាំងឡាយសិក្សាស្វែងយល់ឱ្យបានជាក់ច្បាស់តាមពិតថា ព្រះពុទ្ធសាសនា ជាសាសនាដឹកនាំអ្នកដែលប្រព្រឹត្តបដិបត្តិតាមឱ្យបានរួចផុតចាកទុក្ខពិតប្រាកដមែន ការយល់ឃើញត្រឹមត្រូវតែប៉ុណ្ណោះ ជាបុណ្យកុសលដ៏ធំមួយ និងជាឫសគល់នៃកុសលទាំង-ឡាយទៀតផង )។

ចប់យទាសន្នកម្មក្នុងគម្ពីរសារត្ថសង្គហៈ

ជាបន្តទៅនេះជាការពន្យល់អំពី អាសន្នកម្ម ក្នុងគម្ពីរបរមត្ថជោតិកដីកា « **អាសន្នេ ភតំ > អាសន្នំ** » ការធ្វើនូវអំពើល្អ ឬមិនល្អក្នុងពេលជិតស្លាប់ ឈ្មោះថា **អាសន្នកម្ម** ។



បុគ្គលខ្លះមិនធ្លាប់បានធ្វើបុណ្យអ្វីឯណានីមួយ ដែលគួរឱ្យកត់សម្គាល់ឡើយ ហើយស្រាប់តែត្រឡប់មកជាមានសទ្ធាបំពេញកុសល ដើម្បីបានជាទីពឹងក្នុងដំណើរជីវិតរបស់ខ្លួន ដូចជា បួសក្នុងព្រះពុទ្ធសាសនា ធ្វើកឋិន សាងសាលា ជីកស្រះទឹកទុកជាទាន រក្សាសីល៥ សមាទានឧបោសថ ឬចម្រើនសមថវិបស្សនាជា-ដើម ។ នៅក្នុងពេលដែលកំពុងធ្វើកុសលនោះក្តី ទើបតែបានធ្វើរួចហើយក្តី សេចក្តីស្លាប់ក៏បានមកដល់ កុសលបែបនេះបានឈ្មោះថា **អាសន្នកម្ម** ឬ ម៉្យាងទៀត ដូចជាបុគ្គលខ្លះដែលកំពុងតែសប្បាយនៅក្នុងជីវិត មិនបានគិតសាងកុសលអ្វីឡើយ ក្រោយមកក៏កើតមានរោគដែលធ្វើឱ្យមិនសប្បាយកាយ និងជារោគដែលមិនអាចព្យាបាលឱ្យជាសះស្បើយទៅបានឡើយ ព្រោះអាស្រ័យគេមានរោគយ៉ាងនេះ គេក៏ភ័យខ្លាចចំពោះសេចក្តីស្លាប់ និងសម្លឹងរកមើលទីពឹងរបស់ខ្លួន កាលរកមើលពុំឃើញនូវទីពឹងរបស់ខ្លួនសម្រាប់ទៅកាន់បរលោកដូច្នេះ គេទើបបានបំពេញនូវកុសលឱ្យកើតឡើង មានទានកុសលខ្លះ សមាទានសីលស្តាប់ធម៌ខ្លះ រួចហើយមិនយូរឡើយ គេក៏ស្លាប់ដោយជំងឺនោះទៅ កុសលបែបនេះគឺជាកុសលកម្មក្នុងពេលជិតស្លាប់ ដែលជាអាសន្នកម្មហ្នឹងឯង ។

ចំណែកអាសន្នកម្មជាអកុសលវិញនោះ គឺដូចជា បុគ្គល

ដែលកំពុងមានវិវាទនឹងគ្នា ហើយបានវាយប្រហារគ្នា កាប់សម្លាប់គ្នាដោយសេចក្តីក្រោធដ៏ខ្លាំងក្លា អ្នកដែលត្រូវស្លាប់ក្នុងពេលវាយកាប់ចាក់គ្នានោះ ឈ្មោះថាមានអាសន្នកម្មជាអកុសលឬដូចជាអ្នកដែលកំពុងប្រព្រឹត្តនូវបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារជាដើម ហើយក៏ត្រូវស្លាប់ដោយហេតុឯណានីមួយក្នុងពេលនោះ បាបកម្មទាំងអស់នោះ គឺជាអាសន្នកម្ម ឬម៉្យាងទៀត ដូចជាបុគ្គលខ្លះកំពុងសប្បាយក្នុងកាមគុណ ដោយប្រការផ្សេងៗ ស្រាប់តែមាននូវឧបទ្ទវហេតុ ហើយត្រូវស្លាប់នៅក្នុងពេលនោះទៅ ការសប្បាយរីករាយក្នុងកាមគុណ ដោយប្រការផ្សេងៗនោះឯង គឺជាអាសន្នកម្ម ។

អង្គធម៌នៃអាសន្នកម្ម គឺចេតនាក្នុងអកុសលចិត្ត១២ដួង (វៀរនិយតមិច្ឆាទិដ្ឋិ និងបញ្ចានន្តរិយកម្ម ) និងចេតនាក្នុងមហាកុសលចិត្ត ៨ដួង (ចំពោះមហគ្គតកុសលកម្ម មិនចាត់ចូលក្នុងទីនេះ ព្រោះជាចំណែកនៃគរុកកម្ម ) ។

**លំដាប់ទី៣‿អាចិណ្ណកម្ម** បានដល់កម្មណាដែលបុគ្គលបានសន្សំទុករឿយៗ ដូច្នោះ កម្មនោះឯងឈ្មោះថា អាចិណ្ណកម្ម « **អាចីយតិ បុនប្បុនំ ករីយតីតិ > អាចិណ្ណំ** » ។

អង្គធម៌ គឺ កម្មក្នុងអកុសលចិត្ត ១២ ដួង និងកម្មក្នុង



មហាកុសលចិត្ត៨ដួង ដោយសេចក្តីថា ការធ្វើនូវទុច្ចរិតផ្សេងៗ ដោយកាយខ្លះ ដោយវាចាខ្លះ ដោយចិត្តខ្លះ ជានិច្ចកាល ទោះជាធ្វើដោយអាជីពក្តី មិនមែនជាអាជីពក្តី ការធ្វើនេះហៅថាអាចិណ្ណកម្មជាអកុសល ឯចំណែកការធ្វើបុណ្យជានិច្ចកាលវិញ មានការដាក់បាត្រជារៀងរាល់ថ្ងៃ រក្សាសីល៥ សីល៨ សីល១០ សីលរបស់អ្នកបួស ដោយការរក្សាជាប្រចាំមិនដាច់ បង្រៀនធម៌វិន័យ និងសិក្សានូវធម៌វិន័យជាប្រក្រតីប្រចាំជីវិត ចម្រើនសមថ-វិបស្សនាជារឿយៗ ការធ្វើទាំងអស់នេះឈ្មោះថា អាចិណ្ណកម្មជាកុសល ។

ម៉្យាងទៀត បុគ្គលដែលធ្វើនូវអំពើទុច្ចរិតឯណានីមួយបានសម្រេចរួចហើយ សូម្បីតែម្តងគត់ ប៉ុន្តែអ្នកដែលធ្វើនោះឯងរមែងតែងតែនឹកឃើញជារឿយៗនូវការធ្វើកម្មរបស់ខ្លួននោះ ជាការនឹកឃើញព្រមដោយសេចក្តីក្តៅក្រហាយស្តាយក្រោយ មិនសប្បាយចិត្ត រំខានចិត្ត ឬនឹកឃើញហើយក៏សប្បាយចិត្តរឿយៗត្រេកអររីករាយនៅក្នុងបាបកម្មរបស់ខ្លួនឯណានីមួយដែលបានធ្វើហើយនោះឯង។ ការមិនសប្បាយចិត្តក្តី ការត្រេកអរក្តីប្រព្រឹត្តទៅជាប់ជានិច្ចក្នុងជីវិត ត្បិតធ្វើទុកក្នុងចិត្តមិនល្អចំពោះបាបកម្មដែលខ្លួនបានសាងហើយ យ៉ាងនេះ ក៏ឈ្មោះថា មាននូវអាចិណ្ណកម្មជា

អកុសលដូចគ្នាដែរ ។

ក្នុងការធ្វើនូវកុសលកម្មក៏ដូចគ្នាដែរ សូម្បីបានធ្វើនូវបុណ្យអ្វីមួយតែម្តងក៏ដោយ ប៉ុន្តែ មានការនឹករលឹកឃើញ ដោយសេចក្តីពេញចិត្តជ្រះថ្លាជានិច្ចរឿយៗ នឹកឃើញហើយកើតបីតិសោមនស្សក្នុងបុណ្យកុសលដែលខ្លួនបានធ្វើនោះ ការនឹករលឹកជ្រះថ្លានឹងបុណ្យកុសលរឿយៗយ៉ាងនេះ ឈ្មោះថា អាចិណ្ណកម្មជាកុសលផងដែរ ។

នៅក្នុងគម្ពីរ **សារត្ថសង្គហៈ** បានសម្តែងអំពីពហុលកម្មដោយសេចក្តីដូចតទៅ **កុសលាកុសលេសុ បន យំ ពហុំ ហោតិ តំ ពហុលំ នាម** ក្នុងពហុលកម្មនេះ អ្នកមានប្រាជ្ញាគប្បីយល់ជ្រាបថា កុសលឯណាដែលច្រើន កុសលនោះឈ្មោះថា ពហុលកម្ម ចំណែកឯអកុសលក៏ដូចគ្នា ។

មានពាក្យអដ្ឋកថាវិសជ្ជនាទុកថា **តំ ទីឃរត្តំ លទ្ធាសេវនវសេន ចេតិតព្វំ** អ្នកមានប្រាជ្ញាគប្បីយល់ចូលចិត្តថា កុសល ឬអកុសលដែលបាននូវអាសេវនប្បច្ច័យ អស់កាលដ៏យូរនោះឯង បានឈ្មោះថា ពហុលកម្ម ។

តើយ៉ាងណាទើបបានឈ្មោះថា អាសេវនប្បច្ច័យអស់កាលដ៏យូរនោះ ?





មានពាក្យអធិប្បាយថា **យំ វា ពលវំ កុសលកម្មេសុ សោមនស្សករំ អកុសលកម្មេសុ សន្តាបករំ ឯតំ ទ្វយំ ពហុលំ នាម** បណ្តាកុសលដែលបុគ្គលធ្វើនោះ បើកុសលណាមានកម្លាំង ធ្វើឱ្យរីករាយសោមនស្សក្នុងកាលទាំង៣ គឺមុនដំបូងមានការប្រារព្ធដើម្បីនឹងធ្វើបុណ្យ បានត្រៀមរៀបចំដើម្បីនឹងធ្វើដោយសោមនស្សត្រេកអរក្នុងបុណ្យ ដូចជាប្រាថ្នាដើម្បីនឹងធ្វើទាន រមែងសោមនស្សត្រេកអរក្នុងការចាត់ចែងនូវទេយ្យធម៌ត្រេកអរគ្រប់វារៈគ្រប់គ្រាជាប់បន្តគ្នា ។ ដល់ពេលស្វែងរកវត្ថុទេយ្យទានបានហើយ ឬដល់ពេលវេលាដែលត្រូវធ្វើហើយនោះក៏សោមនស្សត្រេកអរក្នុងកុសលកម្មដែលខ្លួនកំពុងធ្វើ លុះដល់ធ្វើរួចស្រេចហើយ បាននឹករលឹកឃើញតាមក្រោយ ក៏សោមនស្សត្រេកអរក្នុងកុសលកម្មនោះជាបន្តបន្ទាប់ គិតឃើញពេលណា ក៏ជ្រះថ្លាត្រេកអរពេលនោះ ហើយបានគិតឃើញថា អាត្មាអញបានកើតមកជាមនុស្សហើយបានជួបនឹងព្រះពុទ្ធសាសនា អាត្មាអញមិនមែនជាបុគ្គលសាបសូន្យនូវប្រយោជន៍ឡើយ អាត្មាអញបានបដិបត្តិតាមពុទ្ធោវាទ បានធ្វើនូវកុសលកម្មដោយសេចក្តីព្យាយាមដ៏ធំ កុសលកម្មដែលអាត្មាអញបានធ្វើហើយនោះ ជាប្រយោជន៍ដោយពិត អាត្មាអញនឹងបានរួចផុតចាកទុក្ខភ័យជាប្រាកដ ដោយ

អំណាចនៃកុសលដែលអាត្មាអញបានធ្វើនោះឯង ។ កុសលដែលមានកម្លាំង ធ្វើឱ្យត្រេកអរសោមនស្សក្នុងពេលទាំង៣ ដូចដែលបានសម្តែងមកនេះ បានឈ្មោះថា អាសេវនប្បច្ច័យអស់កាលដ៏យូរ ចាត់ជាពហុលកម្មផ្នែកខាងកុសល ។

ចំណែកខាងអកុសលកម្មវិញ បើអកុសលកម្មណាដែលមានកម្លាំងធ្វើឱ្យក្តៅក្រហាយចិត្តច្រើន ក៏ជាពហុលកម្មដោយពិត ដូចជា មុននឹងធ្វើ ក៏គិតធ្វើដោយសេចក្តីក្រោធច្រើនៗ ដល់ពេលធ្វើនូវកម្មនោះ ក៏ធ្វើដោយសេចក្តីក្រោធខ្លាំងក្លា កាប់ចាក់ប្រហារដោយកម្លាំងនៃសេចក្តីក្រោធ លុះធ្វើរួចហើយ មិនអស់នូវសេចក្តីក្រោធឡើយ គិតឃើញពេលណា ក៏ក្រោធពេលនោះទៀត ។ អកុសលដែលធ្វើឱ្យក្តៅក្រហាយចិត្ត និងមានសេចក្តីក្រោធជាបន្តបន្ទាប់ មិនចេះអស់មិនចេះហើយ យ៉ាងនេះឯង រមែងបានឈ្មោះថា អាសេវនប្បច្ច័យអស់កាលដ៏យូរ ចាត់ជាពហុលកម្មផ្នែកខាងអកុសល ។

ម្យ៉ាងទៀត សូមឱ្យអ្នកមានប្រាជ្ញាបានជ្រាបនូវពហុលកម្មដោយឧបមាដូច្នេះថា អ្នកប្រដាល់ពីរនាក់ បានដាល់គ្នាក្នុងទីប្រកួត បើអ្នកណាមានកម្លាំងខ្លាំងជាង ពូកែជាង អ្នកនោះរមែងគ្របសង្កត់នូវគូប្រកួតរបស់ខ្លួន ធ្វើឱ្យគូប្រកួតដែលមានកម្លាំងខ្សោយ



នោះដួលចុះ សេចក្តីនេះយ៉ាងណា កម្មដែលមានកម្លាំងខ្លាំងរមែងគ្របសង្កត់នូវកម្មដែលមានកម្លាំងខ្សោយ ឱ្យនៅក្នុងអំណាចរបស់ខ្លួន មិនឱ្យកម្មដែលមានកម្លាំងខ្សោយបង្កើតផលឯណានីមួយបានឡើយ ហើយក៏ជាកម្មដែលញ៉ាំងផលឱ្យកើតឡើងដោយខ្លួនឯង ប្រៀបដូចអ្នកប្រដាល់ដែលមានកម្លាំងខ្លាំងពូកែគ្របសង្កត់គូប្រកួតដែលមានកម្លាំងខ្សោយជាង ឱ្យនៅក្នុងអំណាចរបស់ខ្លួនដូច្នោះឯង ។

ចប់ពហុលកម្មក្នុងគម្ពីរសារត្ថសង្គហៈ

**លំដាប់ទី៤-កដត្តាកម្ម** ក្នុងបរមត្ថជោតិកៈ សម្តែងថា **កដត្តា ឯវ កម្មំ** ការធ្វើដែលបានឈ្មោះថាកម្ម ក៏គ្រាន់តែជាការធ្វើហើយប៉ុណ្ណោះឯង បានដល់កម្មក្នុងអកុសលចិត្ត១២ដួង និងកម្មក្នុងមហាកុសលចិត្ត៨ដួង ។

ដោយសេចក្តីថា កុសលកម្ម និងអកុសលកម្មដែលធ្លាប់ធ្វើមកហើយក្នុងភពមុនៗ គឺជាអបរាបរិយវេទនីយកម្មនេះម្យ៉ាង និងម្យ៉ាងទៀត កុសលកម្ម និងអកុសលកម្មដែលធ្វើក្នុងភពនេះ តែមិនបានចូលដល់គរុកកម្ម និងមិនមែនជាអាសន្នកម្មផង ព្រមទាំងមិនមែនជាអាចិណ្ណកម្មផង គឺគ្រាន់តែជាកម្មយ៉ាងសាមញ្ញ ដោយអ្នកធ្វើមិនបានតាំងចិត្តឱ្យពេញលេញ ការដែលពោលមកនេះក៏

ព្រោះថា «**ឯវ** » ដែលនៅក្នុងបទថា **កដត្តា ឯវ កម្មំ** នោះ ជាពាក្យបដិសេធនូវកម្មដែលជាគរុកកម្ម អាសន្នកម្ម និងអាចិណ្ណកម្មនោះឯង ។

គរុកកម្ម អាសន្នកម្ម និងអាចិណ្ណកម្ម ទាំង៣នេះ ក៏ចាត់ជាកដត្តាកម្មបានដូចគ្នា ព្រោះបានធ្វើសម្រេចរួចទៅហើយ ប៉ុន្តែ នឹងហៅថាកដត្តាកម្មមិនបានឡើយ ព្រោះកម្មទាំង៣នេះមានឈ្មោះដោយចំពោះខ្លួនឯងហើយ និងពាក្យថា **ឯវ** ដែលសម្តែងមកហើយនោះ ក៏ជាគ្រឿងជំទាស់ មិនឱ្យកម្មទាំង៣នេះមានឈ្មោះថាជាកដត្តាកម្ម ។

កម្មទាំង៤ ដូចដែលបានពោលមកហើយនេះ ព្រះអនុរុទ្ធាចារ្យសម្តែងដល់ការឱ្យផលបដិសន្ធិ គឺឱ្យកើតជាមនុស្ស ទេវតា សត្វតិរច្ឆាន ជាដើម ក្នុងភពទី២ តាមលំដាប់ ដូច្នេះទើបហៅថា **បាកទានបរិយាយចតុក្កៈ** ។ **បាក** = ផលបដិសន្ធិ **ទាន** =ឱ្យ **បរិយាយ** =វារៈ ឬលំដាប់ **ចតុក្កៈ**=៤ ; រួមសេចក្តីនៃពាក្យទាំងអស់មក គឺ កម្មដែលឱ្យផលបដិសន្ធិតាមលំដាប់មាន៤យ៉ាង ។

ដោយហេតុនេះ បើបុគ្គលណាមានកម្មទាំង៤យ៉ាងហើយ គរុកកម្មនឹងឱ្យផលបដិសន្ធិ គឺបើបានឈាន ក៏នឹងទៅកើតជាព្រហ្ម បើធ្វើបញ្ចានន្តរិយកម្ម ឬនិយតមិច្ឆាទិដ្ឋិកម្ម ក៏នឹងទៅកើតជាសត្វ-



នរក ចំណែកកម្មដទៃ៣ទៀត មិនអាចឱ្យផលបដិសន្ធិក្នុងភពទី២ បានឡើយ បានត្រឹមតែឱ្យផលក្នុងបវត្តិកាល ។ បើបុគ្គលណា មិនមាននូវគរុកកម្មទេ គឺមិនបានធ្វើនូវអនន្តរិយកម្ម៥ឯណានីមួយទេ មិនមាននូវនិយតមិច្ឆាទិដ្ឋិទេ និងមិនមែនជាឈានលាភីបុគ្គលទេ ហើយក៏មិនមែនជាព្រះអរិយបុគ្គលដែរនោះ រមែងត្រូវអាសន្នកម្មជាតួឱ្យផលបដិសន្ធិក្នុងកំណើតមនុស្ស ទេវតា ឬក្នុងកំណើតអបាយភូមិ តាមសមគួរដល់កម្មនោះៗ ក្នុងជាតិទី២ហ្នឹងឯង ចំណែកអាចិណ្ណកម្ម និងកដត្តាកម្មទាំងពីរនោះ នឹងអាចឱ្យផលបានក្នុងជាតិទី២ គឺបានត្រឹមតែក្នុងបវត្តិកាលប៉ុណ្ណោះ (នេះពោលចំពោះបុគ្គលណាដែលមានកម្មទាំង៣យ៉ាង វៀរគរុកកម្ម ) ។ បើបុគ្គលណាដែលមិនមាននូវគរុកកម្ម និងអាសន្នកម្មទេ មានតែអាចិណ្ណកម្មនិងកដត្តាកម្មប៉ុណ្ណោះ ដូច្នេះអាចិណ្ណកម្មត្រូវបាននូវឱកាសឱ្យផលបដិសន្ធិក្នុងកំណើតផ្សេងៗ តាមសមគួរដល់ខ្លួនឯងជាកាមាវចរកម្ម ក្នុងភពទី២ (ភពទី១ គឺភពដែលធ្វើកម្មនោះ ) ចំណែកកដត្តាកម្ម អាចឱ្យផលបានក្នុងបវត្តិកាលនៃភពទី២នោះ ។ បើបុគ្គលណាមិនមាននូវគរុកកម្ម មិនមាននូវអាសន្នកម្ម និងមិនមាននូវអាចិណ្ណកម្មទេ ដូច្នេះទើបកដត្តាកម្ម (ដែលធ្វើក្នុងភពមុនក្តី ភពនេះក្តី ) ជាបច្ច័យញ៉ាំងផលវិបាកបដិសន្ធិ តាមសមគួរនៃ

កម្មនោះ ព្រោះថា សត្វទាំងឡាយនៅក្នុងលោកនេះ មិនមានសត្វណាដែលអត់នូវកដត្តាកម្មឡើយ ។

នៅក្នុងលំដាប់នៃកម្មពីរយ៉ាងគឺ អាសន្នកម្ម និងអាចិណ្ណ-កម្ម បើពិចារណាអំពីកម្លាំងវិញនោះ អាចិណ្ណកម្មរមែងមានកម្លាំងខ្លាំងជាង ព្រោះជាកម្មដែលធ្វើជានិច្ច និងសន្សំរឿយៗ ដូច្នេះហើយ ទើបនៅក្នុងគម្ពីរវិសុទ្ធិមគ្គ និងអដ្ឋកថាអង្គុត្តរនិកាយ មានការសម្តែងអំពីកម្មដែលឱ្យផលតាមលំដាប់នោះថា «**អបរម្បិ ចតុព្វិធំ កម្មំ យំ គរុកំ យំ ពហុលំ យទាសន្នំ កដត្តា វា បន កម្មន្តិ** » ប្រែថា « ដោយប្រការម្យ៉ាងទៀត បានដល់កម្ម៤យ៉ាងដែលឱ្យផលទៅតាមលំដាប់ គឺគរុកកម្ម ពហុលកម្ម អាសន្នកម្ម កដត្តាកម្ម » ។

ទោះបីថា អាចិណ្ណកម្មមានកម្លាំងខ្លាំងជាងអាសន្នកម្មក៏ដោយ ក៏ក្នុងការឱ្យផលបដិសន្ធិក្នុងភពទី២នោះ គឺអាសន្នកម្មដែលជាកម្មកើតឡើងនៅពេលជិតស្លាប់ មានសេចក្តីសំខាន់ជាង និងមានឱកាសច្រើនជាង ព្រោះតាមធម្មតាក្នុងពេលជិតស្លាប់នោះ កម្ម កម្មនិមិត្ត គតិនិមិត្ត យ៉ាងណាមួយនឹងប្រាកដឡើងក្នុងមរណាសន្នជវន ដោយអំណាចនៃជនកកម្ម ក្នុងសេចក្តីនេះ អាសន្នកម្មរមែងមានឱកាសជាងអាចិណ្ណកម្ម ក្នុងការនាំមកនូវ





អារម្មណ៍របស់មរណាសន្នជវន បីយ៉ាងណាមួយនោះ ។ សេចក្តីនេះប្រៀបដូចជាគោក្នុងក្រោល គោណាដែលនៅនឹងមាត់ទ្វារក្រោល ទោះបីមានកម្លាំងខ្សោយក៏ដោយ ក៏គោនោះរមែងចេញមកមុន នៅពេលដែលគេបើកទ្វារក្រោល (នេះគឺជាការសំខាន់ណាស់ ចំពោះអំពើធ្វើនៅពេលជិតស្លាប់នោះ ) ដោយហេតុនេះ ទើបនៅក្នុងអភិធម្មត្ថសង្គហៈ បានសម្តែងនូវអាសន្នកម្មក្នុងលំដាប់មុនអាចិណ្ណកម្ម ។

រឿងឧបមាអំពីគោចាស់មានកម្លាំងខ្សោយ ដែលឋិតនៅជិតមាត់ទ្វារក្រោល គឺវាអាចចេញបានមុនគេដោយពិត ប៉ុន្តែប្រសិនបើ គោចាស់នោះវាមានកម្លាំងខ្សោយរហូតដល់ដើរចេញមិនបាន ដូច្នេះត្រូវគោដទៃទៀតដែលនៅខាងក្រោយ មានឱកាសចេញបានមុនគោចាស់នោះ ។ សេចក្តីនេះ សម្តែងឱ្យឃើញថា អាសន្នកម្មដែលមានកម្លាំងខ្សោយ មិនអាចនាំមកនូវអារម្មណ៍របស់មរណាសន្នជវន ៣យ៉ាងណាមួយគឺ កម្ម កម្មនិមិត្ត គតិនិមិត្ត ឱ្យប្រាកដបានឡើយ អាសន្នកម្មដែលខ្សោយបែបនេះក៏មានដែរ ដូច្នេះ អាសន្នកម្មបែបនេះ ទើបមិនមានឱកាសញ៉ាំងផលឱ្យបដិសន្ធិក្នុងភពទី២ទៅបាន ។ វាត្រូវជានាទីរបស់អាចិណ្ណកម្មដែលនាំមកនូវកម្ម ឬកម្មនិមិត្ត ឬគតិនិមិត្ត ឱ្យប្រាកដជាអារម្មណ៍

របស់មរណាសន្នជវន រួចហើយទើបបដិសន្ធិក្នុងភពទី២ដែលជាភពថ្មី ដោយអំណាចនៃអាចិណ្ណកម្មនោះឯងជាជនកកម្មប្បច្ច័យជំនួសអាសន្នកម្ម ។ កាលបើយ៉ាងនេះ អាចិណ្ណកម្មក៏ត្រូវនៅក្នុងលំដាប់ទី២ ឯចំណែកអាសន្នកម្មធ្លាក់ទៅនៅក្នុងលំដាប់ទី៣ ត្រូវនឹងគម្ពីរវិសុទ្ធិមគ្គនិងអដ្ឋកថាអង្គុត្តរនិកាយតិកនិបាត និទានសូត្រដែលបានសម្តែងទុកមក ។

តាមដែលគម្ពីរវិសុទ្ធិមគ្គ បានសម្តែងអំពីលំដាប់នៃការឱ្យផលរបស់កម្ម ដោយលើកយកនូវអាចិណ្ណកម្មមកសម្តែងនៅក្នុងលំដាប់មុនអាសន្នកម្មនោះ ក៏អាចយល់បានម៉្យាងទៀតថា អាសន្នកម្មដែលមានកម្លាំងខ្សោយ រហូតដល់កដត្តាកម្ម និងអាចិណ្ណកម្មមិនអាចជួយឧបត្ថម្ភឱ្យជាជនកកម្មទៅបាន ដោយហេតុនេះទើបធ្លាក់ទៅដល់អាចិណ្ណកម្ម មាននាទីញ៉ាំងផលបដិសន្ធិឱ្យកើតឡើងបន្ទាប់ពីចុតិ ដោយបានទទួលការឧបត្ថម្ភពីកដត្តាកម្មផង ។

**ចប់បាកទានបរិយាយចតុក្កៈ**





# III ‐ បាកកាលចតុក្កៈ

<u>កម្មឱ្យផលតាមកាល</u>

**បាកកាលទី១‐ទិដ្ឋធម្មវេទនីយកម្ម** សភាពដែលអាចឃើញច្បាស់បាននៅក្នុងភពនេះ ឈ្មោះថា **ទិដ្ឋធម្ម** បានដល់អត្តភាពដែលប្រាកដក្នុងភពនេះ ។ ផលណាដែលគប្បីបានសោយផលនោះឈ្មោះថា **វេទនីយ** ។

ទិដ្ឋធម្មវេទនីយកម្ម បានដល់ កម្មដែលឱ្យផលនៅក្នុងបច្ចុប្បន្នជាតិ គឺជាអកុសលកម្ម និងមហាកុសលកម្ម ប្រព្រឹត្តទៅក្នុងជវនៈខណៈទី១ ។

## សេចក្តីអធិប្បាយ

ការធ្វើផ្សេងៗ របស់មនុស្សយើងនេះ ទោះជាផ្លូវកាយក្តី ផ្លូវវាចាក្តី ផ្លូវចិត្តក្តី ទោះជាអំពើល្អក្តី អំពើអាក្រក់ក្តី ក្នុងខណៈដែលធ្វើនោះ ត្រូវមានជវនៈកើតឡើង៧ដង ឬ ៧ខណៈ ។

វិថីចិត្តដែលកើតឡើងមានជវនៈ៧ខណៈនេះ ក៏មានសន្ទឹកសន្ធាប់រាប់មិនអស់ នៅពេលធ្វើកិច្ចការអ្វីមួយនោះ ។ ក្នុងបណ្តាជវនៈ៧ខណៈនេះ ចេតនាដែលប្រកបនៅក្នុងជវនៈដួងទី១ ឈ្មោះ

ថា ទិដ្ឋធម្មវេទនីយកម្ម គឺកម្មនេះឯងជាបច្ច័យញុំាងឱ្យផលប្រាកដឡើង ក្នុងបច្ចុប្បន្នភព ឱ្យឃើញ ឱ្យឮ ឱ្យធុំក្លិន ឱ្យដឹងរស ឱ្យដឹងផោដ្ឋព្វៈ ល្អឬមិនល្អ និងឱ្យកម្មជរូប កម្មប្បច្ចយឧតុជរូប បានដល់អវយវៈក្នុងរាងកាយ និងពណ៌សម្បុរល្អមិនល្អ ជាអហេតុកផល (ផលមិនប្រកបជាមួយហេតុ៦ណាមួយ ) កើតឡើងប៉ុណ្ណោះ ។ ទិដ្ឋធម្មវេទនីយកម្មនេះ មិនអាចឱ្យផលក្នុងបដិសន្ធិកាល និងបវត្តិ-កាល នៅក្នុងភពដទៃ ចាប់តាំងពីភពទី២ទៅបានឡើយ គឺអាចឱ្យផលបានតែក្នុងភពបច្ចុប្បន្ន ពោលគឺធ្វើកម្មក្នុងជាតិណា រមែងសោយផលក្នុងជាតិនោះ ។

កុសលចេតនា ឬអកុសលចេតនាដែលប្រកបនៅក្នុងជវនៈដួងទី១នេះមិនអាចចាត់ចែងឱ្យបុគ្គលនោះ បានទៅកើតជាមនុស្សទេវតា ឬកើតជាសត្វក្នុងអបាយភូមិបានទេ ព្រមទាំងមិនអាចបង្កើតផលឱ្យបុគ្គលនោះបានទទួលរបស់ល្អ ឬអាក្រក់ផ្សេងៗនៅក្នុងភពដទៃណាទៀតបានឡើយ ។

ចេតនានៅក្នុងជវនៈដួងទី១មានកម្លាំងខ្សោយជាងចេតនានៅក្នុងជវនៈដួងទី២ ព្រោះទើបតែកើតឡើងដំបូង មិនបានទទួលកម្លាំងអំពីអាសេវនប្បច្ច័យ (ជវនៈទី១ទើបជាអាសេវនប្បច្ច័យដល់ជវនៈទី២ ដូច្នេះ ចេតនាក្នុងជវនៈដួងទី២ដល់ទី៧ ទើបមានកម្លាំង





ឱ្យផលបដិសន្ធិបាន ) ។

ជវនៈដួងទី១ បានទទួលឧបការៈអំពីមនោទ្វារាវជ្ជនចិត្តដែលជាអនន្តរប្បច្ច័យក៏ពិតមែន ប៉ុន្តែនេះមិនមែនជាឧបការៈផ្នែកខាងកម្លាំងទេ គ្រាន់តែជាឧបការៈក្នុងផ្នែកឱ្យកើតឡើងតែប៉ុណ្ណោះ ដូចព្រះអដ្ឋកថាចារ្យបានសម្តែងទុកក្នុងអដ្ឋសាលិនី អដ្ឋកថា និងនាមរូបបរិច្ឆេទ អដ្ឋកថា ដូច្នេះថា :

**ទិដ្ឋធម្មវេទនីយំ បឋមំ ជវនំ ភវេ**
**អលទ្ធា សេវនត្ថា វា អសមត្ថំ ភវន្តរេ ។**

<u>ប្រែថា</u> : ទិដ្ឋធម្មវេទនីយកម្មនោះបានដល់ ចេតនាដែលនៅក្នុងជវនៈដួងទី១ ចេតនានេះមិនអាចបង្កើតផលទៅក្នុងភពដទៃ ចាប់តាំងអំពីភពទី២ទៅបានឡើយ ព្រោះមិនបានទទួលឧបការៈអំពីអាសេវនប្បច្ច័យ ។

ទិដ្ឋធម្មវេទនីយកម្មនេះមាន២យ៉ាងគឺ ÷

**១-បរិបក្កទិដ្ឋធម្មវេទនីយកម្ម** កម្មដែលនឹងឱ្យបានទទួលផលក្នុងបច្ចុប្បន្នភពនេះ មានសភាពចាស់ក្លា ។

**២-អបរិបក្កទិដ្ឋធម្មវេទនីយកម្ម** កម្មដែលនឹងឱ្យបានទទួលផលក្នុងបច្ចុប្បន្នភពនេះ មិនមាននូវសភាពចាស់ក្លាឡើយ ។

## សេចក្តីអធិប្បាយ

១.កម្មដែលនឹងឱ្យបានទទួល ផលក្នុងបច្ចុប្បន្នភពនេះ មាន សភាពចាស់ក្លាហើយនោះ ដោយសេចក្តីថា នឹងឱ្យបានទទួលផល ក្នុងរវាង៧ថ្ងៃជាពិតប្រាកដ ដូចព្រះអដ្ឋកថាចារ្យបានសម្តែងទុក ក្នុងទេវទហសូត្រ មជ្ឈិមនិកាយ ឧបរិបណ្ណាសក អដ្ឋកថា ថា : **យំ បន សត្តទិវសព្ភន្តរេ វិបាកំ ទេតិ តំ បរិបក្កវេទនីយំ នាម** កម្មណាឱ្យផលក្នុងរវាង៧ថ្ងៃ កម្មនោះឈ្មោះថា បរិបក្កវេទនីយកម្ម ដូចជា មហាទុគ្គតបុរស ជាអ្នកកំសត់ក្រីក្រម្នាក់ បានថ្វាយភត្តាហារដល់ព្រះកស្សបសម្មាសម្ពុទ្ធជាម្ចាស់ កាលបានថ្វាយរួចស្រេចបាច់ហើយ ក្នុង៧ថ្ងៃនោះឯង ក៏បាននូវសម្បត្តិជាសេដ្ឋី ឬដូចនាយបុណ្ណៈនិងភរិយា ជាអ្នកក្រលំបាក បានប្រគេននូវភត្តាហារដល់ព្រះសារីបុត្រដ៏មានអាយុ ហើយក៏បានជាសេដ្ឋីនៅក្នុងរវាង៧ថ្ងៃនោះដែរ និងនាយកាកវឡិយៈជាមួយភរិយា ក៏ជាអ្នកក្រីក្រ មានការខ្វះខាតនូវទ្រព្យសម្បត្តិ តែដោយមានឱកាសបានប្រគេនភត្តាហារដល់ព្រះមហាកស្សបត្ថេរៈ ក៏បានជាសេដ្ឋីក្នុងរវាង៧ថ្ងៃដែរទៅ នៅមានអ្នកដទៃច្រើននាក់ទៀតណាស់ ដែលបានសម្រេចក្នុងរវាង៧ថ្ងៃយ៉ាងនេះ ។ កាលដែលបានសម្រេច



ផលជាសេដ្ឋីហើយ ក៏រមែងបានទទួលអារម្មណ៍ល្អៗ គឺឃើញរូបល្អ ឮសំឡេងល្អ ធុំក្លិនល្អ ដឹងរសល្អ និងប៉ះពាល់នូវផោដ្ឋព្វៈសុទ្ធតែល្អៗ ទាំងអស់នេះសុទ្ធតែជាកុសលវិបាក ឯចំណែករូបវិញ មានមុខមាត់ស្អាតបាតស្រស់បស់ និងរូបរាងកាយសមសួនពេញលេញ ដែលជាកម្មជរូបកើតអំពីកុសលកម្មនោះឯង ។ ទាំងវិបាកទាំងកម្មជរូប សុទ្ធតែជាអហេតុកៈទាំងអស់ ដូច្នេះ ទិដ្ឋធម្មវេទនីយកម្ម គឺជាកម្មដែលឱ្យផលប្រាកដ ក្នុងចំណែកអហេតុកធម៌តែប៉ុណ្ណោះ។

បើបរិបក្កទិដ្ឋធម្មវេទនីយកម្មក្នុងចំណែកជាអកុសលវិញនោះ ដូចជា នន្ទមាណពដែលត្រូវផែនដីស្រូប ព្រោះការប្រទូស្តនឹងព្រះនាងឧប្បលវណ្ណាថេរី និងដូចជានាយគោឃាតកៈម្នាក់ ដែលមានអាជីពជាអ្នកសម្លាប់គោ ថ្ងៃមួយនោះមានការខ្វះខាតម្ហូបក្នុងផ្ទះ ទើបកាន់កាំបិតទៅក្រោលគោ ហើយកាត់យកនូវអណ្តាតគោដែលមានជីវិតកំពុងរស់នៅ យកទៅឱ្យភរិយាចម្អិន កាលដែលភរិយាចម្អិនរួចស្រេចហើយក៏ចាប់យកមកបរិភោគ ក្នុងខណៈដែលកំពុងតែបរិភោគនោះ អណ្តាតរបស់គាត់ក៏បានដាច់ធ្លាក់ចុះមកនឹងចានបាយជាមួយនឹងឈាមស្រស់ៗរបស់គាត់ ហើយគាត់ស្រែកដោយការឈឺចាប់ មានសំឡេងដូចជា សំឡេងគោ រួចហើយគាត់ក៏បានស្លាប់ទៅ ។ ក្នុងពេលដែលនាយគោឃាតកៈបាន

ទទួលនូវការឈឺចាប់នោះ ទុក្ខសហគតកាយវិញ្ញាណចិត្ត និងចក្ខុ-វិញ្ញាណ សោតវិញ្ញាណជាដើម សុទ្ធតែជាអកុសលវិបាកកើតឡើង ព្រមដោយកម្មជ្ជរូប និងកម្មប្បច្ចយឧតុជ្ជរូប (បាបកម្មជានាមធម៌ តែមានអំណាចអាចធ្វើឱ្យផែនដីរហែកបាក់ស្រុត ឬអាចធ្វើឱ្យពិការនូវអវយវៈរហូតដល់ដាច់អណ្តាតបាន តាមតែកម្លាំងនៃអំពើបាបអកុសលនោះៗ) ។

ព្រះទេវទត្ត ដែលត្រូវផែនដីស្រូប ព្រោះញ៉ាំងនូវលោហិតព្រះសម្មាសម្ពុទ្ធឱ្យពុរពងដោយចិត្តប្រទូសរ៉ាយ ព្រមទាំងបានធ្វើនូវសង្ឃភេទកកម្មទៀតផង ។ ព្រះបាទសុប្បពុទ្ធដែលជាព្រះបិតារបស់ទេវទត្តនិងព្រះនាងពិម្ពា ត្រូវបានផែនដីស្រូប ព្រោះការមិនគោរពព្រះសម្មាសម្ពុទ្ធដោយប្រការផ្សេងៗ និងនៅមានបុគ្គលដទៃច្រើនទៀត ដែលត្រូវទទួលផលបាបបែបនេះ ទាំងអស់នេះគឺសុទ្ធតែជាបរិបក្កទិដ្ឋធម្មវេទនីយកម្មទាំងអស់ ។

២.កម្មដែលនឹងឱ្យបានទទួលផល ក្នុងបច្ចុប្បន្នភពនេះ មិនមាននូវសភាពចាស់ក្លានោះ ដោយសេចក្តីថា ការធ្វើនូវកុសលកម្ម ឬ អកុសលកម្មហ្នឹងឯង នឹងញ៉ាំងផលឱ្យកើតប្រាកដ ក្រោយចាកអំពី៧ថ្ងៃទៅ ។

រួមសេចក្តីមក ទិដ្ឋធម្មវេទនីយកម្មនេះ ជាកម្មដែលឱ្យបាន





ទទួលផលក្នុងបច្ចុប្បន្នភពប៉ុណ្ណោះ មិនឱ្យផលឆ្លងភព ឆ្លងជាតិឡើយ គឺបុគ្គលណាធ្វើនូវកុសលកម្ម ឬអកុសលកម្មក្នុងបឋមវ័យ កម្មនេះរមែងបង្កើតផលឱ្យដល់បុគ្គលអ្នកធ្វើនោះ បានទទួលក្នុងបឋមវ័យ ឬមជ្ឈិមវ័យ ឬក្នុងបច្ឆិមវ័យ បុគ្គលណាធ្វើនូវកុសលកម្ម ឬ អកុសលកម្មក្នុងមជ្ឈិមវ័យ កម្មនេះរមែងបង្កើតផលឱ្យបុគ្គលអ្នកធ្វើនោះ បានទទួលក្នុងមជ្ឈិមវ័យ ឬក្នុងបច្ឆិមវ័យ បុគ្គលណាធ្វើនូវកុសលកម្ម ឬអកុសលកម្មក្នុងបច្ឆិមវ័យ កម្មនេះរមែងបង្កើតផលឱ្យបុគ្គលអ្នកធ្វើនោះ បានទទួលក្នុងបច្ឆិមវ័យ ទាំងអស់នេះ គឺសុទ្ធតែជាទិដ្ឋធម្មវេទនីយកម្ម ។

ដោយច្រើនមនុស្សយើងតែងយល់ថា ផលដែលបានទទួលអំពីទិដ្ឋធម្មវេទនីយកម្ម ជាផលដែលមានទម្ងន់ធ្ងន់ ព្រោះអាចបានជាសេដ្ឋីក្នុងរវាង៧ថ្ងៃ ឬព្រោះត្រូវផែនដីស្រូបជាដើម ប៉ុន្តែ បើធ្វើការប្រៀបធៀបជាមួយនឹងផលរបស់ឧបបជ្ជវេទនីយកម្ម ផលរបស់ឧបបជ្ជវេទនីយកម្មរមែងធ្ងន់ជាង ព្រោះផលដែលបានទទួលអំពីទិដ្ឋធម្មវេទនីយកម្មនោះ គ្រាន់តែជាផលដែលទាក់ទងនឹងការរស់នៅមួយជីវិតតែប៉ុណ្ណោះ កាលបើអស់ជីវិតហើយ ផលនោះក៏ត្រូវអស់ដែរ ព្រមជាមួយនឹងទិដ្ឋធម្មវេទនីយកម្មហ្នឹងឯង ចំណែកផលដែលត្រូវបានទទួលអំពីឧបបជ្ជវេទនីយកម្មវិញ គឺកាលបើ

បុគ្គលនោះអស់ជីវិតទៅហើយ អំណាចនៃកម្មនេះ រមែងដូរផ្លាស់នូវជីវិត ប្រែសភាពនៃបុគ្គលនោះឱ្យបានទទួលផលដ៏ក្រៃលែងទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ពោលគឺ បើជាចំណែកអកុសលកម្ម បុគ្គលនោះត្រូវទៅកើតជាសត្វក្នុងអបាយភូមិ មាននរកជាដើម និងបានទទួលនូវសេចក្ដីទុក្ខវេទនាយ៉ាងខ្លាំងក្លា អស់កាលដ៏យូរអង្វែង តែបើជាកុសលកម្មវិញ ក៏បានទៅកើតក្នុងសុគតិភពមានទេវតាជាដើម ហើយក៏បានទទួលនូវសេចក្ដីសុខ-កាយសប្បាយចិត្តក្នុងភពនោះៗ រហូតដល់អស់ជីវិត ។

ទិដ្ឋធម្មវេទនីយកម្ម មានកម្លាំងខ្សោយអាចឱ្យផលបានតែក្នុងបច្ចុប្បន្នភពប៉ុណ្ណោះ បើមិនមាននូវឱកាសឱ្យផលក្នុងបច្ចុប្បន្ន-ភពទេ កម្មនេះក៏ទៅជាអហោសិកម្ម ពោលគឺកម្មដែលបានធ្វើហើយ តែមិនបានញ៉ាំងផលឱ្យកើតឡើង ។

ទិដ្ឋធម្មវេទនីយកម្ម ដែលអាចញ៉ាំងផលឱ្យកើតប្រាកដបាននោះ ត្រូវនៅក្នុងលក្ខណៈ៤យ៉ាងណាមួយ គឺ ÷

**១-បដិបក្ខេហិ អនភិភូតតាយ** មិនមានការបៀតបៀនអំពីកម្មដែលជាបដិបក្ខ ដោយសេចក្ដីថា បើជាកុសលទិដ្ឋធម្មវេទ-នីយកម្ម ក៏មិនមានការបៀតបៀនអំពីអកុសលកម្ម និងបើជាអកុ-សលទិដ្ឋធម្មវេទនីយកម្ម ក៏មិនមានការបៀតបៀនអំពីកុសលកម្ម





ដូច្នេះហើយ ទើបកម្មនោះនឹងឱ្យផលប្រាកដ តែបើត្រូវកម្មបដិបក្ខបៀតបៀនវិញ កម្មនោះមិនអាចឱ្យផលបាន ក៏ទៅជាអហោសិ-កម្ម ។

**២-បច្ចយវិសេសេន បដិលទ្ធវិសេសតាយ** បានសម្រេចនូវកម្លាំងពិសេស ព្រោះមានការជួយឧបត្ថម្ភ អំពីបច្ច័យដ៏ពិសេស ដោយសេចក្ដីថា បើជាកុសលទិដ្ឋធម្មវេទនីយកម្ម ក៏ត្រូវប្រកបដោយសម្បត្តិ៤យ៉ាង (ណាមួយ ) គឺគតិសម្បត្តិ១ កាលសម្បត្តិ១ ឧបធិសម្បត្តិ១ បយោគសម្បត្តិ១ និងបើជាអកុសលទិដ្ឋធម្មវេទ-នីយកម្ម ក៏ត្រូវប្រកបដោយវិបត្តិ៤យ៉ាង (ណាមួយ ) គឺគតិវិបត្តិ១ កាលវិបត្តិ១ ឧបធិវិបត្តិ១ បយោគវិបត្តិ១ ដូច្នេះហើយ កម្មនោះទើបនឹងឱ្យផលប្រាកដ តែបើប្រកបដោយហេតុផ្ទុយគ្នា ពោលគឺកម្មជាកុសលប្រកបដោយវិបត្តិ (ទាំង )៤យ៉ាង ឬកម្មជាអកុសលប្រកបដោយសម្បត្តិ (ទាំង )៤យ៉ាង ដូច្នេះហើយកម្មនោះក៏មិនអាចឱ្យផលបាន ក៏ទៅជាអហោសិកម្ម ។ សម្បត្តិ៤យ៉ាង និងវិបត្តិ៤យ៉ាង មានដូចតទៅ ÷

(១)-គតិសម្បត្តិ បានដល់បុគ្គលដែលកើតនៅក្នុងសុគតិភូមិគឺមនុស្ស ទេវតា និងព្រហ្ម ឯចំណែក គតិវិបត្តិ បានដល់សត្វដែលកើតក្នុងអបាយភូមិ៤ មានសត្វតិរច្ឆានជាដើម ។

(២)-កាលសម្បត្តិ បានដល់ សម័យកាលដែលអ្នកគ្រប់គ្រងប្រទេសប្រកបដោយធម៌ មាននូវសម្មាទិដ្ឋិ និងនៅមានព្រះពុទ្ធ-សាសនា (ឬនៅមានធម៌របស់សប្បុរស ) ឯចំណែក កាលវិបត្តិ បានដល់ សម័យកាលដែលអ្នកគ្រប់គ្រងប្រទេសមិនប្រកបដោយធម៌ មាននូវមិច្ឆាទិដ្ឋិ ទាំងព្រះពុទ្ធសាសនាក៏ដល់នូវការសាបសូន្យ (មិនមានធម៌សប្បុរសនៅក្នុងសម័យកាលនោះឡើយ ) ។

(៣ )-ឧបធិសម្បត្តិ បានដល់ បុគ្គលដែលកើតមកហើយមាននូវអវយវៈគ្រប់គ្រាន់ រូបរាងស្អាតល្អ មិនមានខ្វះខាតត្រង់ណា ពោលគឺ មិនពិការថែមទាំងស្អាតទៀតផង ឯចំណែក ឧបធិវិបត្តិ បានដល់បុគ្គលដែលកើតមកហើយ រូបរាងមិនល្អស្អាត មានអវយវៈខ្វះខាត មិនគ្រប់លក្ខណៈនៃរូបកាយ ។

( ៤ )-បយោគសម្បត្តិ បានដល់ បុគ្គលដែលមានព្យាយាមត្រូវ គឺ មានការគិតត្រូវ និងមានការប្រព្រឹត្តបានត្រឹមត្រូវតាមច្បាប់ប្រទេស តាមច្បាប់ព្រះពុទ្ធសាសនា (មានការប្រព្រឹត្តខ្លះជាអំពើខុសច្បាប់ ទុច្ចរិតដោយប្រការផ្សេងៗ ប៉ុន្តែជាការប្រព្រឹត្តសមប្រកបតាមកាលៈទេសៈ ទើបបានសម្បត្តិជាលាភយសក្នុងបច្ចុប្បន្ន ឯចំណែកបាបកម្មនឹងជាកម្មប្បច្ច័យឱ្យផលទៅតាមគ្រាជាអនាគត ) បយោគវិបត្តិ បានដល់ការប្រព្រឹត្តខុសទំនង មិនសមប្រកបនឹង





កាលៈទេសៈ និងការប្រព្រឹត្តមិនល្អផ្សេងៗដែលផ្ទុយអំពីបយោគ-សម្បត្តិ (ដែលជាហេតុនាំឱ្យបុណ្យមិនមានឱកាសឱ្យផល ) ។

**៣-តាទិសស្ស បុញ្ញាភិសង្ខារស្ស វសេន សាតិសយា** មាននូវកម្លាំងដ៏ខ្លាំងក្លាដោយអំណាចនៃបុញ្ញាភិសង្ខារ ដែលជាសភាពដ៏សមគួរដល់ជវនៈដួងទី១ ដោយសេចក្តីថា មុននឹងធ្វើនូវកុសលកម្ម ឬអកុសលកម្ម មានការតាំងចិត្តមុតមាំនិងអត់ធន់ដល់ការងារនោះៗ មានការគិតថា បុគ្គលដែលមានការពេញចិត្ត (ឆន្ទៈ)នឹងធ្វើនូវការងារណាៗហើយ ការងារនោះៗរមែងសម្រេច ឬមានព្យាយាម (វីរិយៈ )ធ្វើការងារណាៗហើយ ការងារនោះៗរមែងសម្រេច ឬមានការយកចិត្តទុកដាក់ (ចិត្តៈ ) នឹងការងារណាៗហើយ ការងារនោះៗរមែងសម្រេច (បើចំពោះកុសលកម្ម ) មានបញ្ញាក្នុងកិច្ចការងារណាៗហើយ កិច្ចការងារនោះៗរមែងសម្រេច (ឥទ្ធិបាទធម៌៤គឺ ឆន្ទៈ វីរិយៈ ចិត្តៈ វីមំសា នាំឱ្យការងារជាកុសលបានសម្រេចនូវប្រយោជន៍សមតាមបំណង ) កាលបើមានការគិតដូច្នេះហើយ ចិត្តដែលកើតឡើងក្នុងខណៈដែលធ្វើការងារនោះៗ រមែងមានកម្លាំងខ្លាំងក្លា ដូច្នេះចេតនាក្នុងជវនៈដួងទី១ ដែលជាទិដ្ឋធម្មវេទនីយកម្ម ទើបឱ្យផលប្រាកដក្នុងភពនេះបាន បើមិនប្រកបដោយបុញ្ញាភិសង្ខារ (កម្លាំងខ្លាំងក្លានៃឆន្ទៈជា-

ដើមមុននឹងធ្វើនូវការងារ ) នោះទេ កម្មនោះរមែងមិនមាននូវកម្លាំងល្មមដែលនឹងឱ្យផលប្រាកដក្នុងភពនេះបានឡើយ ក៏ទៅជាអហោសិកម្ម ។

**៤-គុណវិសេសយុត្តេសុ ឧបការាបការវសប្បវត្តិយា** បានដល់ជវនៈដែលកើតឡើងនោះឯង ប្រព្រឹត្តទៅដោយអំណាចនៃការធ្វើដែលជាគុណ ឬដែលជាទោស ទៅលើបុគ្គលដែលប្រកបដោយគុណវិសេស មានព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរហន្ត និងព្រះអនាគាមី ជាដើម ដោយសេចក្តីថា បើជាកុសលកម្មក៏ដូចមហាទុគ្គតបុរស ដែលបានថ្វាយទានដល់ព្រះកស្សបសម្មាសម្ពុទ្ធជាម្ចាស់ បើជាអកុសលក៏ដូចជានន្ទមាណព ដែលបានប្រទូសរ៉ាយនឹងព្រះនាងឧប្បលវណ្ណាថេរី ដូច្នេះហើយ កម្មនោះឯងក៏ញ៉ាំងផលឱ្យកើតប្រាកដក្នុងបច្ចុប្បន្នទាន់ភ្នែក បើកម្មទាំងអស់នេះ មិនបានធ្វើចំពោះបុគ្គលដែលប្រកបដោយគុណវិសេស ដូចបានពោលហើយនោះទេ ក៏មិនបានញ៉ាំងផលឱ្យប្រាកដក្នុងភពនេះ ដោយច្រើនក៏ជាអហោសិកម្ម ប៉ុន្តែ ដូចនាយគោឃាតកៈ សូម្បីមិនបានធ្វើនូវអកុសលកម្មចំពោះបុគ្គល ដែលប្រកបដោយគុណវិសេសក៏ដោយ ក៏អកុសលកម្មនោះនៅតែឱ្យផលប្រាកដក្នុងបច្ចុប្បន្ន ព្រោះបាណាតិបាត គឺការសម្លាប់គោដែលប្រព្រឹត្តទៅជាប្រចាំរាល់ថ្ងៃ



នោះ បានចូលជួយឧបត្ថម្ភដល់ទិដ្ឋធម្មវេទនីយកម្ម (អំពើដែលគាត់បានកាត់អណ្តាតគោទាំងរស់ )ធ្វើឱ្យអណ្តាតរបស់គាត់ដាច់ធ្លាក់ចុះមក ក្នុងខណៈដែលកំពុងតែបរិភោគអាហារនោះឯង (ចំពោះកុសលកម្មក៏ដូចគ្នា ការធ្វើហើយធ្វើទៀត សន្សំរឿយៗរាល់ថ្ងៃ ក៏ជាបច្ច័យឧបការៈឱ្យដល់កុសលឯណានីមួយមានកម្លាំង ញ៉ាំងផលក្នុងបច្ចុប្បន្នជាតិឱ្យកើតឡើង គ្រាន់តែមិនប្រាកដជាក់ស្តែងដូចធ្វើជាមួយនឹងព្រះអរហន្ត ដែលទើបតែចេញអំពីនិរោធសមាបត្តិមកប៉ុណ្ណោះ ) ។

ចំពោះទានកុសល ដែលនឹងញ៉ាំងផលឱ្យសម្រេចបានក្នុងបច្ចុប្បន្នទាន់ភ្នែក (ជាផលធំដុំឃើញច្បាស់ៗ ) ត្រូវប្រកបដោយអង្គ៤ គឺ ÷

(១)-វត្ថុសម្បទា បដិគ្គាហក គឺអ្នកទទួលនូវទេយ្យវត្ថុនោះជាព្រះអរហន្ត ឬ ព្រះអនាគាមី ។

(២)-បច្ចយសម្បទា ទេយ្យវត្ថុដែលនាំយកមកថ្វាយនោះ ជាវត្ថុដែលបានមកដោយអំពើស្អាតស្អំ ។

(៣)-ចេតនាសម្បទា អ្នកថ្វាយទានដល់ព្រមដោយចេតនាដ៏ខ្លាំងក្លាគ្រប់កាលទាំង៣ ប្រកបដោយបញ្ញានិងសោមនស្ស ។

(៤)-គុណាតិរេកសម្បទា ព្រះអនាគាមី ឬ ព្រះអរហន្តដែល

ជាបដិគ្គាហកនោះ ដល់ព្រមដោយគុណវិសេស ពោលគឺទើបតែចេញចាកអំពីនិរោធសមាបត្តិ ។

**បាកកាលទី២_ឧបបជ្ជវេទនីយកម្ម** ភពដែលបានចូលដល់ជាប់តគ្នា មិនមានរវាងចន្លោះ ដែលជិតជាទីបំផុតនឹងភពបច្ចុប្បន្ន ដូច្នោះ ភពនោះឈ្មោះថា **ឧបបជ្ជ** បានដល់ភពទី២ ។ ផលដែលបានទទួលក្នុងភពទី២ ឈ្មោះថា **ឧបបជ្ជវេទនីយ** ។

ឧបបជ្ជវេទនីយកម្ម បានដល់កម្មដែលឱ្យសោយផល នៅពេលដែលចូលទៅកាន់ភពទី២ ដែលជិតនឹងបច្ចុប្បន្នភព គឺជាចេតនាដែលនៅក្នុងអកុសលជវនៈ និងមហាកុសលជវនៈដួងទី៧។

បញ្ចានន្តរិយកម្ម និងនិយតមិច្ឆាទិដ្ឋិកម្ម គឺជាឧបបជ្ជវេទនីយកម្ម នៅក្នុងគម្ពីរសារត្ថសង្គហៈ ក៏បានសម្តែងអំពីមហគ្គតកុសលកម្ម ថាជាឧបបជ្ជវេទនីយកម្មផងដែរ ។

ក្នុងអង្គុត្តរនិកាយអដ្ឋកថា សម្តែងថា កម្មទាំង៣ គឺទិដ្ឋធម្មវេទនីយកម្ម ឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្ម រមែងមាននាទីក្នុងការឱ្យផលដោយចំពោះតាមឋានៈរបស់ខ្លួន មិនមានការផ្លាស់ប្តូរទៅជាយ៉ាងដទៃ ដោយសេចក្តីថា ទិដ្ឋធម្មវេទនីយកម្ម ក៏ត្រូវទៅជាអហោសិកម្ម មិនមានការផ្លាស់ប្តូរតួនាទី ឆ្លងទៅឱ្យផលក្នុងភពទី២ទៀតឡើយ ឧបបជ្ជវេទនីយកម្មក៏មានតួនាទីឱ្យផល





ត្រឹមតែក្នុងភពទី២ប៉ុណ្ណោះ បើមិនមានឱកាសឱ្យផលក្នុងភពទី២នោះទេ ក៏ជាអហោសិកម្ម គឺមិនមានការផ្លាស់ប្តូរតួនាទី ឆ្លងទៅឱ្យផលក្នុងភពទី៣ជាដើមបានទៀតឡើយ និងអបរាបរិយវេទនីយកម្មរមែងមានតួនាទីឱ្យផលតាំងតែពីភពទី៣ទៅ រហូតដល់ចូលព្រះនិព្វាន ប៉ុន្តែបើបុគ្គលនោះចូលព្រះនិព្វាន មុនអបរាបរិយវេទនីយកម្មឱ្យផល អបរាបរិយវេទនីយកម្មក៏ជាអហោសិកម្មទៅដូចគ្នាដែរ ដូចមានបាលីសម្តែងថា **«ទិដ្ឋធម្មវេទនីយំ ឧបបជ្ជវេទនីយំ អបរាបរិយវេទនីយន្តិ តេសំ សង្កមនំ នត្ថិ យថាឋានេយេវ តិដ្ឋន្តិ** » ប្រែថា «ការផ្លាស់ប្តូរកន្លែងក្នុងការឱ្យផលនៃកម្មទាំង៣ គឺទិដ្ឋធម្មវេទនីយកម្ម ឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្ម គឺមិនមានឡើយ រមែងតាំងនៅក្នុងឋានៈរបស់ខ្លួនតែប៉ុណ្ណោះ » ។

**បាកកាលទី៣_អបរាបរិយវេទនីយកម្ម** ភពដទៃៗ ឈ្មោះថា អបរាបរ (អបរ + អបរ ) ភពដទៃៗនោះឯង មានឈ្មោះថា អបរាបរិយ (ក្នុងទីនេះ **ឥយ**បច្ច័យ មិនមានសម្តែងសេចក្តីដោយចំពោះឡើយ ) កម្មដែលគប្បីឱ្យបានសោយនូវផលក្នុងភពដទៃៗ ឈ្មោះថា អបរាបរិយវេទនីយកម្ម ។

អបរាបរិយវេទនីយកម្ម ពាក្យនេះ មាននៅក្នុង អភិធម្មត្ថ-

សង្គហៈ ប៉ុន្តែនៅក្នុងព្រះអភិធម្មបាលីក្តី នៅក្នុងវិសុទ្ធិមគ្គមហា-ដីកាក្តី និងនៅក្នុងអង្គុត្តរនិកាយដីកាក្តី បានសម្តែងហៅកម្មនេះថា **អបរបរិយាយវេទនីយកម្ម** ។

**អបរ** សំដៅដល់ភពដទៃក្រៅអំពីទិដ្ឋធម្មភព គឺភពនេះ និងឧបបជ្ជភព គឺភពខាងមុខដែលជាភពទី២ ដូច្នេះអបរភព បានដល់ភពចាប់អំពីភពទី៣តទៅ **បរិយាយ** សំដៅដល់ភពតៗទៅរួមគ្នាហើយគឺ **អបរបរិយាយវេទនីយកម្ម** បានដល់កម្មដែលឱ្យផលក្នុងភពតៗទៅ ចាប់តាំងអំពីភពទី៣ជាដើមទៅ ។

កាលបើពោលដល់កម្ម ដែលឱ្យផលទៅក្នុងអបរបរិយាយ-ភពហើយ កម្មនេះឈ្មោះថាអបរបរិយាយវេទនីយកម្ម កម្មនេះឯងបានដល់ ចេតនាដែលនៅក្នុងជវនៈត្រង់កណ្តាល៥ដួង (៥ខណៈ) គឺចាប់តាំងអំពីជវនៈដួងទី២ដល់ដួងទី៦ ។ អបរបរិយាយ ឬអបរា-បរិយវេទនីយកម្មនេះ កាលបើមានឱកាសឱ្យផលហើយ រមែងឱ្យផលជារឿយៗទៅ មិនជាអហោសិកម្មឡើយ រហូតទាល់តែចូលកាន់ព្រះនិព្វាន ទើបជាអហោសិកម្មលែងឱ្យផល ព្រះអដ្ឋកថាចារ្យសម្តែងទុកក្នុងអង្គុត្តរនិកាយអដ្ឋកថា និងមជ្ឈិមនិកាយ មជ្ឈិម-បណ្ណាសកអដ្ឋកថា ថា «**ឧភិន្នំ អន្តរេ បន បញ្ចជវនចេតនា អបរបរិយាយវេទនីយកម្មំ នាម តំ អនាគតេ យទា**





**ឱកាសំ លភតិ តទា វិបាកំ ទេតិ សតិ សំសារប្បវត្តិយា អហោសិកម្មំ នាម ន ហោតិ**» ប្រែថា « ជវនចេតនា៥ដួងដែលតាំងនៅក្នុងកណ្តាលនៃជវនៈដួងទី១និងជវនៈដួងទី៧ ឈ្មោះថា អបរបរិយាយវេទនីយកម្ម កម្មបែបនេះ ដល់ពេលណាបានឱកាសក្នុងអនាគតហើយ ពេលនោះរមែងឱ្យផល បើសង្សារវដ្តនៅតែមានការប្រព្រឹត្តទៅ កម្មនេះនឹងបានឈ្មោះថា អហោសិកម្មនោះ រមែងមិនមានឡើយ » ។

ការបង្កើតផលនៃអបរាបរិយវេទនីយកម្ម គឺបង្កើតបានទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ប៉ុន្តែមានបញ្ហាថា ចេតនាដែលឈ្មោះថា អបរាបរិយវេទនីយកម្មនេះ នៅក្នុងវិថីចិត្តនីមួយៗមាន៥ខណៈ កាលបើដូច្នេះ ការឱ្យផលបដិសន្ធិ តើឱ្យបដិសន្ធិ៥ដង ពោលគឺឱ្យកើត៥ជាតិឬ ?

ចម្លើយក្នុងបញ្ហានេះ គឺមិនមែនឱ្យកើត៥ជាតិឡើយ ដោយសេចក្តីថា ចេតនាក្នុងជវនៈទាំង៥ខណៈនេះ <u>បើមានឱកាស</u> ឱ្យផលក្នុងបដិសន្ធិកាល គឺរមែងឱ្យកើតបានត្រឹមតែមួយជាតិប៉ុណ្ណោះ តែការឱ្យផលក្នុងបវត្តិកាលវិញនោះ មិនកំណត់ឡើយ គឺអាចឱ្យផលបានច្រើនភពច្រើនជាតិ បើមានឱកាសដ៏សមគួរនោះ ។

ការបង្កើតផលក្នុងបដិសន្ធិកាលរបស់អបរាបរិយវេទនីយ-

កម្ម ដែលបានពោលថា បើមានឱកាស រមែងឱ្យបដិសន្ធិបាន មួយជាតិនោះ ក្នុងការដែលប្រើពាក្យថា « បើមានឱកាស » មាន សេចក្ដីអធិប្បាយដូចតទៅ :

អំពើដែលចាត់ថាសម្រេចជាបុណ្យ ឬបាបបាននោះ ត្រូវគ្រប់បរិបូណ៌ដោយជវនៈ៧ខណៈ កាលគ្រប់បរិបូណ៌ដោយជវនៈ៧ខណៈហើយនោះ ក៏ហៅថាជាអំពើមួយ ឬកម្មមួយ និងមានកម្លាំងបង្កើតផលក្នុងបដិសន្ធិកាលបានម្ដង បើវិថីចិត្តកើតឡើង២វិថី ក៏ឱ្យបដិសន្ធិបាន២ដង ឬ២ជាតិ បើវិថីចិត្តកើតឡើងបាន៣វិថីជាដើម ក៏ឱ្យបដិសន្ធិបាន៣ជាតិជាដើមអ៊ីចឹងទៅ ហើយម្យ៉ាងទៀតក្នុងវិថីចិត្តនីមួយៗដែលមានជវនៈ៧ខណៈនោះ ចេតនាដែលមានសិទ្ធិបង្កើតផលក្នុងបដិសន្ធិកាលបាន មានត្រឹមតែ៦ខណៈប៉ុណ្ណោះ បានដល់ចេតនាដែលនៅក្នុងជវនៈខណៈទី៧ ឬដួងទី៧ ឈ្មោះថាឧបបជ្ជវេទនីយកម្ម និងចេតនាដែលនៅក្នុងជវនៈ៥ខណៈកណ្ដាល (ទី២ដល់ទី៦ ) ឈ្មោះថាអបរាបរិយវេទនីយកម្ម ចំណែកចេតនាដែលនៅក្នុងជវនៈខណៈទី១ ឬដួងទី១នោះ មិនមានសិទ្ធិឱ្យផលបដិសន្ធិឡើយ ដូច្នេះ បើឧបបជ្ជវេទនីយកម្មដែលនៅក្នុងវិថីណាមួយ មានឱកាសឱ្យផលក្នុងបដិសន្ធិកាលទៅហើយ អបរាបរិយវេទនីយកម្មដែលនៅក្នុងវិថីជាមួយគ្នានោះ មិនមាន





ឱកាស ឱ្យផលក្នុងបដិសន្ធិកាលបានទៀតឡើយ បានត្រឹមតែឱ្យផលក្នុងបវត្តិកាលប៉ុណ្ណោះ ប៉ុន្តែ បើឧបបជ្ជវេទនីយកម្មដែលនៅក្នុងវិថីនោះៗ មិនមានឱកាសឱ្យផលបដិសន្ធិក្នុងភពទី២ទេ ដោយអបរាបរិយវេទនីយកម្មក្នុងភពមុន (ឬឧបបជ្ជវេទនីយកម្មក្នុងវិថីដទៃ ) ឱ្យផលបដិសន្ធិជំនួសនោះ បើដូច្នេះ អបរាបរិយវេទនីយ-កម្មក្នុងបច្ចុប្បន្នភព ដែលនៅក្នុងវិថីជាមួយគ្នានឹងឧបបជ្ជវេទនីយ-កម្មនោះ ក៏នឹងមានឱកាស ឱ្យផលក្នុងបដិសន្ធិកាល ចាប់តាំងពីភពទី៣ទៅ (ភពណាមួយ ) ព្រោះសិទ្ធិក្នុងការឱ្យផលនោះនៅមាននៅឡើយ ដោយហេតុនេះទើបបានប្រើពាក្យថា« បើមានឱកាស» សមដូចព្រះអដ្ឋកថាចារ្យសម្ដែងទុកក្នុងអដ្ឋសាលិនី អដ្ឋកថា ថា :
**« ឯកាយ ចេតនាយ កម្មេ អាយូហិតេ ឯកា បដិសន្ធិ ហោតិ »** ប្រែថា « កាលណាសាងកម្មដោយចេតនាមួយហើយ (គឺចេតនាដែលមានជវនៈ៧ខណៈ ) បដិសន្ធិម្ដងរមែងកើតឡើងបាន » ។

សេចក្ដីនេះសម្ដែងឱ្យដឹងថា បុគ្គលណាដែលទៅកើតក្នុងអវិចីមហានរក ដោយអំណាចនៃឧបបជ្ជវេទនីយកម្មណាមួយ មានបិតុឃាតជាដើម កាលបើរួចផុតអំពីអវិចីមហានរកនោះហើយ បុគ្គលនោះ ត្រូវកើតក្នុងអវិចីមហានរកទៀត ដោយអំណាចនៃ

អបរាបរិយវេទនីយកម្ម ដែលតាំងនៅក្នុងវិថីជាមួយគ្នានឹងឧបបជ្ជវេទនីយកម្មនោះ រមែងប្រព្រឹត្តទៅមិនបានឡើយ ប៉ុន្តែយ៉ាងណាក៏ដោយ ការធ្វើកម្មអ្វីណាមួយនោះ រមែងមានចេតនា៤ប្រភេទ (ទៅតាមកាល ) គឺ ១.បុព្វចេតនា បានដល់ ចេតនាដែលកើតឡើងមុននឹងធ្វើកម្ម ២.មុញ្ចនចេតនា បានដល់ ចេតនាដែលកើតឡើងក្នុង ខណៈកំពុងធ្វើឱ្យសម្រេច ;៣.អបរចេតនា បានដល់ ចេតនាដែលកើតឡើងក្រោយអំពីបានធ្វើឱ្យសម្រេចហើយភ្លាមៗ និង ៤.អបរាបរចេតនា បានដល់ចេតនាដែលកើតឡើងក្រោយអំពី បានធ្វើឱ្យសម្រេចយូរហើយ ក្នុងបណ្តាចេតនាទាំង៤ប្រភេទនេះ ប្រភេទនីមួយៗ មានសិទ្ធិឱ្យផលក្នុងបដិសន្ធិកាលបាន២យ៉ាង គឺ ឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្ម ដូច្នេះ បើរួម គ្នាទៅ ក្នុងអំពើអ្វីមួយនោះ កម្មដែលមានសិទ្ធិឱ្យផលក្នុងបដិសន្ធិ កាល ត្រូវជា៨ គឺក្នុងបុព្វចេតនាមាន២ ក្នុងមុញ្ចនចេតនាមាន២ ក្នុងអបរចេតនា មាន២ និងក្នុងអបរាបរចេតនាមាន២ នេះជា ការរាប់រួមប្រភេទនៃកម្មក្នុងកាលទាំង៤ មិនបានពោលដល់វិថី ឡើយ។

ក្នុងកម្មទាំង៨យ៉ាងនេះ ជាឧបបជ្ជវេទនីយកម្ម៤ ជាអបរាបរិយវេទនីយកម្ម៤ ដែលជាកម្មអាចឱ្យផលបដិសន្ធិបាន បើ



ឧបបជ្ជវេទនីយកម្មនៅក្នុងប្រភេទណាមួយមានមុញ្ចនចេតនាជា-ដើម មានឱកាសឱ្យបដិសន្ធិហើយ ឧបបជ្ជវេទនីយកម្មនៅក្នុងប្រភេទ៣យ៉ាងទៀត ក្រៅអំពីមុញ្ចនចេតនា មិនមានសិទ្ធិឱ្យផលក្នុងបដិសន្ធិកាលឡើយ បានត្រឹមតែឱ្យផលក្នុងបវត្តិកាលនៅក្នុងភពទី២តែប៉ុណ្ណោះ ឯចំណែកអបរាបរិយវេទនីយកម្ម ដែលនៅក្នុងមុញ្ចនចេតនាមានវិថីជាមួយនឹងឧបបជ្ជវេទនីយកម្មនោះ ក៏អស់សិទ្ធិក្នុងការឱ្យផលបដិសន្ធិដែរ(ព្រោះឧបបជ្ជវេទនីយកម្មក្នុងវិថីជាមួយ បានឱ្យបដិសន្ធិទៅហើយ )គឺបានត្រឹមតែឱ្យផលក្នុងបវត្តិកាលនៅក្នុងភពចាប់ពីភពទី៣ទៅតែប៉ុណ្ណោះ ប៉ុន្តែ ចំពោះអបរាបរិយ-វេទនីយកម្ម នៅក្នុងប្រភេទ៣យ៉ាងទៀតក្រៅអំពីមុញ្ចនចេតនា (ឬក្រៅអំពីវិថីដែលឧបបជ្ជវេទនីយកម្មបានឱ្យផលបដិសន្ធិហើយ ) នោះ រមែងមានសិទ្ធិឱ្យផលក្នុងបដិសន្ធិកាល ចាប់តាំងអំពីភពទី៣ទៅរហូតដល់រលត់ខន្ធបរិនិព្វាន ព្រោះហេតុនោះ កាលបុគ្គលណាបានធ្វើកម្មអ្វីមួយហើយ បើជាកម្មអាក្រក់ ក៏អាចឱ្យបុគ្គលនោះទៅកើតក្នុងអបាយភូមិមាននរកជាដើម ច្រើនជាតិ តែបើជាកម្មល្អវិញ ក៏អាចឱ្យបុគ្គលនោះទៅកើតក្នុងសុគតិភូមិ ជាមនុស្ស ឬជាទេវតា ច្រើនជាតិផងដែរ (ព្រោះថាក្នុងអំពើកម្មអ្វីមួយ មានការសម្លាប់សត្វ ឬការធ្វើទានជាដើម រមែងមានវិថីចិត្តច្រើនវិថី

ជាទីបំផុត ហើយក្នុងមួយវិថីអាចឱ្យបដិសន្ធិបានមួយជាតិ ដូច្នេះ ក្នុងបុព្វចេតនាមានប៉ុន្មានវិថី ក្នុងមុញ្ចនចេតនា អបរចេតនា និង អបរាបរចេតនាមានប៉ុន្មានវិថី រួមទៅក្នុងអំពើអ្វីមួយនោះ វាមាន វិថីចិត្តច្រើនណាស់ ហើយមួយវិថីៗសុទ្ធតែមានអំណាចអាចឱ្យ បដិសន្ធិបានមួយជាតិ ) សមដូចព្រះអដ្ឋកថាចារ្យបានសម្ដែងទុក នៅក្នុងអដ្ឋសាលិនី អដ្ឋកថា ថា « **នានា ចេតនា ហិ កម្មេ អាយូហិតេ នានា ហោតិ បដិសន្ធិ** » ប្រែថា « កាលណា សាងកម្មដោយចេតនាផ្សេងៗហើយ (មានបុព្វចេតនាជាដើម ) បដិសន្ធិក៏រមែងកើតបានផ្សេងៗដែរ ពោលគឺបដិសន្ធិច្រើនដង ច្រើនជាតិច្រើនភពហ្នឹងឯង » ។

ការសម្ដែងដូចពោលមកនេះ គឺជាការសម្ដែងទៅតាម សេចក្ដីវិនិច្ឆ័យ ដែលប្រាកដនៅក្នុងលក្ខណសំយុត្ត ព្រះបាលី និង អដ្ឋកថាផង ចតុត្ថបារាជិកព្រះបាលីនិងអដ្ឋកថាផង វិមតិវិនោទនី-ដីកាផង តាមរឿងដែលបានសម្ដែងថា មានបុរសម្នាក់ប្រកប អាជីពជាអ្នកសម្លាប់គោ កាលបុរសនោះស្លាប់ចាកលោកនេះទៅ ហើយ ក៏បានទៅកើតក្នុងនរក ទទួលនូវសេចក្ដីទុក្ខវេទនា (ទាំង ទុក្ខផ្លូវកាយ ទាំងទោមនស្សផ្លូវចិត្ត ) អស់កាលដ៏យូរ លុះដល់ផុត ចាកនរកហើយ ក៏បានមកកើតជាអដ្ឋិសង្ខលិកប្រេត គឺប្រេតមាន





តែឆ្អឹងនៅនាភ្នំគិជ្ឈកូដ ។ រឿងនេះមានការវិនិច្ឆ័យថា ការដែល បុរសនោះទៅកើតក្នុងនរក គឺដោយអំណាចនៃឧបបជ្ជវេទនីយកម្ម ដែលនៅក្នុងមុញ្ចនចេតនា ចំណែកការដែលបានមកកើតជាប្រេត នោះ គឺដោយអំណាចនៃអបរាបរិយវេទនីយកម្មដែលនៅក្នុងបុព្វ-ចេតនា ឬអបរចេតនា ដូចមានបាលីសម្ដែងទុកនៅក្នុងវិមតិវិនោ-ទនីដីកាថា « **តេន គោឃាតក កម្មក្ខណេ បុព្វចេតនា អបរចេតនា សន្និដ្ឋាបកចេតនាតិ ឯកស្មឹបិ បាណាតិបាតេ ពហូ ចេតនា ហោន្តិ នានា បាណាតិបាតេសុ វត្តព្វមេវ នត្ថិ ។ តត្ថ ឯកាយ ចេតនាយ នរកេ បចិត្វា តទញ្ញ-ចេតនាសុ ឯកាយ អបរាបរិយចេតនាយ ឥមស្មឹ បេតត្តភាវេ និព្វត្តោតិ ទស្សេតិ** » ប្រែថា « ដោយរឿងនេះ សម្ដែងឱ្យដឹងថា ក្នុងខណៈដែលសម្លាប់គោនោះ រមែងមាន ចេតនាកើតឡើង៣យ៉ាងគឺ បុព្វចេតនា អបរចេតនា មុញ្ចនចេតនា សូម្បីក្នុងការសម្លាប់សត្វត្រឹមតែម្ដង (សត្វមួយ ) ក៏មានចេតនា ច្រើនប្រភេទទៅហើយ ដូច្នេះចាំបាច់ពោលទៅថ្វី ចំពោះការ សម្លាប់សត្វច្រើនដង (គឺច្រើនសត្វច្រើនជីវិតនោះ ) ។ ក្នុងបណ្ដា ចេតនាទាំង៣យ៉ាងនោះ បុរសដែលសម្លាប់គោត្រូវទទួលផលក្នុង នរកដោយអាស្រ័យឧបបជ្ជវេទនីយកម្មនៅក្នុងចេតនាប្រភេទណា

មួយ (មានមុញ្ចនចេតនាជាដើម ) រួចពីនរកហើយមកកើតជាប្រេត ក៏ដោយអាស្រ័យអបរាបរិយវេទនីយកម្ម ក្នុងចេតនាដទៃក្រៅអំពីមុញ្ចនចេតនានោះឯង » ។

ដោយច្រើន មនុស្សយើងតែងយល់ថា អបរាបរិយវេទនី-យកម្មនេះ មិនថាប្រភេទណាឡើយ រមែងឱ្យផលដដែលៗច្រើនដង ការដែលយល់ដូច្នេះ ក៏ដោយអាស្រ័យបានដឹងថា អបរាបរិយ-វេទនីយកម្មរមែងឱ្យផលក្នុងបវត្តិកាលតាំងតែពីភពទី៣ជាដើមទៅរហូតដល់ភពចុងក្រោយ (រលត់ខន្ធបរិនិព្វានទើបអស់ផលកម្ម ) តាមសេចក្ដីពិតពុំមែនដូច្នោះឡើយ ព្រោះអបរាបរិយវេទនីយកម្មណាដែលឱ្យផលក្នុងបវត្តិកាលហើយ អបរាបរិយវេទនីយកម្មនោះក៏អស់អំណាច មិនមានការតាមឱ្យផលបានទៀតឡើយ សូម្បីបុគ្គលនោះនៅមិនទាន់ចូលព្រះនិព្វានក៏ដោយ ចំណែកអបរាបរិ-យវេទនីយកម្មណា ដែលនៅមិនទាន់មានឱកាសឱ្យផលក្នុងបវត្តិ-កាលនោះ អបរាបរិយវេទនីយកម្មនោះឯង ទើបមានឱកាសជាប់តាមឱ្យផលទៅបាន រហូតដល់បុគ្គលនោះចូលដល់ព្រះនិព្វាន ។

ក្នុងនិបាតជាតក បានសម្ដែងរឿងទុកមកច្រើនរឿងណាស់ដែលទាក់ទងនឹងការសម្លាប់សត្វ គឺបានសម្ដែងដូច្នេះថា បុគ្គលដែលសម្លាប់សត្វស្លាប់មួយ លុះដល់ស្លាប់ទៅក៏បានកើតក្នុងនរក





(ដោយសារអកុសលកម្មនោះឱ្យផល ) កាលដែលរួចចាកពីនរកបានមកកើតនៅក្នុងកំណើតណាមួយហើយក៏ត្រូវគេសម្លាប់រឿយៗគ្រប់ជាតិ ស្មើនឹងរោមសត្វដែលខ្លួនបានសម្លាប់នោះ នេះគឺដោយអំណាចនៃអបរាបរិយវេទនីយកម្មក្នុងវិថីផ្សេងៗ (ក្នុងការសម្លាប់សត្វមួយមានវិថីចិត្តច្រើនណាស់ តាំងតែពីបុព្វចេតនាជាដើមទៅគឺម៉ឺនសែនវិថី ហើយក្នុងមួយវិថីត្រូវឱ្យមានកម្មពៀរមួយជាតិ )។

ក្នុងអដ្ឋកថា នេមិរាជជាតក បានសម្ដែងទុកថា « **អបរា-បរវេទនីយំ បន វិបាកំ អទត្វា ន នស្សតិ** » ប្រែថា « អបរាបរិយវេទនីយកម្ម រមែងមិនវិនាសសាបសូន្យឡើយ បើនៅមិនទាន់បានឱ្យផល » នេះជាការសម្ដែងឱ្យឃើញថា បើឱ្យផលហើយ ក៏រមែងលែងឱ្យផលទៀត ។

**បាកកាលទី៤_អហោសិកម្ម** អហោសិកម្មនៅក្នុងគម្ពីរបដិសម្ភិទាមគ្គបានសម្ដែងថា « **អហោសិ កម្មំ នាហោសិ កម្មវិបាកោ, អហោសិ កម្មំ នត្ថិ កម្មវិបាកោ, អហោសិ កម្មំ ន ភវិស្សតិ កម្មវិបាកោ** » ប្រែថា « កម្មដែលបានធ្វើហើយ តែផលរបស់កម្មនោះមិនបានកើតឡើងហើយទេ; កម្មដែលបានធ្វើហើយ តែផលរបស់កម្មនោះមិនមែនកំពុងកើតឡើងទេ; កម្មដែលបានធ្វើហើយ តែផលរបស់កម្មនោះនឹងមិនកើតឡើងឡើយ »។

អហោសិកម្មនេះ មិនមានអង្គធម៌ដោយចំពោះខ្លួនឯងអ្វីទាំងអស់ គឺចេតនានៅក្នុងជវនៈខណៈទី១ ដែលឈ្មោះថា ទិដ្ឋ-ធម្មវេទនីយកម្ម ចេតនាដែលនៅក្នុងជវនៈខណៈទី៧ ដែលឈ្មោះថា ឧបបជ្ជវេទនីយកម្ម និងចេតនា៥ខណៈត្រង់កណ្តាល ដែលឈ្មោះថា អបរាបរិយវេទនីយកម្ម ទាំងអស់នេះឯង កាលណាបើហួសពេលវេលារបស់ខ្លួនដែលត្រូវឱ្យផលហើយ ក៏បានឈ្មោះថាជាអហោសិកម្មទៅ ។

ក្នុងចំនួនកម្ម៤យ៉ាង ដែលសម្តែងអំពីវេលាឱ្យផលនោះ (បាកកាលចតុក្កៈ) ចំពោះទិដ្ឋធម្មវេទនីយកម្ម ឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្ម ទាំង៣យ៉ាងនេះ មានការកំណត់ពេលក្នុងការឱ្យផលរៀងៗខ្លួន ចំណែកអហោសិកម្មមិនមានការកំណត់ពេលនឹងឱ្យផលផង តើហេតុអ្វីបានជាចាត់ចូលនៅក្នុងពួកនេះ ?

សេចក្តីនេះឆ្លើយថា របៀបដូចជាការសម្តែងចែកភូមិដែលទាក់ទងនឹងតណ្ហា៣ គឺមិនមែនសម្តែងត្រឹមតែភូមិ៣ (កាមភូមិ រូបភូមិនិងអរូបភូមិ)នោះទេ រមែងសម្តែងអំពីភូមិដែលមិនប្រព្រឹត្តទៅដោយអំណាចតណ្ហា៣ផងទៀត បានដល់លោកុត្តរភូមិហ្នឹងឯង សេចក្តីនេះយ៉ាងណា ការសម្តែងអំពីកម្មដែលឱ្យផលតាមកាលតាមគ្រា ក៏ដូចគ្នាដែរ កាលបើសម្តែងដល់កម្មដែលមានកំណត់





ពេលវេលាក្នុងការឱ្យផលហើយ ក៏នៅមានកម្មដែលមិនមានការឱ្យផលទៀត គឺអហោសិកម្មហ្នឹងឯង ដូច្នេះទើបចាត់អហោសិកម្មចូលក្នុងបាកកាលចតុក្កៈនេះឯងផង ។

☞ បុគ្គលដែលបានឈាន មានបឋមជ្ឈានជាដើម បើឈាននោះមិនវិនាសទេ កាលបើស្លាប់ទៅ រមែងទៅកើតក្នុងព្រហ្មលោក តាមឋានៈនៃឈានដែលខ្លួនបានសម្រេច ក្នុងភពទី២ជាពិតប្រាកដ ដោយមិនមានការរង់ចាំឱ្យផលទៅក្នុងភពទី៣ជាដើមឡើយ ។ មហគ្គតកុសលកម្ម ឱ្យផលដូចគ្នានឹងចេតនាកាមាវចរជវនៈខណៈទី៧ដែរ ដូច្នេះមហគ្គតកុសលកម្មនេះទើបចាត់ចូលក្នុងឧបបជ្ជវេទនីយកម្ម ។

មហគ្គតកុសលកម្ម ផ្សេងគ្នាពីកាមាវចរកម្ម គឺមហគ្គត-កុសលកម្មរមែងឱ្យផលបានតែចំពោះក្នុងភពទី២តែប៉ុណ្ណោះ បើមិនមានឱកាសឱ្យផលក្នុងភពទី២ទេ ក៏ជាអហោសិកម្មដោយពិតឯចំណែកកាមាវចរកម្មវិញ (វៀរលែងតែចេតនាក្នុងជវនៈខណៈទី១ និងទី៧ចេញ) បើមានឱកាសរមែងឱ្យផលបានរឿយៗ មិនជាអហោសិកម្មឡើយ រហូតដល់ចូលព្រះនិព្វាន ។

ចំពោះលោកុត្តរកុសលកម្ម មានសភាពជាទិដ្ឋធម្មវេទនីយ-កម្មដោយពិត ព្រោះកាលបើមគ្គចិត្តកើតឡើងហើយរលត់ទៅ

ផលចិត្តក៏ត្រូវកើតឡើងបន្តភ្លាម ដោយមិនមានចិត្តដទៃកើតជារវាងចន្លោះឡើយ (លោកុត្តរកុសលកម្ម ជាអនន្តរកម្មប្បច្ច័យដល់លោកុត្តរវិបាក ) ប៉ុន្តែ ទិដ្ឋធម្មវេទនីយកម្មដែលសម្តែងនៅក្នុងបាកកាលចតុក្កៈនេះ មិនបានសំដៅយកលោកុត្តរកុសលកម្មផងឡើយ សំដៅយកតែលោកិយកម្មដែលឱ្យផលក្នុងបដិសន្ធិកាល និងបវត្តិកាលតែប៉ុណ្ណោះ ។

**ចប់បាកកាលចតុក្កៈ**

**តុលាភារកម្ម**

| | |
|---|---|
| កំណាញ់រិះប្រិតត្បិតចង់មាន | ធ្វើបាបបំពានឃ្លានចង់ល្អ |
| ប្រព្រឹត្តអាក្រក់ត្បិតខ្លាចក្រ | រស់ឥតសីលធម៌ចិត្តអប្រិយ៍ ។ |
| អ្នកក្រធ្វើចោរលួចព្រោះឃ្លាន | ចុះចោរអ្នកមានលួចព្រោះអ្វី |
| មានពិសដូចពស់រស់នាំភ័យ | ស្លាប់ទៅអវិចីព្រោះតណ្ហា ។ |
| កម្មអ្នកកាត់ក្តីរឿងសត្វលោក | ឥតស៊ីសំណូកឥតមុសា |
| កាត់យុត្តិធម៌តាមហេតុការណ៍ | ប្រព្រឹត្តយ៉ាងណាបានយ៉ាងនោះ។ |
| កុំសាងទុច្ចរិតព្រោះចង់ឆ្អែត | កុំធ្វើជាប្រេតខ្លួនជាមនុស្ស |
| កុំចង់សោយតែឈាមនិងខ្ទុះ | បើពិតជាមនុស្សត្រូវមានសីល ។ |

ដោយឧបាសក **គុយ-សុធន**





# IV - បាកដ្ឋានចតុក្កៈ

<u>កម្មឱ្យផលតាមឋាន</u>

**បាកដ្ឋានទី ១ -អកុសលកម្ម :** បានដល់ចេតនានៅក្នុងអកុសលចិត្ត១២ដួង ។ លោភៈ១ ទោសៈ១ មោហៈ១ ចេតសិកជាតួអកុសលហេតុទាំង៣នេះ ជាហេតុនាំឱ្យប្រព្រឹត្តនូវអកុសលកម្មបថ ១០ ។

**អំពីអកុសលកម្មបថ១០**

<u>អកុសលកម្មបថទី១</u>- ការសម្លាប់សត្វ មានចេតនាជាតួអកុសលកម្មបថ មានលោភៈស្រឡាញ់ជីវិតខ្លួនឯងជាដើមជាឧបនិស្សយប្បច្ច័យ មានទោសៈជាហេតុប្បច្ច័យ មានមោហៈជាសម្បយុត្តប្បច្ច័យ (មោហៈក៏ជាហេតុប្បច្ច័យផងដែរ ) មានជីវិតិន្ទ្រិយជាអារម្មណប្បច្ច័យ និងមានទោមនស្សវេទនាជាសហជាតប្បច្ច័យ ឯចំណែកចេតនាជាតួកម្មបថជាបច្ចយុប្បន្នធម៌ (ធម៌ដែលកើតឡើងអំពីបច្ច័យផ្សេងៗ ច្រើនបច្ច័យដូចដែលបានសម្តែងហើយ )។

ការសម្លាប់សត្វអង្គធម៌ គឺចេតនា បើពោលដោយបរមត្ថធម៌ «អ្នកសម្លាប់សត្វពុំមានឡើយ » នៅក្នុងសេចក្តីនេះ បើយល់ត្រូវរមែងលះបង់បាននូវអត្តទិដ្ឋិ (សេចក្តីប្រកាន់ថាមានខ្លួនជាអ្នក

ធ្វើកម្ម ) តែបើយល់ខុសក្នុងសេចក្តីនេះវិញ រមែងប្រកាន់នូវ អកិរិយទិដ្ឋិ (យល់ខុសថាអត់មានបាប ព្រោះអ្នកធ្វើបាបពុំមាន )។

តាមពិត ចេតនាបាណាតិបាត (ការសម្លាប់សត្វ ) នេះកើតឡើងអំពីបច្ច័យច្រើនណាស់ ក្រៅអំពីបច្ច័យដែលបានពោលរួចហើយនោះ នៅមានសភាវធម៌ច្រើនទៀតដែលសុទ្ធតែអាចជាបច្ច័យបាន ដូចជា អវិជ្ជា តណ្ហា ទិដ្ឋិ ជាដើម សូម្បីអកុសលកម្ម-បថ៩ដទៃទៀត ក៏អាចជាបច្ច័យបានដោយបកតូបនិស្សយប្បច្ច័យផងដែរ។អ្វីណាដែលកើតអំពីបច្ច័យ អ្វីនោះហៅថា សភាវធម៌ ឬហៅថា សង្ខារធម៌ ។ បុគ្គលគួរឃើញដោយបញ្ញាដ៏ប្រពៃតាមពិតថានេះជាធម្មជាតិក្នុងលោក (មានតែសភាវធម៌ប៉ុណ្ណោះ ដែលកើតឡើងក្នុងលោក ឯពាក្យថាសត្វ បុគ្គល ជាពាក្យសន្មតទៅលើសភាវធម៌ហ្នឹងឯង ) ។

ការសម្លាប់គេ មកអំពីចាញ់គេផង ចាញ់ខ្លួនឯងផង ។

អកុសលកម្មបថទី២- ការកាន់យកនូវទ្រព្យសម្បត្តិ ដែលម្ចាស់គេមិនបានឱ្យ (ចោរកម្ម ) មានចេតនាជាតួអកុសលកម្មបថ ជួនកាលមានលោភៈជាហេតុ ជួនកាលមានទោសៈជាហេតុ ចំណែកឯមោហៈតែងមានការប្រកបជាមួយគ្រប់ពេល ។

-ចោរកម្មគឺជាអំពើខ្វះសមត្ថភាពក្នុងការចិញ្ចឹមជីវិត ។

-១១៧-

-មនុស្សមិនមែនមានអាយុវែង ព្រោះហេតុតែទ្រព្យសម្បត្តិឡើយ។

អកុសលកម្មបថទី៣- ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មានចេតនាជាតួអកុសលកម្មបថ មានលោភៈ និងមោហៈជាហេតុនៃការប្រព្រឹត្ត។ សេពគ្រឿងស្រវឹងផ្សេងៗ មានការបរិភោគសុរាជាដើម ចាត់ចូលក្នុងអកុសលកម្មបថទី៣នេះ។

-សោកសៅ ភ័យ អាប់មុខ អាប់យស ... ព្រោះកាម ។

-ការប្រព្រឹត្តខុសក្នុងកាមព្រោះបាត់ស្មារតីគ្មានអ្វីខុសពីសត្វតិរច្ឆាន។

-រឹតតែស៊ីរឹតតែឃ្លាន រឹតតែបានរឹតតែមិនគ្រប់ បានដល់កាមគុណ៥។

អកុសលកម្មបថទី៤- ការនិយាយកុហក មានចេតនាជាតួអកុសលកម្មបថ ជួនកាលកុហកដោយលោភៈ ជួនកាលកុហកដោយទោសៈ ហើយសុទ្ធតែមានមោហៈរាល់ពេលកុហក ។

-កុហកតែម្តង ត្រូវគេសង្ស័យជារៀងរហូត ។

-ពាក្យកុហកដូចលាមកចេញពីមាត់ គួរឱ្យខ្ពើម ។

-ឈើងាប់អណ្តែតទឹក ប្រសើរជាងមនុស្សនិយាយកុហក ។

-និយាយកុហកដើម្បីចិញ្ចឹមជីវិត ជាការបន្ថោកជីវិតខ្លួនឯង ។

អកុសលកម្មបថទី៥- ការនិយាយញុះញង់ មានចេតនាជាតួអកុសលកម្មបថ មានហេតុរបៀបដូចជាការនិយាយកុហកដែរ ។

-និយាយញុះញង់ព្រោះចង់ដឹងថាគេបែកគ្នាឬមិនបែក ។

-និយាយបំបែកអ្នកដទៃដើម្បីបានមកខ្លួនឯងវិញ ។

-១១៨-

-និយាយប្រឌិតស្មានបង្ខូចកេរ្តិ៍ ព្រោះស្អប់និងច្រណែន ។

-និយាយអាក្រក់ពីម្ខាងដើម្បីយកចិត្តម្ខាងទៀត ។

-កាប់មាត់ខ្លួនឯងនឹងពូថៅវិញប្រសើរជាងនិយាយអុជអាល ។

សម្តីអុជអាល   វែងនាំបណ្តាល   ឱ្យកើតវិវាទ
ឬបើពុំនោះ   ក៏ត្រឹមបែកឃ្លាត   ទោះញាតិនិងញាតិ
ក៏អាចបែកគ្នា ។

ខូចការប្រាស្រ័យ   លុះយូរខែថ្ងៃ   រីករាលទៅជា
បែកសាមគ្គី   ដែលព្រះភគវា   ទ្រង់ត្រាស់ប្រាប់ថា
នឹងមានវិនាស ។

សម្តីអុជអាល   ចង្រៃត្រកាល   ទោះបីអ្នកឈ្លាស
អាចក្លាយជាខ្មៅ   មួម៉ៅផ្តេសផ្តាស   មន្ត្រីឬរាស្ត្រ
ដើរទាសខុសផ្លូវ ។

( ស្រង់ចាកវចនានុក្រមសម្តេច ជួនណាត )

<u>អកុសលកម្មបថទី៦</u>- ការនិយាយពាក្យអាក្រក់ ទ្រគោះបោះ-បោក ជេរប្រទេច លើកឡើងនូវពាក្យបញ្ឈឺចិត្ត មានចេតនាជាតួអកុសលកម្មបថ មានទោសៈនិងមោហៈជាហេតុនាំឱ្យនិយាយ ។

-គ្រោះភ័យចូលតាមផ្លូវមាត់ ភ័យវិបត្តិក៏ចេញពីមាត់ ។

-ពាក្យបញ្ឈឺចិត្តដូចកាំបិតមុតឆ្កៀលបេះដូង ។

-អ្នកដែលចូលចិត្តនិយាយរឿងអាក្រក់ពីអ្នកដទៃ ជាមោឃបុរស ។





-ចូលចិត្តនិយាយអាក្រក់ពីគេព្រោះចង់លើកតម្កើងខ្លួនឯង ។

-ពាក្យអាក្រក់ ពាក្យជេរ ជាពាក្យរបស់អសប្បុរស ។

-ពាក្យសម្តីជាការងារដ៏ធំ មនុស្សល្ងង់មិនចេះប្រយ័ត្នសម្តីឡើយ ។

<u>អកុសលកម្មបថទី៧</u>- ការនិយាយពាក្យឥតប្រយោជន៍ មានចេតនាជាតួអកុសលកម្មបថ ជួនកាលនិយាយដោយលោភៈ ជួនកាលនិយាយដោយទោសៈ រាល់ពេលនិយាយពាក្យឥតបានការដែលធ្វើឱ្យអ្នកស្តាប់ខូចពេល ខាតប្រយោជន៍ សុទ្ធតែមានមោហៈនាំឱ្យនិយាយទាំងអស់ ។

-និយាយតិចតែបានការ ប្រសើរជាងនិយាយច្រើនឥតប្រយោជន៍។

-វាចាបញ្ឆោក់ពីគំនិត មិនរក្សាចិត្ត សម្តីរាយមាយ ។

-គុណធម៌មិននៅនឹងអណ្តាតទេ គឺឋិតនៅតែក្នុងចិត្តប៉ុណ្ណោះ ។

-សម្តីឡេះឡោះឥតសព្ទឥតសារ ជាការបំផ្លាញពេលវេលា ។

-មិនមែនបណ្ឌិតព្រោះហេតុតែនិយាយច្រើនទេ ។

-និយាយចុះនិយាយឡើងមិនផុតពីអួតខ្លួនឯង ។

-ប៉ោតអត់ទឹក នៅពេលគេរែកច្រើនតែឮ រ៉ូងរ៉ាង ។

<u>អកុសលកម្មបថទី៨</u>- សម្លឹងចង់បានទ្រព្យអ្នកដទៃ ដោយគំនិតខូច មានលោភចេតសិកជាតួអកុសលកម្មបថ មានចេតនាប្រកបជាមួយ ជាតួអភិសង្ខារ (កម្មសម្រាប់ឱ្យផល ) និងមានមោហៈជាហេតុនៃការសម្លឹងរំពៃនោះ ។

## មហាចោរ៥ពួកក្នុងព្រះពុទ្ធសាសនា

## វិន័យបិដកលេខ១ ទំព័រ២៩៣

(២៣០) ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ មានភិក្ខុជាមហាចោរ៥ពួក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមហាចោរ៥ពួកនោះដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីត្រិះរិះរបស់មហាចោរខ្លះដែលមានក្នុងលោកនេះថា បើដល់វេលាណាអញបានបរិសទ្យ១រយ ឬ១ពាន់ចោមរោមជាគ្នាហើយ នឹងលើកចូលទៅក្នុងស្រុកនិគមរាជធានី ហើយនឹងវាយសំពងផ្ដាច់ជីវិតពួកអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យផ្ដាច់ជីវិតដុតរោលអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យដុតរោល ។ លុះដល់សម័យខាងក្រោយមក មហាចោរនោះបានបរិសទ្យ១រយ ឬ១ពាន់ចោមរោមជាគ្នាហើយ ក៏លើកចូលទៅក្នុងស្រុកនិគមរាជធានី វាយសំពងផ្ដាច់ជីវិតអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យផ្ដាច់ជីវិត ដុតរោលអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យដុតរោល យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីត្រិះរិះរបស់ភិក្ខុបាបខ្លះដែលមានក្នុងសាសនានេះ ក៏យ៉ាងនោះដែរ (ត្រិះរិះ) ថាបើដល់កាលណាអញបាននូវបរិសទ្យ



១រយ ឬ១ពាន់ចោមរោមជាគ្នាហើយ នឹងត្រាច់ទៅកាន់ចារិកក្នុងស្រុកនិគមរាជធានី ក៏នឹងបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារដែលពួកគ្រហស្ថក្ដី ពួកបព្វជិតក្ដី ធ្វើសក្ការៈគោរពរាប់អានបូជាកោតក្រែង ។ លុះដល់សម័យខាងក្រោយមក ភិក្ខុបាបនោះបានបរិសទ្យ១រយ ឬ១ពាន់ចោមរោមជាគ្នាហើយក៏ត្រាច់ទៅកាន់ចារិកស្រុកនិគមរាជធានី បានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថក្ដី បព្វជិតក្ដី ធ្វើសក្ការៈគោរពរាប់អានបូជាកោតក្រែង។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មហាចោរទី១ ដែលមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះរៀនសូត្រធម្មវិន័យដែលតថាគតបានសំដែងហើយ ដុតកំដៅខ្លួនឯងចោល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មហាចោរទី២ ដែលមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះមានភិក្ខុបាបខ្លះពោលចោទភិក្ខុដែលប្រព្រឹត្តធម៌ប្រសើរដ៏ស្អាត ដែលកំពុងប្រព្រឹត្តធម៌ប្រសើរដ៏បរិសុទ្ធ ចោទដោយការប្រព្រឹត្តមិនប្រសើរកម្មូលគ្មាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថាមហាចោរទី៣ មានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅ

ទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះសង្គ្រោះផ្គាប់ផ្គុនគ្រហស្ថ ដោយគ្រឿងគរុភណ្ឌរបស់សង្ឃ ឬគ្រឿងគរុបរិក្ខារ គ្រឿងគរុភណ្ឌគឺអ្វីខ្លះ គ្រឿងគរុភណ្ឌនោះគឺ គុម្ពផ្កានិងដើមឈើ១ ទីដែលសំរាប់ដាំគុម្ពផ្កានិងដើមឈើ១ កុដិ១ ទីដែលសំរាប់សង់កុដិ១ គ្រែ១ តាំង១ ពូក១ ខ្នើយ១ ឆ្នាំងលោហៈ១ ស្នូកលោហៈ១ ក្អមលោហៈ១ ផើងលោហៈ១ កាំបិត១ ពូថៅ១ ដឹង១ ចប១ ពន្លាក (ឬដែកកណ្តារ )១ វល្លិប្រវែងមួយលូកឡើងទៅ១ ឫស្សីប្រវែង ៨ធ្នាប់ឡើងទៅ១ ស្មៅដំណេកទន្សាយ១ ស្មៅយាប្លង១ ស្មៅធម្មតា១ ដីស្អិត១ គ្រឿងធ្វើនឹងឈើ១ គ្រឿងធ្វើនឹងដី១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថាមហាចោរទី៤ មានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាពោលអួតឧត្តរិមនុស្សធម៌ដែលមិនមាន មិនប្រាកដក្នុងខ្លួន ភិក្ខុនេះជាមហាចោរទី៥ ជាចោរធំបំផុតក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហេតុអ្វីបានជាតថាគតពោលដូច្នោះ ម្នាលភិក្ខុទាំងឡាយ ពីព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន គឺភិក្ខុនោះឯងលួចយកមកបរិភោគ ។

(ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រាថ្នានឹងធ្វើសេចក្តីនេះឱ្យ





បានច្បាស់លាស់ឡើង ទើបព្រះអង្គទ្រង់ត្រាស់សម្តែងនូវសេចក្តីជាគាថាតទៅទៀត ) :

## និគមគាថារបស់ព្រះសម្មាសម្ពុទ្ធ

**អញ្ញថា សន្តមត្តានំ អញ្ញថា យោ បវេទយេ**
**និកច្ច កិតវស្សេវ ភុត្តំ ថេយ្យេន តស្ស តំ។**

ភិក្ខុណាមានខ្លួនតាំងនៅដោយអាការដទៃ គឺថាខ្លួនមានកាយសមាចារមិនបរិសុទ្ធជាដើម ហើយញុំាងអ្នកដទៃឱ្យដឹងថាខ្លួនតាំងនៅដោយអាការដទៃ គឺថាខ្លួនមានកាយសមាចារជាដើមស្អាតវិញ ភិក្ខុនោះឯងហៅថាលួចភោជនគេមកបរិភោគ ដូចជាព្រានសត្វស្លាប លបលាក់ខ្លួនប្របគុម្ពឈើបម្រុងចាំបាញ់សត្វ ។

**កាសាវកណ្ឋា ពហវោ បាបធម្មា អសញ្ញតា**
**បាបា បាបេហិ កម្មេហិ និរយន្តេ ឧបបជ្ជរេ ។**

ភិក្ខុដែលយកសំពត់កាសាវៈមកព័ទ្ធព័ន្ធក តែប្រព្រឹត្តនូវធម៌អាក្រក់ជាធម្មតា គ្មានសង្រួម (តាមធម៌វិន័យ ) ឡើយ ជាបុគ្គលលាមកក្រៃលែងសឹងមានច្រើន ភិក្ខុនោះទៀងតែទៅនរក ព្រោះអំពើដែលខ្លួនធ្វើអាក្រក់ ។

**សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ**
**យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោតិ។**

បរិភោគដុំដែកដែលកំពុងឆេះក្តៅ ឧបមាដូចជាអណ្តាតភ្លើងវិញប្រសើរជាង ឯភិក្ខុដែលទ្រុស្តសីលមិនសង្រួម (តាមធម៌វិន័យ ) នឹងបរិភោគនូវដុំអាមិសរបស់ជនអ្នកនៅក្នុងដែន (នោះ ) ពុំប្រសើរសោះឡើយ ។

## អដ្ឋកថា មហាចោរ៥ពួកក្នុងព្រះពុទ្ធសាសនា

ពាក្យថា **អយំ ភិក្ខវេ បឋមោ មហាចោរោ** មានសេចក្តីថា ភិក្ខុអាក្រក់លាមក ដែលប្រៀបដូចចោរកាត់ទី-ត (កាត់សោផ្ទះដើម្បីចូលលួច )ជាដើមនេះ គប្បីជ្រាបថា ជាមហាចោរពួកទី១ ព្រោះមិនមែនបោកបញ្ឆោតតែត្រកូលមួយ ឬត្រកូលពីរប៉ុណ្ណោះឡើយ ដោយពិតនៅមានការបោកបញ្ឆោតដល់មហាជន កាន់យកនូវបច្ច័យ៤ទៀតផង ។ ចំណែកពួកភិក្ខុណា ដែលជំនាញនៅក្នុងព្រះសូត្រ ជំនាញនៅក្នុងព្រះអភិធម្ម ឬទ្រទ្រង់នូវព្រះវិន័យ កាលភិក្ខាចារមិនសម្បូណ៌ ក៏ត្រាច់ចារិកទៅតាមជនបទ ប្រាប់បាលី ពោលអដ្ឋកថា ញុំាំងពពួកជនឱ្យជ្រះថ្លាដោយអនុមោទនា ដោយធម្មកថា និងដោយសេចក្តីរៀបរយនៃកិរិយាមារយាទ ពួក



ភិក្ខុទាំងនោះ គេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ហើយ គប្បីជ្រាបថា ជាអ្នកញុំាំងនូវព្រះសាសនាឱ្យរុងរឿង បន្តទុកនូវបែបផែន និងប្រពៃណី ។

បទថា **តថាគតប្បវេទិតំ** ដោយសេចក្តីថា ដែលព្រះ-តថាគតចាក់ធ្លុះហើយ គឺ ធ្វើឱ្យប្រចក្សហើយ ឬញុំាំងអ្នកដទៃឱ្យដឹងហើយ ។

ក្នុងពីរបទដែលថា **អត្តនោ ឧហតិ** មានសេចក្តីថា ភិក្ខុអាក្រក់លាមក ប្រៀបផ្ទឹមបាលីនិងអដ្ឋកថា នៅក្នុងកណ្តាលបរិស័ទ ពោលព្រះសូត្រដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ដោយសំឡេងដ៏ពីរោះ រួចហើយត្រូវវិញ្ញូជនមានសេចក្តីអស្ចារ្យក្នុងចិត្ត ដេញសួរក្នុងទីបំផុតនៃធម្មកថា ថា ឱ !លោកម្ចាស់ដ៏ចម្រើន បាលី និងអដ្ឋកថា បរិសុទ្ធ ព្រះគុណម្ចាស់រៀនមកអំពីសំណាក់នៃបុគ្គលណា ? ដូចនេះ (ភិក្ខុអាក្រក់លាមកនោះក៏ឆ្លើយថា ) អ្នកណាទៅ ដែលមាននូវសមត្ថភាព អាចឱ្យមនុស្សដូចជាយើងនេះរៀនបាន ហើយមិនសម្តែងអាចារ្យ (ដោយពោលលើកតម្កើងខ្លួនថា ) ខ្លួនជាអ្នកប្រកាសធម៌វិន័យដែលចាក់ធ្លុះដោយខ្លួនឯង គឺ ដែលខ្លួនបានចាក់ធ្លុះដោយសយម្ភូញាណ ។ ភិក្ខុអ្នកលួចធម៌ ដែលព្រះ-តថាគតទ្រង់បំពេញបារមីមកអស់៤អសង្ខេយ្យ កម្រៃ១សែនកប្ប

ព្រះអង្គទ្រង់បានត្រាស់ដឹងដោយសែនលំបាក នេះចាត់ជាមហាចោរពួកទី២ ។

ពាក្យថា **សុទ្ធំ ព្រហ្មចារឹ** បានដល់ ភិក្ខុដែលអស់នូវអាសវៈហើយ ។

ពាក្យថា **បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តំ** បានដល់សព្រហ្មចារីដែលប្រព្រឹត្តនូវចរិយាដ៏ប្រសើរ មិនមាននូវឧបក្កិលេស ម្យ៉ាងទៀត បានដល់អ្នកប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ដែលជាទីតាំងនៃការមិនក្តៅក្រហាយជាដើម ចាប់ផ្តើមតាំងតែអំពីព្រះអនាគាមីចុះមកដល់បុថុជ្ជនអ្នកមានសីល ។

ពាក្យថា **អមូលកេន អព្រហ្មចរិយេន អនុទ្ធំសេតិ** មានសេចក្តីថា ភិក្ខុអាក្រក់លាមក រមែងពោលទោស គឺចោទ ដោយអន្តិមវត្ថុ (អាបត្តិបារាជិក )ដែលមិនមាននៅក្នុងបុគ្គលនោះ ។ ភិក្ខុ (អាក្រក់ ) លុបបំបាត់គុណដែលមាន (ក្នុងភិក្ខុបរិសុទ្ធ ) ជាការលួចនូវអរិយគុណ នេះចាត់ជា មហាចោរពួកទី៣ ។

ពាក្យថា **តេហិ គិហី សង្គណ្ហាតិ** មានសេចក្តីថា ឱ្យគរុភណ្ឌ គរុបរិក្ខារ មានអារាមជាដើម (ដោយការ )សង្គ្រោះ គឺអនុគ្រោះពួកគ្រហស្ថ ។

ពាក្យថា **ឧបលាបេតិ** មានសេចក្តីថា ធ្វើឱ្យពួកគ្រហស្ថ





នឹកឃើញនិយាយដល់ខ្លួន គឺឱ្យគ្រហស្ថជាប់ចិត្តនឹងខ្លួន ឱ្យមានសេចក្តីស្រឡាញ់យ៉ាងនេះថា ល្អណាស់ ! ព្រះគុណម្ចាស់របស់ពួកយើង ។ ភិក្ខុអ្នកលួចនូវគរុបរិក្ខារ ដែលមិនគួរចំណាយ និងមិនគួរចែក ដោយរបៀបយ៉ាងហ្នឹង (គឺដោយការ ) សង្គ្រោះគ្រហស្ថ នេះចាត់ជា មហាចោរពួកទី៤ ។ ចំពោះភិក្ខុនេះ កាលបើចំណាយគរុភណ្ឌដើម្បីសង្គ្រោះត្រកូល រមែងត្រូវ កុលទូសកទុក្កដ (ភិក្ខុទ្រុស្តត្រកូល ពោលគឺញ៉ាំងសទ្ធាគេឱ្យធ្លាក់ចុះ ត្រូវអាបត្តិទុក្កដ ) ផង រមែងជាអ្នកគួរដល់ បព្វាជនីយកម្ម (ត្រូវសង្ឃធ្វើកម្មបណ្តេញចេញពីវត្ត )ផង ។ កាលចំណាយដោយភាពជាអ្នកធំលើភិក្ខុសង្ឃ រមែងត្រូវអាបត្តិថុល្លច្ច័យ កាលចំណាយដោយថេយ្យចិត្ត (គំនិតលួច ) គប្បីវាយតម្លៃរបស់ហើយកាត់ទោស (ទោសអទិន្នាទានត្រូវអាបត្តិតាមតម្លៃវត្ថុដែលលួច ) ។

ពាក្យថា **អយំ អគ្គោ មហាចោរោ** មានសេចក្តីថា ភិក្ខុដែលលួចយកនូវលោកុត្តរធម៌ ដ៏ល្អិតសុខុមក្រៃលែង ប្រព្រឹត្តទៅកន្លងហួសពីការកាន់យកដោយឥន្ទ្រិយ៥ (មានចក្ខុន្ទ្រិយជាដើម ) នេះចាត់ជាចោរដ៏ធំបំផុតនៃមហាចោរទាំងឡាយ គឺដែលឈ្មោះថាចោរ រមែងមិនមានចោរឯណាឱ្យដូចជាភិក្ខុពួកទី៥នេះឡើយ។

សួរថា លោកុត្តរធម៌ បុគ្គលអាចលួចយក ដូចជាទ្រព្យមាន

មាសប្រាក់ជាដើមបានឬ ?

ឆ្លើយថា មិនអាច ដោយហេតុនេះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ព្រះអង្គទ្រង់ត្រាស់ថា «ភិក្ខុណាពោលអួតឧត្តរិមនុស្សធម្មដែលមិនមាន ដែលមិនប្រាកដក្នុងខ្លួន » តាមពិត ភិក្ខុនេះរមែងពោលអួតធម៌ដែលមិនមាននៅក្នុងខ្លួនតែម្យ៉ាងថា ធម៌នេះរបស់យើង គឺយើងមានមែន តែមិនអាចឱ្យឧត្តរិមនុស្សធម្មនោះ ឃ្លាតចាកទី (ចូលមកនៅក្នុងខ្លួនឯងបានទេ ) គឺមិនអាចធ្វើឧត្តរិមនុស្សធម្មឱ្យមាននៅក្នុងខ្លួន (ដោយការលួចយកពីអ្នកដទៃឡើយ ) ។

សួរថា កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបពោលថា (ភិក្ខុពោលអួតឧត្តរិមនុស្សធម្មនេះ )ជាចោរ ?

ឆ្លើយថា ព្រោះភិក្ខុនេះ ពោលអួតនូវឧត្តរិមនុស្សធម្មនោះហើយ កាន់យកបច្ច័យដែលកើតឡើង ដោយការអួតគុណដែលមិនមានក្នុងខ្លួន ព្រោះហេតុនោះ បច្ច័យទាំងអស់នោះ រមែងជាវត្ថុដែលលោកកាន់យកដោយការបោកបញ្ឆោត ជាការលួចយកដោយឧបាយដ៏ល្អិតសុខុម ដោយហេតុនោះឯង ព្រះដ៏មាន-ព្រះភាគជាម្ចាស់ទើបទ្រង់ត្រាស់ថា សេចក្តីនោះព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ពីព្រោះដុំបាយរបស់អ្នកស្រុកក្នុងដែន គឺភិក្ខុនោះឯងលួចយកមកបរិភោគ ។





## អដ្ឋកថាក្នុងនិគមគាថា

បណ្តាបទទាំងនោះ មានពីរបទដែលថា **អញ្ញថា សន្តំ** ដោយសេចក្តីថា ដែលមានដោយអាការដទៃ សឹងមានកាយសមា-ចារ មិនបរិសុទ្ធជាដើម ។

បាទគាថា ថា **អញ្ញថា យោ បវេទយេ** ដោយសេចក្តីថា ភិក្ខុរូបណា គប្បីប្រកាសដោយអាការយ៉ាងដទៃ ដែលមានកាយ-សមាចារបរិសុទ្ធជាដើម គឺឱ្យជនដទៃយល់យ៉ាងនេះថា យើងជាបុគ្គលបរិសុទ្ធយ៉ាងក្រៃលែង លោកុត្តរធម៌មាននៅក្នុងខ្លួនរបស់យើង គ្រាកាលដែលប្រកាសហើយ ក៏សម្តែងខ្លួនដូចព្រះអរហន្តឆាន់នូវភោជនដែលកើតឡើង ព្រោះការប្រកាសនោះ ។

បទថា **និកច្ច** ក្នុងពីរបាទនៃគាថា ថា **និកច្ច កិតវស្សេវ ភុត្តំ ថេយ្យេន តស្ស តំ** នេះ ប្រែថា បោកបញ្ឆោត គឺសម្តែងខ្លួនដោយអាការដទៃ បានដល់ខ្លួនឯងមិនមែនគុម្ពឈើ ឬមិនមែនដុំបគុម្ពោតឈើឡើយ តែសម្តែងខ្លួនឱ្យដូចគុម្ពឈើ ឬឱ្យដូចជាដុំបគុម្ពោតឈើ ព្រោះយកមែកឈើ ស្លឹកឈើជាដើមមកបិទបាំងកាយ ។

បទថា **កិតវស្សេវ** មានសេចក្តីថា ដូចព្រានបក្សីដែលបោកបញ្ឆោត គឺ បញ្ឆោតចាប់សត្វណាដែលមកហើយក្នុងព្រៃ

ដោយសត្វនោះមានសេចក្តីសំគាល់ថា ជាគុម្ពឈើឬជាដុបគុម្ពោត ឈើ ហើយយកសត្វដែលចាប់បាននោះចិញ្ចឹមជីវិត ដូច្នោះឯង។

បាទគាថា ថា **តុត្តំ ថេយ្យេន តស្ស តំ** មានសេចក្តីថា កាលបើភិក្ខុនោះ មិនមែនជាព្រះអរហន្តទេ តែសម្តែងខ្លួនថាជាព្រះអរហន្ត ឆាន់ភោជនដែលខ្លួនបានមក ភោជនដែលលោកឆាន់ ឈ្មោះថាជាភោជនដែលខ្លួនឯងលួចយកមកបរិភោគ ព្រោះលោកបានបោកបញ្ឆោតនូវមនុស្សទាំងឡាយហើយ ទើបបានមកហ្នឹងឯង ប្រៀបដូចនាយព្រានមានគ្រឿងបិទបាំងកាយ ដើម្បីបោកបញ្ឆោតចាប់បក្សាបក្សី ដូច្នោះដែរ ភិក្ខុណា កាលបើមិនបានដឹងនូវប្រយោជន៍ ក៏រមែងឆាន់នូវភោជនដោយអាការយ៉ាងនេះឯង ។ ភិក្ខុជាច្រើនអង្គ មានសំពត់កាសាវៈ ព័ទ្ធព័ន្ធនឹងក តែជាអ្នកមានធម៌ដ៏លាមក មិនសង្រួមហើយ ភិក្ខុអាក្រក់លាមកទាំងនោះ រមែងចូលទៅនរក ព្រោះអំពើដ៏លាមកទាំងឡាយ (ដែលគេបានធ្វើហើយហ្នឹងឯង ) ។

បទថា **កាសាវកណ្ឋា** បានដល់ បុគ្គលមានកដែលព័ទ្ធព័ន្ធដោយសំពត់កាសាវៈ មានពាក្យអធិប្បាយថា គុណធម៌របស់សមណៈ(ដ៏កំពូល)គឺព្រះអរហត្តផល រមែងមិនមានដល់បុគ្គលពួកណា បុគ្គលពួកនោះមានតែការទ្រទ្រង់នូវទង់ជ័យនៃព្រះអរិយៈ





តែប៉ុណ្ណោះ ។ ពាក្យថា បុគ្គលមានសំពត់កាសាវៈព័ទ្ធព័ន្ធកនេះ ជាឈ្មោះនៃបព្វជិតទ្រុស្តសីល (ដូច )ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកយ៉ាងនេះថា «ម្នាលអានន្ទ គោត្រភូសង្ឃទាំងឡាយ មាននូវសំពត់កាសាវៈព័ទ្ធក នឹងមានក្នុងកាលអនាគត » ។

បទថា **បាបធម្មា** បានដល់ អ្នកមានធម៌ដ៏លាមក ។

បទថា **អសញ្ញតា** បានដល់អ្នកមិនសង្រួមផ្លូវកាយជាដើម។

បទថា **បាបា** បានដល់ បុគ្គលលាមក ។

ក្នុងពីរបទដែលថា **បាបេហិ កម្មេហិ** ដោយសេចក្តីថា ព្រោះកម្មដ៏អាក្រក់លាមកទាំងឡាយ មានការបោកបញ្ឆោតអ្នកដទៃជាដើមនោះ ដែលខ្លួនធ្វើហើយ ព្រោះមិនឃើញទោសក្នុងពេលដែលធ្វើ ។

បាទព្រះគាថា ថា **និរយន្តេ ឧបបជ្ជរេ** ដោយសេចក្តីថា ពួកភិក្ខុដ៏អាក្រក់លាមកទាំងនោះ រមែងចូលដល់ទុគ្គតិដែលអត់នូវសេចក្តីត្រេកអរីករាយ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់នូវព្រះគាថា ថា **សេយ្យោ អយោគុឡោ** ជាដើម ។

គប្បីជ្រាបអត្ថន័យនៃព្រះគាថានោះថា បើបុគ្គលទ្រុស្តសីល មិនសង្រួម តាំងនៅក្នុងឥច្ឆាចារ (កិរិយាប្រព្រឹត្តដោយសេចក្តី

ប្រាថ្នា ) ជាអ្នកចិញ្ចឹមជីវិតដោយកិរិយាបោកបញ្ឆោតនេះ គប្បីបរិភោគ គឺគប្បីលេបនូវដុំដែកដែលក្តៅ ប្រៀបដូចជាអណ្តាតភ្លើង ។ ការដែលបុគ្គលទ្រុស្តសីលឆាន់ដុំបាយរបស់អ្នកស្រុកក្នុងដែននេះ១ ការដែលបុគ្គលគប្បីលេបនូវដុំដែកភ្លើងនេះ១ ក្នុងពីរយ៉ាងនេះ ដុំដែកភ្លើងដែលភិក្ខុនោះបរិភោគលេបចូលហើយ គប្បីជារបស់ប្រសើរជាង គឺល្អជាង និងប្រណីតជាង ព្រោះថា ភិក្ខុនោះនឹងមិនសោយទុក្ខដែលមានការកំណត់ដឹងដោយលំបាកសូម្បី (កំណត់ដឹង )ដោយសព្វញ្ញុតញ្ញាណ ក្នុងសម្បរាយភព ( បរលោក ) ប៉ុន្តែ នឹងបានសោយទុក្ខមានប្រការដូចពោលហើយនេះ ក្នុងសម្បរាយភព ព្រោះហេតុតែ ការបរិភោគនូវដុំបាយរបស់អ្នកស្រុកក្នុងដែន ដែលខ្លួនបានមកដោយអាការយ៉ាងនោះ (គឺដោយការបោកបញ្ឆោតអ្នកស្រុក ) ។

ពិតណាស់ អាជីព (ការចិញ្ចឹមជីវិតដូចភិក្ខុមហាចោរពួកទី៥ ) នេះ ចាត់ជាមិច្ឆាជីពថ្នាក់កំពូល ។

ចប់មហាចោរ៥ពួកក្នុងព្រះពុទ្ធសាសនា

អកុសលកម្មបថទី៩-គិតដើម្បីនឹងទម្លាយនូវប្រយោជន៍សុខនៃអ្នកដទៃគឺគំនិតព្យាបាទ មានទោសចេតសិកជាតួអកុសលកម្មបថ





មានចេតនាប្រកបជាមួយជាតួអភិសង្ខារ ( កម្មសម្រាប់ ឱ្យផល ) មានមោហៈជាហេតុ ។

-គំនុំគុំគួន គឺជាដំបៅរបស់ចិត្ត ។

-ការខឹងក្រោធ គំនុំគុំគួន គឺជាគ្រោះកាចក្នុងជីវិត ។

-គំនុំ គឺជាប្រភពនៃការចងពៀរ ។

-ក្រោធ ចងគំនុំគឺជាភ្លើង មេត្តា ករុណាគឺជាទឹក ។

-ដឹងថានៅមានកិលេសហើយ តែសូមកុំប្រើប្រាស់វាបានទេ ?

-ការខឹងក្រោធ គំនុំគុំគួន គឺជាច្រែះស្នឹមនៃចំណេះដឹងផ្សេងៗ ធ្វើឱ្យចំណេះទាំងនោះប្រើការមិនបាន។ អ្នកមានចំណេះដឹងក្នុងវិជ្ជាទាំងឡាយ កុំទាន់អាលអួតថាពូកែហើយ ល្មមហើយ គ្រាន់បើហើយ ត្រូវប្រយ័ត្នសេចក្តីក្រោធដែលជាច្រែះស្នឹមនៃចំណេះដឹងទាំងនោះផង ព្រោះថា ខឹងក្រោធពេលណា ពេលនោះភាពងងឹតស្លុប គឺសេចក្តីល្ងង់ក៏បានមកដល់ភ្លាមដែរ ដូច្នេះត្រូវតែប្រយ័ត្នឱ្យមែនទែន ប្រយ័ត្នគឺជាមាតានៃគុណធម៌ទាំងអស់ ។

-សេចក្តីក្រោធគ្របសង្កត់បុគ្គលណាហើយ បុគ្គលនោះរមែងលះបង់នូវកុសលធម៌ចោល មិនព្រមធ្វើនូវសេចក្តីល្អឡើយ ព្រោះរវល់តែគិតថា « គេនោះទេដែលខុស » ចំណែកខ្លួនឯងត្រូវសេចក្តីក្រោធនាំទៅ ក៏នៅមិនដឹងខ្លួនខុស ទាំងដឹងថាយ៉ាងនេះល្អហើយ ក៏បិទចោលដែរ ត្រូវទៅតាមសេចក្តីក្រោធ ពោលគឺស្ម័គ្រចិត្តយកខាងក្រោធ មិនយកខាងល្អឡើយ ។

បើយើងមានចិត្តប្រក្រតី យើងចាប់យកខាងល្អ ហើយខ្លាចសេចក្តីអាក្រក់ណាស់ លុះដល់ពេលក្រោធកើតឡើង ស្រាប់តែព្រមលះចោល

សេចក្ដីល្អ ព្រមលះចោលកុសលកម្ម នេះជាអន្តរាយដ៏ធំមួយ គឺព្រមអាក្រក់ ព្រមវិនាស ព្រមដុតផ្ទះ ព្រមបៀតបៀនអ្នកដទៃ ព្រមស្លាប់ខ្លួន ។ល។

-មនុស្សមានកំហឹងរមែងហ៊ានរហូតដល់ថ្នាក់សម្លាប់ម្ដាយរបស់ខ្លួនឯង នេះគួរឱ្យតិះដៀលសេចក្ដីក្រោធណាស់ ព្រោះថា កូនដែលកើតមកហើយ ក្នុងលោកនេះ មិនមានអ្វីឱ្យនៅជិតខ្លួន ឬមិនមានអ្វីធ្វើនូវសេចក្ដីថ្នាក់ថ្នមលួងលោមបបោសអង្អែលឱ្យដល់ខ្លួន ស្មើនឹងមាតាឡើយ តែដល់ក្រោធកើតឡើងហើយ កូនហ៊ានសម្លាប់ម្ដាយបង្កើតព្រោះសេចក្ដីក្រោធរបស់ខ្លួន ហ៊ានសម្លាប់បិតា ហ៊ានសម្លាប់ព្រះអរហន្ត ហ៊ានព្យាបាទព្រះ-សម្មាសម្ពុទ្ធ រហូតដល់ញ៉ាំងលោហិតនៃព្រះអង្គឱ្យពុរពង ហ៊ានបំបែកសង្ឃ ។ល។ ត្រូវឃើញសេចក្ដីក្រោធគ្រប់យ៉ាងក្នុងចិត្តយើង ថាជាកិលេសដែលនៅក្នុងក្រុមធ្វើអនន្តរិយកម្ម មានសម្លាប់ម្ដាយជាដើម ត្រូវប្រញាប់បណ្ដេញពួកវាឱ្យចេញផុតពីសន្តានទៅ យ៉ាងហោចណាស់ក៏មិនត្រូវនៅខាងសេចក្ដីក្រោធដែរ ។

អកុសលកម្មបថទី១០- យល់ខុសថា សត្វទាំងឡាយដែលមានសេចក្ដីសុខទុក្ខ ប្រព្រឹត្តទៅក្នុងលោកនេះ មិនបានអាស្រ័យហេតុអ្វីឡើយ គឺប្រព្រឹត្តទៅឯង១ ម្យ៉ាងទៀត យល់ខុសថា អំពើផ្សេង១របស់សត្វទាំងឡាយនោះ មិនសម្រេចជាបុណ្យឬជាបាបអ្វីឡើយ ហើយនៅមានការយល់ខុសម្យ៉ាងទៀតថា ធ្វើអ្វីក៏ដោយផលដែលត្រូវទទួលនោះរមែងមិនមាន **នត្ថិកទិដ្ឋិ** មាន១០ចំណុច គឺ ÷





-**នត្ថិ ទិន្នំ** ការធ្វើបុណ្យឱ្យទានមិនមានផលឡើយ ។

-**នត្ថិ យិដ្ឋំ** ការបូជាផ្សេង១មិនមានផលឡើយ ។

-**នត្ថិ ហុតំ** បដិសណ្ឋារៈផ្សេង១មិនមានផលឡើយ ។

-**នត្ថិ សុកតទុក្កតានំ កម្មានំ ផលំ វិបាកោ** កម្មល្អកម្មអាក្រក់គ្រប់យ៉ាងដែលបានធ្វើហើយ មិនមានផលវិបាកឡើយ។

-**នត្ថិ អយំ លោកោ** លោកនេះមិនមាន (គឺមិនមានសម្រាប់សត្វដែលកើតក្នុងលោកដទៃ) ។

-**នត្ថិ បរោ លោកោ** លោកដទៃមិនមាន (គឺមិនមានសម្រាប់សត្វដែលកើតក្នុងលោកបច្ចុប្បន្ននេះ) ។

-**នត្ថិ មាតា** មាតាមិនមាន (គឺមិនមានគុណ មិនមានអ្វីដែលជាសេចក្ដីពិសេសខុសពីមនុស្សធម្មតា មិនមានអនន្តរិយកម្មអ្វីក្នុងរឿងមាតុឃាតឡើយ) ។

-**នត្ថិ បិតា** បិតាមិនមាន (ន័យដូច **នត្ថិ មាតា** ដែរ) ។

-**នត្ថិ សត្តា ឱបបាតិកា** សត្វដែលកើតឡើងធំពេញរូប-រាង មាននរក ប្រេត ទេវតា ជាដើមមិនមានឡើយ ។

-**នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិ-បន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ** សមណព្រាហ្មណ៍ទាំងឡាយណា អ្នកមាន

សេចក្តីព្រមព្រៀង និងមានដំណើរបដិបត្តិដោយប្រពៃ មាន សេចក្តីដឹងច្បាស់នូវលោកនេះផង លោកដទៃផង ដោយខ្លួនឯង ហើយអាចប្រកាសសម្តែងប្រាប់ណែនាំឱ្យគេយល់បាន សមណ-ព្រាហ្មណ៍ទាំងនោះ រមែងមិនមានក្នុងលោកឡើយ (ដោយសេចក្តីថា អ្នកធ្វើសមថវិបស្សនា បានឈានមគ្គផលនោះមិនមាន និងអ្នកដែលកាន់ភេទជាបព្វជិត បដិបត្តិល្អ បដិបត្តិប្រពៃ មិនមាន សុទ្ធតែជាអ្នកប្រព្រឹត្តដើម្បីចិញ្ចឹមជីវិតគឺគ្រាន់តែជាអាជីពប៉ុណ្ណោះ) ។

មិច្ឆាទិដ្ឋិ អង្គធម៌គឺ ទិដ្ឋិចេតសិក មានលោភៈ និងមោហៈ ជាហេតុ មានចេតនាប្រកបជាមួយជាតួអភិសង្ខារ មានទោសខ្លាំងក្លាជាងអកុសលកម្មណាៗទាំងអស់ ។

## អកតញ្ញូ

**ស្នាព្រះហស្តក្រោយបន្តស់របស់សម្តេចជួន-ណាត**

អកតញ្ញូ ពុំដឹងគុណគ្រូ មាតាបិតា
និងអ្នកមានគុណ ឯទៀតណាៗ ចិត្តវាហានក្លា
រករឿងចាប់ទោស ។
ទោះអ្នកមានគុណ មានចិត្តជាបុណ្យ អត់ឱនសន្តោស
សង្គ្រោះឱ្យវា រួចចាកទុក្ខទោស វានៅតែកោស
រូសរករឿងទៀត ។





ទោះលើកផែនដី ទាំងមូលឱ្យក្តី វានៅតែឆ្មៀត
រករឿងវាវិញ ដោយការជ្រែកជ្រៀត នាំជនឯទៀត
ឱ្យចូលដៃផង ។
នេះគឺជនពាល គំនិតរោលរាល អាក្រក់កន្លង
ទោះព្រះសម្ពុទ្ធ វិសុទ្ធឥតហ្មង ក៏អាចចម្លង
វាពុំបានឡើយ ។

**ឋានដ្ឋានទី២- កាមាវចរកុសលកម្ម** : កាមាវចរ-កុសលកម្ម បានដល់ចេតនាដែលប្រព្រឹត្តទៅក្នុងមហាកុសលចិត្ត ៨ដួង សម្រេចបានទៅជាកុសលកម្មបថ១០ និងទានសីលភាវនា។

មហាកុសលកម្មដែលជាកុសលកម្មបថ១០ គឺការវៀរចាកនូវអកុសលកម្មបថ៧ (កាយកម្ម៣ និងវចីកម្ម៤) ហើយថែមកុសលកម្មបថផ្នែកមនោកម្ម៣ទៀតគឺ **អនភិជ្ឈា** (មិនសម្លឹងរំពៃចង់បានទ្រព្យអ្នកដទៃដោយចិត្តខូចឡើយ នេះជាអលោភចេតសិក) **អព្យាបាទ** (មិនចងគំនុំដោយគិតធ្វើឱ្យគេវិនាសនូវប្រយោជន៍ឡើយ នេះជាអទោសចេតសិក) **សម្មាទិដ្ឋិ** (បញ្ញាយល់ត្រូវផ្ទុយពីមិច្ឆាទិដ្ឋិ នេះជាបញ្ញាចេតសិក) ។

មហាកុសលកម្មម្យ៉ាងទៀត ប្រព្រឹត្តទៅក្នុងបុញ្ញកិរិយាវត្ថុ ១០ ដែលសង្គ្រោះចូលក្នុងទានសីលភាវនា ។

## មហាកុសលក្នុងបុញ្ញកិរិយាវត្ថុ១០

បុញ្ញកិរិយាវត្ថុទី១ ៖ បុណ្យសម្រេចដោយការឱ្យទាន មានចេតនាជាតួកុសលកម្ម ប្រកបដោយហេតុ២ (អលោភៈ និងអទោសៈ) ក៏មាន ប្រកបដោយហេតុ៣ (អលោភៈ អទោសៈ និងបញ្ញា) ក៏មាន ។

-អ្នកឱ្យមិនសង្ឃឹមផល អ្នកទទួលមិនគួរភ្លេច ។

-បើមិនធ្វើល្អទេ មានជីវិត១០០ឆ្នាំក៏ពុំមានប្រយោជន៍ដែរ។

-បើឃើញតែពីបានទេ កុំសង្ឃឹមទឹកចិត្តអ្នកដទៃ ។

-កុំទុកចិត្តមនុស្សដែលគិតតែពីប្រយោជន៍ខ្លួន ។

-កើតជាមនុស្សត្រូវតែចេះឱ្យទាន មិនច្រើនក៏តិចដែរ ។

-មនុស្សល្អពេញចិត្តជួយឱ្យគេបានសុខ ។

-អ្នកឱ្យរមែងបានមិត្ត កម្ចាត់នូវគំនុំ ។

-ទាន ដូចជាការនាំទ្រព្យចេញពីផ្ទះដែលត្រូវភ្លើងឆេះ ។

-ធម្មទានឈ្នះអស់ទានទាំងពួង ។

-ឱ្យធម៌ជាទានឈ្មោះថាឱ្យនិព្វានដល់អ្នកដទៃ ។

បុញ្ញកិរិយាវត្ថុទី២ ៖ បុណ្យសម្រេចដោយការរក្សាសីល មានចេតនាជាតួកុសលកម្ម ប្រកបដោយហេតុ២ក៏មាន ប្រកបដោយហេតុ៣ក៏មាន មានទាំងសីលគ្រហស្ថ មានទាំងសីលបព្វជិត ។





-សីលធម៌មិនវិនាសឡើយ មនុស្សទេដែលវិនាសពីសីលធម៌។

-កំហុសចាត់ជាគ្រូក៏ពិតហើយ តែសូមកុំខុសដដែលៗ ។

-សេចក្ដីល្អមានតម្លៃជាងបរិញ្ញាបត្រ ។

-រូបស្អាតច្រើនតែជាសត្រូវនឹងសេចក្ដីល្អ ។

-សេចក្ដីល្អ គឺជាមកុដនៃរូបស្អាត ។

-មនុស្សល្ងង់ទុកបេះដូងនឹងអណ្ដាត (និយាយអត់គិត)។

-មនុស្សឆ្លាតទុកអណ្ដាតនឹងបេះដូង (គិតរួចទើបនិយាយ)។

-កុំខ្ជិលសាងគុណធម៌ ព្រោះគ្មានអ្នកណាល្អជំនួសយើងទេ។

-គុណធម៌មានការប្រយ័ត្នជាមាតា មានការអត់ធន់ជាបិតា។

-មនុស្សល្អមិនស្វែងរកសុខលើសេចក្ដីទុក្ខនៃអ្នកដទៃឡើយ។

បុញ្ញកិរិយាវត្ថុទី៣ ៖ បុណ្យសម្រេចដោយសមថៈ និងវិបស្សនា មានចេតនាជាតួកុសលកម្ម មានឯកគ្គតាចេតសិកជាអង្គធម៌របស់សមថៈ មានបញ្ញាចេតសិកជាអង្គធម៌របស់វិបស្សនា មានការចម្រើននៅក្នុងកាមាវចរកុសលដោយមហាកុសល៨ ដួង ។

-បាបកើតពីអារម្មណ៍ណា គប្បីហាមចិត្តចាកអារម្មណ៍នោះ។

-ចូរត្រេកអរក្នុងការមិនប្រមាទ ចូរតាមរក្សាចិត្តរបស់ខ្លួន។

-សេចក្ដីស្ងប់ស្ងាត់របស់អ្នកដែលត្រេកអរក្នុងទីស្ងាត់ ជាអ្នកមានធម៌បានស្ដាប់ហើយ ពិចារណាឃើញនូវធម៌នាំមកនូវសេចក្ដី

សុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្គ្រួមចំពោះសត្វទាំងឡាយនាំមកនូវសេចក្តីសុខ ។

-ពន្លឺភ្លឺស្វាងស្មើដោយបញ្ញាមិនមានឡើយ ។

-បញ្ញានាំឱ្យបានដឹងនូវគុណតម្លៃនៃអប្បមាទធម៌ ។

-ឈើខ្លឹមគ្រប់ដើមមិនមែនបានធំក្នុងពេល១ឆ្នាំនោះទេ។

-ព្យាយាមនិងអំណត់ ជាគ្រូបង្ហាត់ដ៏ធំក្នុងលោក ។

-ជីវិតគឺការដើរផ្លូវឆ្ងាយ រូបរាងកាយជាសាលាសំណាក់។

-កាលវេលារមែងទំពាស៊ីអស់សព្វសត្វព្រមទាំងខ្លួនរបស់វា។

-អ្នកប្រាជ្ញហៅជីវិតដែលរស់នៅប្រកបដោយបញ្ញា ថាជាជីវិតដ៏ប្រសើរ ។

<u>បុញ្ញកិរិយាវត្ថុទី៤</u>-បុណ្យសម្រេចដោយការគោរពឱនលំទោន បុណ្យនេះសង្គ្រោះចូលក្នុងសីល ផ្នែកខាងធ្វើសក្ការៈ គោរព បូជាដល់ព្រះរតនត្រ័យ គ្រូឧបជ្ឈាយាចារ្យ មាតាបិតាជាដើម ជាបុណ្យកុសលផ្នែកខាងផ្តល់ ប្រគល់ ប្រគេន ថ្វាយ នូវកិត្តិយសភាពឧត្តុង្គឧត្តមខ្ពង់ខ្ពស់ និងភាពប្រសើរថ្លៃថ្នូរ ។

-មនុស្សត្រូវមានកិរិយាសុភាពដូចផ្កាឈើត្រូវមានក្លិនក្រអូប។

-មារយាទទន់ភ្លន់ជាមិត្តនឹងគុណធម៌ ដែលមិនបែកគ្នាឡើយ។

-មនុស្សល្អរមែងសាងគុណធម៌ ព្រមឱ្យអ្នកដទៃល្អជាងខ្លួន។



-អ្នកដែលអួតអាងតម្កើងខ្លួន ច្រើនតែជាអ្នកខ្វះសមត្ថភាព ។

-អ្នកដែលស្គាល់ខ្លួនឯងដោយល្អ រមែងមិនលើកតម្កើងខ្លួន។

-យើងត្រូវគោរពរាប់អានខ្លួនឯង បើមិនដូច្នោះទេ នឹងមិនមានអ្នកដទៃណាគេគោរពយើងឡើយ ។ ដំណើរជីវិតរបស់មនុស្សត្រូវនៅក្នុងផ្លូវនៃការគោរពខ្លួន អ្នកដែលមិនគោរពខ្លួនឯងរមែងជាទីប្រមាថមាក់ងាយរបស់អ្នកដទៃ ។

-កតញ្ញូតាធម៌របស់កូន គឺជាសេចក្តីសុខរបស់ឪពុកម្តាយ ។

-កតញ្ញូតាធម៌ជារស្មីចាំងចែងចេញពីចិត្តខ្ពស់និងប្រសើរ។

-ការដឹងគុណដល់គ្នានឹងគ្នា នាំឱ្យគោរពគ្នាទៅវិញទៅមក ។

-ភរិយាស្វាមីមានគុណដល់គ្នានឹងគ្នារាល់ថ្ងៃ ត្រូវដឹងផង ។

តើការគោរពខ្លួនឯងនោះ គួរគោរពដូចម្តេច ?

ជាការងាយយល់ទេ បើយើងនឹកដល់អ្នកដទៃដែលគេត្រូវគោរពយើងនោះ គឺគេគោរពយើងព្រោះយើងជាមនុស្សចាស់ ឬព្រោះយើងជាឪពុកម្តាយរបស់គេជាដើម ដូច្នេះ ពាក្យថា «ការគោរពខ្លួនឯង» គប្បីយល់ថា ជាការតម្កល់ខ្លួនឱ្យប្រពៃ ។

អ្នកដទៃគេមិនគោរពគោក្របីឆ្កែឆ្មាទេ តែគេគោរពយើងព្រោះយើងមានជាតិជាមនុស្ស ចុះចំណែកខ្លួនឯងវិញ ត្រូវគោរពខ្លួនជាមនុស្សយ៉ាងណា ? គឺត្រូវប្រព្រឹត្ត ត្រូវធ្វើនូវអំពើណា កុំឱ្យ

ខ្លួនឯងបាត់បង់នូវភាពជាមនុស្ស យ៉ាងនេះឯង ដែលឈ្មោះថា គោរពខ្លួនឯងជាមនុស្ស ។

អ្នកដទៃគេគោរពយើង ព្រោះយើងជាចាស់ ព្រោះយើងជាគ្រូ ព្រោះយើងជាអ្នកចេះដឹងច្រើន ព្រោះយើងជាម៉ែ ព្រោះយើងជាឪ ... បើយើងជាឪពុកគេ តើយើងត្រូវគោរពខ្លួនឯងយ៉ាងណា ? គឺយើងមិនត្រូវធ្វើនូវអំពើណា ដែលនាំឱ្យបាត់បង់នូវភាពជាឪពុករបស់គេហ្នឹងឯង បើយើងប្រព្រឹត្តនូវអំពើដូចសត្វតិរច្ឆាន ឈ្មោះថាមិនទទួលស្គាល់ខ្លួនឯងថាជាបិតារបស់កូន មិនទទួលស្គាល់ខ្លួនឯងថាជាបុព្វាចារ្យរបស់កូន មិនទទួលស្គាល់ខ្លួនឯងថាជាព្រះព្រហ្មរបស់កូន ព្រមទាំងមិនទទួលស្គាល់ខ្លួនឯងថាជាព្រះអរហន្តរបស់កូន តើឱ្យកូនទទួលស្គាល់និងគោរពខ្លួនឯងដែលជាអ្នកបង្កើតគេមក យ៉ាងដូចម្តេចទៅ ? សូមចាំ កុំភ្លេចថា «ការគោរពខ្លួន មិនមែនការលើកតម្កើងខ្លួនឯងទេ» ។

បុញ្ញកិរិយាវត្ថុទី៥ -បុណ្យសម្រេចដោយការងារជួយដល់អ្នកដទៃ បុណ្យនេះសង្គ្រោះចូលក្នុងសីល ព្រោះជាមារយាទដែលប្រព្រឹត្តល្អដោយកាយដោយវាចា ជា **អត្ថចរិយា** ការប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់អ្នកដទៃ បើបានបម្រើដល់ព្រះរតនត្រ័យជាកំពូលនៃការបម្រើ (បារិចរិយានុត្តរិយ) ។



-កើតមកជាមនុស្សត្រូវខំព្យាយាមធ្វើល្អគ្រប់យ៉ាង ក្រៅអំពីនេះស្រេចនៅលើកម្មចាស់ឱ្យផល (កម្មលិខិត) ។

-សេចក្តីខ្ជិលច្រអូសជាព្រៃស្មសានកប់មនុស្សទាំងអស់។

-គ្រែដេកគឺជាគុករបស់មនុស្សកម្ជិល ។

-សេចក្តីខ្ជិលច្រអូសគឺជាមាតានៃសេចក្តីទុក្ខលំបាក ។

-សេចក្តីខ្ជិលគឺជាប្រភពនៃការប្រព្រឹត្តអាក្រក់ផ្សេងៗ ។

-សេចក្តីខ្ជិលនិងក្រលំបាកជាមិត្តជិតដិតនឹងគ្នា ។

-សេចក្តីខ្ជិលជាប្រធាននៃសេចក្តីវិនាស ។

-កាលបើបុគ្គលសម្លឹងឃើញទោសនៃសេចក្តីខ្ជិលហើយគប្បីក្រវើនក្រតើនក្នុងការងារ ទោះការងារនោះជាប្រយោជន៍សម្រាប់ខ្លួនឯងក្តី សម្រាប់អ្នកដទៃក្តី ក៏ចេះតែធ្វើទៅ ដោយមិនចាំបាច់មើលបំណាំឡើយ ។

-មនុស្សយើងរួចពីនរកមក មិនមែនមកដេកខ្ជិលនោះទេ ត្រូវធ្វើទុកក្នុងចិត្តថា នរកដូចសត្វខ្លាកំពុងតែដេញតាមប្រកិតហើយត្រូវដាស់តឿនខ្លួនឯងជារឿយៗថា បច្ចុប្បន្នភពនេះមិនមែនជាកន្លែងពិតរបស់យើងទេ តាំងពីយើងចាប់បដិសន្ធិមកយើងត្រូវបានបង់ពន្ធជីវិតឱ្យមច្ចុរាជរាល់ថ្ងៃ ជាទីបំផុតជីវិតយើងក៏ត្រូវអស់ ។

-មានព្យាយាមខ្លាំងក្លា ស្មើនឹងការសម្រេចប្រយោជន៍បានពាក់កណ្ដាល ។

បុញ្ញកិរិយាវត្ថុទី៦ -បុណ្យសម្រេចដោយការចែកបុណ្យ និងឧទ្ទិសបុណ្យឱ្យដល់អ្នកដទៃ បុណ្យនេះសង្គ្រោះចូលក្នុងទានដែលសម្រេចដោយទឹកចិត្តមេត្តាព្រមដោយការយល់ដឹង ។

ជូនបុណ្យដល់អ្នកដទៃ ត្រូវប្រកបដោយចិត្តមេត្តា គិតនឹកប្រាថ្នាឱ្យគេបានប្រយោជន៍សុខពិត១ គឺថាបើគេត្រេកអរនឹងបុណ្យដែលយើងបានជូនហើយ គេរមែងបាននូវមហាកុសល ដែលជាគុណជាតិនាំមកនូវប្រយោជន៍និងសេចក្ដីសុខ ។

ជូនបុណ្យ ឧទ្ទិសបុណ្យ ពេលខ្លះក៏ត្រូវប្រកបដោយចិត្តករុណា គិតនឹកប្រាថ្នាឱ្យគេបានផុតចាកអំពីសេចក្ដីទុក្ខលំបាក បើគេអនុមោទនាត្រេកអរហើយ គេរមែងបាននូវបុណ្យ ហើយបុណ្យនោះនឹងជួយឱ្យគេបានរួចផុតអំពីទុក្ខទាំងពួង ។

បើច្រណែននឹងសម្បត្តិអ្នកដទៃ ក៏មិនអាចបំពេញនូវបុណ្យនេះបានដែរ ម្យ៉ាងទៀត ជូនបុណ្យ ប្រគេនបុណ្យ ព្រោះគ្រាន់តែចង់បង្អួតខ្លួនឯង ក៏មិនអាចបំពេញនូវបុណ្យនេះបានដែរ និងម្យ៉ាងទៀតនោះ មនុស្សច្រើនណាស់ដែលមិនបានយល់ច្បាស់អំពីបុណ្យរបៀបនេះ ហើយក៏ស្ងៀម១ទៅ ។





បុញ្ញកិរិយាវត្ថុទី៧ -បុណ្យសម្រេចពីការអនុមោទនា ជ្រះថ្លាត្រេកអរនឹងបុណ្យកុសលដែលអ្នកដទៃបានធ្វើ បុណ្យនេះសង្គ្រោះចូលក្នុងពួកទានកុសលផងដែរ ។

បើមិនយល់ដឹងអំពីមហាកុសលទេ ក៏មិនដឹងថា ការអនុមោទនាជាមហាកុសលដែរ ហើយក៏មិនបានដឹងថា មហាកុសលជាបុណ្យទៀតផង ។ មនុស្សយើងច្រើននាក់ណាស់ដែលមិនដឹងច្បាស់ថាអ្វីជាបុណ្យ ហើយអ្វីជាបាបឱ្យពិតប្រាកដ ព្រោះហេតុនោះឯង ទើបអាចមានជំនឿខុសថា បាបអាចលាងជម្រះដោយទឹកស័ក្តិសិទ្ធិ ឬមានព្រះអាចទទួលយកបាបអំពីខ្លួនឯងបាន ។

ការមើលងាយអ្នកដទៃ ព្រោះជាតិត្រកូល ឬព្រោះទ្រព្យជាដើម ក៏មិនអាចអនុមោទនាបុណ្យ ពីបុគ្គលដែលខ្លួនកំពុងមើលងាយនោះបានដែរ ដូច្នេះ ការអនុមោទនាបុណ្យ ជាការកម្ចាត់បង់នូវមានះ ព្រមទាំងកិលេសផ្សេង១ទៀត មានសេចក្ដីក្រោធជាដើម។

បុញ្ញកិរិយាវត្ថុទី៨-បុណ្យសម្រេចពីការសម្ដែងធម៌ បុណ្យនេះសង្គ្រោះចូលក្នុងទានដោយពិត ព្រោះជាធម្មទាន ប៉ុន្តែចំពោះធម្មទានដោយការសម្ដែងធម៌នេះ មានសេចក្ដីពិសេស ព្រោះជាប់ទាក់ទងនឹងការតម្កល់ចិត្តឱ្យបាននឹងធឹង ដូច្នេះទើបត្រូវសង្គ្រោះ

ចូលក្នុងភាវនា ហើយចាត់ជាទានដែលឈ្នះអស់ទានទាំងពួង ។

ថ្ងៃ១៥កើត ខែអាសាឍ បន្ទាប់ពីព្រះអង្គត្រាស់ដឹងបានពីរខែ ជាថ្ងៃកំណើតព្រះធម៌ទេសនា ហើយក៏ជាថ្ងៃកំណើតព្រះសង្ឃផងដែរ ដូច្នេះគួរពុទ្ធបរិស័ទធ្វើនូវ **អាសាឡ្ហបូជា** ដោយចិត្តជ្រះថ្លា គឺនៅក្នុងថ្ងៃ១៥កើត មុនចូលវស្សា១ថ្ងៃ ។

ការសម្តែងនូវព្រះសទ្ធម្មនាំមកនូវសេចក្តីសុខ ។

បុញ្ញកិរិយាវត្ថុទី៩.បុណ្យសម្រេចពីការស្តាប់ធម៌ បុណ្យនេះសង្គ្រោះចូលក្នុងភាវនា ព្រោះជាការតម្កល់ចិត្តដោយល្អ ប្រាស-ចាកការងោកងក់ និងការរាយមាយ ព្រមទាំងតាំងចិត្តគោរពព្រះ-ធម៌ដែលជាការគោរពដ៏ខ្ពង់ខ្ពស់ទៀតផង ។

បុគ្គលមានសទ្ធាជឿធម៌ព្រះអរហន្ត ថាជាធម៌នាំឱ្យបានសម្រេចដល់ព្រះនិព្វាន១ មានការស្តាប់ព្រះធម៌ដោយល្អ១ គោរពព្រះធម៌ដោយសេចក្តីមិនប្រមាទ១ និងពិចារណានូវសេចក្តីនៃព្រះធម៌១ ទាំង៤នេះជាហេតុនាំឱ្យបានសម្រេចនូវបញ្ញា ។

មនុស្សដែលទៅជាមនុស្សល្អមិនបាន គឺមនុស្សមិនព្រមស្តាប់អ្នកណា (តម្កើងខ្លួនឯង មាក់ងាយអ្នកដទៃ) ។

បុញ្ញកិរិយាវត្ថុទី១០.បុណ្យសម្រេចដោយការយល់ត្រូវ បុណ្យនេះសង្គ្រោះចូលក្នុងទានសីលភាវនា ព្រោះថាបុណ្យនេះជាតួ





បញ្ញា ឬថាជាផ្នែកយល់ដឹងទៅតាមសេចក្តីពិត ម្ល៉ោះហើយ នៅពេលអប់រំបានសម្រេចហើយ ក៏ជាតួបុណ្យផង គ្រប់គ្រងទានសីលភាវនាផង ។

បញ្ញាយល់ត្រូវក្នុងទីនេះ ពោលដោយសរុបគឺជា **កម្មស្សក-តាបញ្ញា** (យល់ឃើញថា ការលិខិតជីវិតឱ្យសត្វលោក គឺអំពើល្អអាក្រក់ដែលសត្វលោកធ្វើដោយខ្លួនឯង) ។ កម្មស្សកតាបញ្ញានេះសម្រេចអំពីបច្ច័យ៣យ៉ាងគឺ : ១.ស្តាប់ដោយល្អ ២.គិតពិចារណាដោយល្អ ៣.ភាវនាអប់រំចម្រើននូវវិបស្សនាដោយល្អ ។

ចេតនាដែលប្រកបជាមួយកម្មស្សកតាបញ្ញា ឈ្មោះថា **ទិដ្ឋុជុកម្ម** មានអលោភៈ និងអទោសៈជាហេតុ ក្នុងមុញ្ចនចេតនាប្រព្រឹត្តទៅដោយមហាកុសលញាណសម្បយុត្ត៤ផង ។

ទិដ្ឋុជុកម្មនេះ កាលបើជាបុព្វចេតនា និងអបរចេតនា មានការប្រព្រឹត្តទៅដោយមហាកុសល៨ដួង ។

ពាក្យថា អ្នកនេះអ្នកនោះធ្វើបុណ្យ គ្រាន់តែជាវោហារសន្មតទៅលើខ្សែតំណនៃបញ្ចក្ខន្ធមួយខ្សែៗ ក្នុងសង្សារវដ្តតែប៉ុណ្ណោះ បើតាមសភាវពិត ត្រឹមតែជាការប្រព្រឹត្តទៅនៃមហា-កុសលចេតនា កើតឡើងក្នុងវត្ថុនេះ ក្នុងវត្ថុនោះ តែប៉ុណ្ណោះឯង កើតហើយក៏បាត់ទៅ កើតហើយក៏បាត់ទៅ រួចត្រូវសន្សំទុកក្នុង

សន្តាន បានជាពូជឱ្យផលយ៉ាងណា១ នឹងសម្តែងក្នុងនានាខណិក-
កម្មប្បច្ច័យ ។

**ចង់ល្អត្រូវកុំ...**

កុំងឿងដោយខ្យល់ កុំឱនពាក្យពល កុំខ្វល់ដោយស្រី
កុំកាន់ពិសយង់ គប់នូវស្ត្រី សមណជនជី
កុំឱ្យក្តីត្រូវ ។

(សាស្ត្រាច្បាប់រាជនេតិ ជានិពន្ធនៃព្រះរាជសម្ភារ)
(ស្រង់ពីវចនានុក្រមសម្តេចជួនណាត)

**ឆាកដ្ឋានទី ៣ រូបាវចរកុសលកម្ម :** រូបាវចរកុសល-
កម្ម ខុសអំពីកាមាវចរកុសលកម្មដូចតទៅ ÷

✍-កាមាវចរកុសលកម្ម ជាកាយកម្មក៏មាន ជាវចីកម្មក៏
មាន ជាមនោកម្មក៏មាន ចំណែករូបាវចរកុសលកម្មជាមនោកម្មតែ
ម្យ៉ាង ព្រោះរូបាវចរកុសលកម្មដែលមិនបានទាក់ទងនឹងអភិញ្ញា
នោះ មិនបានញ៉ាំងវិញ្ញត្តិរូប២ គឺកាយវិញ្ញត្តិរូប និងវចីវិញ្ញត្តិរូបឱ្យ
កើតឡើងឡើយ ។

✍-កាមាវចរកុសលកម្ម ប្រព្រឹត្តទៅជាទានក៏បាន ជា
សីលក៏បាន ជាសមថកម្មដ្ឋានក៏បាន ជាវិបស្សនាកម្មដ្ឋានក៏បាន
ប៉ុន្តែរូបាវចរកុសលកម្ម ប្រព្រឹត្តទៅជាសមថកម្មដ្ឋានតែម្យ៉ាង





ប៉ុណ្ណោះ គឺកាយគតាសតិ១ អានាបានស្សតិ១ អសុភ១០ កសិណ
១០ និងអប្បមញ្ញា៤ ។

✍-កាមាវចរកុសលកម្ម ពិតមែនថា ជាការប្រព្រឹត្តទៅ
ដោយសមថកម្មដ្ឋាន ប៉ុន្តែមិនអាចចូលដល់អប្បនាសមាធិបាន
ឡើយ បានត្រឹមតែបរិកម្មសមាធិ និងឧបចារសមាធិប៉ុណ្ណោះ
ចំណែករូបាវចរកុសលកម្មវិញ គឺជាអប្បនាសមាធិ និងចូលកាន់
ឈានសមាបត្តិបាន តាមការហ្វឹកហាត់ឱ្យមានជំនាញ ។

✍-កាមាវចរកុសលកម្ម ចែកជាមហាកុសល៨ ដោយ
អំណាចវេទនាខ្លះ ដោយញាណខ្លះ និងដោយអំណាចនៃសង្ខារខ្លះ
ចំណែកការកើតឡើងនៃរូបាវចរកុសលកម្ម ចែកជា៥ដោយ
អំណាចអង្គឈាន ។

✍-កាមាវចរកុសលកម្ម ឱ្យវិបាកបដិសន្ធិមិនប្រាកដឋាន
ច្បាស់លាស់ គ្រាន់តែថា កាមសុគតិភព៧ឋានប៉ុណ្ណោះ តែចំណែក
រូបាវចរកុសលកម្មវិញ រមែងឱ្យវិបាកបដិសន្ធិច្បាស់លាស់ទៅតាម
ឈាន មានបឋមជ្ឈានជាដើម នឹងសម្តែងក្នុងនានាខណិក-
កម្មប្បច្ច័យ ។

✍-កាមាវចរកុសលកម្ម ជាទិដ្ឋធម្មវេទនីយកម្មក៏មាន ជា
ឧបបជ្ជវេទនីយកម្មក៏មាន ជាអបរាបរិយវេទនីយកម្មក៏មាន

ចំណែករូបាវចរកុសលកម្មជាឧបបជ្ជវេទនីយកម្មតែម៉្យាង ។

✍.កាមាវចរកុសលកម្ម កើតតាមទ្វារទាំង៦បាន ឱ្យវិបាកក្នុងទ្វារ៦ក៏បានក្រៅទ្វារ៦ក៏បាន (ក្រៅទ្វារ៦ គឺបដិសន្ធិ ភវង្គ ចុតិ) ចំណែករូបាវចរកុសលកម្ម កើតបានតែតាមមនោទ្វារ និងឱ្យវិបាកក្រៅទ្វារតែប៉ុណ្ណោះ ។

✍.កាមាវចរកុសលកម្ម កើតបានក្នុងភពទាំង៣០ (វៀរអសញ្ញិសត្តាព្រហ្ម) ចំណែករូបាវចរកុសលកម្ម មិនកើតមានក្នុងអបាយភូមិ៤ អសញ្ញិសត្តាព្រហ្ម១ និង អរូបភូមិ៤ ។

✍.កាមាវចរកុសលកម្ម កើតបានក្នុងអហេតុកបុគ្គល ទុហេតុកបុគ្គល និងតិហេតុកបុគ្គល ចំណែករូបាវចរកុសលកម្ម កើតបានតែក្នុងតិហេតុកបុគ្គលតែប៉ុណ្ណោះ ។

នៅមានខុសគ្នាច្រើនយ៉ាងទៀត រវាងកាមាវចរកុសលកម្ម និងរូបាវចរកុសលកម្ម សូមអ្នកសិក្សាពិចារណាផងចុះ ។

នៅពេលរូបាវចរកុសលកម្មកើតឡើង កាមាវចរចិត្តទាំងអស់ រមែងមិនមាន នេះជាការរំលឹកស្មារតីថា សេចក្ដីដឹងខ្លួនថា អញក្នុងពេលនេះ គ្រាន់តែជាការកើតឡើង នៃកាមាវចរចិត្តប៉ុណ្ណោះ ជារបស់មិនទៀង និងមិនមែនជាអត្តាឡើយ ។



**បាតដ្ឋានទី ៤ អរូបាវចរកុសលកម្ម :** អរូបាវចរកុសលកម្ម ខុសគ្នាអំពីរូបាវចរកុសលកម្មយ៉ាងណា គឺថា រូបាវចរកុសលកម្ម ចែកជា៥ដោយអំណាចអង្គឈាន បានដល់ វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា ជាអង្គនៃបឋមជ្ឈានរូបាវចរ វិចារៈ បីតិ សុខ ឯកគ្គតា ជាអង្គនៃទុតិយជ្ឈានរូបាវចរ បីតិ សុខ ឯកគ្គតា ជាអង្គនៃតតិយជ្ឈានរូបាវចរ សុខ ឯកគ្គតា ជាអង្គនៃចតុត្ថជ្ឈានរូបាវចរ ឧបេក្ខា ឯកគ្គតា ជាអង្គនៃបញ្ចមជ្ឈានរូបាវចរ និងបញ្ចមជ្ឈានអរូបាវចរ ; បញ្ចមជ្ឈានអរូបាវចរមាន៤ តែមិនមែនខុសគ្នា ដោយអំណាចនៃអង្គឈានទេ ព្រោះអង្គឈានមាន២ដូចគ្នា គឺ ឧបេក្ខា និងឯកគ្គតា ។

អរូបាវចរកុសលកម្ម ចែកជា៤ ដោយអំណាចនៃអារម្មណ៍ អរូបាវចរកុសលកម្ម ដែលកើតឡើងដោយមាន កសិណុគ្ឃាដិមាកាសប្បញ្ញត្តិ (បើកនូវកសិណមានអាកាសប្បញ្ញត្តិ) ជាអារម្មណ៍ ក៏ឈ្មោះថា អាកាសានញ្ចាយតនកុសល ។

អរូបាវចរកុសលកម្ម ដែលកើតឡើងដោយមានអាកាសានញ្ចាយតនកុសលជាអារម្មណ៍ ក៏ឈ្មោះថា វិញ្ញាណញ្ចាយតនកុសលកម្ម (មានអរូបទី១ជាអារម្មណ៍) ។

អរូបាវចរកុសលកម្ម ដែលកើតឡើងដោយមាន នត្ថិភាវ-

ប្បញ្ញត្តិ (បញ្ញត្តិមិនមានអាស្រ័យនូវសភាវធម៌ ) ជាអារម្មណ៍ ក៏ឈ្មោះថា អាកិញ្ចញ្ញាយតនកុសលកម្ម ។

អរូបាវចរកុសលកម្ម ដែលកើតឡើងដោយមាន អាកិញ្ចញ្ញាយតនកុសលជាអារម្មណ៍ ក៏ឈ្មោះថា នេវសញ្ញានាសញ្ញាយតនកុសលកម្ម (មានអរូបទី៣ជាអារម្មណ៍ ) ។

បាកដ្ឋានចតុក្កៈ មានការសម្តែងកម្មក្នុងភូមិ៣ គឺកាមភូមិ១ រូបភូមិ១ និងអរូបភូមិ១ ។ កាមាវចរកម្មឱ្យបដិសន្ធិក្នុងកាមភព រូបាវចរកុសលកម្ម ឱ្យបដិសន្ធិក្នុងរូបភព ចំណែកអរូបាវចរកុសលកម្ម ឱ្យបដិសន្ធិក្នុងអរូបភព ។

កាមាវចរកម្មចែកជា២គឺៈអកុសលកម្ម និងមហាកុសលកម្ម ព្រោះហេតុដូច្នេះ ទើបបានជាបាកដ្ឋាន (ទីតាំងដែលនាំឱ្យមានវិបាក ) ត្រូវជា៤ ហៅថា បាកដ្ឋានចតុក្កៈ ។

សរុបចេតនាក្នុងបាកដ្ឋានចតុក្កៈ មាន២៩ គឺអកុសលចេតនា១២ មហាកុសលចេតនា៨ រូបាវចរកុសលចេតនា៥ អរូបាវចរកុសលចេតនា៤ ចេតនាទាំង២៩នេះ ជា**កម្មវដ្តៈ** ។

**ចប់បាកដ្ឋានចតុក្កៈ**





# មហាបដ្ឋាន កម្មប្បច្ចយោ

## នៅក្នុងបញ្ហាវារៈ មាន៧វារៈ

## ( អភិធម្មបិដកលេខ៨៤ ទំព័រ២៧៥)

១-កុសលោ ធម្មោ កុសលស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ កុសលា ចេតនា សម្បយុត្តកានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយកម្មប្បច្ច័យ គឺ កុសលចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

**អត្ថធម៌**

**បច្ច័យ** = ចេតនានៅក្នុងកុសលចិត្ត៣៧ដួង ។

**បច្ចយុប្បន្ន**= កុសលចិត្ត៣៧ដួង ចេតសិក៣៧ (វៀរចេតនា )។

**២- កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ សហជាតា កុសលា ចេតនា ចិត្តសមុដ្ឋានានំ រូបានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា កុសលា ចេតនា**

**វិបាកានំ ខន្ធានំ កដត្តា ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។**

កុសលធម៌ជាបច្ច័យនៃអព្យាកតធម៌ ដោយកម្មប្បច្ច័យ បាន ដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺកុសលចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ នានាខណិកៈ គឺ កុសលចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ និងពួកកដត្តារូប ដោយកម្មប្បច្ច័យ ។

**<u>អង្គធម៌</u>**

**ក-សហជាត**

**បច្ច័យ** = ចេតនានៅក្នុងកុសលចិត្ត ៣៧ដួង ។

**បច្ចយុប្បន្ន** = កុសលចិត្តសមុដ្ឋានរូប ១៧ ។

**ខ-នានាខណិកៈ**

**បច្ច័យ** = ចេតនានៅក្នុងកុសលចិត្ត ៣៧ដួង ។

**បច្ចយុប្បន្ន** = កុសលវិបាកចិត្ត៤៥ដួង គឺ កាមាវចរវិបាក១៦ដួង (វៀរអកុសលវិបាក៧ដួង) មហគ្គតវិបាក៩ដួង និងលោកុត្តរវិបាក ២០ដួង ចេតសិក៣៨ និងកម្មជរូប២០ (មហាកុសលចេតនា៨ និង រូបាវចរកុសលចេតនា៥នាំឱ្យកើតកម្មជរូប) ។

**៣-កុសលោ ធម្មោ កុសលស្ស ច អព្យាកតស្ស ច**





**ធម្មស្ស កម្មប្បច្ចយេន បច្ចយោ កុសលា ចេតនា សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃកុសលធម៌ និងអព្យាកតធម៌ ដោយ កម្មប្បច្ច័យ គឺ កុសលចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និង ពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។

**<u>អង្គធម៌</u>**

**បច្ច័យ** = ចេតនានៅក្នុងកុសលចិត្ត៣៧ដួង ។

**បច្ចយុប្បន្ន** = កុសលចិត្ត៣៧ដួង ចេតសិក៣៧ (វៀរចេតនា) និងកុសលចិត្តសមុដ្ឋានរូប ១៧ ។

**៤-អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ អកុសលា ចេតនា សម្បយុត្តកានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។**

អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយកម្មប្បច្ច័យ គឺ អកុសលចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ។

**<u>អង្គធម៌</u>**

**បច្ច័យ** = ចេតនានៅក្នុងអកុសលចិត្ត១២ដួង ។

**បច្ចយុប្បន្ន** = អកុសលចិត្ត១២ដួង ចេតសិក២៦ (វៀរចេតនា)។

**៥.អកុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា។ សហជាតា អកុសលា ចេតនា ចិត្តសមុដ្ឋានានំ រូបានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា អកុសលា ចេតនា វិបាកានំ ខន្ធានំ កដត្តា ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។**

អកុសលធម៌ជាបច្ច័យនៃអព្យាកតធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺអកុសលចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ នានាខណិកៈ គឺ អកុសលចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ និង ពួកកដត្តារូប ដោយកម្មប្បច្ច័យ ។

**<u>អត្ថធម៌</u>**

**ក.សហជាត**

**បច្ច័យ** = ចេតនានៅក្នុងអកុសលចិត្ត ១២ដួង ។

**បច្ចយុប្បន្ន** = អកុសលចិត្តសមុដ្ឋានរូប ១៧ ។

**ខ.នានាខណិកៈ**

**បច្ច័យ** = ចេតនានៅក្នុងអកុសលចិត្ត ១២ដួង ។

**បច្ចយុប្បន្ន** = អកុសលវិបាកចិត្ត៧ដួង ចេតសិក១០ និង





អកុសលកម្មជរូប ២០ ។

**៦.អកុសលោ ធម្មោ អកុសលស្ស ច អព្យាកតស្ស ច ធម្មស្ស កម្មប្បច្ចយេន បច្ចយោ អកុសលា ចេតនា សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។**

អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ និងអព្យាកតធម៌ ដោយកម្មប្បច្ច័យ គឺអកុសលចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និង ពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។

**<u>អត្ថធម៌</u>**

**បច្ច័យ** = ចេតនានៅក្នុងអកុសលចិត្ត១២ដួង ។

**បច្ចយុប្បន្ន** = អកុសលចិត្ត១២ដួង ចេតសិក២៦ (វៀរចេតនា) និង អកុសលចិត្តសមុដ្ឋានរូប ១៧ ។

**៧.អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ វិបាកាព្យាកតា កិរិយាព្យាកតា ចេតនា សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ កម្មប្បច្ចយេន បច្ចយោ បដិសន្ធិក្ខណេ វិបាកាព្យាកតា ចេតនា សម្បយុត្តកានំ ខន្ធានំ កដត្តា ច រូបានំ**

**កម្មប្បច្ចយេន បច្ចយោ ចេតនា វត្ថុស្ស កម្មប្បច្ចយេន បច្ចយោ** ។

អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយកម្មប្បច្ច័យ គឺ វិបាកាព្យាកតចេតនា និងកិរិយាព្យាកតចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ និងពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ក្នុងខណៈបដិសន្ធិ វិបាកាព្យាកតចេតនា ជាបច្ច័យនៃពួកសម្បយុត្តក-ក្ខន្ធ និងពួកកដត្តារូប ដោយកម្មប្បច្ច័យ ។ ចេតនាជាបច្ច័យនៃ វត្ថុ ដោយកម្មប្បច្ច័យ ។

## អព្ពធម៌

### ក-ក្នុងបវត្តិកាល

**បច្ច័យ** =ចេតនានៅក្នុងវិបាកចិត្ត ៥២ដួង និងកិរិយាចិត្ត២០ដួង (ត្រូវជាអព្យាកតចេតនា ៧២)។

**បច្ចយុប្បន្ន** =អព្យាកតចិត្ត៧២ដួង ចេតសិក៣៧ (វៀរចេតនា) អព្យាកតចិត្តសមុដ្ឋានរូប១៧ (ទ្វិបញ្ចវិញ្ញាណ១០ដួង អរូបាវចរ-វិបាកចិត្ត ៤ដួង បដិសន្ធិចិត្តទាំងអស់ និងចុតិចិត្តរបស់ព្រះអរហន្ត មិននាំឱ្យកើតចិត្តសមុដ្ឋានរូបឡើយ) ។

### ខ-ក្នុងបដិសន្ធិកាល

**បច្ច័យ** = ចេតនានៅក្នុងវិបាកបដិសន្ធិចិត្ត ១៩ដួង ។





**បច្ចយុប្បន្ន** = បដិសន្ធិចិត្ត១៩ដួង ចេតសិក៣៤ (វៀរចេតនា) បដិសន្ធិកម្មជរូប២០ (អរូបាវចរវិបាកចេតនា៤ មិននាំឱ្យកើតបដិសន្ធិកម្មជរូបឡើយ) ។

### គ-ចំពោះបញ្ចវោការភពបដិសន្ធិហទយវត្ថុកម្មជរូប

**បច្ច័យ** = ចេតនានៅក្នុងវិបាកបដិសន្ធិចិត្ត ១៥ដួង (វៀរអរូបា-វចរវិបាកចេតនា៤) ។

**បច្ចយុប្បន្ន** = បដិសន្ធិហទយវត្ថុ (តាមពិតបដិសន្ធិហទយវត្ថុ-កម្មជរូបនេះ រួមនៅក្នុងបដិសន្ធិកម្មជរូប២០ក្នុងចំណុច **ខ**រួចទៅហើយ ប៉ុន្តែដោយអំណាចហទយវត្ថុកម្មជរូបនេះ ជាទីអាស្រ័យនៃវិបាកបដិសន្ធិនៅក្នុងបញ្ចវោការភព ដោយអញ្ញមញ្ញប្បច្ច័យ ទើបសម្តែងបញ្ជាក់នៅក្នុងចំណុច **គ**បន្ថែមទៀត) ។

**អានអ្វី ?**

| | |
|---|---|
| សេចក្តីព្យាយាមនិងចិត្តអំណត់ | ជាគ្រូបង្ហាត់ឱ្យយើងចំណាំ |
| បើមិនសាងល្អជាប់ជាប្រចាំ | រស់រាប់រយឆ្នាំក៏ឥតមានន័យ។ |
| គ្រាន់តែពាក្យពិតរក្សាពុំបាន | តើឱ្យសន្តានសង្ឃឹមលើអ្វី |
| ឬអាងចាស់ស្លាប់ចាប់កំណើតថ្មី | ចុះស្លាប់ក្មេងវ័យនោះអាងអ្វីដែរ។ |

ដោយឧបាសក **គុយ-សុធន**

# នានាខណិកកម្មប្បច្ច័យ

**នានាខណិកកម្ម** គឺ កម្មក្នុងខណៈផ្សេងគ្នាអំពីផលវិបាក បានសេចក្តីថា កុសលកម្ម និងអកុសលកម្មដែលបានធ្វើរួចហើយ កន្លងទៅហើយជាអតីតៈ ជាបច្ច័យញ៉ាំងផលវិបាកឱ្យកើតឡើងតាមក្រោយ ដូច្នេះឈ្មោះថា នានាខណិកកម្មប្បច្ច័យ ។

## អង្គធម៌១៦ពួកនៃនានាខណិកកម្មប្បច្ច័យ

១.អកុសលនានាខណិកចេតនា១២ ជាបច្ច័យនៃអកុសល-វិបាកចិត្ត៧ដួង និងចេតសិកសម្បយុត្ត ព្រមទាំងអបាយបដិសន្ធិ-កម្មជរូប បវត្តិអនិដ្ឋកម្មជរូប ។

២.តិហេតុកុក្កដ្ឋមហាកុសលនានាខណិកចេតនា៤ ជាបច្ច័យនៃអហេតុកកុសលវិបាកចិត្ត៨ដួង មហាវិបាកចិត្ត៨ដួង និងចេតសិកសម្បយុត្ត ព្រមទាំងកាមសុគតិបដិសន្ធិកម្មជរូប បវត្តិ-ឥដ្ឋកម្មជរូប ។

៣.តិហេតុកោមកៈ និង ទុហេតុកុក្កដ្ឋមហាកុសលនានា-ខណិកចេតនា រួមជាចេតនា៨ ជាបច្ច័យនៃអហេតុកកុសលវិបាក-ចិត្ត៨ដួង មហាវិបាកញាណវិប្បយុត្តចិត្ត៤ដួង និងចេតសិកសម្បយុត្ត ព្រមទាំងកាមសុគតិបដិសន្ធិកម្មជរូប បវត្តិឥដ្ឋកម្មជរូប។

៤.ទុហេតុកោមកមហាកុសលនានាខណិកចេតនា៤ ជាបច្ច័យនៃអហេតុកកុសលវិបាកចិត្ត៨ដួង និងចេតសិកសម្បយុត្ត ព្រមទាំងកាមសុគតិអហេតុកបដិសន្ធិកម្មជរូប បវត្តិឥដ្ឋកម្មជរូប ។

៥.បឋមជ្ឈានកុសលនានាខណិកចេតនា១ ជាបច្ច័យនៃបឋមជ្ឈានវិបាកចិត្ត១ដួង និងចេតសិកសម្បយុត្ត ធ្វើកិច្ចបដិសន្ធិភវង្គចុតិក្នុងព្រហ្មបឋមជ្ឈានភូមិ ព្រមទាំងបដិសន្ធិកម្មជរូប បវត្តិ-ឥដ្ឋកម្មជរូបក្នុងភូមិនោះផង ។

៦.ទុតិយជ្ឈាន និងតតិយជ្ឈានកុសលនានាខណិកចេតនា រួមជាចេតនា២ ជាបច្ច័យនៃទុតិយជ្ឈានវិបាកចិត្ត និងតតិយជ្ឈាន-វិបាកចិត្ត រួមជាចិត្ត២ដួង និងចេតសិកសម្បយុត្ត ធ្វើកិច្ចបដិសន្ធិភវង្គចុតិក្នុងព្រហ្មទុតិយជ្ឈានភូមិ ព្រមទាំងបដិសន្ធិកម្មជរូប បវត្តិ-ឥដ្ឋកម្មជរូបក្នុងភូមិនោះផង ។

៧.ចតុត្ថជ្ឈានកុសលនានាខណិកចេតនា១ ជាបច្ច័យនៃចតុត្ថជ្ឈានវិបាកចិត្ត១ដួង និងចេតសិកសម្បយុត្ត ធ្វើកិច្ចបដិសន្ធិភវង្គចុតិក្នុងព្រហ្មតតិយជ្ឈានភូមិ ព្រមទាំងបដិសន្ធិកម្មជរូប បវត្តិ-ឥដ្ឋកម្មជរូបក្នុងភូមិនោះផង ។

៨.បញ្ចមជ្ឈានកុសលនានាខណិកចេតនា១ ជាបច្ច័យនៃ

បញ្ចមជ្ឈានវិបាកចិត្ត១ដួង និងចេតសិកសម្បយុត្ត ធ្វើកិច្ចបដិសន្ធិ ភវង្គចុតិក្នុងព្រហ្មចតុត្ថជ្ឈានភូមិ ព្រមទាំងបដិសន្ធិកម្មជ្ជរូប បវត្តិ-ឥដ្ឋកម្មជ្ជរូប អសញ្ញិសត្តកម្មជ្ជរូបក្នុងចតុត្ថជ្ឈានភូមិនោះផង ។

៩-អាកាសានញ្ចាយតនជ្ឈានកុសលនានាខណិកចេតនា១ ជាបច្ច័យនៃអាកាសានញ្ចាយតនជ្ឈានវិបាកចិត្ត១ដួង និងចេតសិកសម្បយុត្ត ធ្វើកិច្ចបដិសន្ធិភវង្គចុតិក្នុងអរូបព្រហ្មទី១ ។

១០-វិញ្ញាណញ្ចាយតនជ្ឈានកុសលនានាខណិកចេតនា១ ជាបច្ច័យនៃវិញ្ញាណញ្ចាយតនជ្ឈានវិបាកចិត្ត១ដួង និងចេតសិកសម្បយុត្ត ធ្វើកិច្ចបដិសន្ធិភវង្គចុតិក្នុងអរូបព្រហ្មទី២ ។

១១-អាកិញ្ចញ្ញាយតនជ្ឈានកុសលនានាខណិកចេតនា១ ជាបច្ច័យនៃអាកិញ្ចញ្ញាយតនជ្ឈានវិបាកចិត្ត១ដួង និងចេតសិកសម្បយុត្ត ធ្វើកិច្ចបដិសន្ធិភវង្គចុតិក្នុងអរូបព្រហ្មទី៣ ។

១២-នេវសញ្ញានាសញ្ញាយតនជ្ឈានកុសលនានាខណិក-ចេតនា១ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនជ្ឈានវិបាកចិត្ត១ដួង និងចេតសិកសម្បយុត្ត ធ្វើកិច្ចបដិសន្ធិភវង្គចុតិក្នុងអរូបព្រហ្មទី៤ ។

១៣-សោតាបត្តិមគ្គនានាខណិកចេតនា៥(គិតតាមឈាន) ជាបច្ច័យនៃសោតាបត្តិផលចិត្ត៥ដួង និងចេតសិកសម្បយុត្ត ។

១៤-សកទាគាមិមគ្គនានាខណិកចេតនា៥ ជាបច្ច័យនៃ





សកទាគាមិផលចិត្ត៥ដួង និងចេតសិកសម្បយុត្ត ។

១៥-អនាគាមិមគ្គនានាខណិកចេតនា៥ ជាបច្ច័យនៃអនាគាមិផលចិត្ត៥ដួង និងចេតសិកសម្បយុត្ត ។

១៦-អរហត្តមគ្គនានាខណិកចេតនា៥ ជាបច្ច័យនៃអរហត្ត-ផលចិត្ត៥ដួង និងចេតសិកសម្បយុត្ត ។

## បច្ច័យដែលជាសភាគ:

១-លោកិយកុសលចេតនា១៧ និងអកុសលចេតនា១២ ជានានាខណិកកម្មប្បច្ច័យ រមែងមាននូវបច្ច័យដែលជាសភាគ: ១ បច្ច័យ គឺ បកតូបនិស្សយប្បច្ច័យ ។

២-លោកុត្តរកុសលចេតនា២០ ជានានាខណិកកម្មប្បច្ច័យ ដល់លោកុត្តរវិបាកក្នុងមគ្គវិថី រមែងមាននូវបច្ច័យដែលជាសភាគ: ៥បច្ច័យ គឺ អនន្តរប្បច្ច័យ១ សមនន្តរប្បច្ច័យ១ អនន្តរូបនិស្ស-យប្បច្ច័យ១ នត្ថិប្បច្ច័យ១ និងវិគតប្បច្ច័យ១ ។

៣-លោកុត្តរកុសលចេតនា២០ ជានានាខណិកកម្មប្បច្ច័យ ដល់លោកុត្តរវិបាកក្នុងផលសមាបត្តិវិថី រមែងមាននូវបច្ច័យដែលជាសភាគ: ១បច្ច័យ គឺ បកតូបនិស្សយប្បច្ច័យ ។

## សេចក្ដីអធិប្បាយអំពីកម្មប្បច្ច័យ

ពាក្យថា **កម្មប្បច្ច័យ** នេះ គឺសំដៅដល់ការធ្វើណា ឬអំពើណាដែលចាត់ចែង តាក់តែងនូវបច្ចយុប្បន្នធម៌ (បច្ចយ +ឧប្បន្ន + ធម៌ = បច្ចយុប្បន្នធម៌ ប្រែថា ធម៌ដែលកើតឡើងអំពីបច្ច័យ ) ការធ្វើនោះ ឬអំពើនោះ ឈ្មោះថា កម្មប្បច្ច័យ ។ អង្គធម៌បានដល់ចេតនាចេតសិក ដូច្នេះ ចេតនាចេតសិកទើបជាតួកម្ម ដូចមានពុទ្ធភាសិត ដែលព្រះអង្គទ្រង់ត្រាស់នៅក្នុង និព្វេធិកសូត្រ អង្គុត្តរ-និកាយ ឆក្កនិបាត (បិដកលេខ៤៦ ទំព័រ២៧២ ) ថា « **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ចេតយិត្វា កម្មំ ករោតិ កាយេន វាចាយ មនសា** » ប្រែថា « ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាថាជាតួកម្ម ព្រោះបុគ្គលគិតហើយ ទើបធ្វើកម្មដោយកាយ វាចា ចិត្ត » ។

នៅក្នុងព្រះសូត្រនោះ ព្រះអង្គទ្រង់ត្រាស់សម្ដែងជាបន្តទៀតថា **កតមោ ច ភិក្ខវេ កម្មានំ និទានសម្ភវោ** ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលនាំឱ្យកើតកម្មទាំងឡាយ តើដូច-ម្ដេច ? **ផស្សោ ភិក្ខវេ កម្មានំ និទានសម្ភវោ** ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឱ្យកើតកម្មទាំងឡាយ ។ **កតមោ ច ភិក្ខវេ កម្មានំ វេមត្តតា** ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីប្លែក





គ្នានៃកម្មទាំងឡាយ តើដូចម្ដេច ? **អត្ថិ ភិក្ខវេ កម្មំ និរយ-វេទនិយំ អត្ថិ កម្មំ តិរច្ឆានយោនិវេទនិយំ អត្ថិ កម្មំ បេត្តិវិសយវេទនិយំ អត្ថិ កម្មំ មនុស្សលោកវេទនិយំ អត្ថិ កម្មំ ទេវលោកវេទនិយំ អយំ វុច្ចតិ ភិក្ខវេ កម្មានំ វេមត្តតា** ម្នាលភិក្ខុទាំងឡាយ កម្មនាំឱ្យទទួលផលក្នុងនរកក៏មាន កម្មនាំឱ្យទទួលផលក្នុងកំណើតសត្វតិរច្ឆានក៏មាន កម្មនាំឱ្យទទួលផលក្នុងប្រេតវិស័យ (ពពួកប្រេត ) ក៏មាន កម្មនាំឱ្យទទួលផលក្នុងមនុស្សលោកក៏មាន កម្មនាំឱ្យទទួលផលក្នុងទេវលោកក៏មាន ម្នាលភិក្ខុទាំងឡាយ នេះហៅថាសេចក្ដីប្លែកគ្នានៃកម្មទាំងឡាយ។ **កតមោ ច ភិក្ខវេ កម្មានំ វិបាកោ** ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់កម្មទាំងឡាយ តើដូចម្ដេច ? **តិវិធាហំ ភិក្ខវេ កម្មានំ វិបាកំ វទាមិ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ អយំ វុច្ចតិ ភិក្ខវេ កម្មានំ វិបាកោ** ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវវិបាករបស់កម្មទាំងឡាយថាមាន៣ប្រការ គឺវិបាករបស់កម្មក្នុងបច្ចុប្បន្ន១ វិបាករបស់កម្មក្នុងអត្តភាពបន្ទាប់១ វិបាករបស់កម្មក្នុងអត្តភាពជាលំដាប់ត១ (ចាប់អំពីភពទី៣ជាដើមទៅ )១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់កម្មទាំងឡាយ ។ រួចទៅព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីការ

រលត់កម្ម (កម្មនិរោធោ) និងបដិបទាទៅកាន់ការរលត់កម្ម (កម្មនិរោធគាមិនីបដិបទា)។

មនោរថបូរណី អដ្ឋកថា បានពន្យល់ថា បទថា **ចេតនាហំ** កាត់បទជា **ចេតនំ អហំ** នៅក្នុងបទថា **ចេតនាហំ** នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សំដៅយកចេតនាដែលមានការចាត់-ចែង មានការរួបរួមធម៌គ្រប់យ៉ាង ។ បទថា **ចេតយិត្វា** បានដល់ចេតនាដែលប្រព្រឹត្តទៅក្នុងទ្វារ បទថា **មនសា** បានដល់ចិត្តដែលសម្បយុត្តដោយចេតនា ។

គប្បីជ្រាបថា អំពើដែលធ្វើដោយកាយ ឬដោយវាចា ឬដោយចិត្ត ទោះជាកុសលក្តី អកុសលក្តី ត្រូវអាស្រ័យចេតនាជាធំជាប្រធានក្នុងការធ្វើនោះៗ។ ចេតនាប្រៀបដូចមេទ័ព សហជាត-ធម៌គឺចិត្ត ចេតសិក បដិសន្ធិកម្មជរូប និងចិត្តជរូប ដែលកើតព្រមជាមួយនឹងចេតនា ប្រៀបដូចជាកងទ័ព ។

**សហជាតកម្មប្បច្ច័យ** សំដៅដល់ចេតនាចេតសិកដែលជាតួកម្មនោះ កើតរួមជាមួយបច្ចុប្បន្នធម៌ និងជួយគាក់តែងនូវបច្ចុប្បន្នធម៌នោះផង ដោយសេចក្តីថា កាលសម្បយុត្តធម៌ គឺចិត្តនិងចេតសិក កំពុងធ្វើកិច្ចទទួលអារម្មណ៍ មានរូបារម្មណ៍ជាដើម ចេតនាចេតសិកដែលកើតរួមជាមួយនោះឯង ក៏ជួយចាត់ចែងគាក់តែង ក្នុងការទទួលអារម្មណ៍នោះៗ ឧទាហរណ៍ដូចជា ការ





ប៉ះនូវរូបារម្មណ៍ដោយចក្ខុ លោភមូលចិត្តនិងចេតសិកបានកើតឡើង ចេតនាចេតសិកក៏ជួយចាត់ចែងឱ្យលោភមូលចិត្តនោះ បានទទួលអារម្មណ៍ដោយពេញលេញស៊ប់សួន កាលលោភមូលចិត្តកើតឡើងដោយបរិបូណ៌ពេញលេញហើយ អាការរបស់កាយ ឬវាចា ដែលកើតឡើងអំពីលោភមូលចិត្តនោះ ក៏រមែងសម្តែងនូវអាការរបស់លោភៈចេញមក នេះដោយអំណាចនៃលោភមូល-ចេតនាហ្នឹងឯង យ៉ាងនេះជាដើម ទើបចេតនាចេតសិកនេះបានឈ្មោះថា សហជាតកម្មប្បច្ច័យ ។

**នានាខណិកកម្មប្បច្ច័យ** ចេតនាចេតសិកដែលជាតួកម្មនេះមានកិច្ចពីរយ៉ាងគឺ ÷

**១-សវិធានកិច្ច** មាននាទីចាត់ចែង ឬគាក់តែងឱ្យសម្រេចកិច្ច ក្នុងការកើតឡើងមួយខណៈៗនៃសម្បយុត្តធម៌ ដែលជាកុសលជាអកុសល ជាវិបាក និងជាកិរិយា ។

**២-ពីជនិធានកិច្ច** មាននាទីសាបព្រោះនូវពូជ ឬមានកិច្ចធ្វើជាពូជកប់ក្នុងសន្តានចិត្ត ដោយសេចក្តីថា កាលកុសលចេតនាឬអកុសលចេតនា កើតឡើងព្រមជាមួយនឹងចិត្ត រួចហើយក៏រលត់ទៅ ចេតនាចេតសិកនោះក៏មានអំណាចញ៉ាំងផលឱ្យប្រាកដឡើង

ក្នុងកាលជាខាងក្រោយ ។ ពីជនិធានកិច្ចនេះ មាននៅក្នុងតែកុសលចិត្តនិងអកុសលចិត្តប៉ុណ្ណោះ ។

ចំពោះចេតនាចេតសិកដែលធ្វើនូវសំវិធានកិច្ចនោះ បានសម្តែងហើយនៅក្នុងសហជាតកម្មប្បច្ច័យ គឺថា ចេតនាចេតសិកដែលកើតរួមជាមួយចិត្ត១២១ដួងហ្នឹងឯង ជាសហជាតប្បច្ច័យដោយធ្វើនូវសំវិធានកិច្ច ចំណែកពីជនិធានកិច្ចវិញ គឺនៅលើចេតនាចេតសិកដែលកើតក្នុងកុសលចិត្ត៣៧ដួង និងអកុសលចិត្ត១២ដួង ជានានាខណិកកម្មប្បច្ច័យ ដូច្នេះ ចេតនាចេតសិកក្នុងកុសលចិត្តនិងអកុសលចិត្ត រមែងធ្វើកិច្ចបានទាំងពីរ គឺធ្វើនូវសំវិធានកិច្ចផង ហើយធ្វើនូវពីជនិធានកិច្ចផង ។

នានាខណិកកម្មប្បច្ច័យ គឺចេតនាចេតសិកដែលជាតួកម្មហ្នឹងឯង រមែងកើតឡើងផ្សេងខណៈផ្សេងវេលាគ្នានឹងបច្ចុប្បន្ន-ធម៌ ដោយសេចក្តីថា ចេតនាចេតសិកដែលកើតឡើងក្នុងកុសល-ចិត្តនិងអកុសលចិត្តនោះ ធ្វើនូវសំវិធានកិច្ចរួចហើយរលត់ទៅ ក្នុងការរលត់ទៅនៃចេតនាចេតសិកនោះ មានអំណាចញ៉ាំងនូវបច្ចុ-យុប្បន្នធម៌ឱ្យកើតឡើងតាមក្រោយទៀតបាន ដូច្នេះ កាលខណៈនៃបច្ចុប្បន្នធម៌ ដែលជាផលកើតឡើងនោះ បច្ច័យដែលជាតួតាក់តែងមិនមានក្នុងខណៈនោះឡើយ ។





នៅក្នុងនានាខណិកកម្មប្បច្ច័យនេះ គប្បីជ្រាបនូវសេចក្តីបន្ថែមថា កុសលចេតនា និងអកុសលចេតនា ដែលជាអតីតៈ ទាំងក្នុងជាតិនេះ ទាំងក្នុងជាតិមុន ដែលរលត់ទៅហើយនោះជាបច្ច័យរឹងផលគឺវិបាកនាមក្ខន្ធ៤ និងកម្មជរូបដែលកើតឡើងក្នុងជាតិនេះ ឬដែលនឹងកើតឡើងក្នុងជាតិមុខតទៅនោះ ជាបច្ចុប្បន្នធម៌ ។ ជាបន្តទៅទៀតនេះ គឺជាការបកស្រាយនូវអង្គធម៌ផ្សេងៗ ក្នុង១៦ពួកខាងដើម ដែលសម្តែងអំពីនានាខណិកកម្មប្បច្ច័យ ។

## អធិប្បាយអំពីអង្គធម៌១៦ពួក

**១-អកុសលចេតនា**ព្រមដោយអកុសលចិត្ត បានកើតឡើងនៅពេលប្រព្រឹត្តទុច្ចរិតឯណានីមួយ ចេតនាចេតសិកនេះជាសហជាត-កម្មប្បច្ច័យ ។ ជាធម្មតានៃសង្ខារធម៌ រមែងកើតឡើងហើយរលត់ទៅវិញ កាលអកុសលចេតនារលត់ទៅ កន្លងទៅហើយ ក៏បានជាពូជកប់ទុកក្នុងចិត្ត ព្រោះធម្មជាតិចិត្ត តែងតែសន្សំនូវកម្មទុកសម្រាប់ឱ្យមានផលវិបាកតាមក្រោយ ពោលគឺខណៈចិត្តមុនដែលរលត់ទៅ បានជាបច្ច័យបញ្ជូននូវអ្វីៗដែលចិត្តសន្សំហើយ ឱ្យមកខណៈចិត្តក្រោយទាំងអស់ ។ អកុសលចេតនាជាពូជទុក្ខលំបាក ជាពូជអាយុខ្លី ជាពូជក្រ ជាពូជថោកទាប។ល។ ព្រោះហេតុនេះទើប

បានជានៅពេលអកុសលចេតនាកើតឡើង រមែងធ្វើឱ្យអ្នកដទៃរង ទុក្ខលំបាកស្លាប់បាត់បង់ជីវិត វិនាសអស់ទ្រព្យសម្បត្តិជាដើម ។

ជាធម្មតាក្នុងលោក បើគេដាំពូជយ៉ាងណា គេរមែងបាន ផលផ្លែផ្កាយ៉ាងនោះ ដូច្នេះ អកុសលចេតនាជាពូជទុក្ខលំបាកមាន ច្រើនប្រភេទ កាលបើជានានាខណិកកម្មប្បច្ច័យហើយ ទុក្ខលំបាក ជាផលរមែងកើតឡើងទៅតាមប្រភេទនៃពូជនោះៗ ។

អកុសលចេតនាជានានាខណិកកម្មប្បច្ច័យ ញ៉ាំងនូវអកុ-សលវិបាកចិត្ត៧ដួងឱ្យកើតឡើង ព្រមដោយចេតសិកដែលប្រកប ជាមួយនឹងចិត្តនោះៗ ។ អកុសលវិបាកចិត្ត៧ដួងគឺ ÷

១-ចក្ខុវិញ្ញាណ ឃើញរូបមិនល្អ

២-សោតវិញ្ញាណ ឮសំឡេងមិនល្អ

៣-ឃានវិញ្ញាណ ធុំក្លិនមិនល្អ

៤-ជិវ្ហាវិញ្ញាណ ដឹងរសមិនល្អ

៥-កាយវិញ្ញាណ ដឹងផោដ្ឋព្វៈមិនល្អ (កាយវិញ្ញាណនេះ ប្រកបដោយទុក្ខវេទនា)

៦-វិបាកមនោធាតុ ទទួលអារម្មណ៍មិនល្អបន្តអំពីបញ្ច-វិញ្ញាណណាមួយ

៧-វិបាកមនោវិញ្ញាណធាតុ ដឹងអារម្មណ៍មិនល្អដោយកិច្ច





ផ្សេងៗ ជាពិសេសបដិសន្ធិកិច្ចក្នុងអបាយភូមិ៤ គឺនរក ប្រេត តិរច្ឆាន អសុរកាយ ។

អកុសលចេតនាជានានាខណិកកម្មប្បច្ច័យ ញ៉ាំងអកុសល-វិបាកមនោវិញ្ញាណធាតុ ១ ដួង ឱ្យធ្វើកិច្ចបដិសន្ធិភវង្គចុតិក្នុង អបាយភូមិ៤ណាមួយ តាមអំណាចនៃអកុសលចេតនានោះជា ជនកកម្មហ្នឹងឯង។ ព្រមជាមួយនឹងអកុសលវិបាកបដិសន្ធិ ក៏មាន កម្មជរូបកើតឡើងផងដែរ ពោលគឺអកុសលចេតនា មិនត្រឹមតែ ជានានាខណិកកម្មប្បច្ច័យនៃអកុសលវិបាកបដិសន្ធិប៉ុណ្ណោះទេ គឺ នៅជានានាខណិកកម្មប្បច្ច័យនៃកម្មជរូបទៀត ធ្វើឱ្យអបាយភូមិ៤ ជាបញ្ចវោការភព ។

បញ្ចវោការភព គឺ ភពដែលមានខន្ធផ្សេងគ្នាជា ៥ពួក គឺ បដិសន្ធិកម្មជរូបជារូបក្ខន្ធ ឯចំណែកវិបាកបដិសន្ធិ មាននាមក្ខន្ធ៤ គឺវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ។

សត្វនៅក្នុងអបាយភូមិ៤ រាប់ចំនួនមិនអស់ ប៉ុន្តែសត្វទាំង អស់នេះបដិសន្ធិដោយអកុសលវិបាកទី៧ដូចគ្នា គឺអកុសលវិបាក-មនោវិញ្ញាណធាតុ ព្រោះហេតុនេះទើបសត្វក្នុងអបាយភូមិ៤ មាន ឈ្មោះថា **សត្តា នានត្តកាយា ឯកត្តសញ្ញិនោ** សត្វទាំងឡាយ មានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នា ពោលគឺសញ្ញាបដិសន្ធិ

ដោយអកុសលវិបាកហ្នឹងឯង ។

ពាក្យថា បវត្តិអនិដ្ឋកម្មជ្ជរូប គឺកម្មជ្ជរូបដែលមិនល្អប្រសើរ មិនជាទីប្រាថ្នា ព្រោះកើតអំពីបាបកម្មជាបច្ច័យ ប្រព្រឹត្តទៅក្នុងជីវិតរស់នៅបន្ទាប់ពីបដិសន្ធិរួចហើយ ។

អកុសលចេតនាជានានាខណិកកម្មប្បច្ច័យ ញ៉ាំងផលមិនល្អឱ្យកើតឡើងក្នុងបវត្តិកាល សូម្បីតែក្នុងជីវិតរស់នៅរបស់មនុស្សយើង ដូចជាចក្ខុវិញ្ញាណឃើញរូបមិនល្អ ឬកាយវិញ្ញាណដែលប្រកបដោយទុក្ខវេទនាជាដើម មួយអន្លើដោយរូបកាយដែលមានរោគផ្សេង១ និងសភាពដែលជាអនិដ្ឋារម្មណ៍ផ្សេង១ទៀត ។ អកុ-សលវិបាកផ្សេង១ក្នុងបច្ចុប្បន្ននៃជីវិតមនុស្សយើង ជាសភាវធម៌ពិត មានពិត កើតឡើងពិត ហាមឃាត់មិនបានយ៉ាងណា អកុសលវិបាកដែលធ្វើកិច្ចបដិសន្ធិបន្ទាប់ពីស្លាប់ទៅ ក៏ហាមឃាត់មិនបានដូចគ្នាយ៉ាងនោះដែរ កាលណាបើអកុសលចេតនាជានានាខណិកកម្មប្បច្ច័យហើយនោះ ។

**២-តិហេតុកុក្កដ្ឋមហាកុសលចេតនា** បានសេចក្តីថា មហាកុសលដែលប្រកបដោយហេតុ៣ គឺ អលោភៈ១ អទោសៈ១ និង អមោហៈ១ ប្រព្រឹត្តទៅក្នុងទានសីលភាវនា ។ កាលដែលបានធ្វើនូវកុសលណាមួយរួចស្រេចហើយ ក៏រមែងជ្រះថ្លាដោយអបរចេតនា





គឺចេតនាដែលជ្រះថ្លាត្រេកអរតាមក្រោយ ដូច្នេះ ក្នុងការបំពេញនូវកុសលកម្មអ្វីមួយ មានទានកុសលជាដើម បើសម្បូណ៌ទៅដោយសេចក្តីជ្រះថ្លា នៅជុំវិញកុសលកម្មនោះ កុសលកម្មនោះក៏ទៅជាឧក្រិដ្ឋ ។

**តិហេតុក + ឧក្កដ្ឋ = តិហេតុកុក្កដ្ឋ** គឺជាមហាកុសលកម្មប្រកបដោយហេតុ៣ (តិហេតុកៈ) ទាំងជាមហាកុសលឧក្រិដ្ឋ (ឧក្កដ្ឋៈ) ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តមក្រៃលែង ។

តិហេតុកុក្កដ្ឋមហាកុសលចេតនាជានានាខណិកកម្មប្បច្ច័យនៃកុសលវិបាកអហេតុក៨ គឺ ÷

១-ចក្ខុវិញ្ញាណ ឃើញរូបល្អ

២-សោតវិញ្ញាណ ឮសំឡេងល្អ

៣-ឃានវិញ្ញាណ ធុំក្លិនល្អ

៤-ជិវ្ហាវិញ្ញាណ ដឹងរសល្អ

៥-កាយវិញ្ញាណ ដឹងផោដ្ឋព្វៈល្អ (កាយវិញ្ញាណនេះប្រកបដោយសុខវេទនា)

៦-វិបាកមនោធាតុ ទទួលអារម្មណ៍ល្អបន្តអំពីបញ្ចវិញ្ញាណណាមួយ នៅក្នុងបញ្ចទ្វារ

៧-វិបាកមនោវិញ្ញាណធាតុ ដឹងអារម្មណ៍ល្អដោយកិច្ច

ផ្សេងៗ ប្រកបដោយសោមនស្សវេទនាតាមទ្វារ៦

៨-វិបាកមនោវិញ្ញាណធាតុ ដឹងអារម្មណ៍ល្អដោយកិច្ចផ្សេងៗ ប្រកបដោយឧបេក្ខាវេទនាតាមទ្វារ៦ ។

តិហេតុកុក្កដ្ឋមហាកុសលចេតនានេះ នៅជានានាខណិក-កម្មប្បច្ច័យ នៃមហាវិបាកចិត្ត៨ដួងព្រមដោយចេតសិកសម្បយុត្តទៀត ហើយក្នុងមហាវិបាក៨ដួងនេះ មានមហាវិបាកដួង១ដែលប្រកបដោយបញ្ញា ធ្វើកិច្ចបដិសន្ធិក្នុងកាមសុគតិភព៧ជាន់ (គឺមនុស្ស១ជាន់ និងទេវតា៦ជាន់ ) ជាន់ណាមួយ ។ កាលបើបដិសន្ធិដោយវិបាកចិត្តបែបនេះហើយ ក៏ជាអ្នកសម្បូណ៌ទៅដោយបញ្ញាក្នុងជីវិតរស់នៅ ឆ្លាត ឈ្លាសវៃ នេះដោយឧបនិស្ស័យល្អដាស់តឿនផង ។ ទោះជាឆ្លាតយ៉ាងណាក៏ដោយ គឺត្រឹមតែជាសភាវធម៌ដែលកើតឡើងព្រោះអាស្រ័យបច្ច័យប៉ុណ្ណោះ បញ្ញាជាបរមត្ថ មិនមែនជាសត្វបុគ្គលឡើយ ឯការដែលអាចដឹងនូវសភាវ-ធម៌តាមសេចក្តីពិតបានយ៉ាងនេះ ក៏ព្រោះមកអំពីមានបញ្ញាកើតឡើងហ្នឹងឯង ។

នៅមានកាមសុគតិបដិសន្ធិកម្មជរូប និងបវត្តិឥដ្ឋកម្មជរូបទៀត ពាក្យថា បវត្តិឥដ្ឋកម្មជរូប បានដល់ កម្មជរូបដែលល្អស្អាតគួរជាទីប្រាថ្នា ប្រព្រឹត្តទៅក្នុងជីវិតរស់នៅ បន្ទាប់អំពីបដិសន្ធិជា





មនុស្ស ឬជាទេវតារួចហើយនោះ ។

សរុបមក តិហេតុកុក្កដ្ឋមហាកុសលចេតនា ជានានា-ខណិកកម្មប្បច្ច័យនៃមហាវិបាកញាណសម្បយុត្តបដិសន្ធិ ពោលគឺឱ្យបដិសន្ធិប្រកបដោយបញ្ញាក្នុងកាមសុគតិភព ព្រមដោយកម្មជរូបក្នុងសុគតិភពនោះ បន្ទាប់មកក្នុងជីវិតរស់នៅនៃអត្តភាពនោះឯងរមែងឱ្យឃើញនូវរូបល្អ ឱ្យឮនូវសំឡេងល្អ ឱ្យដឹងនូវអារម្មណ៍ផ្សេងៗទៀតសុទ្ធតែល្អៗ ឱ្យមានអាយុវែងក្នុងសេចក្តីសុខ ឱ្យមានវណ្ណៈគឺពណ៌សម្បុរល្អស្អាត ឱ្យនូវសេចក្តីសុខកាយ មាននូវកម្លាំងប្រាសចាករោគ ឱ្យនូវយស ឱ្យនូវអធិបតី ។ល។

**៣-តិហេតុកោមក:** គឺមហាកុសលចេតនាដែលប្រកបដោយហេតុ៣ បានដល់ អលោភ: អទោស: និងអមោហ: **ឱមក:** ប្រែថា ទន់ខ្សោយ អន់ថយ ព្រោះខ្វះសេចក្តីជ្រះថ្លាត្រេកអរជុំវិញមុញ្ចនចេតនាក្នុងកុសលកម្មឯណានីមួយនោះ ជាពិសេសខ្វះនូវអបរចេតនា ជ្រះថ្លាត្រេកអរនៅពេលធ្វើបុណ្យហើយភ្លាមៗនោះឯង (តិហេតុក +ឱមក =តិហេតុកោមក ) ។

តិហេតុកោមកមហាកុសលចេតនា ជានានាខណិកកម្មប្ប-ច្ច័យឱ្យមហាវិបាកញាណវិប្បយុត្តបដិសន្ធិ ពោលគឺបដិសន្ធិជាមនុស្ស ឬទេវតា ដោយមហាវិបាកដែលប្រាសចាកនូវបញ្ញា នេះ

ព្រោះហេតុតែមហាកុសលចេតនាដែលប្រកបដោយបញ្ញា ជានា-នាខណិកកម្មប្បច្ច័យនោះ មានកម្លាំងខ្សោយហ្នឹងឯង ។

**ទុហេតុកុក្កដ្ឋមហាកុសលចេតនា** គឺចេតនាមហាកុសលប្រកបដោយហេតុ២ បានដល់ អលោភៈ និងអទោសៈ (ខ្វះបញ្ញាក្នុងមហាកុសលនោះ ) ប៉ុន្តែជាមហាកុសលឧក្រិដ្ឋ ដោយបានហាមឃាត់នូវការសៅហ្មងចិត្តក្នុងពេលធ្វើបុណ្យនោះរួចហើយ ពោលគឺមាននូវអបរចេតនាជ្រះថ្លាតាមក្រោយ ។

ទុហេតុកុក្កដ្ឋមហាកុសលចេតនាជានានាខណិកកម្មប្បច្ច័យឱ្យមហាកុសលញាណវិប្បយុត្តបដិសន្ធិ ដូចគ្នានឹងតិហេតុកោមក-មហាកុសលចេតនាដែរ ។

ក្នុងនានាខណិកកម្មប្បច្ច័យពួកទី៣នេះបានឱ្យវិបាកបដិសន្ធិមិនប្រកបដោយបញ្ញា បដិសន្ធិកម្មជរូប និងបវត្តិកម្មជរូប នេះជាផលរបស់កម្មដែលប្រព្រឹត្តទៅទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ទើបមានការសន្មតថាសត្វលោក ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងនៅក្នុងវាសេដ្ឋសូត្រថា **កម្មុនា វត្តតី លោកោ** ប្រែថា សត្វលោករមែងប្រព្រឹត្តទៅតាមកម្ម ។ មនុស្ស និងទេវតាណាដែលបដិសន្ធិដោយមហាវិបាកប្រភេទបែបនេះ រមែងជាអ្នកខ្វះឧបនិស្ស័យនៃបញ្ញា មិនអាចជាអ្នកបានសម្រេចនូវ





ឈានសមាបត្តិ និងលោកុត្តរសម្បត្តិក្នុងអត្តភាពហ្នឹងឡើយ ទោះជាខំប្រឹងយ៉ាងណាក៏ដោយ នេះព្រោះមកអំពីវិបាកធ្វើនូវសេចក្តីអន្តរាយ ។

**៤-ទុហេតុកោមកមហាកុសលចេតនា** គឺជាមហាកុសលចេតនាដែលទន់ខ្សោយជាងគេ ព្រោះអត់បញ្ញាផង ខ្វះនូវសេចក្តីជ្រះថ្លាជុំវិញការងារជាបុណ្យកុសលនោះផង ម្ល៉ោះហើយកាលបើកុសលកម្មប្រភេទនេះជានានាខណិកកម្មប្បច្ច័យ ក៏ឱ្យបដិសន្ធិជាអហេតុក-វិបាកក្នុងកំណើតមនុស្ស និងទេវតាថ្នាក់ក្រោម អាចពិការអវយវៈ មានរូបមិនគ្រប់គ្រាន់ មិនមាំមួន ប្រៀបបីដូចអ្នកដែលខ្វះប្រាក់ទៅផ្សារទិញសម្ភារៈប្រើប្រាស់ បានតែរបស់អន់និងមិនគ្រប់គ្រឿងដូច្នោះឯង ។

មនុស្សនិងទេវតាគ្រាន់តែជាបុគ្គលប្បញ្ញត្តិប៉ុណ្ណោះ ដោយពិតដោយបរមត្ថ គឺជាបញ្ចវោការភព (បានដល់ការកើតឡើងនៃខន្ធមានសភាពផ្សេងគ្នាជា៥ចំណែក )ជាឧបបត្តិភព ជាសញ្ញាភព និងជាកាមភព ។

ក្នុងកំណើតមនុស្សនិងទេវតា រួមមកហៅថា **សត្តា នា-នត្តកាយា នានត្តសញ្ញិនោ** សត្វទាំងឡាយមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដែលថាសញ្ញាផ្សេងគ្នា ព្រោះមនុស្សនិងទេវតាខ្វះ

បដិសន្ធិដោយអហេតុកវិបាក មនុស្សនិងទេវតាខ្លះបដិសន្ធិដោយទុហេតុកវិបាក ហើយមនុស្សនិងទេវតាខ្លះទៀតនោះបដិសន្ធិដោយតិហេតុកវិបាក ដូចនេះហៅថាសញ្ញាផ្សេងគ្នា ។ ពួកវិនិបាតិកាសុរមានបិយង្ករមាតា ឧត្តរមាតាជាដើម(ក្នុងសំយុត្តនិកាយ សគាថវគ្គយក្ខសំយុត្ត ) ពួកនេះនៅលើផែនដី តាមព្រៃភ្នំ ហើយស្វែងរកនូវអាហារស្មោកគ្រោក តាមភូមិស្រុកដែលមានមនុស្សរស់នៅ និងពួកអសុរកាយដែលធ្លាក់ចុះពីឋានតាវត្តិង្ស មកនៅក្នុងវិមានបាតភ្នំសិនេរុ ក៏មានកាយផ្សេងគ្នា និងមានសញ្ញាផ្សេងគ្នាផងដែរ ។

សរុបមក មហាកុសលចេតនា៨ អាចឱ្យវិបាកបដិសន្ធិ៩ដួង គឺ មហាវិបាកចិត្ត៨ដួង និងកុសលវិបាកអហេតុកចិត្ត១ដួង នៅក្នុងកាមសុគតិភព៧ជាន់ ដូច្នេះនៅក្នុងកាមភព១១ជាន់ (កាមសុគតិ-ភព៧ និងអបាយភូមិ៤ ) ត្រូវមានវិបាកបដិសន្ធិចិត្ត១០ដួង គឺកាម-សុគតិភព៧ មានវិបាកបដិសន្ធិចិត្ត៩ដួង និងអបាយភូមិ៤មានវិបាកបដិសន្ធិចិត្ត១ដួង ។

មនុស្សយើងមានអធ្យាស្រ័យផ្សេងៗគ្នា ពាក្យថាអធ្យា-ស្រ័យ បានដល់ សភាវធម៌ជាឧបនិស្ស័យដេកអាស្រ័យនៅក្នុងចិត្ត គឺជាចំណង់ចំណូលចិត្ត ជាសភាវធម៌ពិត ជាខ្សែឧបនិស្ស័យក្នុងចិត្ត ពុំមែនសត្វ ពុំមែនជាតួខ្លួនយើងឡើយ ។





មនុស្សខ្លះច្រើនដោយលោភៈ ចង់តែបានរបស់នេះ របស់នោះ ប៉ុន្តែ ឆ្លាតនិងមិនសូវចេះខឹងក្រោធផ្តេសផ្តាសឡើយ នេះមកអំពីកុសលកម្មអ្វីមួយនោះ មានអលោភៈខ្សោយ តែអទោសៈខ្លាំង អមោហៈខ្លាំង ហើយជានានាខណិកកម្មប្បច្ច័យឱ្យវិបាកបដិសន្ធិជាមនុស្សហ្នឹងឯង ។ បានជាកុសលកម្មនោះឯងមានអលោភៈខ្សោយ ព្រោះក្នុងពេលធ្វើបុណ្យនោះច្រើនដោយលោភៈ ច្រើនដោយសេចក្តីប្រាថ្នា ។

មនុស្សខ្លះច្រើនដោយទោសៈ នេះព្រោះបដិសន្ធិដោយវិបាករបស់កម្មដែលមានអទោសៈខ្សោយ ។ បានជាកុសលកម្មនោះមានអទោសៈខ្សោយ ព្រោះនៅពេលធ្វើបុណ្យនោះឯងច្រើនដោយការខឹងក្រោធ មួម៉ៅក្តៅក្រហាយនឹងរឿងផ្សេងៗ ចូលមកជ្រៀតជ្រែកកុសល ។

មនុស្សខ្លះល្ងង់ខ្លៅមិនសូវឆ្លាត ខ្លះទៀតល្ងង់ទាល់តែមែនទែន ព្រោះមកអំពីបដិសន្ធិដោយវិបាករបស់កម្ម ដែលកម្មនោះមានអមោហៈខ្សោយ ឬប្រាសចាកអមោហៈ គឺបញ្ញាតែម្តង ។ បានជាកុសលកម្មនោះមានអមោហៈខ្សោយ ឬអត់អមោហៈតែម្តង ព្រោះខ្វះការស្តាប់ធម៌ ខ្វះការយល់ដឹងរហូតមក ដល់ពេលធ្វើបុណ្យអ្វីមួយ គឺធ្វើទាំងងងឹតល្ងង់គ្មានបញ្ញាយល់ដឹងអ្វីទាំងអស់

ម៉្លោះហើយកាលបើកុសលកម្មនេះជានានាខណិកកម្មប្បច្ច័យ ក៏ឱ្យវិបាកបដិសន្ធិជាមនុស្សល្ងង់ម្នាក់អីចឹងទៅ (វិបាកបដិសន្ធិមិនមែនជាមនុស្សទេ ប៉ុន្តែដែលថាជាមនុស្សព្រោះសន្មតទៅលើបញ្ចក្ខន្ធដែលកើតឡើងមានសភាពផ្សេងៗគ្នាហ្នឹងឯង ) ។

មនុស្សយើងនៅមានអធ្យាស្រ័យខុសគ្នា ផ្សេងគ្នាច្រើនយ៉ាងទៀតណាស់ ខ្លះច្រើនដោយអលោភៈ ខ្លះច្រើនដោយអទោសៈ ខ្លះច្រើនដោយអមោហៈ ខ្លះច្រើនដោយអលោភៈនិងអទោសៈ ខ្លះទៀតច្រើនដោយធម៌ទាំង៣គឺអលោភៈ អទោសៈនិងអមោហៈ ។ល។ ដូចបានសម្តែងប្រាប់ខាងដើមហើយថាអធ្យាស្រ័យបានដល់ សភាវធម៌ជាឧបនិស្ស័យដេកអាស្រ័យនៅក្នុងចិត្ត ខ្លះចូលចិត្តយ៉ាងនេះ ខ្លះចូលចិត្តយ៉ាងនោះ ច្រើនបែបច្រើនយ៉ាងជាទីបំផុត ដូច្នេះ **យើងមិនត្រូវយកអធ្យាស្រ័យរបស់យើងទៅវិនិច្ឆ័យវែកញែកចំពោះអធ្យាស្រ័យរបស់អ្នកដទៃឡើយ** ព្រោះអធ្យាស្រ័យគឺជាសភាវធម៌ ចំណង់ចំណូលចិត្ត ធ្លាប់សន្សំក្នុងចិត្តប្រព្រឹត្តទៅតាមបច្ច័យផ្សេងៗគ្នា បច្ច័យខ្លះមានពីអតីតជាតិ បច្ច័យខ្លះមានក្នុងបច្ចុប្បន្នជាតិ ។

នៅក្នុងព្រះពុទ្ធសាសនា មានគោលធម៌បដិបត្តិ១សំខាន់ជាទីបំផុត គឺ **យោនិសោមនសិការ** បានដល់ ការធ្វើទុកក្នុងចិត្ត



ដោយឧបាយត្រូវទំនង ពោលគឺត្រូវតាមហេតុផលរបស់ធម្មជាតិ ។ ការដែលមាននូវយោនិសោមនសិការ វិនិច្ឆ័យទៅលើអធ្យាស្រ័យរបស់អ្នកដទៃ រមែងទប់ស្កាត់បាននូវការស្រឡាញ់ស្អប់ ធ្វើឱ្យអភិជ្ឈាតណ្ហាមិនអាចដឹកនាំគំនិតទៅបានឡើយ ដូច្នេះ **យើងត្រូវយកយោនិសោមនសិការ ទៅវិនិច្ឆ័យវែកញែកចំពោះអធ្យាស្រ័យរបស់អ្នកដទៃវិញ** ដើម្បីបាននូវបញ្ញាដឹកនាំគំនិត ដឹកនាំជីវិតឈានទៅរកភាពភ្លឺស្វាង ។

យោនិសោមនសិការ រមែងចម្រើនដោយអង្គប្រកបទាំងក្រៅទាំងក្នុង អង្គប្រកបខាងក្រៅគឺការគប់រកកល្យាណមិត្តដែលជាហេតុនាំឱ្យបានស្តាប់ធម៌ ស្តាប់ពាក្យពន្យល់ពីហេតុផលផ្សេងៗព្រមទាំងឧស្សាហ៍អានគម្ពីរធម៌ និងសៀវភៅល្អៗផ្សេងៗទៀតផងចំណែកអង្គប្រកបខាងក្នុង បានដល់សទ្ធា ដែលសទ្ធានេះប្រៀបបីដូចជាការជីកប្រឡាយបង្ហូរទឹក រីឯយោនិសោមនសិការ ប្រៀបបីដូចជាទឹកដែលហូរតាមប្រឡាយហ្នឹងឯង ។

នៅក្នុងតណ្ហាសូត្រ អង្គុត្តរនិកាយ ទសកនិបាត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា ការសេពគប់នឹងសប្បុរសជាអាហារនៃការស្តាប់ធម៌ ការស្តាប់ធម៌ជាអាហារនៃសទ្ធា សទ្ធាជាអាហារនៃយោនិសោមនសិការ យោនិសោមនសិការជាអាហារ

នៃសតិសម្បជញ្ញៈ សតិសម្បជញ្ញៈជាអាហារនៃការសង្រួមឥន្ទ្រិយ ការសង្រួមឥន្ទ្រិយជាអាហារនៃសុចរិត៣ សុចរិត៣ជាអាហារនៃសតិប្បដ្ឋាន៤ សតិប្បដ្ឋាន៤ជាអាហារនៃពោជ្ឈង្គ៧ ពោជ្ឈង្គ៧ជាអាហារនៃវិជ្ជានិងវិមុត្តិ ។

**៥-បឋមជ្ឈានកុសលចេតនា** ជានានាខណិកកម្មប្បច្ច័យ ឱ្យបឋ-មជ្ឈានវិបាកបដិសន្ធិក្នុងព្រហ្មបឋមជ្ឈានភូមិ៣ឋាន គឺឋានព្រហ្មបារិសជ្ជា១ ឋានព្រហ្មបុរោហិតា១ និងឋានមហាព្រហ្មា១ ។

ព្រហ្មបឋមជ្ឈានភូមិ៣ឋាននេះ ជាបញ្ចវោការភព ជា **សត្តា នានត្តកាយា ឯកត្តសញ្ញិនោ** សត្វទាំងឡាយមានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នា ដែលថាមានសញ្ញាដូចគ្នា ព្រោះបដិសន្ធិដោយបឋមជ្ឈានវិបាកដូចគ្នា ។

មានមនុស្សចំនួនច្រើននាក់ដែលយល់ឃើញថាមហាព្រហ្មជាអ្នកបង្កើតផែនដីព្រៃភ្នំទន្លេសមុទ្រ ព្រះអាទិត្យព្រះចន្ទ ។ល។ ព្រមទាំងសត្វលោក ដូច្នេះទើបមានពាក្យ «ព្រហ្មលិខិត» រហូតមកដល់សព្វថ្ងៃនេះ ប៉ុន្តែតាមច្បាប់ធម្មជាតិ អ្វីៗរមែងកើតអំពីហេតុ សូម្បីមហាព្រហ្មខ្លួនឯងក៏ត្រឹមតែខន្ធ៥ប៉ុណ្ណោះ ខណៈបដិសន្ធិមានកម្មជរូប (រូបដែលកើតអំពីកម្ម) និងវិបាកនាមក្ខន្ធ៤ ដែលជាផលរបស់នានាខណិកកម្មប្បច្ច័យ ឯពាក្យថាមហាព្រហ្មគឺ





ជាបញ្ញត្តិ ជាការសន្មតចំពោះនាមរូបដែលកើតឡើងហ្នឹងឯង ។

**៦-ទុតិយជ្ឈានកុសលចេតនា** និង **តតិយជ្ឈានកុសលចេតនា** ជានានា-ខណិកកម្មប្បច្ច័យ ឱ្យវិបាកបដិសន្ធិក្នុងព្រហ្មទុតិយជ្ឈានភូមិ៣ឋាន គឺ ឋានព្រហ្មបរិត្តាភា១ ឋានព្រហ្មអប្បមាណាភា១ និងឋានព្រហ្មអាភស្សរា១ ។

ព្រហ្មទុតិយជ្ឈានភូមិ ៣ឋាននេះ ឈ្មោះថា **សត្តា ឯកត្តកាយា នានត្តសញ្ញិនោ** សត្វទាំងឡាយមានកាយដូចគ្នា តែមានសញ្ញាផ្សេងគ្នា ដែលថាសញ្ញាផ្សេងគ្នា ព្រោះព្រហ្មខ្លះបដិសន្ធិដោយទុតិយជ្ឈានវិបាក ព្រហ្មខ្លះទៀតបដិសន្ធិដោយតតិយជ្ឈាន-វិបាក ។

**៧-ចតុត្ថជ្ឈានកុសលចេតនា** ជានានាខណិកកម្មប្បច្ច័យ ឱ្យចតុត្ថជ្ឈានវិបាកបដិសន្ធិក្នុងព្រហ្មតតិយជ្ឈានភូមិ ៣ឋាន គឺ ឋានព្រហ្មបរិត្តសុភា១ ឋានព្រហ្មអប្បមាណសុភា១ និងឋានព្រហ្មសុភកិណ្ហា១ ។

**៨-បញ្ចមជ្ឈានកុសលចេតនា** ជានានាខណិកកម្មប្បច្ច័យ ឱ្យបញ្ច-មជ្ឈានវិបាកបដិសន្ធិក្នុងព្រហ្មចតុត្ថជ្ឈានភូមិ ៦ឋាន គឺ ឋានព្រហ្មវេហប្ផលា១ និងឋានព្រហ្មសុទ្ធាវាស៥ (អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា) ម្យ៉ាងទៀត បញ្ចមជ្ឈានកុសលចេតនា ដែល

ជាសញ្ញាវិរាគភាវនា (ចម្រើននូវការប្រាសចាកសេចក្ដីត្រេកអរចំពោះសញ្ញា ) ជានានាខណិកកម្មប្បច្ច័យនៃរូបបដិសន្ធិតែម្យ៉ាងក្នុងអសញ្ញិសត្តាភូមិ ដូច្នេះ ព្រហ្មចតុត្ថជ្ឈានភូមិត្រូវជា ៧ឋាន ដោយរួមអសញ្ញិសត្តាភូមិនេះ១ឋានផង ។

ព្រហ្មតតិយជ្ឈានភូមិ៣ឋាន និងព្រហ្មចតុត្ថជ្ឈានភូមិ៦ឋាន (វៀរអសញ្ញិសត្តាភូមិ ) ត្រូវជា ៩ឋាននេះជាបញ្ចវោការភព និងជា **សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ** សត្វទាំងឡាយ មានកាយដូចគ្នា មានសញ្ញាដូចគ្នា គឺមានសញ្ញាបដិសន្ធិដូចគ្នាតាមភូមិនោះ ៗ ។

សរុបរួម **រូបភព១៦ឋាន** គឺ បឋមជ្ឈានភូមិ៣ឋាន ទុតិយជ្ឈានភូមិ ៣ឋាន តតិយជ្ឈានភូមិ៣ឋាន និងចតុត្ថជ្ឈានភូមិ៧ឋាន ចែកទៅជាសញ្ញាភព១៥ឋាន អសញ្ញាភព១ឋាន (អសញ្ញាភព = ឯកវោការភព ព្រោះមានតែរូបក្ខន្ធប៉ុណ្ណោះ ) ។

**៩ -អរូបជ្ឈានកុសលចេតនាទី១** ជានានាខណិកកម្មប្បច្ច័យ ឱ្យអរូបវិបាកបដិសន្ធិក្នុងអរូបព្រហ្មទី១ ។

**១០ -អរូបជ្ឈានកុសលចេតនាទី២** ជានានាខណិកកម្មប្បច្ច័យ ឱ្យអរូបវិបាកបដិសន្ធិក្នុងអរូបព្រហ្មទី២ ។

**១១ -អរូបជ្ឈានកុសលចេតនាទី៣** ជានានាខណិកកម្មប្បច្ច័យ ឱ្យ





អរូបវិបាកបដិសន្ធិក្នុងអរូបព្រហ្មទី៣ ។

**១២ -អរូបជ្ឈានកុសលចេតនាទី៤** ជានានាខណិកកម្មប្បច្ច័យ ឱ្យអរូបវិបាកបដិសន្ធិក្នុងអរូបព្រហ្មទី៤ ។

អរូបព្រហ្មទាំង៤ឋាននេះ ជាចតុវោការភព អរូបព្រហ្ម៣ឋានជាសញ្ញាភព ចំណែកនេវសញ្ញានាសញ្ញាយតនព្រហ្ម ដែលជាអរូបព្រហ្មទី៤នោះ ជានេវសញ្ញានាសញ្ញាយតនភព (មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ពោលគឺមានសញ្ញាល្អិតដ៏ក្រៃលែង ទើបមិនរាប់បញ្ចូលក្នុងសញ្ញាភព ) ។

**រូបភពទាំងអស់ត្រូវជា ៣១ឋាន** គឺអបាយភូមិ៤ កាមសុគតិ៧ រូបភព១៦ និងអរូបភព៤ ។ ឋាន៣១នេះ មាន១១ឋានជាកាមភព ១៦ឋានជារូបភព ៤ឋានជាអរូបភព ។ ក្នុង៣១ឋានដដែលចាត់ជាសញ្ញាភព២៩ឋាន អសញ្ញាភព១ឋាន នេវសញ្ញានាសញ្ញាភព ១ឋាន ។ ក្នុង៣១ឋានដដែលទៀត ចែកទៅជា បញ្ចវោការភព ២៦ឋាន ចតុវោការភព៤ឋាន ឯកវោការភព១ឋាន ។ ភព៣១ឋានចែកជាសត្តាវាស (លំនៅឬទីអាស្រ័យរបស់សត្វ )មាន៩គឺ ÷

១.នានត្តកាយនានត្តសញ្ញី ពួកសត្វដែលមានកាយផ្សេងគ្នាទាំងមានសញ្ញាក៏ផ្សេងគ្នា បានដល់កាមសុគតិភព៧ឋាន (មានពួកអសុរខ្លះរាប់បញ្ចូលក្នុងពួកទេវតា ) ។

២-នានត្តកាយឯកត្តសញ្ញី ពួកសត្វដែលមានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នា បានដល់អបាយភូមិ៤ និងព្រហ្មបឋមជ្ឈាន-ភូមិ៣ឋាន (រួមត្រូវជា៧ឋាន) ។

៣-ឯកត្តកាយនានត្តសញ្ញី ពួកសត្វដែលមានកាយដូចគ្នា តែមានសញ្ញាផ្សេងគ្នា បានដល់ព្រហ្មទុតិយជ្ឈានភូមិ៣ឋាន ។

៤-ឯកត្តកាយឯកត្តសញ្ញី ពួកសត្វដែលមានកាយដូចគ្នា ទាំងមានសញ្ញាក៏ដូចគ្នា បានដល់ព្រហ្មតតិយជ្ឈានភូមិ៣ឋាន និងព្រហ្មចតុត្ថជ្ឈានភូមិ៦ឋាន តាមឋាននោះៗ (រួមត្រូវជា៩ឋាន វៀរអសញ្ញិសត្តាព្រហ្ម)។

៥-អសញ្ញិសត្តា ពួកសត្វដែលអត់សញ្ញា (តាមពិតអត់មាននាមក្ខន្ធទាំង៤ តែក្នុងទីនេះលើកយកសញ្ញាជាប្រធាន)។

៦-អាកាសានញ្ចាយតនព្រហ្ម គឺអរូបព្រហ្មទី១

៧-វិញ្ញាណញ្ចាយតនព្រហ្ម គឺអរូបព្រហ្មទី២

៨-អាកិញ្ចញ្ញាយតនព្រហ្ម គឺអរូបព្រហ្មទី៣

៩-នេវសញ្ញានាសញ្ញាយតនព្រហ្ម គឺអរូបព្រហ្មទី៤ ។

✳-ការដែលមិនចាត់អសញ្ញិសត្វ និងអរូបព្រហ្មចូលក្នុងនានត្តៈ ឬឯកត្តៈ ព្រោះក្នុងអសញ្ញិសត្តាភូមិមិនមាននូវនាមក្ខន្ធ និងក្នុងអរូបភូមិ៤មិនមានរូបក្ខន្ធ ។



✳-អសញ្ញិសត្តាភូមិមិនមាននូវនាមក្ខន្ធ ទើបមិនរាប់ចូលក្នុង **វិញ្ញាណដ្ឋិតិភូមិ** (ភូមិជាទីតាំងនៃវិញ្ញាណ) ចំណែកនេវ-សញ្ញានាសញ្ញាយតនភូមិ ទោះជាមាននូវនាមក្ខន្ធក៏ដោយ ក៏នាម-ក្ខន្ធនោះមិនប្រាកដច្បាស់ឡើយ ទើបមិនរាប់ចូលក្នុងវិញ្ញាណដ្ឋិតិ-ភូមិដែរ ដូច្នេះ **វិញ្ញាណដ្ឋិតិភូមិមាន៧ភូមិ** (សត្តាវាស៩ដកសត្តា-វាស២ចេញ នៅសល់សត្តាវាស៧ សត្តាវាស៧ដែលនៅសល់នេះ ហៅថាវិញ្ញាណដ្ឋិតិភូមិ) ។

✳-ការសម្ដែងភពភូមិឋានទាំងអស់នេះ ដើម្បីបញ្ជាក់ឱ្យឃើញថា ជាភូមិឋានដែលកម្មបានបង្កើតឡើង គឺសំដៅយកកម្មជ្ជ-រូបនិងវិបាកបដិសន្ធិ ដែលកើតឡើងដោយអំណាចនានាខណិក-កម្មប្បច្ច័យ ។ សត្វលោកត្រាច់រង្គាត់ក្នុងសង្សារវដ្ដ មិនប្រាកដភពភូមិណាជាលំនៅឋានរបស់ខ្លួនឡើយ តាមពិត វដ្ដសង្សារគឺជាតំណនៃសង្ខារធម៌សុទ្ធ បុគ្គលចេញផុតអំពីសង្សារវដ្ដទៅបាន ព្រោះរំលត់សេចក្ដីប្រកាន់ដោយអរិយមគ្គ ។

**១៣-សោតាបត្តិមគ្គចេតនា** ជានានាខណិកកម្មប្បច្ច័យនៃសោតា-បត្តិផល ដោយអនន្តរកម្មប្បច្ច័យ គឺថាខណៈដែលមគ្គចិត្តកើតឡើង ព្រមដោយចេតនាចេតសិក ចេតនាចេតសិកខណៈហ្នឹងជាសហជាតកម្មប្បច្ច័យ កាលមគ្គចិត្តព្រមដោយចេតនារលត់ហើយ

នោះ ចេតនាចេតសិកក៏ត្រឡប់ជានានាខណិកកម្មប្បច្ច័យ និងមានអំណាចឱ្យផលជាអកាលិក: គឺផលដែលកើតឡើងនោះមិនមានរវាងចន្លោះ បានដល់ ផលចិត្តដែលកើតតអំពីមគ្គចិត្តនោះឯងជាបច្ចុប្បន្នធម៌ (ធម៌ដែលកើតអំពីនានាខណិកកម្មប្បច្ច័យ )ម្យ៉ាងទៀត មគ្គចេតនាដែលរលត់ទៅច្រើនខណៈចិត្តហើយក៏ដោយ ក៏នៅជានានាខណិកកម្មប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យនៃផលចិត្តក្នុងផលសមាបត្តិវិថីបានទៀតផង ។

**១៤-សកទាគាមិមគ្គចេតនា** ជានានាខណិកកម្មប្បច្ច័យនៃសកទាគាមិផល (មានសេចក្តីអធិប្បាយដូចសោតាបត្តិមគ្គចេតនាដែរ)។

**១៥-អនាគាមិមគ្គចេតនា** ជានានាខណិកកម្មប្បច្ច័យនៃអនាគាមិផល (មានសេចក្តីអធិប្បាយដូចសោតាបត្តិមគ្គចេតនាដែរ)។

**១៦-អរហត្តមគ្គចេតនា** ជានានាខណិកកម្មប្បច្ច័យនៃអរហត្តផល (មានសេចក្តីអធិប្បាយដូចសោតាបត្តិមគ្គចេតនាដែរ)។

✳-លោកុត្តរកុសលចេតនា មានសោតាបត្តិមគ្គចេតនាជាដើម មិនឱ្យវិបាកបដិសន្ធិនិងកម្មជរូបឡើយ ជាសំខាន់គឺឱ្យលោកុត្តរវិបាកសោយសុខក្នុងផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ។

✳-លោកុត្តរកុសល ជាកុសលកាត់ផ្តាច់នូវបាបអកុសល





ដាច់ឫសដាច់គល់អស់អំពីសន្តាន មិនបានត្រឡប់កើតវិញឡើយ ជាពិសេសគឺលះនូវសេចក្តីប្រកាន់ ដូច្នេះហើយទើបលោកុត្តរ-កុសលជាអរិយមគ្គ ជាផ្លូវទៅកាន់ព្រះនិព្វាន ។

## ផ្លូវឆ្ងាយ

≈≈≈≈≈

ជីវិតគឺជាដំណើរផ្លូវឆ្ងាយ ឯរូបរាងកាយជាខ្ទមសំណាក់
អ្នកសាងគុណធម៌ពិតល្អឥតអាក់ ព្រោះថាគ្មានអ្នកណាសាងជួសបាន។
សីលធម៌ពុំដែលចោលអ្នកដំណើរ គឺមនុស្សទេតើនិរាសចាកឋាន
រត់ចោលសីលធម៌ធ្លាប់ឱ្យសុខសាន្ត គប់ពាលនឹកស្មានថាបានផុតភ័យ។
បណ្ឌិតពុំដែលស្វែងរកក្តីសុខ លើគំនរទុក្ខនៃអ្នកដទៃ
តែងប្រាប់ផ្លូវល្អទានដ៏ប្រពៃ ដល់ជនគ្រប់វ័យឱ្យបានចាំចេះ ។
អ្នកដែលធ្វើទានពិតជាមានភ័ព្វ ប្រៀបដូចនាំទ្រព្យពីផ្ទះភ្លើងឆេះ
ទោះផ្ទះខ្ទេចអស់គង់មានចំណេះ សល់ទ្រព្យពិសេសសម្រាប់ផ្លូវឆ្ងាយ។

ដោយឧបាសក **គុយ-សុធន**

# ទីបំផុតនៃកុសលធម៌

ប្រយោជន៍នៃបុណ្យកុសលដ៏យ៉ាងសំខាន់ នៅក្នុងព្រះពុទ្ធសាសនានេះ គឺការលាងជម្រះនូវមន្ទិលសៅហ្មងរបស់ចិត្ត ។ តាមពិត មន្ទិលសៅហ្មងរបស់ចិត្ត មានលោភៈជាដើម មិនអាចលាងជម្រះដោយទឹកស្ទឹងទន្លេណា។ ដែលគេជឿថាស័ក្តិសិទ្ធិនោះឡើយ សូម្បីទេវតាព្រះឥន្ទ្រព្រះព្រហ្ម ឬព្រះអាទិទេពដែលគេជឿថាជាទេវតាខាងដើម ជាព្រះអ្នកបង្កើតទឹកដីនិងសត្វលោក ជាអ្នករក្សាការពារនិងឱ្យសុខទុក្ខដល់សត្វលោក ក៏បុគ្គលទាំងអស់នោះ មិនមានអំណាចមកកម្ចាត់បង់ នូវគ្រឿងសៅហ្មងក្នុងចិត្តសន្តាននៃសត្វលោកបានដែរ ។

ព្រះសម្មាសម្ពុទ្ធដែលព្រះអង្គអស់មន្ទិលសៅហ្មង ក្លាយទៅជាបុគ្គលបរិសុទ្ធនោះដោយសារការបំពេញនូវបុណ្យបារមី សេចក្តីល្អគ្រប់បែបយ៉ាង រាប់ជាតិជាអនេកមកហើយ ជាទីបំផុតព្រះអង្គបាននូវបញ្ញាជាពន្លឺភ្លឺស្វាង កម្ចាត់បង់នូវភាពងងឹតគឺអវិជ្ជាព្រមទាំងគ្រឿងសៅហ្មងគ្រប់យ៉ាង អស់អំពីខន្ធសន្តាននៃព្រះអង្គ ។

នៅក្នុងពុទ្ធកិច្ច៤៥ព្រះវស្សា ព្រះសម្មាសម្ពុទ្ធទ្រង់មិនមាន





កិច្ចកម្ចាត់នូវកិលេសឱ្យសត្វណាដោយចំៗនោះទេ គឺព្រះអង្គគ្រាន់តែមានតួនាទីប្រាប់នូវឧបាយស្រាយចំណង ឱ្យដល់សត្វលោកតែប៉ុណ្ណោះ សត្វលោកបានដឹងនូវឧបាយហើយ ក៏ព្យាយាមស្រាយដោយខ្លួនឯង ពោលគឺការបដិបត្តិកម្ចាត់នូវកិលេសគ្រឿងសៅហ្មង ដែលជាចំណងចងខ្លួនឱ្យជាប់ក្នុងកងទុក្ខនោះដោយខ្លួនឯង ព្រះអង្គបដិបត្តិជួសមិនបានឡើយ ។

សេចក្តីនេះពិតណាស់ ដូចជាអ្នកឈឺអឺចឹង អ្នកដទៃលេបថ្នាំផឹកថ្នាំជួស គឺមិនអាចជាសះស្បើយបានឡើយ ត្រូវតែខ្លួនឯងជាអ្នកឈឺហ្នឹងហើយ ដែលខំលេប ខំផឹកនូវថ្នាំដោយខ្លួនឯងទៅ ទើបឈ្មោះថាជាការព្យាបាលរោគដោយត្រឹមត្រូវ យ៉ាងណាមិញ មន្ទិលសៅហ្មង មានលោភៈទោសៈមោហៈទិដ្ឋិមានះជាដើម មាននៅក្នុងចិត្តសន្តាននៃបុគ្គលណា បុគ្គលនោះត្រូវតែខំចម្រើននូវកុសលធម៌ ដែលជាធម៌បដិបក្ខជាមួយនឹងកិលេសគ្រឿងសៅហ្មងក្នុងចិត្តសន្តានរបស់ខ្លួនហ្នឹងឯង ដូចជាការព្យាបាលរោគ យ៉ាងនោះដែរ ។

ព្រះសម្មាសម្ពុទ្ធប្រៀបបីដូចជាលោកគ្រូពេទ្យ ព្រះវិន័យដែលព្រះអង្គទ្រង់បញ្ញត្តហើយប្រៀបបីដូចជាបញ្ជារបស់លោកគ្រូពេទ្យ ព្រះធម៌អប់រំដែលព្រះអង្គទ្រង់សម្តែងហើយ ប្រៀបបីដូចជា

ឱវាទរបស់លោកគ្រូពេទ្យ ធម៌បដិបត្តិបានដល់កុសលធម៌ទាំងពួង ប្រៀបបីដូចជាឱសថដ៏ស័ក្តិសិទ្ធិ ដូច្នេះ សត្វលោកដែលមានបាប មានមន្ទិលសៅហ្មងក្នុងសន្តាន ប្រៀបបាននឹងអ្នកឈឺ ជាធម្មតា នៃអ្នកឈឺត្រូវស្តាប់តាមបញ្ញានិងឱវាទរបស់លោកគ្រូពេទ្យ យ៉ាងណា សត្វលោកដែលមានបាបមានមន្ទិលសៅហ្មងក្នុងសន្តានចិត្ត ត្រូវបដិបត្តិតាមព្រះធម៌និងព្រះវិន័យរបស់ព្រះសម្មាសម្ពុទ្ធ យ៉ាងនោះឯង ។

នេះជាច្បាប់ហេតុផលរបស់ធម្មជាតិ គឺអ្នកឈឺត្រូវដឹងថា ខ្លួនឯងជាអ្នកឈឺផង ត្រូវស្គាល់ថ្នាំផង ត្រូវព្យាយាមលេបឬផឹកនូវថ្នាំផង និងត្រូវដឹងប្រមាណនៃការលេបឬផឹកនោះផង ក៏ដូចជាសត្វលោកដែលមានបាបមានមន្ទិលសៅហ្មង គឺត្រូវតែដឹងខ្លួនដោយសម្បជញ្ញៈថា ខ្លួនឯងមានបាប មានគ្រឿងសៅហ្មងផង ត្រូវមានសម្បជញ្ញៈដឹងធម៌បដិបត្តិផង ត្រូវព្យាយាមបដិបត្តិផង និងត្រូវដឹងប្រមាណក្នុងការបដិបត្តិផង ។

សរុបសេចក្តីមក ដើម្បីកម្ចាត់បង់នូវមន្ទិលសៅហ្មងក្នុងសន្តានចិត្តណា ត្រូវតែមានកុសលធម៌ចម្រើនអស់កាលជានិច្ច នៅក្នុងសន្តានចិត្តនោះ។ ជាការជាក់ស្តែង ដូចដែលពុទ្ធបរិស័ទបានមកជាអ្នកមិនសម្លាប់សត្វ មិនប្រព្រឹត្តចោរកម្ម និងមិនប្រព្រឹត្តនូវ





ទុច្ចរិតផ្សេងៗទៀតនោះ មិនមែនមកអំពីវត្ថុស័ក្តិសិទ្ធិឬមកអំពីបុគ្គលដែលអស្ចារ្យអ្វីណានោះឡើយ គឺព្រោះមកអំពី **កុសលសីល** បានចម្រើនឡើងក្នុងសន្តានចិត្តហ្នឹងតែម្តង បើមិនដូច្នោះទេ ក៏នៅតែជាអ្នកទ្រុស្តសីលរហូតមកហ្នឹងឯង ដូច្នេះ ពុទ្ធបរិស័ទគប្បីជាអ្នកមាននូវជំនឿ មាននូវសទ្ធាដែលគ្រប់គ្រងដោយបញ្ញា គឺគប្បីជឿយ៉ាងមាំថា **មានតែកុសលធម៌ទេដែលអាចលាងជម្រះនូវបាបអកុសលក្នុងសន្តានចិត្តរបស់ខ្លួនបាន ។**

សូមមនុស្សលោកទាំងឡាយ បានយល់ដឹងថា រាគៈជាបាបធម៌ ទោសៈជាបាបធម៌ មោហៈជាបាបធម៌ ។ តើបាបធម៌ទាំងនេះមាននៅក្នុងជីវិតយើងប្រចាំថ្ងៃដែរឬទេ ?

អ្នកដែលជឿព្រះគ្រប់សាសនាទាំងអស់ក្នុងលោក តើមានអ្នកណាម្នាក់ដែលអស់បាបធម៌ពីក្នុងខ្លួន ដោយសារព្រះមកកម្ចាត់បង់ឱ្យឬដោយសារត្រឹមតែថា ខ្លួនបានជឿលើព្រះហើយ សារភាពចំពោះព្រះអង្គហើយ ខ្លួនត្រូវអស់នូវបាបធម៌ ?

ការសារភាពនូវទោសកំហុស ហើយដល់នូវសេចក្តីសង្រួមតទៅ ជារឿងល្អរបស់មនុស្សគ្រប់គ្នា ប៉ុន្តែចំពោះបាបកម្មដែលបានធ្វើហើយ មានការសម្លាប់សត្វជាដើម បានធ្វើកិច្ចជាពូជកប់ក្នុងសន្តានចិត្ត នេះជា **កម្មនិយាម** (ច្បាប់របស់កម្ម ឬការកំណត់

របស់កម្ម ) ដូចដែលបានសម្តែងអំពីកម្មខាងដើមរួចហើយ ។ ប្រ-សិនបើមានព្រះអាចទទួលយកបាបបាន ចុះរាគៈទោសៈមោហៈ ដែលជាហេតុនាំឱ្យប្រព្រឹត្តនូវបាបកម្មគ្រប់យ៉ាងនោះ ដូចម្តេច ក៏ព្រះមិនទទួលយកតែម្តងទៅ ទុកឱ្យសត្វលោកលំបាកទ្រាំនឹងកិលេសរបស់ខ្លួនឯងធ្វើអ្វី ? ឬក៏ព្រះជាអ្នកបង្កើតរាគៈទោសៈមោហៈឱ្យសត្វលោក ?

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងប្រាប់នូវឧបាយ ដែលសម្រាប់លាងជម្រះនូវរាគៈ ទោសៈ មោហៈ គឺការចម្រើននូវអលោភៈ អទោសៈ អមោហៈ ដោយសីល ដោយសមាធិនិងដោយបញ្ញា ជាការចម្រើនរឿយៗ សន្សំរឿយៗ ដោយសេចក្តីមិនប្រមាទរបស់ខ្លួនឯង ។

ព្រះសម្មាសម្ពុទ្ធទ្រង់ពន្យល់ឱ្យមនុស្សលោក ទីពឹងខ្លួនឯងក្នុងការកសាងនូវសមត្ថភាពរបស់ខ្លួន ដែលជាសមត្ថភាពក្នុងការប្រយុទ្ធប្រឆាំងជាមួយសត្រូវ ពោលគឺរាគៈ ទោសៈ មោហៈហ្នឹងឯង ។ មនុស្សអាចមានសមត្ថភាពកសាងខ្លួនឱ្យបានជាបុគ្គលបរិសុទ្ធ ឱ្យបានជាបព្វជិតល្អ ឱ្យបានជាព្រះអរហន្ត ឱ្យបានជាព្រះពុទ្ធ គឺបានទៅជាមនុស្សដែលទេវតាឥន្ទ្រព្រហ្មគោរពបូជា ថ្វាយបង្គំនមស្ការ ដូច្នេះ មនុស្សមិនមែននៅត្រឹមតែសំពះទេវតា អង្វរ





សូមសេចក្តីសុខពីទេវតាឥន្ទ្រព្រហ្មនោះទេ ។

ការចម្រើននូវសភាវៈល្អក្នុងជីវិតរាល់ថ្ងៃ ដើម្បីកម្ចាត់បង់នូវសភាវៈអាក្រក់នោះ គឺស្ថិតនៅលើសតិសម្បជញ្ញៈរបស់មនុស្សគ្រប់គ្នាហ្នឹងឯង ហើយទីបំផុតនៃសភាវៈល្អ គឺនៅត្រង់ការអស់ទៅនៃសភាវៈអាក្រក់ ក្នុងសេចក្តីនេះ មនុស្សគ្រប់គ្នាត្រូវតែជឿលើខ្លួនឯង ដែលជាអ្នកចម្រើននូវសភាវៈល្អ ឱ្យបានដល់ទីបំផុត មិនមានអ្នកដទៃណាមកចម្រើនជួសបានឡើយ ។

សភាវៈល្អបានដល់កុសលធម៌ ជាធម៌ស មានកិច្ចកម្ចាត់បង់នូវធម៌ខ្មៅ គឺបាបអកុសលដែលជាសភាវៈអាក្រក់ ដូច្នេះ ទីបំផុតនៃកុសលធម៌ ស្មើនឹងការអស់ទៅនៃបាបអកុសលទាំងពួង ។

**ឧកចិត្តម្តេចបាន**

លោកចៅហ្វាយធំមានខ្ញុំបម្រើ បង្គាប់ប្រាប់ប្រើបម្រើកិច្ចការ
ទាស់តែចៅហ្វាយជាខ្ញុំតណ្ហា កិលេសត្រួតត្រាទ្រូងតឹងស្ទើរប្រេះ។
ចង់រត់ទៅណាក៏មិនសុខដែរ គឺលុះត្រាតែរត់ពីកិលេស
ទោះមានឬក្រ ក៏កុំប្រហែស ត្បិតអីលោកនេះក្រោមអំណាចកម្ម។
ដោយឧបាសក **គុយ-សុធន**

# កម្មវដ្ដៈ

**កម្មវដ្ដៈ** គឺជាដំណើរវិលវល់ក្នុងភពទាំង៣១ឋាន ព្រោះកម្មជាបច្ច័យ ។

យើងតែងនិយាយដោយការជាប់ទាក់ទងនឹងបុគ្គលប្បញ្ញត្តិថា អ្នកនេះធ្វើកម្មយ៉ាងនេះមួយ យ៉ាងនោះមួយ ប៉ុន្តែបើពោលតាមបរមត្ថធម៌ ដែលជាធម៌នាំមកនូវប្រយោជន៍ដ៏ក្រៃលែងឱ្យដល់អ្នកឃើញច្បាស់នោះ អ្នកធ្វើកម្មពុំមានឡើយ ។

ក្នុងជីវិតរស់នៅនៃសត្វលោកគ្រប់គ្នា ម្នាក់ៗគឺជាតំណនៃសង្ខារធម៌សុទ្ធ ក្នុងសង្ខារធម៌មួយខ្សែៗមានតែរូបធម៌និងនាមធម៌ប៉ុណ្ណោះ ។ រូបធម៌និងនាមធម៌មិនមែនជាអ្នកធ្វើកម្មឡើយ ប៉ុន្តែវាមានបច្ច័យដែលនាំឱ្យកើតកម្ម តើអ្វីជាបច្ច័យ ?

ការឃើញបច្ច័យដែលនាំឱ្យកើតកម្មវដ្ដៈ គឺត្រូវឃើញដោយភ្នែកបញ្ញា មុនដំបូងត្រូវអប់រំបញ្ញាឱ្យបានជាក់ច្បាស់ថា មានត្រឹមតែនាមរូបប៉ុណ្ណោះក្នុងមនុស្សម្នាក់ៗ ។ រូបធម៌ជាធាតុមិនដឹង ចំណែកនាមធម៌ជាធាតុដឹង រូបធាតុនិងនាមធាតុអាស្រ័យគ្នាទៅវិញទៅមក ដោយរូបជាបច្ច័យនៃនាម ហើយនាមក៏ជាបច្ច័យនៃរូបវិញដែរ ។ កាលបើនាមរូបអាស្រ័យគ្នាទៅវិញទៅមកយ៉ាងនេះ ទើបបញ្ញាបានឃើញជាក់ច្បាស់ថា នាមរូបសូន្យចាកតួខ្លួនឯង ព្រោះបើមិនអាស្រ័យបច្ច័យទេ នាមក្ដីរូបក្ដីក៏រមែងមិនមាន ។

មកដល់ថ្នាក់បញ្ញា ឃើញនាមរូបសូន្យចាកតួខ្លួនឯងយ៉ាងនេះហើយ ទើបបញ្ញាបានឃើញដល់អវិជ្ជាគឺការមិនដឹងនាមរូបតាមពិត ថាជាហេតុជាបច្ច័យនាំឱ្យមានតណ្ហានិងការភ័យខ្លាចតក់ស្លុតកើតឡើង ហើយបញ្ញាក៏បានឃើញការកើតមាននៃកម្មវដ្ដៈជាមួយគ្នានឹងឃើញការកើតឡើងនៃតណ្ហានិងសេចក្ដីតក់ស្លុតការភ័យខ្លាចផងដែរ នេះជាការឃើញបដិច្ចសមុប្បាទធម៌ (ធម៌ដែលកើតឡើងព្រោះអាស្រ័យបច្ច័យ ឬ បច្ច័យដែលនាំឱ្យកើតនូវបច្ចយុប្បន្នធម៌ ) គឺឃើញថាអវិជ្ជា ជាបច្ច័យនៃអភិសង្ខារ (កម្មដែលតាក់តែងនូវភព៣១ឋាន ) និងឃើញថា តណ្ហាជាបច្ច័យនៃឧបាទាន និងឧបាទានជាបច្ច័យនៃភព (កម្មភពនិងឧបបត្តិភព ) ។

ព្រមគ្នានឹងបញ្ញាឃើញការកើតឡើងនៃកម្មវដ្ដៈ បញ្ញាក៏បានឃើញការអស់ទៅនៃកម្មវដ្ដៈផងដែរ ព្រោះថា បើសេចក្ដីល្ងង់ឬការមិនដឹងនូវនាមរូបតាមពិត ត្រូវកម្ចាត់បង់អស់ហើយ សេចក្ដីប្រាថ្នា ការតក់ស្លុត ការប្រកាន់និងកម្មវដ្ដៈក៏រមែងមិនមានជាពិតប្រាកដ ជាមួយនោះទៀតបញ្ញាក៏បានឃើញថា អវិជ្ជាគឺពិតជាត្រូវ

កម្ចាត់បង់អស់អំពីសន្តាន ព្រោះហេតុនៃការចម្រើនឡើងនៃវិជ្ជា។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា « **អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា** » ប្រែថា «ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ » (ចាកសំយុត្តនិកាយ និទានវគ្គ បិដកលេខ៣១ ) នៅក្នុងគម្ពីរវិសុទ្ធិមគ្គបានសម្ដែងប្រាប់អំពីខ្លឹមសារនៃពុទ្ធភាសិតនេះថា «ជាការបដិសេធនូវអ្នកសាងលោក » ។

មានមនុស្សច្រើននាក់ណាស់ដែលយល់ឃើញថា ព្រះព្រហ្មឬព្រះអាទិទេពជាអ្នកសាងលោក ជាអ្នកបង្កើតសត្វលោក ប៉ុន្តែព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា អវិជ្ជា តណ្ហា ឧបាទាន ជាបច្ច័យនៃភព (កម្មភព និងឧបបត្តិភព ) ភពជាបច្ច័យនៃជាតិ (ភពគឺលោកិយចេតនាជានានាខណិកកម្មប្បច្ច័យ ឯចំណែកជាតិបានដល់បដិសន្ធិកម្មជរូបនិងវិបាកបដិសន្ធិ ) ជាតិជាបច្ច័យនៃជរាមរណៈ (ដោយបកតូបនិស្សយប្បច្ច័យ ) ។ តាមពិត សត្វលោកកើតអំពីសេចក្ដីល្ងង់របស់ខ្លួនឯង ដរាបណា សេចក្ដីល្ងង់គឺអវិជ្ជានៅមិនទាន់កម្ចាត់បង់ទេ កម្មវដ្ដៈមិនអាចអស់ទៅបានឡើយ កម្មវដ្ដៈអស់ទៅបាន លុះត្រាតែអស់អវិជ្ជាដែលមិនដឹងនូវសច្ចធម៌ ។



# ចុតិ-បដិសន្ធិ

រឿងក្រោយអំពីស្លាប់ ជារឿងដែលមនុស្សយើងមិនងាយយល់ រហូតដល់យល់ខុសដោយប្រការផ្សេងៗ អ្នកខ្លះយល់ថាមានវិញ្ញាណចេញពីរូបដែលស្លាប់ហើយទៅចាប់បដិសន្ធិ ក្នុងការយល់ឃើញនេះ ខ្លះក៏យល់ថាកម្មល្អនាំឱ្យវិញ្ញាណទៅបដិសន្ធិក្នុងសុគតិភព កម្មអាក្រក់នាំឱ្យវិញ្ញាណទៅបដិសន្ធិក្នុងអបាយភូមិ ខ្លះទៀតយល់ថា វិញ្ញាណរបស់មនុស្សត្រូវទៅកើតជាមនុស្សដដែល បើវិញ្ញាណសត្វអ្វីត្រូវទៅកើតជាសត្វនោះដដែល ប៉ុន្តែក្នុងសេចក្ដីនេះគេឆ្ងល់ថា តើវិញ្ញាណចូលតាមណាក្នុងការចុះចាប់បដិសន្ធិក្នុងផ្ទៃម្ដាយ ។

តាមការត្រាស់សម្ដែងរបស់ព្រះសម្មាសម្ពុទ្ធ វិញ្ញាណគឺជាសង្ខារធម៌មួយប្រភេទ ដែលតែងតែកើតរលត់ជាមួយនឹងវេទនា សញ្ញា សង្ខារ ។ វិញ្ញាណនៃមនុស្សយើងគ្រប់គ្នារាល់ថ្ងៃនេះ តែងអាស្រ័យវត្ថុរូបជានិច្ច គឺ ចក្ខុវិញ្ញាណកើតឡើងអាស្រ័យចក្ខុវត្ថុ សោតវិញ្ញាណកើតឡើងអាស្រ័យសោតវត្ថុ ឃានវិញ្ញាណកើតឡើងអាស្រ័យឃានវត្ថុ ជីវ្ហាវិញ្ញាណកើតឡើងអាស្រ័យជីវ្ហាវត្ថុ

កាយវិញ្ញាណកើតឡើងអាស្រ័យកាយវត្ថុ និងមនោធាតុ មនោ-វិញ្ញាណធាតុកើតឡើងអាស្រ័យហទយវត្ថុ ប្រៀបដូចភ្លើងកើតឡើងអាស្រ័យវត្ថុណា ក៏ហៅទៅតាមវត្ថុនោះៗ ដូចជាហៅថា ភ្លើងព្រៃ ភ្លើងអុស ភ្លើងទៀន ភ្លើងធូបជាដើម ។

នៅពេលស្លាប់ បញ្ចក្ខន្ធត្រូវបែកធ្លាយ នៅសល់តែសរីរៈសាកសព ត្រូវយកទៅកប់ ឬដុត ឬចោល តាមសមគួរ មិនមានអ្វីដែលមិនចេះរលត់ ហើយត្រូវចេញទៅស្វែងរកភពថ្មីទៀតនោះឡើយ នៅក្នុងសភាពបែបនេះ តើចុតិ-បដិសន្ធិ ប្រព្រឹត្តទៅយ៉ាងណាដែរ ?

កាលណាបើអវិជ្ជាតណ្ហា នៅមិនទាន់បានលះអស់ទេនោះ រមែងជាបច្ច័យញុំាងកម្មឱ្យជានានាខណិកកម្មប្បច្ច័យ បង្កើតឡើងនូវវិបាកបដិសន្ធិ បន្តពីចុតិចិត្តដែលរលត់ទៅភ្លាមនោះឯង ។ ចុតិ-ចិត្ត គឺជាចិត្តដែលឃ្លាតចាកភព បានដល់ភវង្គចុងក្រោយ ។

**ចុតិចិត្ត**មិនមែនជាចិត្តដែលចេញទៅបដិសន្ធិទេ ព្រោះមិនមែនជាចិត្តតែមួយ ចុតិចិត្តខ្លះជាមហាវិបាកចិត្ត លុះដល់បដិសន្ធិ-ចិត្តកើតបន្តជាអកុសលវិបាកចិត្ត (ចុតិ-បដិសន្ធិនេះ គឺមនុស្ស ឬទេវតាចុតិទៅកើតក្នុងអបាយភូមិ ) ។ ចុតិចិត្តខ្លះជាមហគ្គតវិបាក-ចិត្ត លុះដល់បដិសន្ធិចិត្តកើតឡើងបន្តជាមហាវិបាកចិត្ត (ចុតិ-



បដិសន្ធិនេះ គឺព្រហ្មចុតិមកកើតជាមនុស្សឬទេវតា ) ។ ចុតិចិត្តខ្លះជាមហាវិបាកចិត្ត លុះដល់បដិសន្ធិចិត្តកើតបន្តជារូបាវចរវិបាកចិត្តក៏មាន ជាអរូបាវចរវិបាកចិត្តក៏មាន ជាអកុសលវិបាកចិត្តក៏មាន (ចុតិ-បដិសន្ធិនេះ គឺមនុស្សឬទេវតាចុតិទៅកើតជារូបព្រហ្មដោយរូបាវចរវិបាកចិត្ត ចុតិទៅកើតជាអរូបព្រហ្មដោយអរូបាវចរវិបាក-ចិត្ត ចុតិទៅកើតជាសត្វក្នុងអបាយភូមិ ៤ ដោយអកុសលវិបាក-ចិត្ត ) ។ ចុតិចិត្តខ្លះប្រកបដោយសោមនស្សវេទនា លុះដល់បដិសន្ធិចិត្តបន្តប្រកបដោយឧបេក្ខាវេទនា ចុតិចិត្តខ្លះប្រកបដោយហេតុ២ លុះដល់បដិសន្ធិចិត្តបន្តប្រកបដោយហេតុ៣ ចុតិចិត្តខ្លះប្រកបដោយវិតក្កៈនិងវិចារៈ លុះដល់បដិសន្ធិចិត្តបន្តមិនប្រកបដោយវិតក្កៈ ប្រកបតែជាមួយវិចារៈ ។ល។ នៅច្រើនយ៉ាងទៀតណាស់ដែលប្រភេទចុតិនិងបដិសន្ធិមិនដូចគ្នា ។ ទោះជាយ៉ាងណាក៏ដោយក៏ចុតិចិត្តគ្រាន់តែជាខណៈចិត្តមួយបានរលត់បាត់ទៅហើយមិនអាចឋិតនៅអន្ទោលទៅរកបដិសន្ធិទៀតបានឡើយ ។

តាមសភាពពិតរបស់ចិត្ត មិនមែនទើបតែរលត់នៅពេលស្លាប់នោះទេ គឺវាកើតរលត់បន្តគ្នារហូតក្នុងមួយថ្ងៃៗ មួយខែៗ មួយឆ្នាំៗ មិនមានចិត្តដួងណាមួយនៅឋិតថេរទៀងទាត់រហូតឡើយ ចុតិចិត្តគ្រាន់តែជាខណៈចិត្តមួយដែលកើតរលត់ជាចុង-

ក្រោយ នៅក្នុងកំណើតមួយអត្តភាពតែប៉ុណ្ណោះ ចិត្តណាដែលរលត់ទៅហើយមិនដែលត្រឡប់មកកើតជាថ្មីម្តងទៀតទេ បើមិនដូច្នេះ អតីតៈនឹងត្រឡប់មកជាបច្ចុប្បន្នទៅហើយ ។

**បដិសន្ធិចិត្ត** គឺជាចិត្តមួយខណៈមុនដំបូងបង្អស់ក្នុងមួយអត្តភាពគឺកំណើតក្នុងជាតិណាមួយនោះ បដិសន្ធិចិត្ត ជាចិត្តកើតឡើងក្នុងភពថ្មី បន្តពីចុតិចិត្ត ដែលជាចិត្តខណៈចុងក្រោយនៃភពចាស់ ដោយមិនមានអ្វីមកជារវាងចន្លោះចុតិនិងបដិសន្ធិនោះឡើយ គឺថា ចុតិហើយភ្លាមត្រូវតែបដិសន្ធិ វៀរលែងតែចុតិចិត្តរបស់ព្រះអរហន្ត ។

បដិសន្ធិចិត្តបានប្រមូលយកទាំងអស់ នូវបុណ្យបាបដែលបានធ្វើហើយ អធ្យាស្រ័យឧបនិស្ស័យយ៉ាងណាៗ គឺថាមិនបានបាត់បង់នៅពេលស្លាប់ទៅនោះឡើយ តាមពិតបដិសន្ធិចិត្តមិនមែនជាតួប្រមូលនូវបុណ្យបាប អធ្យាស្រ័យឧបនិស្ស័យដោយខ្លួនឯងនោះទេ គឺនេះមកអំពីចុតិចិត្តជាអនន្តរូបនិស្សយប្បច្ច័យ (ចុតិចិត្តជាទីអាស្រ័យដ៏មានកម្លាំងញ៉ាំងបដិសន្ធិចិត្តឱ្យកើតឡើង ព្រមដោយអ្វីៗទាំងអស់ដែលចិត្តមុនៗបានសន្សំមក មិនមានចិត្តអ្វីដទៃមកកាត់ជារវាងចន្លោះ ) ។

ដែលឈ្មោះថា **ចិត្ត** ព្រោះជាធម្មជាតិសន្សំនូវអ្វីៗដែលជា



**ជវនវិថី** ជវនវិថី គឺវិថីនៃបុណ្យឬបាប ម៉្លោះហើយអធ្យាស្រ័យឧបនិស្ស័យយ៉ាងណាៗ វាអាស្រ័យនៅលើជវនវិថីនេះឯង ឯចំណែកការសន្សំរបស់ចិត្តនោះ គឺមិនមែនចិត្តមួយដួងឋិតថេរទៀងទាត់ទេ គឺសន្សំកប់ទុកក្នុងសន្តានចិត្ត ដោយអំណាចជាបច្ច័យញ៉ាំងខណៈចិត្តថ្មីឱ្យកើតឡើង និងឱ្យទទួលយកជាបន្តនូវអ្វីៗនោះដែលជាជវនវិថី បានសន្សំមកហើយហ្នឹងឯង ។

ចុតិចិត្តគ្រាន់តែជាអនន្តរូបនិស្សយប្បច្ច័យ បញ្ជូននូវអ្វីៗដែលចិត្តមុនៗបានសន្សំគ្រប់ខណៈមកហើយនោះ ឱ្យបដិសន្ធិប្រមូលយកក្នុងខណៈបដិសន្ធិចិត្តកើតឡើងតែប៉ុណ្ណោះ ចុតិចិត្តមិនបានជាកម្មប្បច្ច័យចាត់ចែងឱ្យបដិសន្ធិកើតក្នុងភពថ្មី ភពណាមួយនោះឡើយ បដិសន្ធិក្នុងភពណាៗ វាស្រេចនៅលើនានាខណិកកម្មប្បច្ច័យព្រមដោយបកតូបនិស្សយប្បច្ច័យ ដូច្នេះបដិសន្ធិចិត្តមិនមែនកើតឡើងព្រោះអាស្រ័យបច្ច័យតែមួយនោះទេ គឺត្រូវអាស្រ័យបច្ច័យច្រើនណាស់ ទាំងអតីតប្បច្ច័យទាំងបច្ចុប្បន្នប្បច្ច័យ ប៉ុន្តែសេចក្តីសំខាន់សូមជ្រាបថា បដិសន្ធិចិត្តទើបតែកើតឡើងនៅពេលបដិសន្ធិនោះឯង មិនធ្លាប់ជាចិត្តអ្វីពីមុនមកនោះទេ គឺទើបតែកើតឡើងដោយឧប្បាទខណៈ នៃខណៈបដិសន្ធិហ្នឹងតែប៉ុណ្ណោះ ដូច្នេះ អ្នកដែលឆ្ងល់អំពីបដិសន្ធិក្នុងផ្ទៃម្តាយ ថាតើវិញ្ញាណចូល

តាមទ្វារណានោះ គប្បីជ្រាបផងចុះ ។

អ្នកសិក្សាបរមត្ថធម៌ព្រមដោយការចម្រើននូវសតិប្បដ្ឋាន-វិបស្សនា រមែងបានជ្រាបអំពីកម្លាំងរបស់កម្ម ព្រោះថានៅពេលស្លាប់បញ្ចក្ខន្ធត្រូវរលត់ទាំងអស់ មិនមានអ្វីជាអមតៈត្រូវទៅបដិសន្ធិនោះទេ ប៉ុន្តែបដិសន្ធិវិញ្ញាណត្រូវកើតមានបន្តពីចុតិចិត្តភ្លាមមួយរំពេច ព្រោះកម្មណាមួយដែលបានធ្វើហើយកប់ទុកក្នុងចិត្ត ជានានាខណិកកម្មប្បច្ច័យហ្នឹងឯង ។ (ពាក្យថាចិត្ត និងវិញ្ញាណប្រើជួសគ្នាបាន ) ។

ចំពោះចុតិ-បដិសន្ធិដែលប្រព្រឹត្តទៅជាសង្សារវដ្តនេះ គឺអវិជ្ជាជាបច្ច័យនៃអភិសង្ខារ ហើយអភិសង្ខារគឺកម្មនេះជាបច្ច័យនៃវិបាកវិញ្ញាណ មានវិបាកបដិសន្ធិជាដើម ដូចជាពូជនៃរុក្ខជាតិដែលនាំឱ្យដុះទៅជាដើមឈើផ្សេងៗ បើមានបញ្ញាឃើញបានត្រឹមត្រូវក្នុងសេចក្តីនេះ រមែងលះបង់បាននូវ **ឧច្ឆេទទិដ្ឋិ** (យល់ខុសថាសត្វស្លាប់ទៅសូន្យមិនកើតទៀត )ប៉ុន្តែបើយល់ខុសក្នុងសេចក្តីនេះទៅវិញ រមែងប្រកាន់នូវ **សស្សតទិដ្ឋិ** ( យល់ថា មានសត្វស្លាប់ទៅកើតទៀត ) ។

ម៉្យាងទៀត ក្នុងសេចក្តីដែលសម្តែងអំពីបញ្ចក្ខន្ធត្រូវបែក-ធ្លាយទាំងអស់ នៅពេលស្លាប់មិនមានអ្វីត្រូវនៅជាអមតៈទៅ





បដិសន្ធិទៀតទេ តែបដិសន្ធិកើតមានព្រោះកម្មជាបច្ច័យ បើយល់ត្រូវក្នុងសេចក្តីនេះ រមែងលះបង់នូវ **សស្សតទិដ្ឋិ** ប៉ុន្តែបើយល់ខុសក្នុងសេចក្តីនេះវិញនោះ រមែងប្រកាន់នូវ **ឧច្ឆេទទិដ្ឋិ** (ដែលលះបង់នូវសស្សតទិដ្ឋិបាន ព្រោះមិនឃើញថាមានសត្វត្រូវទៅកើតទៀត គឺឃើញថា បដិសន្ធិវិញ្ញាណកើតបន្តពីស្លាប់ព្រោះកម្មប្បច្ច័យនិងឧបនិស្សយប្បច្ច័យ ឯចំណែកការដែលយល់ខុសហើយប្រកាន់នូវឧច្ឆេទទិដ្ឋិនោះ ព្រោះបន្ទាប់ពីស្លាប់មិនមានអ្វីដែលនៅជាអមតៈត្រូវទៅចាប់បដិសន្ធិ យ៉ាងនេះក៏យល់ខុសថា សត្វដាច់សូន្យ )។

ក្នុងន័យម៉្យាងទៀត អវិជ្ជាពុំមែនជាសត្វ ហើយពុំបានគិតខ្វល់ខ្វាយថា «អញនឹងធ្វើឱ្យកើតកម្មគឺអភិសង្ខារទាំងឡាយ » ឯចំណែកសង្ខារទាំងឡាយ(អភិសង្ខារ )ក៏ពុំមែនជាសត្វដែរ ហើយក៏ពុំបានគិតខ្វល់ខ្វាយថា «អញនឹងធ្វើឱ្យកើតមានបដិសន្ធិវិញ្ញាណ » ដូច្នេះដែរ ជាដើមយ៉ាងនេះ បើមានការឃើញត្រូវ រមែងលះបង់បាននូវ **អត្តទិដ្ឋិ** (យល់ខុសថាមានអត្តាតួខ្លួន ) ព្រោះឃើញថាមិនមានអ្នកសាងលោក តែបើឃើញខុសក្នុងសេចក្តីនេះ រមែងប្រកាន់នូវ **អកិរិយទិដ្ឋិ** (គឺប្រកាន់ថាអ្នកធ្វើកម្មមិនមាន ដូច្នេះ កម្មក៏មិនមានដែរ ) តាមពិត អ្នកធ្វើកម្មមិនមានមែនដោយបរមត្ថធម៌ ប៉ុន្តែកម្មពិតជាមានព្រោះអវិជ្ជាតណ្ហាឧបាទានជាបច្ច័យ ។

ក្នុងសេចក្តីម្យ៉ាងទៀតជាចុងក្រោយ អំពីការកើតឡើងនៃផល មានអភិសង្ខារជាដើមដែលមានអវិជ្ជាជាបច្ច័យ បើមានបញ្ញា បានឃើញនៅក្នុងសេចក្តីនេះត្រឹមត្រូវ រមែងលះបង់បាននូវ **អហេតុកទិដ្ឋិ** (យល់ខុសថាអ្វីៗកើតឡើងដោយមិនមានហេតុ) និងលះនូវ **អកិរិយទិដ្ឋិ** (បដិសេធនូវកម្មល្អកម្មអាក្រក់ថាមិនមាន) ការលះបង់បាននូវការយល់ខុសទាំងនេះ ព្រោះបានឃើញថាផលទាំងឡាយរមែងប្រព្រឹត្តទៅតាមហេតុ-បច្ច័យ ប៉ុន្តែបើយល់ខុសក្នុងសេចក្តីចុងក្រោយនេះវិញ រមែងប្រកាន់នូវ **អហេតុកទិដ្ឋិ** និង **និយតិវាទ** (គឺយល់ខុសថាអ្វីៗដែលកើតឡើងនោះ រមែងកើតឯងៗ មិនមានហេតុឡើយ) **និយតិវាទ** គឺវាទៈអាស្រ័យទិដ្ឋិយល់ខុសថា ជីវិតនេះល្អឬអាក្រក់នៅលើព្រហ្មលិខិត នៅលើជោគជតារាសី នៅលើថ្ងៃខែឆ្នាំកំណើត ឬថាមានគ្រោះត្រូវរំដោះគ្រោះដោយវិធីយ៉ាងនេះយ៉ាងនោះ ។ល។ ពោលគឺយល់ឃើញថាសុខឬទុក្ខ ល្អឬអាក្រក់ រមែងបណ្តាលមកអំពីអ្វីៗផ្សេងៗ តាមតែការភ្ញាក់ផ្អើល មិនឃើញដល់ហេតុតាមសេចក្តីពិតឡើយ ។





# ប្រយោជន៍គួរយល់ដឹង

ប្រយោជន៍ដែលសម្រេចបានមកអំពីការចេះដឹងនៅក្នុងច្បាប់របស់កម្ម គួរយល់ដឹងដូចតទៅ ÷

១-ជាអ្នកធ្ងន់ក្នុងហេតុផល ពេញចិត្តក្នុងការងារសុចរិត ចេះសម្លឹងមើលការងារនិងផលរបស់ការងារ មិនវង្វេងជឿមង្គលភ្ញាក់ផ្អើលផ្សេងៗ មានទឹកទន្លេស័ក្តិសិទ្ធិជាដើម ។

២-ជាអ្នកឃើញដោយប្រពៃថា ផលសម្រេចតាមដែលខ្លួនត្រូវការ ឬទិសដៅដែលខ្លួនប្រាថ្នានឹងចូលទៅឱ្យដល់នោះ រមែងសម្រេចបានដោយការចុះដៃធ្វើ ដូច្នេះទើបត្រូវពឹងខ្លួនឯង និងត្រូវធ្វើនូវសេចក្តីព្យាយាម មិនរង់ចាំជោគជតា មិនសង្ឃឹមផលដោយការអង្វរករបន់ស្រន់បួងសួងដល់បច្ច័យខាងក្រៅឡើយ ។

៣-ជាអ្នកទទួលខុសត្រូវចំពោះខ្លួនឯង ដោយការវៀរចាកនូវអំពើអាក្រក់ និងទទួលខុសត្រូវចំពោះអ្នកដទៃ ដោយការធ្វើនូវអំពើល្អទៅរកគេ ។

៤-ជាអ្នកបានដឹងច្បាស់ថា មនុស្សមានសិទ្ធិតាមច្បាប់ធម្ម-ជាតិ ដែលធម្មជាតិតម្រូវឱ្យមនុស្សធ្វើការងារផ្សេងៗ គឺដើម្បីកែប្រែទម្លាប់មិនល្អ ឧបនិស្ស័យអាក្រក់ មកជាការកសាងខ្លួនឱ្យបាន

ជាមនុស្សល្អប្រសើរ រហូតដល់ថ្នាក់ទេវតាឥន្រ្ទព្រហ្មក៏គោរពបូជាដែរ **ការងារអាចធ្វើមនុស្សធម្មតាម្នាក់ ឱ្យបានទៅជាព្រះពុទ្ធមួយអង្គ** ។

៥_ជាអ្នកមានការធូរថយនូវសេចក្តីខឹងក្រោធ ចេះពិចារ_ណាក្នុងខ្លួនឯងនិងអ្នកដទៃតាមហេតុផល មិនច្រណែន មិនសម្លឹងទោសអ្នកដទៃដោយសេចក្តីប្រកាន់ ។

៦_ជាអ្នកមិនចែកវណ្ណៈតាមជាតិកំណើត កាន់យកតែអំពើធ្វើជាសំខាន់ គឺថា អ្នកណាចូលបួស អ្នកនោះជាព្រះសង្ឃ អ្នកណាលួចគេ អ្នកនោះជាចោរ អ្នកណាប្រព្រឹត្តអាក្រក់ អ្នកនោះជាអ្នកទោស ។

៧_ជាអ្នកមានឱកាសចម្រើនយោនិសោមនសិការរឿយៗ ព្រោះការចេះដឹងនៅក្នុងច្បាប់កម្មផល ប្រៀបដូចជាការជីកប្រ_ឡាយបង្ហូរទឹក ឯយោនិសោមនសិការ ប្រៀបដូចជាទឹកហូរតាមប្រឡាយដែលជីកនោះឯង ។ យោនិសោមនសិការ ជាហេតុនាំឱ្យចម្រើននូវសតិសម្បជញ្ញៈ ។

**សតិសម្បជញ្ញៈ** មានគុណដ៏ក្រៃលែងដល់ខ្លួនឯងផង ដល់ក្រុមគ្រួសារផង ដល់សង្គមជាតិផង ។ មើលចុះ មនុស្សដែលបៀតបៀនដល់សង្គម ធ្វើឱ្យសង្គមមនុស្ស សង្គមសត្វ ដល់នូវភាពវឹកវរ ច្របូកច្របល់ ព្រោះបាត់បង់នូវសតិសម្បជញ្ញៈហ្នឹងឯង





ដូច្នេះសូមមនុស្សលោកទាំងឡាយ សម្លឹងឱ្យឃើញនូវទោសនៃការបាត់បង់សតិសម្បជញ្ញៈ ដែលក្នុងលោកនេះ មិនមានការបាត់បង់អ្វីហើយ នាំមកនូវសេចក្តីវិនាស ឱ្យដូចជាការបាត់បង់នូវសតិសម្បជញ្ញៈនេះឡើយ ត្រូវរក្សាសតិសម្បជញ្ញៈឱ្យក្រៃលែងជាងការរក្សានូវទ្រព្យសម្បត្តិដ៏មានតម្លៃក្នុងលោក ត្រូវជៀសវាងនូវការប្រព្រឹត្តណាដែលនាំឱ្យបាត់បង់ស្មារតី ត្រូវស្គាល់ថាអ្វីជាសតិអ្វីជាសម្បជញ្ញៈ និងត្រូវទុកសតិសម្បជញ្ញៈស្មើនឹងជីវិតរបស់ខ្លួន ។

✍✳ប្រយោជន៍ដែលសម្រេចបានមកពីការយល់ដឹង នៅក្នុងច្បាប់របស់កម្ម នៅមានច្រើនទៀត ប៉ុន្តែប្រយោជន៍៧យ៉ាងដែលសម្តែងមកនេះ ជាការជ្រើសយកគោលសំខាន់ៗ បញ្ជាក់អំពីចរិយាធម៌ដ៏ប្រសើរក្នុងសង្គមនៃសត្វលោកទាំងមូល ។

**ជំនួយសតិភាគ៧ កម្មកថា**



# កំណាព្យ

## កម្មសកម្មខ្មៅ

បុណ្យគឺផលសជាញាតិផៅ　　បាបគឺផលខ្មៅបោលសម្រុក
ជីវិតសោយផលទុក្ខឬសុខ　　លំបាកស្រណុកកើតពីកម្ម ។
ដាំស្វាយបេះស្វាយដោយខ្លួនឯង ដាំស្លែងបេះស្លែងជាប្រចាំ
បេះផ្លែពីដើមដែលខ្លួនដាំ　　ផលកើតពីកម្មដែលខ្លួនធ្វើ ។
រូបតែងប្រែប្រួលដួលរលំ　　វេទនាស្រែកយំជូនដំណើរ
សញ្ញាចាំផ្លូវដែលត្រូវដើរ　　សង្ខាររុះរើសាងរូបថ្មី ។
វិញ្ញាណឆក់បាបឬឆាបបុណ្យ　តាមផលសុខសុន្ទរ៍ឬអប្រិយ៍
វិបាកជាញាតិក្នុងភពថ្មី　　អាក្រក់-ល្អក្តីផ្សំសន្តាន ។
លះបាបចាប់បុណ្យពុនជាស្បៀង ស្វែងរកផលទៀងស្ងប់សុខសាន្ត
ស្ពានមគ្គឥតមារមករំខាន　　គឺសតិប្បដ្ឋានផ្លូវបវរ ។
សតិបញ្ញាថ្លាផ្លូវផង់　　　ចិត្តចំពោះត្រង់កាយចេញចរ
មគ្គចំពោះមុខឃើញផលស　និព្វានបវរសុខសុចិណ្ណ ។
ចេះដឹងយល់ស្គាល់រាល់បទបែប ទុរេនធ្វាញ់ក្លែបក្រអូបក្លិន
អ្នកប្រាជ្ញបណ្ឌិតគំនិតឆ្អិន　　ក៏គង់តែមិនស្មើព្រះធម៌ ។



ចេះដឹងធម៌ពិតខំគិតគូរ　　ហើយខំតស៊ូរាយពិព័រណ៌
ស្មារតីរឹងប៉ឹងកុំញាប់ញ័រ　　«រំងាស់យកជ័រចេញពីសាច់»។
គឺសតិប្បដ្ឋានវិបស្សនា　　ចូលលុកកាប់ឆ្ការស៊ូប្តូរផ្តាច់
ឃើញចិត្តចេតសិករូបជាបាច់　គាស់រំលើងកាច់ផ្តាច់ឫសគល់។
បើចិត្តជំពាក់នឹងជាតិភព　　ព្រោះមោហ៍ទល់ទប់ងប់វិលវល់
សតិបញ្ញាថ្លាវិមល　　　កម្ចាត់ឫសគល់ឱ្យអស់ទៅ ។
សត្វដែលកើតស្លាប់ក្នុងត្រៃភព ងងឹតដូចយប់កុំចង់នៅ
បើមិនព្រមឡើងទូកសំពៅ　លិចកាន់តែជ្រៅងើបលែងរួច។
រូបប្រៀបបាននឹងពពុះទឹក　　ដែលភក់វល់វឹកឱ្យងើបព្រួច
ជីវិតតាំងនៅបានតិចតួច　　ដូចភ្លើងកាំជ្រួចឆេះរលត់ ។
នាមដែលពឹងរូបមិនថេរឋិត　ចេតសិកនាំចិត្តឱ្យរន្ធត់
រូបជាជម្រកតែមួយគត់　　នាមកើតរលត់រាល់ខណៈ ។
សតិប្បដ្ឋានវិបស្សនា　　　លើកយកបញ្ញាចាំងប្រចក្ស
ឃើញសភាវធម៌រងគ្រោះថ្នាក់ តោងលោកុត្តរលះលោកីយ៍។
លះបាបចាប់បុណ្យសម្អាតចិត្ត បានតោងជាប់ស្អិតក្នុងស្មារតី
គំនិតមិនថ្លាបញ្ញាខ្លី　　　សូមទានប្រណីអភ័យផង ។
ដឹងខ្លះស្វះស្វែងឈ្លេចខ្លឹមសារ ឱ្យយល់អត្ថអាថ៌ខំដោតក្រង
ទើបបានសម្រេចដូចបំណង　លើកបុណ្យចម្បងជូនលោកអ្នក។

បើឃើញខ្វះខាតឬខុសឆ្គង លើសលស់រំលងឆ្គងវោតវគ្គ
គំនិតមិនជ្រៅបញ្ញារាក់ សូមទានបញ្ជាក់យកបុណ្យទៀត។
វិបុណ្យលោកអ្នកបុណ្យខ្ញុំបាទ កុំឱ្យបង់ខាតគប្បីផ្ទៀត
ប្រមូលលើកជូនជនឯទៀត គឺជនរួមជាតិទាំងប្រុសស្រី ។
មិនថាសត្រូវឬមួយមិត្ត ព្រមទាំងមិនគិតចាស់ក្មេងក្តី
រហូតសព្វសត្វក្នុងភពបី បានសុខសួស្តីតទៅមុខ ។
សូមឃើញពន្លឺនៃព្រះធម៌ ឈប់ភ័យញាប់ញ័រព្រោះកងទុក្ខ
ក្នុងជាតិកំផុយភពកំពុក ចាកលោកជាគុកតទៅហោង ។

ដោយឧបាសក **ខៀវ-យ៉ុន**

## ទិប្បជិសារី

បញ្ញាជីវិត ថានសួគ៌ងងឹត ត្បិតចិត្តមោហា
ស្មានថាសួគ៌សុខ នៅក្នុងកាមា បំណុលតណ្ហា
ចងរឹតយ៉ាងតឹង។
មិនដឹងខ្លួនសោះ ពេលភ្ញាក់ស្ទើរអស់ ពុំមានទីពឹង
សមុទ្រសង្សារ មហាល្វើយល្វឹង ខ្លួនអើយពុំដឹង
កោះត្រើយឯណា ។
កាលនៅកម្លាំង ប្រឹងរត់ប្រណាំង ជាមួយវាសនា
មិនស្តាប់ព្រះធម៌ ព្រះសង្ឃទេសនា សំណាញ់កាមា
គ្របយ៉ាងងងឹត ។
ឥឡូវនេះចាស់ ភ្នែកមើលមិនច្បាស់ សែនខ្វល់ក្នុងចិត្ត
ត្រចៀកក៏ថ្លង់ ផ្លង់បង់គំនិត ខំផ្ទៀងពេកពិត
ឥតដឹងសេចក្តី ។
កាលពីនៅក្មេង អាចឮសំឡេង គំនិតក៏វៃ
គេហៅទៅវត្ត ថាកុំទាន់អី ចាំខ្ញុំលកលៃ
នៅពេលខ្ញុំចាស់ ។
ដល់ពេលជិតស្លាប់ ទើបបានប្រញាប់ ម្តេចនឹងរហ័ស
ងាករកទីពឹង ដឹងថាស្រឡះ គិតខុសពេកណាស់
ឱ ! ខ្លួនខ្ញុំអើយ ។

ដោយឧបាសិកា **ជូ-ស៊ុំហៀង**

## ឈ្នះនិងចាញ់

អ្នកឈ្នះរមែងបាននូវពៀរ អ្នកចាញ់វេទនាដេកជាទុក្ខ
អ្នកឈ្នះខ្លួនឯងរមែងបានសុខ អ្នករួចផុតទុក្ខព្រោះអស់តណ្ហា។

ដោយឧបាសិកា **ជូ-ស៊ុំហៀង**

## មិច្ឆាទិដ្ឋិ

-បុថុជ្ជន ដែលវិលវល់ ក្នុងវដ្តៈ
សុទ្ធជាអ្នក ជាប់អន្ទាក់ នៃទិដ្ឋិ
មានកម្រង ភ្លូងមាលា គឺអស្មិ
ជាកិលេស ដ៏សែនល្អិត ស្អិតកន្ទុង ។
-បើជាអ្នក ដែលមិនមាន នូវសទ្ធា
ទៅគប់ពារ អសប្បុរស ជាមិត្តផង
ញុំាងទិដ្ឋិ រឹតតែខុស បន្តិចម្តង
ផុតគន្លង នៃព្រះធម៌ នឹងទូន្មាន ។
-ដោយតណ្ហា នេះអុជអាល នូវដួងចិត្ត
បែកគំនិត ឥតជំនឿ ធ្វើបំពាន
បដិសេធ នូវកម្មផល សូគឺនិព្វាន
រឹតតែហ៊ាន ធ្វើទុច្ចរិត ត្បិតល្ងង់ខ្លៅ។
-ព្រោះតែគេ មិនបានជឿ បុណ្យនិងបាប
ចិត្តនោះដាប ជាទម្ងន់ ដោយធម៌ខ្មៅ
ផ្ទត់សីលធម៌ សុចរិតល្អ ឥតហ្មងសៅ
គ្មានសល់នៅ ក្នុងសន្តាន បានតិចតួច។
-ជំរុញខ្លួន អោយទៅក្នុង ក្តីអន្តរាយ





ធ្លាក់អបាយ មិនងាយនឹង បានងើបរួច
រងទុក្ខធ្ងន់ សែនទារុណ គួរព្រឺព្រួច
ព្រោះមិនស្រួច ដោយបញ្ញា ភ្លាខាងខុស ។

ដោយឧបាសិកា **ជូ ស៊ូហៀង**

## មនុស្សធម៌

-ជាតិមនុស្ស ដែលខ្ពង់ខ្ពស់ ព្រោះមានធម៌
សេចក្តីល្អ ដែលជាគុណ ដ៏ឧត្តម
លើសពួកសត្វ យ៉ាងនោះហើយ គួរតែខំ
ប្រឹងសន្សំ ធម៌ជាគុណ ទុនតទៅ ។
-ពិភពមនុស្ស អាចថេរឋិត និត្យនៅបាន
សុខក្សេមក្សាន្ត ឥតរំខាន នោះគឺផ្លូវ
ដែលព្រះពុទ្ធ បានទូន្មាន ប្រៀនប្រដៅ
ជាទិសដៅ ដែលគួរដើរ ប្រសើរពិត ។
-គឺសីលប្រាំ ដែលព្រះអង្គ បានកំណត់
សិក្ខាបទ ជារបង ចងយ៉ាងជិត
អាចរារាំង កាយវាចា ជាទុច្ចរិត

នេះឯងពិត ជាកំពូល មនុស្សធម៌ ។
-ព្រោះជាធម៌ មិនបៀតបៀន អ្នកដទៃ
ជាវិន័យ គោរពសិទ្ធិ ដ៏កម្រ
ជាសីលធម៌ ក្នុងសង្គម ដ៏បវរ
ជាលំអ នៃជីវិត ពិតគ្រប់ប្រាណ។
-ហើយសីលធម៌ ដ៏ប្រពៃ អាចតាំងនៅ
នោះឯងត្រូវ ចេះខ្មើមខ្លាច បាបប៉ុន្មាន
គឺហិរិ ឱត្តប្បៈ ទាំងពីរប្រាណ
នេះឯងបាន ឈ្មោះជាធម៌ រក្សាលោក ។
-រក្សាលោក រក្សាធម៌ រក្សាមនុស្ស
ឋិតលង់លុះ អង្វែងទៅ ដោយជ័យជោគ
កំចាត់បង់ នូវទុក្ខសោក វិប្បយោគ
ដែលជារោគ មនុស្សលោក មិនត្រូវការ ។
-បើដូច្នេះ ជនម្នាក់ៗ ក្នុងសង្គម
គួរអប់រំ សន្ដានចិត្ត ហើយរក្សា
នូវសីលប្រាំ ទៅតាមផ្លូវ នៃសាសនា
ជាចរិយា ដ៏ប្រពៃ នៃមនុស្ស ។
-បើសង្គម នេះប្រជុំ ដោយជនល្អ





នោះបាបធម៌ ពិតមិនអាច មានសន្ទុះ
គ្មានកម្លាំង នឹងតតាំង ប្រឹងប្រទូស្ត
សង្គមនោះ នៅថេរឋិត ពិតសុខសាន្ត ។

ដោយឧបាសិកា **ជូ-ស៊ុំហឿង**

## ច្បាប់របស់កម្ម

មនុស្សគ្រប់រស់នៅលំបាកខ្លាំងណាស់ ពុំមានបុណ្យចាស់តម្កល់តាក់តែង
បានព្រឹកខ្វះល្ងាចវែងព្រួយចំបែង ខំប្រឹងស្វះស្វែងនៅតែមិនគ្រប់។
នេះជាកម្មផលសម្រាប់សត្វលោក ព្រះទ្រង់មានជោគសម្ដែងជាម្ចប់
កម្មស្សកោម្មិទ្រង់បានប្រារព្ធ រៀងរាល់ថ្ងៃយប់ជារបស់ខ្លួន ។
កុំយល់ថាព្រោះមកពីអ្នកណា ហេតុច្រើនប្រការឱ្យផលផ្ទួនៗ
សន្សំសន្ដានទុកយ៉ាងខ្ជាប់ខ្ជួន ជួបម្ចាស់គាប់ជូនផ្ដល់ជូនពិសេស។
កម្មទាយាទោសម្ដែងប្រាប់ មរតកច្បាប់បួសកែវចំណេះ
កុសលអកុសលផលមិនរបេះ ជាប់ស្អិតដូចច្រេះស៊ីរូងផ្ទៃក្នុង ។
កម្មយោនិប្រាប់ថាកំណើត មានជាតិរួមកើតទំនុកបម្រុង
យកបាបនិងបុណ្យគាំទ្រផ្ដើមផ្ទុង ចុះចិត្តសំយុងចាត់ចែងឧស្សាហ៍។
កម្មពន្ធុដែលជាផៅពង្ស ជួយបន្តវង្សត្រកូលអង្គចេតនា
ហុចផលវិបាកដល់រូបអាត្មា រសធ្ងាញ់អស្ចារ្យចូលចិត្តចាំចង ។

កម្មបដិនិស្សរណោ ជាសង្កប្បោរលើកចងក្រង
មានមកគ្រប់ជាតិជាធំចម្បង អ្វីៗចាំត្រងបន្តភពទៀត ។
នេះគឺអំពើរបស់យើងធ្វើ មិនមានល្មើល្មើគ្មានអ្វីមកជ្រៀត
ដឹងហេតុស្គាល់ផលពុំមានអ្វីបៀត ទីណាចង្អៀតនៅតែឆ្អៀតបាន។
នត្ថិ កម្មំ សមំ ពលំ កម្លាំងយ៉ាងខ្លាំងមិនអាចប្រមាណ
តាមមកឱ្យផលគ្រប់ពេលមិនខាន គ្មានអ្វីប្រែប្រាណពីច្បាប់ធម្មជាតិ។
បើយល់ដូច្នេះគួរកុំសន្សំ អំពើលោភលន់អកុសលធាតុ
ធ្វើឱ្យរងទុក្ខលំបាកគ្រប់ជាតិ ត្រូវខំខ្មីឃ្មាតសាងកុសលធម៌ ។
អង្គមគ្គប្រាំបីផ្លូវព្រះអរិយ នៅជាលោកិយមិនទាន់គ្រប់គភ៌
ជ្រើសយកកុសលជួយផ្តល់បន្ទរ ទាញផលនុ៎ះន៏ ! សន្សំតទៅ ។
ផលបុណ្យទាំងឡាយទុកដូចមាតា ថ្នាក់ថ្នមរក្សារុញដល់គោលដៅ
អដ្ឋង្គិកមគ្គល្អពេកក្រៃ ស្រស់ថ្លាគ្មានក្តៅត្រើយព្រះនិព្វាន។
ច្បាប់កម្មមានប្រាំព្រះទ្រង់សម្តែង ប្រាប់ឱ្យជាក់ស្តែងចូរកុំបំពាន
យល់ខុសបណ្តាំពីព្រះទ្រង់ញាណ មុខជាខកខានលែងបានជួបសុខ ។

ដោយឧបាសក **នា~សុខា**

# សទ្ធាជូនជំនួនកម្ម

≈≈≈≈≈≈≈≈≈≈≈≈≈

សទ្ធាជាទ្រព្យល្អលើសអ្វីៗ នាំជនប្រុសស្រីឱ្យប្រព្រឹត្តល្អ
បើមានតែទ្រព្យសទ្ធាទ័លក្រ មាសប្រាក់ទាក់ក រកចាយពុំបាន។



រដូវភ្ជុំបិណ្ឌតែងតែទៅវត្ត ទោះជាក្រខ្សត់ក៏ឥតហ៊ានខាន
ទោះបាយមួយវែកសម្លមួយចាន ទៅវត្តឥតខានត្បិតខ្លាចញាតិជេរ។
ឧទ្ទិសឱ្យប្រេតប្រុងខ្លួនផងទៅ កុំឱ្យធ្លាក់ផ្លូវទៅប្រេតដូចគេ
ស្លាប់ទៅជាប្រេតពុំអាចដឹងទេ តែខ្លាចជាងគេគឺប្រេតទាំងរស់។
កម្មធ្វើចំណារចារជាជំនួន សម្រាប់ទុកជូនសត្វលោកទាំងអស់
សាងល្អបានល្អជួបសប្បុរស ពុតពាលឥតស្មោះជួបទុក្ខគ្រាំគ្រា។
បើជួបបណ្ឌិតពិតបានស្តាប់ធម៌ ប្រុងស្តាប់ដោយល្អនាំកើតសទ្ធា
ជឿហេតុនៃផលបានដល់បញ្ញា ជីវិតថ្លៃថ្លាឥតអាប់រស្មី ។

ដោយឧបាសក **គុយ~ សុធន**

# សំណូមពរ

≈≈≈≈≈≈≈≈≈≈≈≈≈

សូមជនអ្នកអានបានសុខប្រពៃ រួចផុតទុក្ខភ័យចង្រៃនានា
ទ្រព្យពុំប្រសើរស្មើនឹងសទ្ធា រសព្រះធម្មាឈ្នះរសអ្វីៗ ។
សូមកុំកើតជាអ្នកសទ្ធាក្រ ឥតចេះអក្សរឥតធម៌វិន័យ
ជីវិតនៅរស់បាត់អស់ស្មារតី មានទ្រព្យច្រើនក្តីក៏ឥតខ្លឹមសារ។
សូមសាធុជនធ្ងន់ក្នុងទានសីល ជម្រះមន្ទិលចម្រើនមេត្តា
សូមកុំមាក់ងាយព្រះពុទ្ធសាសនា ព្រោះតែដោយសារកំហុសអ្នកកាន់ ។

ដោយឧបាសក **គុយ~សុធន**

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការទារធម្មទាន

១.ឧបាសក សំរ៉ាង. វណ្ណ ២.ឧបាសក យន្ត . សួន
៣.ឧបាសក គួង.លាងផេង ៤.ឧបាសក មូង .យេន
៥.ឧបាសក រស់ . សូផាត ៦.ឧបាសក គុយ .សុធន
៧.នាង ជា . សុណារី ៨.នាង យុន .សូនីម៉ា

## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយធម៌ប្រចាំឆ្នាំ

១. ឧបាសក យូស៊ាង.ងួនលី និង ឧបាសិកា លីម.ឃីម
២. ឧបាសក ឆាយ.អ៊ីវស៊ាង និងឧបាសិកា ហុង.គីមសែ
៣. ឧបាសកឆាយអ៊ីវ.ស្រេងលីម និងឧបាសិកាហួត.ឃីម
៤. ឧបាសកហៃ.ប៊ុនណារិន និងឧបាសិកាអោង.ស៊ីថាន់
៥. ក្រុមឧបាសក ឈុំ.កុសល និងឧបាសក អ៊ុន.ឆាយគ្រី
៦. ក្រុមឧបាសក លឹម .ស៊ាង ( ហៅ ទូច )
៧. ឧបាសក យន្ត. សួន និងភរិយា ព្រមទាំងបុត្រ



៨. ឧបាសក ប៊ុន.ហេង ឧបាសិកា ជុំ.សុខុម ព្រមទាំងបុត្រ
៩. ឧបាសិកា ឱម.លក្ខណា ព្រមទាំងបុត្រ
១០. ឧបាសិកា ញឹក.ប៊ុនថា និងឧបាសិកា ម៉ែន.សុភារី
១១. ឧបាសិកា ច័ន្ទ.បុប្ផាណា ព្រមទាំងបុត្រ
១២. ឧបាសិកា ស្រង់.ឡេង ព្រមទាំងបុត្រ
១៣. ឧបាសក អ៊ុត .ឆៃវ៉ាន និងភរិយា ព្រមទាំងបុត្រ
១៤. ឧបាសក ប្លោក .ងួនថៃ និងភរិយា ព្រមទាំងបុត្រ
១៥. ឧបាសក ជឹម .អេងស្រ៊ន និងភរិយា ព្រមទាំងបុត្រ
១៦. ក្រុមឧបាសក មូង .យេន (វត្តសំពៅមាស)
១៧. ឧបាសិកា ជី.ឡាង
១៨. លោកម៉ៅ.សុគន្ធ អ្នកស្រី យ៉េក.ហួយ ព្រមទាំងបុត្រ
១៩. លោកយាយ ម៉េង.ហ៊ន
២០. ឧបាសក សំរ៉ាង.វណ្ណ និងឧបាសិកា សេង.គីមលន់
២១. ឧបាសិកា សេង.ឃីម
២២. លោក សេង.វ៉ានី និងអ្នកស្រី ណារិន
២៣. ឧបាសិកា ហេង.ស៊ីវខេង និងម្តាយឈ្មោះ អៀង.ហ្គិច
២៤. លោក ឃឹម.ស៊ីមុន្នី និងអ្នកស្រី យូ.ប៉ូលីន ព្រមទាំងបុត្រ
២៥.ឧបាសក ឡាយ.សុខុម
២៦. ឧបាសិកា អ៊ំ.អ៊ន់
២៧. ឧបាសិកា ធម្មិកា

២៨. ឧបាសិកា មូនី.សុខ

២៩. ឧបាសិកា តាំង.គីមហូ

៣០. ឧបាសក ស៊ុន.តាំងម៉ាប

៣១. ឧបាសិកា ប៉ូអាន.ស៊ីវត្ថា

៣២. ឧបាសិកា ប៉ូផាវ៉ាណេ

៣៣. ឧបាសិកា តឹក.សារឿន ព្រមទាំងកូនចៅទាំងអស់

៣៤. ឧបាសិកា លឹម.ឆេងហ្គិច ព្រមទាំងបុត្រ

៣៥. ឧបាសិកា សាក់.ស៊ាងអេង

៣៦. ឧបាសិកា ជា.ផាត ព្រមទាំងបុត្រ

៣៧. ឧបាសក ប៉ុល.នាង និងឧបាសិកា គ្រៀល.ស៊ីយ៉ា ព្រមទាំងបុត្រ

៣៨. ឧបាសិកា គា.ស៊ីន

៣៩. ពុទ្ធបរិស័ទ សុខ.ចាន់រី និង ភឿក.កុម្ភ

៤០. ឧបាសិកា កង. ភឹម

៤១. ឧបាសិកា អ៊ឹម . ស៊ីវន

៤២. ឧបាសិកា រស់ .លីណា

៤៣. ឧបាសិកា យូ . ណូសណារី

៤៤. ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី ប្រទេសអូស្ត្រាលី

៤៥. ក្រុមពុទ្ធបរិស័ទចិត្តបុណ្យក្នុងសហគមន៍ធម្មទាន



**សព្វទានំ ធម្មទានំ ជិនាតិ**

**ធម្មទានឈ្នះអស់ទានទាំងពួង**

**ចោះពុម្ព ៣០.០០០ ក្បាល**

**សម្រាប់ជាធម្មទាន**

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌
## ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | ពេលផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -05h00 mn<br>-19h00 mn<br>-19h30 mn<br>-19h30 mn<br>-20h00 mn<br>-20h30 mn | -FM 99 MHz<br>-AM 918 MHz<br>-FM 95 MHz<br>-FM 97 MHz<br>-FM 98 MHz<br>-FM 107 MHz |
| ក្រុងព្រះសីហនុ | -06h30 mn<br>-13h30 mn | -FM 92 MHz |
| ខេត្តបាត់ដំបង | -06h00 mn<br>-17h30 mn | -FM 103.2MHz<br>-FM 91 MHz |
| ក្រុងប៉ៃលិន | -18h00 mn | -FM 90 MHz |
| ខេត្តសៀមរាប | -18h30 mn | -FM 100.5MHz |

### សុខា សទ្ធម្មទេសនា

កិរិយាសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ





## សៀវភៅដែលរៀបរៀងដោយ
## ខ្ញុំព្រះករុណា ខ្ញុំបាទ
## ប៊ុត-សាវង្ស

១-ជំនួយសតិភាគ ៧

២-ខ្លឹមសារគួរយល់ដឹង

៣-ជំនួយសតិភាគ ១ ដល់ភាគ៦

៤-មនុស្សជាមួយនឹងការងារ

៥-សិក្ខាបទមនុស្សល្អ

៦-ពរ៤ប្រការ

៧-ព្រះពុទ្ធភាសិត ៤៣គាថា

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**

ភោគៈទាំងឡាយ តែងសម្លាប់នូវបុគ្គលល្ងង់ខ្លៅ តែមិនសម្លាប់នូវបុគ្គលដែលស្វែងរកត្រើយ គឺ ព្រះនិព្វានឡើយ ។